# ព្រះ

# អភិធម្មត្ថសង្គហ

## បរិច្ឆេទទី ១

# ចិត្តសង្គហវិភាគ

រៀបរៀងដោយ
បណ្ឌិតធម្មាចារ្យ រស់ សុជាត

ព.ស ២៥៤១

# អារម្ភកថា

កាលពីដើមឡើយ សៀវភៅព្រះអភិធម្មនេះ លោកគ្រូធម្មាចារ្យ **រស់ សុផាត** បានរៀបរៀងកែសម្រួលនិងសរសេរដោយដៃផ្ទាល់ ។

ក្រោយមក លោកគ្រូបានអញ្ជើញមកប្រទេសបារាំង ដើម្បីព្យាបាលរោគ ហើយបាននាំយកសៀវភៅព្រះអភិធម្មនេះចំនួន ៥ ក្បាល មកប្រគេនខ្ញុំព្រះករុណាអាត្មាភាព នៅប្រទេសបារាំង ខ្ញុំព្រះករុណាអាត្មាភាពមើលហើយ យល់ថាមិនសូវជារៀបរយ ព្រោះសរសេរដោយដៃ គឺ ធ្វើឲ្យមានការពិបាកមើល ពិបាកក្នុងការសិក្សារៀនសូត្រ ។

ដូច្នេះហើយខ្ញុំព្រះករុណាអាត្មាភាព មានសទ្ធាជ្រះថ្លាថានឹងជួយវាយកុំព្យូទ័រ គឺ ធ្វើជាអក្សរពុម្ព ហើយបានធានាថានឹងជួយវាយកុំព្យូទ័រជូនលោកគ្រូគ្រប់ក្បាលទាំងអស់ ដែលលោកគ្រូបានសរសេរដោយដៃរួចហើយ ទើបចាប់ផ្ដើមវាយកុំព្យូទ័រ កាលពីថ្ងៃទី ២៤ ខែ ៦ ឆ្នាំ ២០០៦ រួចហើយបានបញ្ជូនឲ្យឧបាសិកា **លី ឈុនស៊** ជួយត្រួតពិនិត្យតួអក្សរ ក្រែងមានខុសតួអក្សរខ្លះៗ ព្រោះសរសេរតាមជាថ្មី ។

ក្នុងការសរសេរជាថ្មីនេះ ខ្ញុំព្រះករុណាអាត្មាភាពបានបន្ថែមតារាងរូបដួងចិត្ត ១២១ តារាងរូបចេតសិក ៥២ និង តារាងរូប ២៨

មានតារាងរូបឲ្យមើលទៅឃើញថា ងាយយល់ជាង រីឯតួអក្សរមិនបាន បន្ថែម ឬ បន្ថយអត្ថន័យទេ ។

សៀវភៅនេះល្អណាស់សូមឲ្យកើតជាប្រយោជន៍ដល់ ពុទ្ធបរិស័ទយើងទាំងក្នុងប្រទេស និងក្រៅប្រទេស សិក្សារៀនសូត្រដើម្បីឲ្យព្រះពុទ្ធសាសនារីកចម្រើនតរៀងទៅជាយូរអង្វែង ។

សូមឲ្យខ្មែរយើងចេះដឹង និង ប្រព្រឹត្តបដិបត្តិក្នុងធម៌របស់ព្រះសម្មាសម្ពុទ្ធឲ្យបានច្រើន ដើម្បីសេចក្ដីសុខគ្រប់ៗគ្នា កុំបីអាក់ខានឡើយ ៕

ធ្វើនៅវត្ត រស្មីសាមគ្គី
ថ្ងៃទី ២៣ ខែ ១០ ឆ្នាំ ២០០៦
32 RUE HORACE VERNET
59100 ROUBAIX - FRANCE

លោកគ្រូ
**នៅ សាខន អគ្គតេជោ**

# អភិធម្មត្ថសង្គហៈ

សេចក្តីនៃពាក្យថា **អភិធម្មត្ថសង្គហ** ចែកចេញជា ៥ ស័ព្ទ គឺ **អភិ + ធម្ម + អត្ថ + សំ + គហ** រួមជា **អភិធម្មត្ថសង្គហ** ។

- **អភិ** ប្រែថា ដ៏ប្រសើរ ។
- **ធម្ម** ប្រែថា សភាវៈដែលទ្រទ្រង់ ។
- **អត្ថ** ប្រែថា អត្ថ ឬ សេចក្តី ។
- **សំ** ប្រែថា ដោយសង្ខេប ។
- **គហ** ប្រែថា ការរួបរួមទុក ។

ដូច្នេះ ពាក្យថា **អភិធម្មត្ថសង្គហ** នេះ ប្រែថា ការរួបរួមសេចក្តីនៃព្រះអភិធម្ម ( ៧ គម្ពីរ ) ទុកដោយសង្ខេប ៕

# ព្រះ
# អភិធម្ម ៧ គម្ពីរ

## ព្រះអភិធម្មមាន ៧ គម្ពីរ គឺ :-

១.ធម្មសង្គណីបករណៈ អដ្ឋកថា គឺ អដ្ឋសាលិនី ។

២.វិភង្គបករណៈ អដ្ឋកថា គឺ សម្មោហវិនោទនី ។

៣.ធាតុកថាបករណៈ

៤.បុគ្គលប្បញ្ញត្តិបករណៈ

៥.កថាវត្ថុបករណៈ

៦.យមកបករណៈ

៧.បដ្ឋានបករណៈ

(៣–៧) អដ្ឋកថា គឺ បរមត្ថទីបនី បញ្ចបករណដ្ឋកថា ។

អដ្ឋកថាព្រះត្រៃបិដកនោះ ចំណែកធំ ព្រះពុទ្ធឃោសាចារ្យលោកប្រែនិងរៀបរៀងពីអដ្ឋកថាដើម ក្នុងភាសាសីហឡៈ គឺ មហាអដ្ឋកថា មហាបច្ចរី និង កុរុនទី ដែលបន្តគ្នាមកតាំងតែអំពីសម័យព្រះមហិន្ទត្ថេរ ព្រះឱរសរបស់ព្រះចៅអសោកមហារាជ បានទៅផ្សព្វផ្សាយព្រះពុទ្ធសាសនា នៅក្នុងប្រទេសសេរីលង្កានោះម្ល៉េះ ។

**តត្ថ វុត្តាភិធម្មត្ថា ចតុធា បរមត្ថតោ**
**ចិត្តំ ចេតសិកំ រូបំ និព្វានមីតិ សព្វថា**

អត្ថនៃព្រះអភិធម្មទាំង ៧ គម្ពីរ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកដោយសេចក្តីសុខុមក្រៃពេកនោះ ដោយបរមត្ថ មាន ៤ ប្រការ គឺ ចិត្ត ចេតសិក រូប និព្វាន ។

សភាវៈទាំង ៤ នេះ ជាបរមត្ថ ដែលហៅថា **ព្រះបរមត្ថ-បិដក** ហើយព្រះបរមត្ថបិដកទាំង ៧ គម្ពីរនេះ ព្រះអនុរុទ្ធាចារ្យបានរួបរួមសេចក្តីទុកដោយសង្ខេប ហៅថា **ព្រះអភិធម្មត្ថសង្គហៈ** ចាត់ជាបរិច្ឆេទ មាន **៩ បរិច្ឆេទ** ។

ព្រះបរមត្ថធម៌ទាំង ៤ ប្រការនេះ តាមន័យ ព្រះអភិធម្មត្ថ-សង្គហៈ លោកពោលពីរឿង **ចិត្ត** ជាបរិច្ឆេទទី ១ ។

ពាក្យថា **បរមត្ថ** ចែកជា ២ បទ គឺ **បរម + អត្ថ** ប្រែថា អត្ថសេចក្តីដ៏ប្រសើរខ្ពង់ខ្ពស់មិនវិបរិត ។

**បរមត្ថធម៌** មាន ២ គឺ :

- **សង្ខតធម៌** ធម៌ដែលមានបច្ច័យតាក់តែង គឺ ចិត្ត ចេតសិក រូប ។

- **អសង្ខតធម៌** ធម៌ដែលមិនមានបច្ច័យតាក់តែង គឺ ព្រះនិព្វាន ។

**សច្ចៈ** សេចក្ដីពិត ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ជាអ្នកឆ្លាតឈ្លាសក្នុងការទេសនា បានត្រាស់នូវសច្ចៈ ២ គឺ **បរមត្ថសច្ចៈ** ពិតដោយបរមត្ថ ១ និង **សម្មតិសច្ចៈ** ពិតដោយសម្មតិ ១ តែប៉ុណ្ណោះ មិនមានសច្ចៈទី ៣ ឡើយ ។

## ហេតុដែលព្រះអង្គទ្រង់ត្រាស់នូវសម្មតិសច្ចៈ

\+ ដោយហេតុ ៨ ប្រការ គឺ :

**១.** ដើម្បីទ្រង់សំដែង ហិរិ និង ឱត្តប្បៈ ។

**២.** ដើម្បីទ្រង់សំដែង កម្មស្សកតា ។

**៣.** ដើម្បីទ្រង់សំដែង ដល់អ្នកប្រព្រឹត្តចំពោះខ្លួន ។

**៤.** ដើម្បីទ្រង់សំដែង ដល់អនន្តរិយកម្ម ។

**៥.** ដើម្បីទ្រង់សំដែង ដល់ព្រហ្មវិហារធម៌ ។

**៦.** ដើម្បីទ្រង់សំដែង បុព្វេនិវាសញ្ញាណ ។

**៧.** ដើម្បីទ្រង់សំដែង ដល់ទក្ខិណាវិសុទ្ធិ ។

**៨.** ដើម្បីទ្រង់មិនលះ បញ្ញត្តិនៃលោក ។

ធម៌ទាំងពួង បានដល់ បរមត្ថធម៌ទាំង ៤ គឺ ចិត្ត ចេតសិក រូប និព្វាន ជាអនត្តា គឺ មិនមែនតួខ្លួន មិនទៅក្នុងអំណាចបង្គាប់បញ្ញារបស់បុគ្គលណាឡើយ ។

ក្នុងបរមត្ថធម៌ទាំង ៤ នេះ

- **ចិត្តបរមត្ថ** បានដល់ ចិត្ត ៨៩ ឬ ១២១ ដួង ។
- **រូបបរមត្ថ** បានដល់ រូប ២៨ ។
- **ចេតសិកបរមត្ថ** បានដល់ ចេតសិក ៥២ ដួង ជាលោកិយ ដល់នូវការបែកធ្លាយ និង រលត់ទៅវិញ ជាសង្ខារធម៌ គឺ កើតឡើងមានបច្ច័យតាក់តែង ជាសង្ខតធម៌ គឺ ជាធម៌ដែលកើតរលត់ ។
- **និព្វានបរមត្ថ** បានដល់ ព្រះនិព្វាន ជាលោកុត្តរ គឺ ការឆ្លងផុតពីលោក ជាវិសង្ខារធម៌ គឺ មិនមានបច្ច័យតាក់តែង ជាអសង្ខតធម៌ គឺ មិនកើតរលត់ ។

- ចិត្តបរមត្ថ ចេតសិកបរមត្ថ និព្វានបរមត្ថ ទាំង ៣ នេះ ជានាមធម៌ ប៉ុន្តែ ចិត្ត និង ចេតសិក ជានាមធម៌ ដឹងនូវអារម្មណ៍ ចំណែកឯ និព្វាន ជានាមធម៌ មិនដឹងអារម្មណ៍ ។

- **ចិត្ត ៨៩ ឬ ១២១**
- **ចេតសិក ៥២**

} ជានាមធម៌ ជាសង្ខារធម៌ ជាសង្ខតធម៌

- **រូប ២៨** } ជារូបធម៌ ជាសង្ខារធម៌ ជាសង្ខតធម៌
- **និព្វាន** } ជានាមធម៌ ជាវិសង្ខារធម៌ និង ជាអសង្ខតធម៌ ។

# ខន្ធ ៥

**ខន្ធ ៥** គឺ រូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ ។

ពាក្យថា **ខន្ធ** សំដៅដល់សភាវធម៌ដែលចំណែកជា អតីត អនាគត បច្ចុប្បន្ន ខាងក្នុង ខាងក្រៅ គ្រោតគ្រាត ល្អិត ថោក-ទាប ប្រណីត ឆ្ងាយ ជិត ។

**ខន្ធ** ជារូបធម៌នាមធម៌ ជាសង្ខារធម៌ ជាសង្ខតធម៌ គឺជាធម៌ដែលបច្ច័យតាក់តែង និងកើតរលត់ ។

ពាក្យថា **ឧបាទានក្ខន្ធ** សំដៅយកខន្ធណាដែលប្រព្រឹត្តប្រកបនឹងអាសវៈ ជាបច្ច័យដល់ឧបាទាន នេះហៅថា ឧបាទានក្ខន្ធ ។

**លោកុត្តរចិត្ត និងចេតសិកប្រកប** មិនមែនជាឧបាទានក្ខន្ធទេ ។

អត្ថក្នុងព្រះអភិធម្មទាំងឡាយ ដែលព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ទ្រង់ត្រាស់ទុកនោះ គឺ ដោយអំណាចនៃធម៌ មានខន្ធដោយបរមត្ថ វៀរនូវសម្មតិចេញ គឺមាន ៤ ប្រការ :

- **រូប ២៨** ជារូបក្ខន្ធ ។
- **ចេតសិក ៥២** គឺ វេទនាចេតសិក ១ ជាវេទនាខន្ធ សញ្ញា-ចេតសិក ១ ជាសញ្ញាខន្ធ នៅសល់ចេតសិក ៥០ ទៀតជាសង្ខារក្ខន្ធ រួមជាខន្ធ ៣ ។
- **ចិត្ត ៨៩** ជាវិញ្ញាណក្ខន្ធ ។
- **និព្វាន** ជាខន្ធវិមុត្តិ ផុតចាកខន្ធទាំង ៥ ។

ដូច្នេះ បរមត្ថធម៌ ៣ ជាខន្ធ ៥ , ខន្ធ ៥ ជាបរមត្ថធម៌ ៣ ។

- **រូបក្ខន្ធ** បានដល់ រូបបរមត្ថ ២៨ ។
- **វេទនាខន្ធ** បានដល់ វេទនាចេតសិក ១ ។
- **សញ្ញាខន្ធ** បានដល់ សញ្ញាចេតសិក ១ ។
- **សង្ខារក្ខន្ធ** បានដល់ សង្ខារចេតសិក ៥០ ។
- **វិញ្ញាណក្ខន្ធ** បានដល់ ចិត្តបរមត្ថ ៨៩ ឬ ១២១ ។

# សំណួរ

| | | |
|---|---|---|
| **១.** បរមត្ថធម៌អ្វីខ្លះ | ជាសង្ខារធម៌ | ? |
| **២.** សង្ខារធម៌ | ជាសង្ខារក្ខន្ធ ឬទេ | ? |
| **៣.** វិសង្ខារធម៌ | ជាសង្ខតធម៌ ឬទេ | ? |
| **៤.** អសង្ខតធម៌ | ជាខន្ធអ្វី | ? |
| **៥.** អសង្ខតធម៌ | ជាលោកិយ ឬជាលោកុត្តរ | ? |
| **៦.** ចិត្ត | ជាសង្ខារក្ខន្ធ ឬទេ | ? |
| **៧.** ចេតសិក | ជាសង្ខារក្ខន្ធ ឬទេ | ? |
| **៨.** វេទនាខន្ធ | ជាបរមត្ថធម៌អ្វី | ? |
| **៩.** ខន្ធអ្វី | មិនមែនជាបរមត្ថធម៌ | ? |
| **១០.** បរមត្ថធម៌អ្វី | មិនមែនជាខន្ធ | ? |

# ចិត្តបរមត្ថ

ពាក្យថា **ចិត្ត** មានសេចក្ដីថា :

- ធម្មជាតិណារមែងគិត គឺ ដឹងអារម្មណ៍ ធម្មជាតិនោះ ឈ្មោះថា **ចិត្ត** ។

- ធម្មជាតិដែលឈ្មោះថា **ចិត្ត** ព្រោះអត្ថថា ជាហេតុឲ្យសម្បយុត្តធម៌ដឹងនូវអារម្មណ៍ ។

- ធម្មជាតិដែលគ្រាន់តែគិត គឺ ដឹង ឈ្មោះថា **ចិត្ត** ។

ក្នុងអដ្ឋសាលិនី ពោលទុកថា :

**យំ ចិត្តំ មនោ ហទយំ មានសំ បណ្ឌរំ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ ចិត្តំ ។**

ប្រែថា :

**១.** ធម្មជាតិណា រមែងគិត ធម្មជាតិនោះ ឈ្មោះថា **ចិត្ត**

**២.** ធម្មជាតិណា តែងបង្អោនទៅ ធម្មជាតិនោះ ឈ្មោះថា **មនោ**

**៣.** ធម្មជាតិណា ដែលដឹងអារម្មណ៍ ទុកនៅខាងក្នុង ធម្មជាតិ

នោះ ឈ្មោះថា **ហទយះ**

៤. ចិត្ត នោះឯងមានឆន្ទះ គឺ ការពេញចិត្ត ឈ្មោះថា **មានសះ**

៥. ចិត្ត នោះជាធម្មជាតិបរិសុទ្ធ ឈ្មោះថា **បណ្ឌរះ**

៦. មនះ ដែលជាអាយតនះខាងក្នុង ឈ្មោះថា **មនាយតនះ**

៧. មនះ ដែលជាឥន្ទ្រីយ៍ ឈ្មោះថា **មនិន្ទ្រីយ៍**

៨. ធម្មជាតិ ដែលដឹងច្បាស់នូវអារម្មណ៍ ឈ្មោះថា **វិញ្ញាណ**

៩. ខន្ធ គឺ កងនៃវិញ្ញាណ ឈ្មោះថា **វិញ្ញាណក្ខន្ធ**

១០. មនះ ដែលជាធាតុដឹងច្បាស់នូវអារម្មណ៍ ឈ្មោះថា **មនោវិញ្ញាណធាតុ**

# លក្ខណះរបស់ចិត្ត

**ចិត្ត** ជាសង្ខតធម៌ គឺ ធម៌ដែលមានបច្ច័យតាក់តែង ដោយការតាក់តែងរបស់បច្ច័យទាំងឡាយដូច្នេះឯង ទើបចិត្តធ្លាក់ចុះក្នុងអំណាចនៃសាមញ្ញលក្ខណះ ( ត្រៃលក្ខណ៍ ) គឺ អនិច្ចលក្ខណះ

ទុក្ខលក្ខណៈ និង អនត្តលក្ខណៈ ព្រោះតែចិត្ត មានសភាពជាត្រៃ-លក្ខណ៍ យ៉ាងនេះឯង ទើបចិត្ត មានអាការកើតរលត់បន្តជាប់គ្នា មិនដាច់ខ្សែរយៈ ហើយប្រព្រឹត្តទៅយ៉ាងរហ័សបំផុត លំបាកនឹងប្រមាណបានណាស់ ៕

# លក្ខណាទិចតុកៈរបស់ចិត្ត

**-វិជាននលក្ខណំ** មានការដឹងអារម្មណ៍ ជាលក្ខណៈ
**-បុព្វង្គមរសំ** មានសភាពជាប្រធាន ជាកិច្ច
**-សន្ធានបច្ចុប្បដ្ឋានំ** មានការកើតបន្តជាប់គ្នាជាអាការប្រាកដ
**-នាមរូបបទដ្ឋានំ** មាននាមក្ខន្ធ ៣ និង រូប ជាបទដ្ឋាន

# អំណាចរបស់ចិត្ត

**ចិត្ត** ក្នុងស័ព្ទនេះ មានសេចក្តីសង្ខេបថា :

**១. វិចិត្តករណា ចិត្តំ** ឈ្មោះថា **ចិត្ត** ព្រោះធ្វើឲ្យវិចិត្រផ្សេងៗ និងធ្វើវត្ថុផ្សេងៗឲ្យវិចិត្រ គឺថា វត្ថុផ្សេងៗដែលកើតពីសិល្ប-វិទ្យាផ្សេងៗ ក៏ព្រោះចិត្ត ដូចជាគំនូរ ចម្លាក់ជាដើម និង ធ្វើកិរិយាមាយាទឲ្យវិចិត្រ សមរម្យសុភាព ក៏ព្រោះចិត្ត និងម្យ៉ាងទៀត សំដៅ

ដល់ការធ្វើទីកើតប្លែកៗ ដែលកើតពីចិត្តជាកុសលនិងអកុសល ឲ្យវិចិត្រ គឺសន្ទឹកសន្ធាប់ មាននរក តិរច្ឆាន មនុស្ស ទេវតាជាដើម ។

**២. អត្តនោ ចិត្តតាយ វា** ឈ្មោះថា **ចិត្ត** ព្រោះសភាវៈខ្លួនឯងវិចិត្រ គឺ វិចិត្រដោយខ្លួនឯង បានសេចក្ដីថា ចិត្តនោះឯងជាកុសលក៏មាន ជាអកុសលក៏មាន ជាវិបាកក៏មាន ជាកិរិយាក៏មាន គឺថាចិត្តនោះឯង ខណៈខ្លះក៏ជាកុសល ខណៈខ្លះក៏ជាអកុសល ខណៈខ្លះក៏ជាវិបាក ខណៈខ្លះក៏ជាកិរិយា ។

**៣. ចិត្តំ កម្មកិលេសេហិ** ឈ្មោះថា **ចិត្ត** ព្រោះសន្សំកម្ម និង កិលេស ។ គឺ ចិត្តនោះឯង ជាតួសន្សំកម្មដែលជាកុសលជាអកុសល និង សន្សំកិលេស មាន រាគៈ ទោសៈ និង មោហៈជាដើម នឹងសន្សំក្នុងទីដទៃមិនបាន ដូចមានរាគៈហើយ ចិត្តនោះក៏សន្សំ រាគៈនោះឲ្យច្រើនឡើងៗ ជាដើម ។

**៤. ចិត្តំ តាយតិ វា តថា** ឈ្មោះថា **ចិត្ត** ព្រោះរក្សាទុកនូវវិបាករបស់ខ្លួន ។ គឺ កម្មនិងកិលេសដែលសន្សំហើយនោះ រក្សាវិបាករបស់ខ្លួនមិនឲ្យបាត់បង់សូន្យទៅទេ កាលណាមានឱកាស បានបច្ច័យហើយ វិបាកនោះៗ តែងនឹងកើតឡើង ដូចកើតឡើងតាមទ្វារភ្នែកជាដើម ។

**៥. ចិនោតិ អត្តសន្តានំ** ឈ្មោះថា **ចិត្ត** ព្រោះសន្សំសន្តាននៃខ្លួន ។ គឺថា ចិត្តនោះឯង តែងសន្សំសេចក្ដីល្អខ្លះ សេចក្ដីអាក្រក់ខ្លះ ទុកក្នុងសន្តានមិនឲ្យសាបសូន្យ ធ្វើឲ្យកើតជាទម្លាប់ដ៏ថ្មីក ក្នុងការប្រព្រឹត្តរហូតទៅជានិស្ស័យ ឬជាចរិតជាប់ក្នុងសន្តាន ។

**៦. វិចិត្តារម្មណន្តិ ចាតិ** ឈ្មោះថា **ចិត្ត** ព្រោះមានអារម្មណ៍វិចិត្រដោយប្រការផ្សេងៗ គឺថា ចិត្តនេះ ជាធម្មជាតិដឹងនូវអារម្មណ៍ទាំង ៦ បានទាំងអស់ ទាំង ៦ ទ្វារ តែដឹងបានចំពោះអារម្មណ៍មួយៗប៉ុណ្ណោះ មានរូបារម្មណ៍ជាដើម ។

ក្នុងអដ្ឋកថាបរមត្ថទីបនីដីកា ពោលថា :

**ចិត្តវិចិត្តតាយ សញ្ញាវិចិត្តតា សញ្ញាវិចិត្តតាយ តណ្ហាវិចិត្តតា តណ្ហាវិចិត្តតាយ កម្មានិវិចិត្តានិ កម្មវិចិត្តតា យោនិយោវិចិត្តតា យោនីវិចិត្តតាយ តេសំ តិរច្ឆានគតានំ វិចិត្តតា វេទិតព្វា ។**

ប្រែថា សភាពដែលសត្វទាំងឡាយវិចិត្រនោះ ក៏ព្រោះកំណើតវិចិត្រ កំណើតវិចិត្រព្រោះកម្មវិចិត្រ កម្មវិចិត្រព្រោះតណ្ហាវិចិត្រ តណ្ហាវិចិត្រព្រោះសញ្ញាវិចិត្រ សញ្ញាវិចិត្រព្រោះចិត្តវិចិត្រ ។

ពាក្យថា **សត្វទាំងនោះវិចិត្រ ព្រោះកំណើតវិចិត្រនោះ** គឺ សត្វទាំងឡាយដែលកើតឡើងក្នុងលោក មានច្រើនប្រភេទ ហើយប្រភេទនីមួយៗ ក៏ច្រើនសន្ធឹកសន្ធាប់ ទាំងអស់នេះ រស់ព្រោះកំណើតវិចិត្រ គឺ សន្ធឹកសន្ធាប់ប្រមាណមិនបាន ។

ពាក្យថា **កំណើតវិចិត្រ ព្រោះកម្មវិចិត្រនោះ** គឺជាធម្មតា សត្វដែលកើតមក សុទ្ធតែធ្វើកម្មទុកផ្សេងៗគ្នា ខ្លះក៏ធ្វើកុសល ខ្លះក៏ធ្វើអកុសល ។

ពាក្យថា **កម្មវិចិត្រ ព្រោះតណ្ហាវិចិត្រនោះ** សេចក្តីថា តណ្ហា គឺ ចំណង់ក្នុងវត្ថុផ្សេងៗ ក្នុងសត្វ ក្នុងបុគ្គល មិនចង់ឲ្យព្រាត់ប្រាស ឬក៏ចង់ដោយប្រការណាៗក្តី ទើបខ្លួនឯងក៏ត្រូវធ្វើកម្មដោយអំណាចនៃតណ្ហា ដែលមានប្រភេទផ្សេងៗនោះ ។

ពាក្យថា **តណ្ហាវិចិត្រ ព្រោះសញ្ញាវិចិត្រនោះ** សេចក្តីថា សញ្ញា គឺ ការចាំ ការសំគាល់បាន មានច្រើនយ៉ាង ។ ឃើញម្តងការចាំក៏កើតឡើងម្តង ឮម្តងការចាំក៏កើតឡើងម្តង យ៉ាងនេះជាដើម កាលណាចំណាំបានក្នុងវត្ថុដែលល្អ តណ្ហា ក៏កើតសេចក្តីពេញចិត្តក្នុងវត្ថុនោះៗ ។

ពាក្យថា **សញ្ញាវិចិត្រ ព្រោះចិត្តវិចិត្រនោះ** មានន័យថា កាលណាចិត្តដួងមួយកើតឡើង សញ្ញាមួយដួងក៏កើតឡើង ចិត្តកើត

មួយរយផង មួយពាន់ផង សញ្ញាក៏កើតមួយរយផង មួយពាន់ផង ស្មើនឹងចិត្តនោះដែរ ។

# ចំណែកចិត្ត ៨៩ ដួង

ចិត្តទាំងអស់មាន ៨៩ ដួង ( ប្រភេទ ) ដោយពិស្តារ មាន ១២១ ដួង ។ កាលពោលដោយលក្ខណៈ ( គឺ **អារម្មណវិជាននលក្ខណំ** ) មានត្រឹមតែ ១ ប៉ុណ្ណោះ កាលបើចែកដោយប្រភេទផ្សេងៗ ក៏ចំណែកបានដោយន័យដទៃៗ ដូច្នេះ គឺ :

ដោយជាតិ ដោយភូមិ ដោយវេទនា ដោយហេតុ ដោយសង្ខារ ដោយសម្បយោគ ដោយសោភណៈ ដោយឈាន ដោយលោកៈ ដោយកិច្ច ដោយអារម្មណ៍ ដោយទ្វារ ដោយវត្ថុ និងដោយវិញ្ញាណធាតុ ។

# ១.ន័យដោយជាតិ

**ជាតិ** មាន ៤ គឺ កុសលជាតិ ១ អកុសលជាតិ ១ វិបាកជាតិ ១ និង កិរិយាជាតិ ១ ។

| | | |
|---|---|---|
| - កុសលជាតិ | មានចិត្ត ២១ ឬ ៣៧ | ដួង |
| - អកុសលជាតិ | មានចិត្ត ១២ | ដួង |
| - វិបាកជាតិ | មានចិត្ត ៣៦ ឬ ៥២ | ដួង |
| - កិរិយាជាតិ | មានចិត្ត ២០ | ដួង |
| រួមទាំងអស់ | មានចិត្ត ៨៩ ឬ ១២១ | ដួង |

# ២.ន័យដោយភូមិ

**ភូមិ** មាន ៤ គឺ កាមភូមិ ១ រូបភូមិ ១ អរូបភូមិ ១ និង លោកុត្តរភូមិ ១ ។

| | | |
|---|---|---|
| - កាមភូមិ | មានចិត្ត ៥៤ | ដួង |
| - រូបភូមិ | មានចិត្ត ១៥ | ដួង |
| - អរូបភូមិ | មានចិត្ត ១២ | ដួង |
| - លោកុត្តរភូមិ | មានចិត្ត ៨ ឬ ៤០ | ដួង |
| រួមទាំងអស់ | មានចិត្ត ៨៩ ឬ ១២១ | ដួង |

# ៣.ន័យដោយវេទនា

**វេទនា** មាន ៥ គឺ សុខវេទនា ១ ទុក្ខវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ។

| | | | |
|---|---|---|---|
| - សុខវេទនា | មានចិត្ត | ១ | ដួង |
| - ទុក្ខវេទនា | មានចិត្ត | ១ | ដួង |
| - សោមនស្សវេទនា | មានចិត្ត | ៣០ ឬ ៦២ | ដួង |
| - ទោមនស្សវេទនា | មានចិត្ត | ២ | ដួង |
| - ឧបេក្ខាវេទនា | មានចិត្ត | ៥៥ | ដួង |
| រួមទាំងអស់ | មានចិត្ត | ៨៩ ឬ ១២១ | ដួង |

# ៤.ន័យដោយហេតុ

**ចិត្ត** ចែកចេញជា ២ ប្រភេទ គឺ **សហេតុកៈ ១** និង **អហេតុកៈ ១** ។

ចិត្តដែលប្រកបដោយហេតុ ៦ ហៅថា **សហេតុកចិត្ត** មាន ៧១ ឬ ១០៣ ដួង ។

ចិត្តដែលមិនប្រកបដោយហេតុ ៦ ហៅថា **អហេតុកចិត្ត** មាន ១៨ ដួង ។

រួមទាំងអស់មាន ៨៩ ឬ ១២១ ដួង ។

# ៥.ន័យដោយសង្ខារ

**ចិត្ត** បើគិតដោយប្រភេទនៃសង្ខារមាន ២ គឺ **អសង្ខារិក ១** និង **សសង្ខារិក ១** ។

ចិត្តដែលកើតឡើង ដោយមិនមានសភាវៈវត្ថុដឹកនាំ មានកម្លាំងខ្លាំង ហៅថា **អសង្ខារិកចិត្ត** មាន ៣៧ ដួង ។

ចិត្តដែលកើតឡើង ដោយអាស្រ័យមានសភាវៈវត្ថុដឹកនាំ ហៅថា **សសង្ខារិកចិត្ត** មាន ៥២ ឬ ៨៤ ដួង ។

រួមទាំងអស់ មាន ៨៩ ឬ ១២១ ដួង ។

# ៦.ន័យដោយសម្បយោគ

**ចិត្ត** បើគិតដោយប្រភេទនៃសម្បយោគមាន ២ គឺ **សម្បយុត្ត ១** និង **វិប្បយុត្ត ១** ។

ចិត្តដែលប្រកបជាមួយនឹង ទិដ្ឋិ ទោសៈ ឧទ្ធច្ចៈ វិចិកិច្ឆា និង បញ្ញា ហៅថា **សម្បយុត្តចិត្ត** មានចិត្ត ៥៥ ឬ ៨៧ ដួង ។

ចិត្តដែលមិនប្រកបជាមួយនឹង ទិដ្ឋិ ទោសៈ ឧទ្ធច្ចៈ វិចិកិច្ឆា និង បញ្ញា ហៅថា **វិប្បយុត្តចិត្ត** មាន ៣៤ ដួង ។

រួមទាំងអស់ មាន ៨៩ ឬ ១២១ ដួង ។

# ៧.ន័យដោយសោភណៈ

**ចិត្ត** ដែលប្រកបជាមួយនឹងសោភណចេតសិក ២៥ ហៅថា **សោភណចិត្ត** មាន ៥៩ ឬ ៩១ ដួង ។

**ចិត្ត** ដែលមិនប្រកបជាមួយនឹងសោភណចេតសិក ២៥ ហៅថា **អសោភណចិត្ត** មាន ៣០ ដួង ។

រួមទាំងអស់ មាន ៨៩ ឬ ១២១ ដួង ។

# ៨.ន័យដោយឈាន

**ឈាន** មាន ២ យ៉ាង គឺ **អារម្មណូបនិជ្ឈាន ១** បានដល់ សមាបត្តិ ៨ និង **លក្ខណូបនិជ្ឈាន ១** បានដល់ វិបស្សនា មគ្គ

និង ផល ។

ដោយន័យនៃ **អារម្មណូបនិជ្ឈាន** រូបាវចរចិត្ត ១៥ ដួង អរូបាវចរចិត្ត ១២ ដួង រួមជា ២៧ ដួង ហៅថា **ឈានចិត្ត** ។

អកុសលចិត្ត ១២ ដួង អហេតុកចិត្ត ១៨ ដួង កាមាវចរសោភណចិត្ត ២៤ ដួង និងលោកុត្តរចិត្ត ៨ ដួង រួមជា ៦២ ដួង ហៅថា **អឈានចិត្ត** ។

ក្នុងវិភាវិនីដីកា លោកពោលថា ចិត្ត ៨៩ ដួង ជាចិត្តពិស្តារ ១២១ ដួង យ៉ាងណានោះ គឺ :

| | | | |
|---|---|---|---|
| បឋមជ្ឈាន | សោតាបត្តិមគ្គចិត្ត | ១ | ដួង |
| ទុតិយជ្ឈាន | សោតាបត្តិមគ្គចិត្ត | ១ | ដួង |
| តតិយជ្ឈាន | ” ” ” | ១ | ដួង |
| ចតុត្ថជ្ឈាន | ” ” ” | ១ | ដួង |
| បញ្ចមជ្ឈាន | ” ” ” | ១ | ដួង |

សកទាគាមិមគ្គចិត្ត អនាគាមិមគ្គចិត្ត អរហត្តមគ្គចិត្ត មគ្គនីមួយៗក៏មាន ៥ ដួង ដូចគ្នា រួមជាមគ្គចិត្តទាំងអស់ ២០ ដួង ។ ផលចិត្តក៏មានន័យដូចគ្នា មាន ២០ ដួង រួមទាំងអស់ ជាលោកុត្តរចិត្ត ៤០ ដួង ។

រូបាវចរចិត្ត ក្នុងប្រភេទនៃឈាន មានបឋមជ្ឈានជាដើម យ៉ាងណា លោកុត្តរចិត្តក្នុងប្រភេទនៃឈាន មានបឋមជ្ឈានជាដើម ក៏យ៉ាងនោះដែរ ព្រមទាំងការប្រកបដោយអង្គឈានក៏ដូចគ្នា ។

សូម្បី អរូបឈាន ក៏សង្គ្រោះចូលនៅក្នុងបញ្ចមជ្ឈាន ព្រោះហេតុដូច្នោះហើយ ឈានចិត្តក្នុងឈានទីមួយៗ ទើបមានចំនួនចិត្ត :

-បឋមជ្ឈានចិត្ត ១១ ដួង (គឺរូបាវចរចិត្ត ៣ លោកុត្តរចិត្ត ៨ )
-ទុតិយជ្ឈានចិត្ត ១១ ដួង (គឺរូបាវចរចិត្ត ៣ លោកុត្តរចិត្ត ៨ )
-តតិយជ្ឈានចិត្ត ១១ ដួង (គឺរូបាវចរចិត្ត ៣ លោកុត្តរចិត្ត ៨ )
-ចតុត្ថជ្ឈានចិត្ត ១១ ដួង (គឺរូបាវចរចិត្ត ៣ លោកុត្តរចិត្ត ៨ )
-បញ្ចមជ្ឈានចិត្ត ២៣ ដួង (គឺរូបាវចរចិត្ត ៣ អរូបាវចរចិត្ត ១២ និង លោកុត្តរចិត្ត ៨ )

ដូច្នេះចិត្តដែលជាឈានចិត្តមាន ៦៧ ដួង ។

ដោយន័យនៃចិត្តពិស្តារ រូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ លោកុត្តរចិត្ត ៤០ រួមទាំងអស់ជាចិត្ត ៦៧ ដួង ហៅថា **ឈានចិត្ត** ។

អកុសលចិត្ត ១២ អហេតុកចិត្ត ១៨ កាមាវចរសោភណ-ចិត្ត ២៤ រួមជា ៥៤ ចិត្ត ហៅថា **អឈានចិត្ត** ។

រួមទាំងអស់មាន ១២១ ដួង ។

# ៩.ន័យដោយលោកៈ

**ចិត្ត** បើគិតដោយប្រភេទនៃ **លោកៈ** មាន ២ គឺ **លោកិយ-ចិត្ត** ១ និង **លោកុត្តរចិត្ត** ១ ។

ចិត្តដែលមិនមានអារម្មណ៍ជាព្រះនិព្វាន ហៅថា **លោកិយ-ចិត្ត** មាន ៨១ ដួង ។

ចិត្តដែលមានព្រះនិព្វានជាអារម្មណ៍ ហៅថា **លោកុត្តរចិត្ត** មាន ៨ ឬ ៤០ ដួង ។

រួមទាំងអស់មាន ៨៩ ឬ ១២១ ដួង ។

# ១០.ន័យដោយកិច្ច

**កិច្ច** របស់ចិត្តមាន ១៤ កិច្ច គឺ :

| | | | | |
|---|---|---|---|---|
| **១.** | **បដិសន្ធិកិច្ច** | មាន | ១៩ | ដួង |
| **២.** | **ភវង្គកិច្ច** | មាន | ១៩ | ដួង |
| **៣.** | **អាវជ្ជនកិច្ច** | មាន | ២ | ដួង |
| **៤.** | **ទស្សនកិច្ច** | មាន | ២ | ដួង |

| | | | | |
|---|---|---|---|---|
| **៥.** | **សវនកិច្ច** | មាន | ២ | ដួង |
| **៦.** | **ឃាយនកិច្ច** | មាន | ២ | ដួង |
| **៧.** | **សាយនកិច្ច** | មាន | ២ | ដួង |
| **៨.** | **ផុស្សនកិច្ច** | មាន | ២ | ដួង |
| **៩.** | **សម្បដិច្ឆន្នកិច្ច** | មាន | ២ | ដួង |
| **១០.** | **សន្តីរណកិច្ច** | មាន | ៣ | ដួង |
| **១១.** | **វោដ្ឋវនកិច្ច** | មាន | ១ | ដួង |
| **១២.** | **ជវនកិច្ច** | មាន | ៥៥ | ដួង |
| **១៣.** | **តទាលម្ពណកិច្ច** | មាន | ១១ | ដួង |
| **១៤.** | **ចុតិកិច្ច** | មាន | ១៩ | ដួង |
| រួមទាំងអស់ | | មាន | ៨៩ | ដួង |

# ១១.ន័យដោយអារម្មណ៍

**អារម្មណ៍** របស់ចិត្តមាន ៦ គឺ រូបារម្មណ៍ ១ សទ្ទារម្មណ៍ ១ គន្ធារម្មណ៍ ១ រសារម្មណ៍ ១ ផោដ្ឋព្វារម្មណ៍ ១ និងធម្មារម្មណ៍ ១ ។

| | | | |
|---|---|---|---|
| រូបារម្មណ៍ | ដឹងដោយចិត្ត | ២ | ដួង |

| | | | |
|---|---|---|---|
| សទ្ទារម្មណ៍ | ដឹងដោយចិត្ត | ២ | ដួង |
| គន្ធារម្មណ៍ | ដឹងដោយចិត្ត | ២ | ដួង |
| រសារម្មណ៍ | ដឹងដោយចិត្ត | ២ | ដួង |
| ផោដ្ឋព្វារម្មណ៍ | ដឹងដោយចិត្ត | ២ | ដួង |
| អារម្មណ៍ទាំង ៥ ខាងលើនេះដឹងដោយចិត្ត | | ៣ | ដួង |
| អារម្មណ៍ទាំង ៦ ដឹងដោយចិត្ត | | ៤១ | ដួង |
| ធម្មារម្មណ៍ ដឹងដោយចិត្ត | ៣៥ ដួង ឬ | ៦៧ | ដួង |
| រួមទាំងអស់ មានចិត្ត | ៨៩ ដួង ឬ | ១២១ | ដួង |

# ១២.ន័យដោយទ្វារ

**ទ្វារ** របស់ចិត្តមាន ៦ គឺ ចក្ខុទ្វារ ១ សោតទ្វារ ១ ឃានទ្វារ ១ ជីវ្ហាទ្វារ ១ កាយទ្វារ ១ មនោទ្វារ ១ ។

- ចិត្ត ២ ដួង អាស្រ័យកើតតាមតែ ចក្ខុទ្វារ
- ចិត្ត ២ ដួង ” ” ” សោតទ្វារ
- ចិត្ត ២ ដួង ” ” ” ឃានទ្វារ
- ចិត្ត ២ ដួង ” ” ” ជីវ្ហាទ្វារ
- ចិត្ត ២ ដួង ” ” ” កាយទ្វារ
- ចិត្ត ២៦ ឬ ៥៨ ដួង ” ” មនោទ្វារ

- ចិត្ត ៣ ដួង អាស្រ័យកើតតាមតែ បញ្ចទ្វារ
- ចិត្ត ៤១ ដួង ” ” ” ទ្វារទាំង ៦
- ចិត្ត ១០ ដួង អាស្រ័យកើតតាមទ្វារទាំង ៦ ខ្លះ មិនអាស្រ័យ ខ្លះ ។
- ចិត្ត ៩ ដួង មិនអាស្រ័យទ្វារទាំង ៦

រួមទាំងអស់មាន ៨៩ ឬ ១២១ ដួង ។

# ១៣.ន័យដោយវត្ថុ

**វត្ថុ** ទីអាស្រ័យកើតរបស់ចិត្តមាន ៦ គឺ :

ចក្ខុវត្ថុ ១ សោតវត្ថុ ១ ឃានវត្ថុ ១ ជីវ្ហាវត្ថុ ១ កាយវត្ថុ ១ និង ហទយវត្ថុ ១ ។

| | | | | | | |
|---|---|---|---|---|---|---|
| -ចក្ខុវត្ថុ | ជាទីអាស្រ័យកើតនៃចិត្ត | | | | ២ | ដួង |
| -សោតវត្ថុ | ” | ” | ” | ” | ២ | ដួង |
| -ឃានវត្ថុ | ” | ” | ” | ” | ២ | ដួង |
| -ជីវ្ហាវត្ថុ | ” | ” | ” | ” | ២ | ដួង |
| -កាយវត្ថុ | ” | ” | ” | ” | ២ | ដួង |
| -ហទយវត្ថុ | ” | ” | ” | ” | ៧៥ | ដួង |

ចិត្តមិនអាស្រ័យវត្ថុសោះមាន ៤ ដួង ។

រួមទាំងអស់មាន ៨៩ ឬ ១២១ ដួង ॥

# ១៤.ដោយវិញ្ញាណធាតុ៧

**វិញ្ញាណធាតុ ៧** គឺចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញាណធាតុ ១ ជីវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណធាតុ ១ មនោធាតុ ១ និង មនោវិញ្ញាណធាតុ ១ ។

| | | | | |
|---|---|---|---|---|
| - ចក្ខុវិញ្ញាណធាតុ | បានដល់ចិត្ត | | ២ | ដួង |
| - សោតវិញ្ញាណធាតុ | ” | ” | ២ | ដួង |
| - ឃានវិញ្ញាណធាតុ | ” | ” | ២ | ដួង |
| - ជីវ្ហាវិញ្ញាណធាតុ | ” | ” | ២ | ដួង |
| - កាយវិញ្ញាណធាតុ | ” | ” | ២ | ដួង |
| - មនោធាតុ | ” | ” | ៣ | ដួង |
| - មនោវិញ្ញាណធាតុ | ” | ” | ៧៦ ដួង ឬ ១០៨ | ដួង |

រួមទាំងអស់មាន ៨៩ ឬ ១២១ ដួង ॥

( ចប់ វិធីចែកចិត្ត ១៤ ន័យ )

# ចិត្តបរមត្ថ ៨៩ បរិច្ឆេទទី ១

- ចិត្ត ៨៩
  - កាមាវចរចិត្ត ៥៤
    - អកុសលចិត្ត ១២
      - លោភមូលចិត្ត ៨
      - ទោសមូលចិត្ត ២
      - មោហមូលចិត្ត ២
    - អហេតុកចិត្ត ១៨
      - អកុសលវិបាកចិត្ត ៧
      - អហេតុកកុសលវិបាក ៨
      - អហេតុកកិរិយាចិត្ត ៣
    - កាមាវចរសោភណចិត្ត ២៤
      - កាមាវចរកុសលចិត្ត ៨
      - កាមាវចរវិបាកចិត្ត ៨
      - កាមាវចរកិរិយាចិត្ត ៨
  - មហគ្គតចិត្ត ២៧
    - រូបាវចរចិត្ត ១៥
      - រូបាវចរកុសលចិត្ត ៥
      - រូបាវចរវិបាកចិត្ត ៥
      - រូបាវចរកិរិយាចិត្ត ៥
    - អរូបាវចរចិត្ត ១២
      - អរូបាវចរកុសលចិត្ត ៤
      - អរូបាវចរវិបាកចិត្ត ៤
      - អរូបាវចរកិរិយាចិត្ត ៤
  - លោកុត្តរចិត្ត ៨
    - លោកុត្តរកុសលចិត្ត ៤
    - លោកុត្តរវិបាកចិត្ត ៤

# ចិត្តបរមត្ថ មាន ៨៩ ឬ ១២១

| | | | | |
|---|---|---|---|---|
| លោកិយចិត្ត ៨១ ដួង | លោភមូលចិត្ត | ៨ | OOOOOOOO | អកុសលចិត្ត ១២ ដួង |
| | ទោសមូលចិត្ត | ២ | OO | |
| | មោហមូលចិត្ត | ២ | OO | |
| | អកុសលវិបាកចិត្ត | ៧ | OOOOOOO | អហេតុកចិត្ត ១៨ ដួង |
| | អហេតុកកុសលវិបាកចិត្ត | ៨ | OOOOOOOO | |
| | អហេតុកកិរិយាចិត្ត | ៣ | OOO | |
| | មហាកុសលចិត្ត | ៨ | OOOOOOOO | កាមាវចរសោភណចិត្ត ២៤ ដួង |
| | មហាវិបាកចិត្ត | ៨ | OOOOOOOO | |
| | មហាកិរិយាចិត្ត | ៨ | OOOOOOOO | |
| | រូបាវចរកុសលចិត្ត | ៥ | OOOOO | រូបាវចរចិត្ត ១៥ ដួង |
| | រូបាវចរវិបាកចិត្ត | ៥ | OOOOO | |
| | រូបាវចរកិរិយាចិត្ត | ៥ | OOOOO | |
| | អរូបាវចរកុសលចិត្ត | ៤ | OOOO | អរូបាវចរចិត្ត ១២ ដួង |
| | អរូបាវចរវិបាកចិត្ត | ៤ | OOOO | |
| | អរូបាវចរកិរិយាចិត្ត | ៤ | OOOO | |
| លោកុត្តរចិត្ត ៨ ឬ ៤០ ដួង | សោតាបត្តិមគ្គចិត្ត | ១-៥ | O - OOOOO | លោកុត្តរកុសលចិត្ត ៤ ដួង |
| | សកទាគាមិមគ្គចិត្ត | ១-៥ | O - OOOOO | |
| | អនាគាមិមគ្គចិត្ត | ១-៥ | O - OOOOO | |
| | អរហត្តមគ្គចិត្ត | ១-៥ | O - OOOOO | |
| | សោតាបត្តិផលចិត្ត | ១-៥ | O - OOOOO | លោកុត្តរវិបាកចិត្ត ៤ ដួង |
| | សកទាគាមិផលចិត្ត | ១-៥ | O - OOOOO | |
| | អនាគាមិផលចិត្ត | ១-៥ | O - OOOOO | |
| | អរហត្តផលចិត្ត | ១-៥ | O - OOOOO | |

# ចិត្ត ៤ យ៉ាង

## តត្ថ ចិត្តំ តាវ ចតុព្វិធំ ហោតិ កាមាវចរំ រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ ។

ប្រែថា ក្នុងបណ្ដាអត្ថនៃព្រះអភិធម្មទាំង ៤ នោះ ចិត្តបរមត្ថ ដែលសម្ដែងទុកជាលំដាប់ដំបូងនេះ មាន ៤ យ៉ាង គឺ :

១. កាមាវចរចិត្ត    ២. រូបាវចរចិត្ត

៣. អរូបាវចរចិត្ត    ៤. លោកុត្តរចិត្ត

បណ្ដាចិត្ត ៤ យ៉ាងនោះ កាមាវចរចិត្ត តើដូចម្ដេច ?

# កាមាវចរចិត្ត ៥៤

កាមាវចរចិត្ត ( **កាម + អវចរ + ចិត្ត** )

ពាក្យថា **កាម** បានដល់ កិលេសកាម និងវត្ថុកាម ។

ពាក្យថា **អវចរ** បានដល់ ការត្រាច់ទៅ ។

ពាក្យថា **ចិត្ត** បានដល់ ធម្មជាតិដែលដឹងអារម្មណ៍។

- សភាវៈណាតែងញុំាងចិត្តឲ្យស្រឡាញ់ សភាវៈនោះ ឈ្មោះថា **កាម** គឺ កិលេសកាម បានដល់ កាមតណ្ហា ។

កាមតណ្ហានោះតែងត្រាច់ទៅក្នុងចិត្តនេះ ដោយអំណាចធ្វើឲ្យជាប់ជំពាក់ ព្រោះហេតុដូច្នេះ ទើបឈ្មោះថា **កាមាវចរៈ** ។

- សភាវៈណាដែលចិត្តតែងស្រឡាញ់ សភាវៈនោះ ឈ្មោះថា **កាម** គឺ វត្ថុកាម បានដល់ កាមភព ១១ ដែលប្រព្រឹត្តទៅដឹង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាអារម្មណ៍ ។ ចិត្តដែលឈ្មោះថា កាមាវចរៈ ព្រោះអត្ថថា រមែងត្រាច់ទៅក្នុងកាមភព ១១ នោះ ។

ពាក្យថា **កាមាវចរចិត្ត ឬ កាមចិត្តនោះ** មានសេចក្ដីច្រើនន័យ គឺ :

**១.**សំដែងដល់ ចិត្តដែលកើតក្នុងកាមភូមិ ១១ ជាចំណែកច្រើន ព្រោះភូមិនេះបរិបូណ៌ដោយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាភូមិរបស់ **កាមបុគ្គល** ។

**២.** សំដៅដល់ ចិត្តនៃអ្នកដែលជាប់ជំពាក់ក្នុងកាមគុណ-អារម្មណ៍ គឺ ជាប់ជំពាក់ដោយកិលេសកាម គឺ កាមតណ្ហាខ្លះ និងក្នុងវត្ថុកាម គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈខ្លះ ឬក៏សំដៅដល់ចិត្តដែលប្រព្រឹត្តទៅក្នុងកាមារម្មណ៍នោះៗ ។

**៣.** សំដៅដល់ ចិត្តដែលទទួលអារម្មណ៍ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ( គឺ រឹងទន់ ក្តៅត្រជាក់ តឹងញ័រ ) ។

ទោះជាគេកើតក្នុងភូមិណាៗក្តី កាលណាមាន រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាអារម្មណ៍ ខណៈនោះក៏ហៅថា **កាមចិត្ត** សូម្បីព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏មានកាមចិត្តដែរ ។

ក្នុងកាមាវចរចិត្ត ៥៤ ដួងនេះ ចែកចេញជា ៣ ប្រភេទ គឺ :

| | | |
|---|---|---|
| **១. អកុសលចិត្ត** | ១២ | ដួង |
| **២. អហេតុកចិត្ត** | ១៨ | ដួង |
| **៣. កាមាវចរសោភណចិត្ត** | ២៤ | ដួង |
| រួម | ៥៤ | ដួង |

# អកុសលចិត្ត ១២ ដួង

**អកុសលចិត្ត** ជាចិត្តដែលបដិបក្ខនឹងកុសល ជាចិត្តមិនស្អាតល្អ អាក្រក់គ្រោតគ្រាត ជាចិត្តដែលប្រកបដោយអកុសល-ចេតសិក ជាបាប មានទោស ឲ្យផលជាទុក្ខ មាន ១២ ដួង គឺ:

| | | |
|---|---|---|
| - **លោភមូលចិត្ត** | ៨ | ដួង |
| - **ទោសមូលចិត្ត** | ២ | ដួង |
| - **មោហមូលចិត្ត** | ២ | ដួង |

## លោភមូលចិត្ត ៨

| | | | |
|---|---|---|---|
| **១.** | សោមនស្សសហគត | ទិដ្ឋិគតសម្បយុត្ត | អសង្ខារិក |
| **២.** | សោមនស្សសហគត | ទិដ្ឋិគតសម្បយុត្ត | សសង្ខារិក |
| **៣.** | សោមនស្សសហគត | ទិដ្ឋិគតវិប្បយុត្ត | អសង្ខារិក |
| **៤.** | សោមនស្សសហគត | ទិដ្ឋិគតវិប្បយុត្ត | សសង្ខារិក |
| **៥.** | ឧបេក្ខាសហគត | ទិដ្ឋិគតសម្បយុត្ត | អសង្ខារិក |
| **៦.** | ឧបេក្ខាសហគត | ទិដ្ឋិគតសម្បយុត្ត | សសង្ខារិក |

## ៧. ឧបេក្ខាសហគត ទិដ្ឋិគតវិប្បយុត្ត អសង្ខារិក
## ៨. ឧបេក្ខាសហគត ទិដ្ឋិគតវិប្បយុត្ត សសង្ខារិក

លោភសហគតចិត្ត ប្រែថា ចិត្តកើតព្រមជាមួយនឹងសេចក្ដីលោភ នេះហៅថា **លោភមូលចិត្ត** ខ្លះ **លោភចិត្ត** ខ្លះ មានសេចក្ដីដូចគ្នា គឺ ជាចិត្តដែលកើតឡើងព្រោះលោភៈជាហេតុ គឺ ជាចិត្តដែលពេញចិត្ត ត្រូវការ ចង់បាន ទោះមានត្រឹមតែបន្តិចបន្តួច ក៏ដោយក៏ហៅថា **លោភមូលចិត្ត** ជាហេតុឲ្យកើតសេចក្ដីក្ដៅក្រហាយ ជាគ្រឿងឃុំឃាំងដ៏មាំ និងជាភ័យខាងក្នុង ធ្វើចិត្តឲ្យងងឹតឈឹង ។ សមដូចព្រះអង្គត្រាស់ថា ( ក្នុង ខុទ្ទកនិកាយ មហានិទ្ទេស ) **“ លោភៈ តែងញ៉ាំងវត្ថុដែលមិនជាប្រយោជន៍ ឲ្យកើតឡើង លោភៈ តែងញ៉ាំងចិត្តឲ្យកំរើក លោភៈជាភ័យកើតឡើងខាងក្នុង ជនពាលតែងមិនដឹង មិនស្គាល់នូវភ័យនោះ ។ បុគ្គលល្មោភដែលមិនស្គាល់នូវប្រយោជន៍ ដែលមិនបានឃើញនូវធម៌ កាលណា លោភៈគ្របសង្កត់ កាលណោះ គេក៏រមែងងងឹតឈឹង ” ។**

ពាក្យថា **សោមនស្សសហគត** ប្រែថា កើតព្រមដោយសោមនស្សវេទនា គឺ សភាពពេញចិត្តរីករាយ ។

ពាក្យថា **ទិដ្ឋិគតសម្បយុត្ត** ប្រែថា ប្រកបដោយមិច្ឆាទិដ្ឋិ គឺ

សស្សតទិដ្ឋិ ១ និង ឧច្ឆេទទិដ្ឋិ ១ ។ សស្សតទិដ្ឋិ សេចក្តីយល់ខុសថា សត្វស្លាប់ហើយ កើតទៀត ។ ឧច្ឆេទទិដ្ឋិ សេចក្តីយល់ខុសថា សត្វស្លាប់ហើយសូន្យ មិនកើតទៀត ។

ពាក្យថា **អសង្ខារិក** ប្រែថា មិនមានការដឹកនាំឲ្យកើតឡើងដោយកាយ ឬដោយវាចា គឺ មានកម្លាំងក្លៀវក្លាដោយខ្លួនឯង ។

ពាក្យថា **សសង្ខារិក** ប្រែថា មានការដឹកនាំឲ្យកើតឡើងដោយកាយ ឬដោយវាចា គឺ មានកម្លាំងខ្សោយ ។

ពាក្យថា **ទិដ្ឋិគតវិប្បយុត្ត** ប្រែថា មិនប្រកបដោយមិច្ឆាទិដ្ឋិ គឺ ប្រាសចាកទិដ្ឋិទាំង ២ ។

ពាក្យថា **ឧបេក្ខាសហគត** ប្រែថា កើតព្រមដោយឧបេក្ខា-វេទនា គឺ សភាពជាកណ្តាល ព្រងើយៗ ។

## -សោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត អសង្ខារិក

ប្រែថា ចិត្តកើតព្រមដោយសោមនស្ស ប្រកបដោយទិដ្ឋិ មិនមានការដឹកនាំ ។

## -ឧបេក្ខាសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក

ប្រែថា ចិត្តកើតព្រមដោយឧបេក្ខា មិនប្រកបដោយទិដ្ឋិ មានការដឹកនាំ ។

ក្នុងវិភាវិនី បានអធិប្បាយនូវលោភមូលចិត្តនេះទុកថា

-ពេលណា បុគ្គលធ្វើមិច្ឆាទិដ្ឋិជាខាងដើមថា ទោសក្នុងកាមទាំងឡាយមិនមាន ហើយសប្បាយត្រេកអររីករាយ បរិភោគកាមក្តីមានជំនឿក្នុង ទិដ្ឋិមង្គលជាដើម ថាជាសារៈក្តី ដោយចិត្តខ្លួនឯងដ៏មានកម្លាំង មិនមានអ្នកណាបង្ខំ ឬជំរុញ ពេលនោះ លោភមូលចិត្តទី ១ តែងកើតឡើង ។ ប៉ុន្តែបើដោយចិត្ត កម្លាំងខ្សោយដោយមានអ្នកជួយបង្ខំ ឬជំរុញ ពេលនោះ លោភមូលចិត្តទី ២ តែងកើតឡើង ។

- ពេលណា បុគ្គលមិនធ្វើនូវមិច្ឆាទិដ្ឋិជាខាងដើមទេ សប្បាយរីករាយត្រេកអរតែម្តង បានសេពមេថុនខ្លះ ឬ គិតចង់បានសម្បត្តិអ្នកដទៃខ្លះ ឬលួចខ្លះ ដោយចិត្តកម្លាំងខ្លាំងខ្លួនឯងតាមសភាវៈ តែម្យ៉ាង មិនមានអ្នកណាបង្ខំ ឬជំរុញ ពេលនោះ លោភមូលចិត្ត ទី ៣ តែងកើតឡើង ។ ប៉ុន្តែបើដោយចិត្តកម្លាំងខ្សោយ មិនមានកម្លាំងខ្លាំង មានអ្នកជួយបង្ខំ ឬជំរុញ ពេលនោះ លោភមូលចិត្តទី ៤ តែងកើតឡើង ។

- លោភមូលចិត្តដួងទី ៥ ដូចដួងទី ១ , ដួងទី ៦ ដូចដួងទី ២ , ដួងទី ៧ ដូចដួងទី ៣ , ដួងទី ៨ ដូចដួងទី ៤ , ខុសគ្នាត្រឹមតែបទមួយ គឺ ដួងទី ៥-៦ ៧-៨ ជាចិត្តប្រកបព្រមដោយឧបេក្ខាវេទនាប៉ុណ្ណោះ ។

- ពេលណា បុគ្គលប្រាសចាកសោមនស្សវេទនា ដោយអាស្រ័យ

មិនសំប្ូរនូវកាមទាំងឡាយក្តី ឬដោយមិនមានហេតុ ឲ្យកើតសោមនស្សក្តី ពេលនោះ លោភមូលចិត្ត ៤ ដួង ដែលសហគតដោយឧបេក្ខា តែងកើតឡើង ។

**លុព្ភតីតិ លោភោ** ឈ្មោះថា លោភៈ ព្រោះអត្ថថា ចង់បាន ។

# លក្ខណាទិចតុកៈរបស់លោភៈ

**-អារម្មណគហណ លក្ខណោ** លោភៈ មានការប្រកាន់នូវអារម្មណ៍ ជាលក្ខណៈ ។

**-អភិសង្គ រសោ** មានការជាប់ស្អិតនូវ អារម្មណ៍ ជាកិច្ច ។

**-អបរិច្ចាគ បច្ចុប្បដ្ឋានោ** មានការមិនលះបង់ចេញ ជាអាការប្រាកដ ។

**-សំយោជនីយធម្មេសុ អស្សាទទស្សន បទដ្ឋានោ** មានការឃើញ ដោយការពេញចិត្តនូវធម៌ទាំងឡាយដែលជាទីតាំងនៃសំយោជនៈជាបទដ្ឋាន។

លោភមូលចិត្តនេះ ជាបរមត្ថធម៌ មិននៅក្នុងការបង្គាប់បញ្ជា

នៃនរណាឡើយ កាលបើមានហេតុបច្ច័យក៏កើតឡើង , កើតហើយកើតទៀត ។ ហេតុដែលធ្វើឲ្យកើតឡើង មាន ៤ ប្រការ :

# ហេតុឲ្យកើតលោភមូលចិត្ត មាន ៤ ប្រការ

ពាក្យថា **លោភបរិវារកម្ម បដិសន្ធិកតា** មានន័យថា បដិសន្ធិមកដោយកម្មដែលមានលោភៈជាបរិវារ ។

- បុគ្គលខ្លះ បដិសន្ធិក្នុងសុគតិភូមិ ដោយការធ្វើកុសលណាមួយ មានការឲ្យទាន រក្សាសីលជាដើម ដោយអំណាចនៃលោភៈ ចង់បានរូបស្អាត ចង់បានទ្រព្យច្រើន ចង់មានអាយុវែងជាដើម មិនមែនធ្វើដើម្បីដុសខាត់កិលេស គិតតែពីស្វែងរក ចង់បានវត្ថុដែលពេញចិត្តឲ្យបានច្រើនៗ យ៉ាងនេះហៅថា មានលោភៈជាបរិវារ មានទាំងខាងមុខ មានទាំងខាងក្រោយ ក៏ជាបច្ច័យឲ្យកើតលោភៈក្នុងភពថ្មីទៀត ។

ពាក្យថា **លោភឧស្សន្នភវតោ ចវនតា** មានន័យថា ចុតិមកចាកភព ដែលច្រើន ឬ ក្រាស់ទៅដោយលោភៈ ។

- មានឋានសួគ៌ជាដើម កាលមកកើតក្នុងជាតិថ្មីនេះ លោភៈ

ក៏ជាប់តាមមកជានិស្ស័យ សន្តានជារាគចរិត ធ្វើឲ្យស្រឡាញ់តែស្អាត តែល្អក្នុងរូប សំឡេងជាដើម ក៏ជាហេតុឲ្យកើតលោភៈ ជាយូរអង្វែងតទៅ ។

ពាក្យថា **ឥដ្ឋារម្មណសមាយោគោ** មានន័យថា ប្រកប ឬ ប្រទះនឹងអារម្មណ៍ គឺវត្ថុដែលគួរជាប់ចិត្ត គួរប្រាថ្នាក្នុងជាតិដែលខ្លួនកើតនេះ បើជួបប្រទះនឹងអារម្មណ៍មិនល្អ មិនពេញចិត្ត ទោសៈក៏កើតឡើង តែបើជួបប្រទះនឹងអារម្មណ៍ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលល្អជាទីប្រាថ្នាហើយ លោភៈក៏បានឱកាសកើតឡើង ចង់បានអារម្មណ៍នោះឲ្យប្រណីតថែមទៀត មិនចេះឆ្អែត មិនចេះពេញដោយកាម ។

ពាក្យថា **ឱស្សាទទស្សនំ** មានន័យថា ឃើញវត្ថុដែលពេញចិត្ត ឬ សប្បាយចិត្ត ។

- ពេលឃើញវត្ថុដែលពេញចិត្ត ឬ ឮសំឡេងដែលសប្បាយចិត្ត ដូចអ្នកដែលទិញរបស់ជាដើម ក៏មានចិត្តចង់បាន លោភៈក៏កើតឡើង ។

ម្យ៉ាងទៀត សូម្បីលោភសោមនស្ស ក៏មានហេតុឲ្យកើតដែរ ព្រោះបរមត្ថធម៌ទាំងពួងមានហេតុជាដែនកើត ។

# ហេតុឲ្យកើតលោភសោមនស្ស
# មាន ៤ ប្រការ

ពាក្យថា **សោមនស្សបដិសន្ធិកតា** មានន័យថា ភាពជាអ្នកបដិសន្ធិដោយ សោមនស្ស ។

- ធម្មតា បុគ្គលដែលបដិសន្ធិចិត្ត កើតព្រមនឹងសោមនស្សវេទនា កាលបើប្រទះនឹងអារម្មណ៍មិនល្អ ក៏មិនសូវមានទុក្ខក្តៅរោលរាលដែរ តែបើបានទទួលអារម្មណ៍ដែលល្អ ពេញចិត្ត សោមនស្សសប្បាយរីករាយត្រេកត្រអាល ក៏រមែងកើតឡើង ដោយហេតុនេះហើយ បដិសន្ធិដោយសោមនស្ស ទើបជាហេតុឲ្យកើតសោមនស្ស ។

ពាក្យថា **អគម្ភីរបកតិតា** មានន័យថា ភាពជាអ្នកមានប្រក្រតីមិនសុខុម ។

- គឺជាបុគ្គលដែលមិនមានសេចក្តីសុខជាប្រក្រតី ពេលណាលោភមូលចិត្តកើតព្រមនឹងសោមនស្ស ក៏រមែងឲ្យកើតការសប្បាយត្រេកត្រអាល រីករាយជាមួយនឹងរឿងនោះៗ ។

យ៉ាងនេះឯង ភាពជាបុគ្គលមិនសុខុមជាប្រក្រតី ទើបជាហេតុឲ្យសោមនស្សកើតឡើង ។

ពាក្យថា **ឥដ្ឋារម្មណសមាយោគោ** មានន័យថា ប្រកប

នឹងឥដ្ឋារម្មណ៍ ។

- គឺ ជួបប្រទះតែនឹងរបស់ដែលគួរឲ្យកើតសេចក្ដីពេញចិត្ត ត្រេកត្រអាលជានិច្ច ទើបជាហេតុឲ្យសោមនស្សកើត ។

ពាក្យថា **ព្យសនវិមុត្តិ** មានន័យថា ផុតចាកសេចក្ដីវិនាស ៥ គឺថា កាលបើផុតចាកសេចក្ដីវិនាសណាមួយហើយ ក៏ជាហេតុឲ្យកើតសោមនស្សវេទនា ។

# ព្យសនៈ( សេចក្ដីវិនាស ) ៥ យ៉ាង

**១.** ញាតិព្យសនៈ សេចក្ដីវិនាសព្រោះ ញាតិ ។

**២.** ភោគព្យសនៈ ” ” ភោគៈ ។

**៣.** រោគព្យសនៈ ” ” រោគ ។

**៤.** សីលព្យសនៈ ” ” សីល ។

**៥.** ទិដ្ឋិព្យសនៈ ” ” ទិដ្ឋិ ។

កាលបើសេចក្ដីវិនាសក្ដី សេចក្ដីហិនហោចក្ដី កើតពីព្យសនៈទាំងនេះហើយ សោមនស្សវេទនា តែងកើតដោយលំបាកណាស់ ។

# ហេតុឲ្យកើត
# លោភឧបេក្ខាមាន ៤ ប្រការ

ពាក្យថា **ឧបេក្ខាបដិសន្ធិកតា** មានន័យថា បដិសន្ធិដោយឧបេក្ខា ។

- ធម្មតា អ្នកដែលបដិសន្ធិដោយឧបេក្ខាវេទនានោះ តែងជាបុគ្គលព្រងើយៗ សូម្បីបានទទួលអារម្មណ៍ល្អពេញចិត្តក្តី គេតែងតែមានចិត្តជាកណ្តាលៗ មិនដល់ថ្នាក់ត្រេកត្រអាល សប្បាយរីករាយខ្លាំងពេកទេ ។

ពាក្យថា **គម្ភីរបកតិតា** មានន័យថា ជាអ្នកមានប្រក្រតីសុខុម ។

- ជាអ្នកមានសេចក្តីសុខុមជ្រាលជ្រៅ មិនប្រថុយប្រថាន មិនងាយសប្បាយចិត្ត មិនងាយអន់ចិត្ត ចេះរម្ងាប់អារម្មណ៍បាន អាចធ្វើចិត្តឲ្យជាកណ្តាល ព្រងើយ ព្រោះជាអ្នកសន្សំអារម្មណ៍ យ៉ាងនោះមក ពិចារណាអារម្មណ៍បានយ៉ាងត្រឹមត្រូវ ក្នុងហេតុផល ដោយសុខុម ដូច្នេះហើយ បុគ្គលអ្នកមានចិត្តសុខុម មានអារម្មណ៍ជាកណ្តាល ទើបជាហេតុឲ្យឧបេក្ខាកើតឡើង ។

ពាក្យថា **មជ្ឈត្តារម្មណសមាយោគោ** មានន័យថា ប្រកប

ដោយអារម្មណ៍ដែលជាកណ្តាល ។

- គឺថា បានជួបប្រទះអារម្មណ៍សមល្មមប្រមាណ មិនដល់សោមនស្ស ទើបជាហេតុឲ្យឧបេក្ខាកើតឡើង ។

**៤ . ព្យសនវិមុត្តិ** = ផុតចាកសេចក្តីវិនាស ។

- ព្រោះព្យសនធម៌ តែងធ្វើឲ្យចិត្តកើតនូវទោមនស្សវេទនា ។

# ហេតុឲ្យកើត
# ទិដ្ឋិគតសម្បយុត្តមាន ៥ ប្រការ

**១.ទិដ្ឋិជ្ឈាសយតា** = មានការយល់ខុសជាអធ្យាស្រ័យ ។

**២.ទិដ្ឋិវិប្បន្នបុគ្គល-សេវនតា** = សេពគប់នឹងបុគ្គលដែលយល់ខុស ។

**៣.សទ្ធម្មវិមុខតា** = បែរមុខចេញពីព្រះសទ្ធម្ម ។

**៤.មិច្ឆាវិតក្កពហុលតា** = ជាអ្នកច្រើនទៅដោយមិច្ឆាវិតក្ក ។

**៥.អយោនិសោ ឧម្មុជ្ជនំ** = មិនពិចារណាដោយឧបាយនៃប្រាជ្ញា។

ពាក្យថា **ទិដ្ឋិជ្ឈាសយតា** គឺ **ទិដ្ឋិ + អជ្ឈាសយ + តា** បានសេចក្តីថា លោភមូលចិត្តដែលប្រកបនឹងការយល់ខុស ព្រោះមាន

អធ្យាស្រ័យចូលចិត្តតែគិតក្រៅពីហេតុផល ហើយសន្ទុំអប់រំតែក្នុងផ្លូវដែលខុស ទើបជាហេតុឲ្យកើតទិដ្ឋិគតសម្បយុត្ត ។

ពាក្យថា **ទិដ្ឋិវិប្បន្នបុគ្គលសេវនតា** គឺ **ទិដ្ឋិ + វិប្បន្ន + បុគ្គល + សេវនតា** បានសេចក្ដីថា ការសេពគប់នឹងបុគ្គលដែលមានវិបត្តិព្រោះយល់ខុស ក៏ធ្វើឲ្យមានការយល់ខុសទៅដែរ ព្រោះបុគ្គលប្រភេទនោះ តែងដឹកនាំឲ្យទៅតាមការយល់ឃើញរបស់ខ្លួន ។

ទិដ្ឋិដែលមានទោសច្រើន ទោសធ្ងន់មាន ៣ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ ) គឺ :

**១ . អកិរិយទិដ្ឋិ** យល់ឃើញថា មិនជាការធ្វើល្អ ( របស់គ្រូបុរណកស្សបៈ ) គឺ បដិសេធការធ្វើល្អ ការធ្វើអាក្រក់ទាំងអស់ ។ គេថា សូម្បីវិញ្ញាណអ្នកនោះឯង ក៏មិនទទួលដឹងឮការធ្វើនោះៗ ដែរ បើបដិសេធការធ្វើហើយ ក៏រមែងបដិសេធផលរបស់កម្មនោះថា មិនមានដែរ ។

**២ . អហេតុកទិដ្ឋិ** យល់ថាអ្វីៗទាំងអស់ មិនមានហេតុ(របស់គ្រូមក្ខលិគោសាល ) គឺ បដិសេធផលដែលកើតពីការធ្វើ កម្មមិនមានផលនៃកម្មមិនមាន សេចក្ដីព្យាយាមមិនមាន អ្វីៗទាំងអស់ដែលកើតឡើងក្នុងជីវិតរបស់មនុស្សនោះ មិនថាសេចក្ដីសុខ សេចក្ដីទុក្ខ សេចក្ដីបរិសុទ្ធិ គឺ កើតមកដោយឯកឯង ដោយមិនមានហេតុបច្ច័យ មិនចាំ

បាច់អាស្រ័យហេតុជាបច្ច័យ គឺ អ្វីៗទាំងអស់ កើតដោយឯកឯង ហើយរលត់ ក៏ដោយឯកឯងដែរ ។

**៣ . នត្ថិកទិដ្ឋិ** យល់ថា បុណ្យមិនមាន បាបមិនមាន(របស់គ្រូអជិតកេសកម្ពល ) គឺ បដិសេធទាំងហេតុទាំងផល គឺ យល់ថា បាបបុណ្យ ការធ្វើ ផលនៃការធ្វើ និង លោកខាងមុខមិនមាន ទីបំផុតរបស់សត្វទាំងឡាយចប់នៅត្រង់ការស្លាប់ ដូចគ្នានឹងឧច្ឆេទទិដ្ឋិ ។

ការយល់ខុសទាំង ៣ នេះហៅថា **និយតមិច្ឆាទិដ្ឋិ** ជាការយល់សិយុងចុះលំបាកនឹងកែខៃបាន ជាការយល់ដែលមានទោសធ្ងន់បំផុត ក្នុងទោសចំណែកនៃអកុសល ។

ពាក្យថា **សទ្ធម្មវិមុខតា** = សទ្ធម្ម + វិ + មុខតា ។

វិមុខតា ប្រែថា បែរ ឬ គេចមុខចេញ បានសេចក្តីថា មិនសិក្សាព្រះសទ្ធម្ម ។ ពាក្យថា សទ្ធម្ម នេះ ប្រែថា ធម៌របស់សប្បុរស ឬ របស់អ្នកស្ងប់ ។

សទ្ធម្ម នេះ ទីខ្លះហៅថា ព្រះពុទ្ធសាសនា ឬ ហៅថា ព្រះធម្មវិន័យ ក្រោយមកទៀតហៅថា ព្រះត្រៃបិដក ។ ព្រះសទ្ធម្មនោះមាន ៣ គឺ បរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ និង បដិវេធសទ្ធម្ម ១ ។ ក្នុងអភិធម្មវិភង្គ ពោលនូវសទ្ធម្ម ១០ គឺ មគ្គ ៤ ផល ៤

និព្វាន ១ និង បរិយត្តិធម៌ ១ ។ កាលណាមិនសិក្សានូវព្រះសទ្ធម្ម ទេ ក៏មិនអាចលះការយល់ខុសនោះបានឡើយ ។

ពាក្យថា **មិច្ឆាវិតក្កពហុលតា** គឺ មិច្ឆា+វិតក្ក+ពហុលតា។

មិច្ឆា = ខុស , វិតក្កៈ = ត្រិះរិះ នឹកគិត , ពហុលតា = ភាពជាអ្នកច្រើន បានសេចក្តីថា ជាអ្នកត្រិះរិះនឹកគិតតែក្នុងផ្លូវដែលខុស ដោយសភាពជាអ្នកមិនឈ្លាស ហៅថា មិច្ឆាវិតក្កៈ មាន ៣ គឺ :

**១ . កាមវិតក្កៈ** ត្រិះរិះនឹកគិតដល់ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ណាដែលជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីពេញចិត្ត ។

**២ . ព្យាបាទវិតក្កៈ** ការត្រិះរិះនឹកគិតដោយអំណាចការព្យា- បាទ ដូចអ្នកខ្លះខឹងហើយ ក៏ចងកំហឹងនោះទុកដោយអំណាចការចង ពៀរវេរា ។

**៣ . វិហឹង្សាវិតក្កៈ** ការត្រិះរិះនឹកគិតដោយអំណាចការមិន ចូលចិត្ត ចង់ឲ្យអ្នកដទៃវិនាសដោយសេចក្តីក្តៅក្រហាយណាមួយ ។

កាលបុគ្គល ជាអ្នកច្រើនទៅដោយមិច្ឆាវិតក្កៈយ៉ាងនេះហើយ ក៏ជាហេតុឲ្យទិដ្ឋិគតសម្បយុត្តកើត ។

ពាក្យថា **អយោនិសោឧម្មុជ្ជនំ** គឺ អ+យោនិសោ+ឧម្មុជ្ជនំ ។

**អ** = មិន, **យោនិសោ** = ដោយឧបាយនៃប្រាជ្ញា, **ឧម្មុជ្ជនំ** = ការលេចឡើង គឺការពិចារណា បានសេចក្តីថា ជាអ្នកមិនពិចារណា

ដោយត្រូវទំនង គឺ កាលណាប្រទះនឹងអារម្មណ៍ណាហើយ ក៏មិនពិចារណាអារម្មណ៍នោះៗ ឲ្យត្រឹមត្រូវតាមសេចក្តីពិត យ៉ាងនេះក៏ធ្វើឲ្យកើតការយល់ខុស ។

# ហេតុឲ្យកើតទិដ្ឋិគតវិប្បយុត្ត មាន ៥ ប្រការ

**១.អទិដ្ឋិជ្ឈាសយតា** ជាអ្នកមិនមានការយល់ខុស ជាអធ្យាស្រ័យ ។

**២.ទិដ្ឋិវិប្បន្នបុគ្គលអសេវនតា** ជាអ្នកមិនសេពគប់នឹង បុគ្គលដែលវិបត្តិព្រោះទិដ្ឋិ ។

**៣.សទ្ធម្មសម្មុខាតា** ជាអ្នកប៉ងសំដៅចំពោះ ព្រះសទ្ធម្ម ។

**៤.មិច្ឆាវិតក្កាពហុលតា** ជាអ្នកមិនចំណូលដោយ មិច្ឆា-វិតក្កៈ ។

**៥.យោនិសោឧម្មុជ្ជនំ** ការពិចារណា ដោយឧបាយនៃប្រាជ្ញា ។

ហេតុឲ្យកើតទិដ្ឋិគតវិប្បយុត្ត ៥ នេះ ជាធម៌ផ្ទុយនឹងហេតុឲ្យ

កើតទិដ្ឋិគតសម្បយុត្ត ដូច្នេះបណ្ឌិតគប្បីប្រៀបធៀបនឹងន័យដែលបានពោលហើយនោះចុះ ។

# ហេតុឲ្យកើតអសង្ខារិក មាន ៦ ប្រការ

| | |
|---|---|
| ១.អសង្ខារិកកម្មជនិត-បដិសន្ធិកតា | ជាអ្នកមានបដិសន្ធិ ដោយកម្មដែលជាអសង្ខារិកៈ ។ |
| ២.កល្លកាយចិត្តតា | ជាអ្នកដែលមានកាយ និង ចិត្តរឹងមាំ ។ |
| ៣.ខន្តិពហុលតា | ជាអ្នកច្រើនដោយការអត់ធន់។ |
| ៤.កត្តព្វកម្មេសុទិដ្ឋានិសំសតា | ជាអ្នកឃើញនូវប្រយោជន៍ ក្នុងការងារដែលគប្បីធ្វើ ។ |
| ៥.កម្មេសុ ចិណ្ណវសិតា | ជាអ្នកដែលជំនាញ ក្នុងការងារទាំងឡាយ ។ |
| ៦.ឧតុភោជនាទិសប្បាយ-លាភោ | មានការសប្បាយចិត្ត ក្នុងឧតុ និង ភោជនជាដើម ។ |

ពាក្យថា **អសង្ខារិកកម្មជនិតបដិសន្ធិកតា** គឺ អសង្ខារិក + កម្ម + ជនិត + បដិសន្ធិកតា ។

**អសង្ខារិក** = មិនមានអ្នកណាដឹកនាំ , **កម្ម** = អំពើ , **ជនិត** = បានកើតហើយ , **បដិសន្ធិកតា** = ភាពជាអ្នកមានបដិសន្ធិ ។

បានសេចក្តីថា បដិសន្ធិចិត្ត ជាផលរបស់កម្ម ដែលជាអសង្ខារិកៈ កាលបើកម្មដែលជាអសង្ខារិក ជាជនកកម្ម ក៏ធ្វើឲ្យបដិសន្ធិចិត្តជាអសង្ខារិកៈ ។ អ្នកដែលបដិសន្ធិដោយកម្មនោះ រមែងមិនខ្លាច ធ្វើអ្វីតាមតែខ្លួនឯង មិនត្រូវការជួយដឹកនាំពីអ្នកដទៃឡើយ ។

ពាក្យថា **កល្លកាយចិត្តតា** គឺ កល្ល + កាយ + ចិត្ត + តា ។

**កល្ល** = អាច រឹងមាំ ឈ្លាស ។

បានសេចក្តីថា សភាពចិត្ត និង កាយរបស់បុគ្គលនោះ មានអំណាចក្នុងខ្លួន ហ៊ានសម្រេច ហ៊ានធ្វើដោយខ្លួនឯង មិនត្រូវការអាស្រ័យការតាក់តែងដឹកនាំពីអ្នកដទៃ មិនងាយទៅតាមអ្នកណាបានស្រួលៗឡើយ ។

ពាក្យថា **ខន្តិពហុលតា** គឺ ខន្តិ + ពហុល + តា ។

**ខន្តិ** = ការអត់ធន់ , **ពហុល** = មានច្រើន ។

បានសេចក្តីថា ជាអ្នកមានការអត់ធន់ ព្យាយាម ធន់ចំពោះ

ភាពរងា ភាពក្តៅ ធន់ចំពោះវត្ថុដែលជាសឹកសត្រូវនឹងចិត្តរបស់ខ្លួន រហូតកើតជាទម្លាប់ ។ ព្រោះការទម្លាប់អត់ធន់ចំពោះការលំបាកមកច្រើនៗ និងឆ្លងឧបសគ្គមកច្រើនៗនេះ ដល់ជួបប្រទះនឹងការខុសឆ្គង ក៏ព្យាយាមកែខៃមិនរាថយ មិនទម្លាប់ត្រូវការឲ្យអ្នកដទៃដឹកនាំ ។

ពាក្យថា **កត្តព្វកម្មេសុ ទិដ្ឋានិសំសតា** គឺ កត្តព្វ + កម្មេសុ + ទិដ្ឋិ + អានិសំស + តា ។

**កត្តព្វ** = គប្បីធ្វើ, **កម្មេសុ** = ក្នុងការងារទាំងឡាយ, **អានិសំស** = អានិសង្ស ប្រយោជន៍ ។

បានសេចក្តីថា ចិត្តរបស់គេ បានឃើញផលពីការងារ គឺ ឃើញប្រយោជន៍ដែលសម្រេចពីការប្រព្រឹត្តរួចហើយ ការឃើញយ៉ាងនោះហើយ រមែងហ៊ានធ្វើដោយខ្លួនឯងដោយមិនអាស្រ័យពីអ្នកដទៃដឹកនាំឡើយ ។

ពាក្យថា **កម្មេសុ ចិណ្ណវសិតា** គឺ កម្មេសុ + ចិណ្ណ + វសិ + តា ។

**ចិណ្ណ** = ដែលខ្លួនបានប្រព្រឹត្តហើយ , **វសិ** = មានការជំនាញ ។

បានសេចក្តីថា ជាអ្នកធ្លាប់បានធ្វើការងារនោះ ៗ មកហើយ

រួចក៏មានការជំនាញ ។ អាស្រ័យការធ្លាប់ធ្វើ និង មានការជំនាញនោះ ទើបជាហេតុឲ្យកើតអសង្ខារិកៈ ។

ពាក្យថា **ឧតុភោជនាទិសប្បាយលាភោ** គឺ ឧតុ + ភោជន + អាទិ + សប្បាយ + លាភោ ។

**ឧតុ** = រដូវ អាកាស, **ភោជន** = អាហារ, **អាទិ** = ជាដើម , **លាភោ** = ការបាន ។

បានសេចក្តីថា បានទទួលនូវរដូវ គឺ អាកាសល្អ អាហារសមរម្យ ក៏មានការស្រួល សុខសប្បាយ គឺមានអនាម័យល្អ ប្រាសចាករោគភ័យ ។ បើរាងកាយមិនមានរោគភ័យបៀតបៀន ចិត្តក៏សប្បាយរីករាយរឹងប៉ឹង មិនទន់ទំរន់ អាចធ្វើកិច្ចការអ្វីៗបានដោយចិត្តដែលជាអសង្ខារិកៈ ។

# ហេតុឲ្យកើតសសង្ខារិកៈ
# មាន ៦ ប្រការ

**១.សសង្ខារិកកម្មជនិត-បដិសន្ធិកតា** បដិសន្ធិ ដោយកម្មដែលជាសសង្ខារិកៈ ។

| | |
|---|---|
| **២.អកល្លកាយចិត្តតា** | ជាអ្នកមានកាយ និង ចិត្តមិនរឹងប៉ឹង ។ |
| **៣.អខន្តិពហុលតា** | ជាអ្នកច្រើនទៅ ដោយការមិនអត់ធន់ ។ |
| **៤.អកត្តញ្ញកម្មេសុទិដ្ឋានិសំសតា** | មិនធ្លាប់ឃើញនូវ ប្រយោជន៍ក្នុងការងារដែលធ្វើ ។ |
| **៥.កម្មេសុ អចិណ្ណវសិតា** | ជាអ្នកមិនជំនាញ មិនឈ្លាសក្នុងការងារទាំងឡាយ ។ |
| **៦.ឧតុភោជនាទិ អសប្បាយលាភោ** | មិនមាន សេចក្តីសុខសប្បាយក្នុងឧតុ និងភោជនជាដើម ។ |

ហេតុឲ្យកើតសសង្ខារិក ៦ នេះ មានខ្លឹមសារផ្ទុយនឹងហេតុឲ្យកើតអសង្ខារិក ៦ ដូច្នេះបណ្ឌិតគប្បីប្រៀបធៀបផងចុះ ៕

# ចំណែកលោភមូលចិត្ត ៨ ដោយន័យផ្សេងៗ

**១.ដោយជាតិ** លោភមូលចិត្ត៨ ជាអកុសលជាតិ

| | | |
|---|---|---|
| **២.ដោយភូមិ** | លោភមូលចិត្ត ៨ | ជាកាមាវចរភូមិ (កើតបាន ៣០ ភូមិ ) |
| **៣.ដោយវេទនា** | ” ” | ជាសោមនស្ស ៤<br>ជាឧបេក្ខា ៤ |
| **៤.ដោយហេតុ** | ” ” | ជានហេតុ និង ជាទ្វិហេតុកចិត្ត |
| **៥.ដោយសង្ខារ** | ” ” | ជាអសង្ខារិក ៤<br>សសង្ខារិក ៤ |
| **៦.ដោយសម្បយុត្ត** | ” ” | ជាសម្បយុត្ត ៤<br>ជាវិប្បយុត្ត ៤ |
| **៧.ដោយសោភណៈ** | ” ” | ជាអសោភណចិត្ត |
| **៨.ដោយឈាន** | ” ” | ជាអឈានចិត្ត |
| **៩.ដោយលោកិយ** | ” ” | ជាលោកិយចិត្ត |
| **១០.ដោយកិច្ច** | ” ” | ជាជវនកិច្ច |
| **១១.ដោយអារម្មណ៍** | ” ” | ជាចិត្តមានអារម្មណ៍ ៦ |
| **១២.ដោយទ្វារ** | ” ” | ជាចិត្តកើតបាន ៦ ទ្វារ |

**១៣.ដោយវត្ថុ** ” ” កើតត្រង់ហទយវត្ថុ (ក្នុងភូមិដែលមានខន្ធ ៥ )

**១៤.ដោយវិញ្ញាណធាតុ** ” ” ជាមនោវិញ្ញាណធាតុ

# ផលរបស់លោភមូលចិត្ត

ផលនៃលោភមូលចិត្ត ដែលប្រាកដក្នុងបច្ចុប្បន្ន ព្រះអង្គទ្រង់ត្រាស់ថា រមែងកើតទុរ្ភិក្សអន្តរាយផ្សេងៗដល់មហាជន ប្រមាណមិនបាន កាលណាសន្តាននៃមនុស្សក្រាស់ទៅដោយលោភៈ ។

ចំណែកផលរបស់លោភមូលចិត្ត ដែលនឹងប្រាកដក្នុងអនាគតកាលនោះ ទ្រង់ត្រាស់ទុកថា សត្វទាំងឡាយដោយច្រើនតែងទៅកាន់បេត្តិវិស័យ គឺ កំណើតប្រែតព្រោះតណ្ហា(លោភមូលចិត្ត)ជាហេតុ ៕

( ចប់លោភមូលចិត្ត ៨ ដួង )

# ទោសមូលចិត្ត ២ ដួង

## ១. ទោមនស្សសហគត បដិឃសម្បយុត្ត អសង្ខារិក
## ២. ទោមនស្សសហគត បដិឃសម្បយុត្ត សសង្ខារិក

ទោសមូលចិត្ត ឬហៅថា បដិឃសម្បយុត្តចិត្ត ឬហៅថា បដិឃចិត្ត ជាចិត្តកើតឡើងព្រោះមានទោសៈជាហេតុ ។ សេចក្ដីមិនប្រាថ្នាក្នុងអារម្មណ៍ផ្សេងៗនោះ តែងកើតឡើង ព្រោះទោសៈ ឬមានទោសៈជាដើមហេតុ ។ ទោសៈជា អកុសលចេតសិក តាក់តែងចិត្តឲ្យកើតសេចក្ដីក្រោធ សេចក្ដីស្អប់ខ្ពើម សេចក្ដីខ្លាច សេចក្ដីអន់ចិត្ត សេចក្ដីព្រួយបារម្ភ រំខានចិត្តជាដើម ព្រោះទោសៈជាសភាវៈគ្រោតគ្រាត ។

ពាក្យថា **ទោមនស្សសហគត** ប្រែថា ចិត្តកើតព្រមដោយទោមនស្សវេទនា គឺ សភាពនៃចិត្តអាក្រក់ ឬសភាពលំបាកចិត្ត ។

ពាក្យថា **បដិឃសម្បយុត្ត** ប្រែថា ប្រកបដោយបដិឃៈ គឺ ថ្នាំងថ្នាក់ក្នុងអារម្មណ៍ ។

**ទោមនស្សសហគត បដិឃសម្បយុត្ត អសង្ខារិកៈ** ប្រែថា ចិត្តកើតព្រមដោយទោមនស្ស ប្រកបដោយបដិឃៈ សេចក្ដី

ថ្នាំងថ្នាក់មិនមានការដឹកនាំ ។

ទោសមូលចិត្តនេះ មានលក្ខណៈផ្ទុយពីលោភមូលចិត្ត ព្រោះសភាពនៃទោសចេតសិកនោះ គ្រោតគ្រាត មិនពេញចិត្ត មានលក្ខណៈប្រទូស្តកាច ។ ស័ព្ទដែលជាឈ្មោះនៃទោសៈ មានច្រើនដូចពាក្យថា **អាឃាតោ** = អាឃាត គឺ ក្រោធ, **បដិហាតោ** = ខឹង, **បដិឃំ** = ថ្នាំងថ្នាក់, **បដិវិរោធោ** = គុំគួន, ជាដើម ។

# លក្ខណាទិចតុកៈនៃទោសៈ

**-ចណ្ឌិក លក្ខណោ** មានការកាចសាហាវ ជាលក្ខណៈ ។

**-និស្សយទហន រសោ** មានការដុតរោលនូវសម្បយុត្តធម៌ ជាកិច្ច ។

**-ទូស្សន បច្ចុប្បដ្ឋានោ** មានការប្រទូសរ៉ាយជាអាការប្រាកដ ។

**-អាឃាតវត្ថុ បទដ្ឋានោ** មានអាឃាតវត្ថុ ជាបទដ្ឋាន ។

# អាឃាតវត្ថុ ១០ ប្រការ

**១.**អាឃាតគេ ដោយគិតថា បានធ្លាប់ធ្វើសេចក្តីវិនាសដល់យើង ។

**២**.អាឃាតគេ ដោយគិតថា កំពុងធ្វើសេចក្តីវិនាសដល់យើង ។

**៣**.អាឃាតគេ ដោយគិតថា នឹងធ្វើនូវសេចក្តីវិនាសដល់យើង ។

**៤**.អាឃាតគេ ដោយគិតថា ធ្លាប់បានធ្វើនូវសេចក្តីវិនាស ដល់អ្នកដែលយើងស្រឡាញ់ ។

**៥**.អាឃាតគេ ដោយគិតថា កំពុងធ្វើនូវសេចក្តីវិនាស ដល់អ្នកដែលយើងស្រឡាញ់ ។

**៦**.អាឃាតគេ ដោយគិតថា នឹងធ្វើនូវសេចក្តីវិនាស ដល់អ្នកដែលយើងស្រឡាញ់ ។

**៧**.អាឃាតគេ ដោយគិតថា ធ្លាប់បានធ្វើនូវប្រយោជន៍ដល់អ្នកដែលយើងស្អប់ ។

**៨**.អាឃាតគេ ដោយគិតថា កំពុងធ្វើនូវប្រយោជន៍ ដល់អ្នកដែលយើងស្អប់ ។

**៩**.អាឃាតគេ ដោយគិតថា នឹងធ្វើប្រយោជន៍ឲ្យអ្នកដែលយើងស្អប់។

**១០**.អាឃាត ក្នុងឋានៈដែលមិនសមគួរ ដូចជាខណៈដែលដើរជំពប់ ឬ ជាន់ភ្លើងជាដើម ។

# ហេតុឲ្យកើតទោសមូលចិត្ត
# មាន ៤ ប្រការ

**១.ទោសជ្ឈាសយតា** មានអធ្យាស្រ័យ ជាអ្នកចងនូវសេចក្ដីក្រោធទុក ។

**២.អគម្ភីរបកតិតា** មានសេចក្ដីមិនសុខុមជាប្រក្រតី ។

**៣.អប្បសុតតា** មានការស្ដាប់នូវព្រះសទ្ធម្មតិចតួច ។

**៤.អនិដ្ឋារម្មណសមាយោគោ** ប្រកបនឹងអារម្មណ៍ ដែលមិនល្អ មិនគាប់ចិត្ត ។

ពាក្យថា **ទោសជ្ឈាសយតា** គឺ **ទោស + អជ្ឈាសយ + តា** មានសេចក្ដីថា ជាអ្នកមាននិស្ស័យខាងក្រោធ រហ័សក្រោធ ព្រោះមកពីបានសន្សំទុកច្រើនរហូតជាប់ក្នុងសន្ដាន ។ ខណៈទោសៈកើតឡើងម្ដងណាក៏ដោយ ទោមនស្សវេទនាក៏កើតឡើងដែរ ។ ព្រោះដូច្នេះឯង ទើបលោកពោលថា ទោសៈជាភ័យដ៏ខ្លាំងក្លា មានទោសច្រើនតែរហ័សរំសាយជាងលោភៈ ពេលកើតឡើងធ្វើចិត្តឲ្យខឹង ព្យាបាទ មិនពេញចិត្ត ហួងហែង កង្វល់ អផ្សុក បាក់ទឹកចិត្ត ខ្លាច មិនត្រូវ

ការឲ្យអ្នកដទៃមានសេចក្តីសុខចំរើនឡើយ ។

ពាក្យថា **អគម្ភីរបកតិតា** គឺ **អ + គម្ភីរ + បកតិតា** មានសេចក្តីថា ពេលទោសមូលចិត្តកើតឡើង ចិត្តដួងនេះមិនមានសេចក្តីសុខុមទេ ជាអ្នកឆេវឆាវ តែងញ៉ាំងសភាវៈដែលមិនជាប្រយោជន៍ ឲ្យកើតឡើងជានីវរណៈ រារាំងចិត្តមិនឲ្យដឹងអត្ថ និង ធម៌ តាមសេចក្តីពិតទេ ។

ពាក្យថា **អប្បសុតតា** គឺ **អប្ប + សុត + តា** ។
**អប្ប** = តិច , **សុត** = អ្នកស្តាប់ ។

មានសេចក្តីថា អ្នកដែលសិក្សា រៀនសូត្រព្រះសទ្ធម្មតិចតួច តែងមិនដឹងធម៌ណាជាគុណ ជាទោស ធម៌ណាមានប្រយោជន៍ ធម៌ណាគួរចំរើន បើមិនដឹងហើយ ក៏ជាហេតុឲ្យទោសៈកើតឡើង ។

ពាក្យថា **អនិដ្ឋារម្មណសមាយោគោ** គឺ **អនិដ្ឋ + អារម្មណ + សមាយោគោ** ។ **អនិដ្ឋ** = មិននាំមកជាទីប្រាថ្នា ។

មានសេចក្តីថា ពេលដែលជួបប្រទះនឹង រូប សំឡេង ក្លិន រស និង ផោដ្ឋព្វៈ ដែលមិននាំមកជាទីប្រាថ្នា ក៏កើតទោមនស្ស-ទោសមូលចិត្ត ៕

# ធម៌ដែលជាហេតុ
# លះទោសមូលចិត្ត ៦ គឺ

១. មេត្តានិមិត្តស្ស ឧគ្គហោ  ការរៀនទូវមេត្តានិមិត្ត ។

២. មេត្តាភាវនានុយោគោ  ការបំពេញព្យាយាមចំរើនមេត្តាភាវនា ។

៣. កម្មស្សកតាបច្ចវេក្ខណា  ការពិចារណាថា សត្វមានកម្មជារបស់ខ្លួន ។

៤. បដិសង្ខានពហុលីកតា  ភាពជាអ្នកច្រើនទៅ ដោយការពិចារណា ។

៥. កល្យាណមិត្តតា  ភាពជាអ្នកមានកល្យាណមិត្ត ។

៦. សប្បាយកថា  សន្ទនាក្នុងរឿងដែលសប្បាយ ។

( បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ មូលបណ្ណាសក: )

# ចំណែកទោសមូលចិត្ត ២
# ដោយន័យផ្សេងៗ

| | | | |
|---|---|---|---|
| ១.ដោយជាតិ | ទោសមូលចិត្ត២ | ជាអកុសលជាតិ | ។ |
| ២.ដោយភូមិ | ” | ” | ជាកាមាវចរភូមិ(កើតក្នុងភូមិ១១) |
| ៣.ដោយវេទនា | ” | ” | ជាទោមនស្សវេទនា ។ |
| ៤.ដោយហេតុ | ” | ” | ជានហេតុនិងទ្វិហេតុកចិត្ត ។ |
| ៥.ដោយសង្ខារ | ” | ” | ជាអសង្ខារិក១ ជាសសង្ខារិក១ |
| ៦.ដោយសម្បយុត្ត | ” | ” | ជាបដិឃសម្បយុត្ត ។ |
| ៧.ដោយសោភណៈ | ” | ” | ជាអសោភណៈ ។ |
| ៨.ដោយឈាន | ” | ” | ជាអកុសលឈាន ។ |
| ៩.ដោយលោកិយ | ” | ” | ជាលោកិយចិត្ត ។ |
| ១០.ដោយកិច្ច | ” | ” | ជាជវនកិច្ច ។ |
| ១១.ដោយអារម្មណ៍ | ” | ” | មានអារម្មណ៍ទាំង ៦ ។ |
| ១២.ដោយទ្វារ | ” | ” | ជាចិត្តកើតក្នុងទ្វារទាំង ៦ ។ |
| ១៣.ដោយវត្ថុ | ” | ” | ជាចិត្តកើតត្រង់ហទយវត្ថុ ។ |

**១៤.ដោយវិញ្ញាណធាតុ ” ”** ជាមនៅវិញ្ញាណធាតុ ។

# ផលរបស់ទោសមូលចិត្ត

សម័យណា មនុស្សមានចិត្តសន្តានអាក្រក់ ច្រើនទៅដោយទោសៈ សម័យនោះតែងកើតសត្ថន្តរាយ ( អន្តរាយដែលកើតពីការបៀតបៀនគ្នាដោយសស្ត្រាវុធ ) ផ្សេងៗ ជាហេតុឲ្យកើតចម្បាំងរាំងជល់គ្នា ។

ក្នុងអនាគតកាល ព្រោះទោសៈជាហេតុ សត្វទាំងឡាយទើបទៅកាន់នរក ដូចជាទោសៈ ព្រោះសភាពនៃទោសចិត្តនោះ ជាជាតិកាចសាហាវ ៕

( ចប់ទោសមូលចិត្ត ២ ដួង )

# មោហមូលចិត្ត ២ ដួង

## ១. ឧបេក្ខាសហគត វិចិកិច្ឆាសម្បយុត្ត
## ២. ឧបេក្ខាសហគត ឧទ្ធច្ចសម្បយុត្ត

**មោហមូលចិត្ត** ជាចិត្តដែលមានមោហៈជាហេតុ ជាចិត្តមិនដឹង វង្វេង ល្ងង់ខ្លៅ មិនដឹងតាមសេចក្ដីពិត ។

**វិចិកិច្ឆា** ជាធម្មជាតិដែលជាហេតុឲ្យសម្រេចសភាវៈលំបាក ជាធម៌បិទបាំងនូវបញ្ញា ។ ចិត្តដែលប្រកបនឹងវិចិកិច្ឆា ឈ្មោះថា **វិចិកិច្ឆាសម្បយុត្តចិត្ត** ។

**ឧទ្ធច្ចៈ** ជាភាវៈនៃចិត្តដែលរវើរវាយ ។ ចិត្តដែលប្រកបនឹងឧទ្ធច្ចៈ ឈ្មោះថា **ឧទ្ធច្ចសម្បយុត្តចិត្ត** , ឧទ្ធច្ចៈជាអកុសលចេតសិកកើតទូទៅក្នុងអកុសលចិត្ត ប៉ុន្តែជាប្រធានក្នុងសម្បយុត្តធម៌ ក្នុងមោហមូលចិត្តដួងទី ២ គឺជា ឧទ្ធច្ចនីវរណៈ ។

អកុសលមោហមូលចិត្តទាំង ២ នេះ វៀរចាកនូវចំណង់ត្រេកត្រអាល និង ការខឹងក្រោធក្នុងអារម្មណ៍ទាំងពួង ព្រោះជាភាពនៃចិត្តវង្វេងល្ងង់ខ្លៅយ៉ាងក្រៃលែង និង ញាប់ញ័រ ព្រោះប្រកបនឹងវិចិកិច្ឆា និង ឧទ្ធច្ចៈ ដែលប្រព្រឹត្តជាមួយនឹងសេចក្ដីរសាប់រសល់ និង

ការរវើរវាយ ហើយតែងកើតព្រមនឹងឧបេក្ខាវេទនាប៉ុណ្ណោះ មាន មោហចេតសិកជាមូល ហៅថា **ឯកហេតុកចិត្ត** ( មិនមានលោភៈ និង ទោសៈជាហេតុទេ ) ។

# ហេតុឲ្យកើត
# មោហមូលចិត្ត ២ ប្រការ

**១.អយោនិសោមនសិការោ** ធ្វើទុកក្នុងចិត្ត មិនដោយឧបាយនៃប្រាជ្ញា ។

**២.អាសវសមុប្បាទោ** មានអាសវៈជាហេតុកើតឡើង។

ពាក្យថា **អយោនិសោមនសិការោ** នោះបានដល់ ការមិនពិចារណាអារម្មណ៍ ដែលមកខ្ទាំងខ្ទប់តាមទ្វារនោះៗ ឲ្យឃើញតាមសេចក្ដីពិត មិនពិចារណាហេតុ មិនពិចារណាផល មិនពិចារណាសភាវៈខាងដើម និង ខាងចុងនៃធម៌នោះៗ ទើបជាហេតុឲ្យកើតមោហមូលចិត្ត ២ ដួង ។

ពាក្យថា **អាសវៈ** នោះ បានដល់ កិលេសដែលជាគ្រឿងដេកត្រាំនៅក្នុងចិត្តសន្តាន មាន ៤ ប្រភេទ គឺ :

**១.កាមាសវៈ** អាសវៈ គឺ កាម បានដល់ សេចក្ដីស្រឡាញ់ពេញចិត្តក្នុង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ ។

**២.ភវាសវៈ** អាសវៈ គឺ ភព បានដល់ ការត្រេកអរ ជាប់ជំពាក់ចិត្តក្នុងភព ។

**៣.ទិដ្ឋាសវៈ** អាសវៈ គឺ ទិដ្ឋិ បានដល់ មិច្ឆាទិដ្ឋិទាំងអស់ ។

**៤.អវិជ្ជាសវៈ** អាសវៈ គឺ អវិជ្ជា បានដល់ សេចក្ដីល្ងង់ខ្លៅមិនដឹងពិតក្នុងសភាវៈទាំងពួង ។

មោហចេតសិកនេះ ក្នុងធម្មសង្គណី ពោលថា :

**១- អញ្ញាណំ** ការមិនដឹង ។

**២- អទស្សនំ** ការមិនឃើញ ។

**៣- អនភិសមយោ** ការមិនត្រាស់ដឹង ។

**៤- អននុពោធោ** ការមិនដឹងដោយសមគួរ ។

# លក្ខណាទិចតុក:របស់មោហ:

**-ចិត្តស្ស អន្ធភាវលក្ខណោ** មានការងងឹតស្អប់នៃចិត្ត ជាលក្ខណ: ។

អញ្ញាណ លក្ខណោ — មានការមិនដឹង ជាលក្ខណៈ។

-អារម្មណសភាវច្ឆាទន រសោ — មានការបិទបាំងសភាវៈនៃអារម្មណ៍ ជាកិច្ច ។

អសម្បដិវេធ រសោ — មានការមិនចាក់ធ្លុះ ជាកិច្ច ។

-អន្ធការ បច្ចុប្បដ្ឋានោ — មានការងងឹតស្លុប ជាផល ។

អសម្មាបដិបត្តិ បច្ចុប្បដ្ឋានោ — មានការមិនបដិបត្តិ ដោយត្រឹមត្រូវ ជាអាការប្រាកដ ។

-អយោនិសោមនសិការ បទដ្ឋានោ — មានការធ្វើទុកក្នុងចិត្តមិនដោយឧបាយនៃប្រាជ្ញា ជាបទដ្ឋាន ។

# លក្ខណាទិចតុកៈរបស់វិចិកិច្ឆា

-សំសយ លក្ខណា — មានការសង្ស័យ ជាលក្ខណៈ ។

-កម្បន រសា — មានការញាប់ញ័រ(ក្នុងអារម្មណ៍)ជាកិច្ច ។

-អនិច្ឆយ បច្ចុប្បដ្ឋានា — មានការសម្រេចចិត្តមិនបាន ជាអាការប្រាកដ ។

| | |
|---|---|
| **អនេកំសគាហ បច្ចុប្បដ្ឋានា** | មានការកាន់យកតែម៉្យាងមិនបាន ជាអាការប្រាកដ ។ |
| **-អយោនិសោមនសិការ បទដ្ឋានា** | មានការធ្វើទុកក្នុងចិត្តមិនដោយឧបាយនៃប្រាជ្ញា ជាបទដ្ឋាន ។ |

# ចិត្តសម្បយុត្តដោយ
# វិចិកិច្ឆា ៨

| | |
|---|---|
| **១. ពុទ្ធេ កង្ខតិ** | សង្ស័យក្នុងព្រះពុទ្ធ ។ |
| **២. ធម្មេ កង្ខតិ** | សង្ស័យក្នុងព្រះធម៌ ។ |
| **៣. សង្ឃេ កង្ខតិ** | សង្ស័យក្នុងព្រះសង្ឃ ។ |
| **៤. សិក្ខាយ កង្ខតិ** | សង្ស័យក្នុងសិក្ខា ។ |
| **៥. បុព្វន្តេ កង្ខតិ** | សង្ស័យក្នុងខន្ធជាដើម ជាអតីត ។ |
| **៦. អបរន្តេ កង្ខតិ** | សង្ស័យក្នុងខន្ធជាដើម ជាអនាគត ។ |
| **៧. បុព្វន្តាបរន្តេ កង្ខតិ** | សង្ស័យក្នុងខន្ធជាដើម ដែលជាអតីតនិង អនាគត ។ |
| **៨.បដិច្ចសមុប្បាទេ កង្ខតិ** | សង្ស័យក្នុងបដិច្ចសមុប្បាទ ។ |

# អធិប្បាយ វិចិកិច្ឆា ៨

ពាក្យថា **ពុទ្ធេ កង្ខតិ** គឺ សង្ស័យក្នុងព្រះសរីរៈ របស់ព្រះពុទ្ធជាម្ចាស់ថា មានពិតមែនឬ ? ប្រហែលជាសន្មតឡើងដើម្បីជាឧបាយឲ្យប្រជាជនសាមគ្គីគ្នាប៉ុណ្ណោះទេ សង្ស័យក្នុងព្រះគុណទាំង ១០ បទ មានពាក្យថា អរហំ ជាដើម តើព្រះនាមទាំងនេះ មានពិតមែន ឬ មិនមែន ? ។

ពាក្យថា **ធម្មេ កង្ខតិ** តែងសង្ស័យក្នុងព្រះធម៌ គឺ មគ្គ ៤ ផល ៤ និព្វាន ១ ឬ ក្នុងព្រះធម្មគុណ ៦ បទ ថាតើ ព្រះធម៌ទាំងនេះ នឹងនាំឲ្យផុតទុក្ខពិត ឬ មិនពិត ? ។

ពាក្យថា **សង្ឃេ កង្ខតិ** តែងសង្ស័យក្នុងព្រះអរិយសង្ឃ ឬ ក្នុងសង្ឃគុណទាំង ៩ បទ ថាតើ មានពិតឬទេ ? ។

ពាក្យថា **សិក្ខាយ កង្ខតិ** តែងសង្ស័យក្នុងសិក្ខា ៣ គឺ អធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិប្បញ្ញាសិក្ខា ថាមានពិតឬទេ ? សង្ស័យក្នុងផលានិសង្ស ក្នុងការបដិបត្តិសិក្ខាទាំង ៣ នោះ ថាតើនឹងជួយមិនឲ្យទៅកាន់អបាយពិតឬទេ ? ។

**អធិសីលសិក្ខា** លោកិយ គឺ បាដិមោក្ខសំវរសីល បើ

លោកុត្តរៈ គឺ សីលដែលសម្បយុត្តនឹងមគ្គ-ផល ។

**អធិចិត្តសិក្ខា** លោកិយ គឺ សមាបត្តិចិត្តដែលជាបាទនៃវិបស្សនា បើលោកុត្តរៈ គឺ ចិត្តដែលសម្បយុត្តនឹងមគ្គ-ផល ។

**អធិប្បញ្ញាសិក្ខា** លោកិយ គឺ វិបស្សនាញាណ បើលោកុត្តរៈ គឺ បញ្ញាដែលសម្បយុត្តនឹងមគ្គ-ផល ។

ពាក្យថា **បុព្វន្តេ កង្ខតិ** សង្ស័យក្នុង ខន្ធ អាយតនៈ ធាតុ ដែលជាអតីត ដែលសន្មតថា ជាតួខ្លួន ជាបុគ្គល ជាសត្វ មានពិត ឬទេ ? ហើយជាតិមុនមានពិតឬទេ ? ។

ពាក្យថា **អបរន្តេ កង្ខតិ** តែងសង្ស័យក្នុង ខន្ធ អាយតនៈ ធាតុ ដែលជាអនាគត គឺ សភាវៈធម៌ដែលសន្មតថា ជាសត្វបុគ្គលតួខ្លួន តើនឹងប្រាកដក្នុងអនាគតមានពិតឬទេ ? ឬ សង្ស័យថាសត្វស្លាប់ហើយនឹងកើតក្នុងជាតិមុខ ក្នុងភពមុខ មានពិតឬទេ ? ។

ពាក្យថា **បុព្វន្តាបរន្តេ កង្ខតិ** តែងសង្ស័យក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត និងដែលជាអនាគត ថា មានពិតឬទេ ? ។

ពាក្យថា **បដិច្ចសមុប្បាទេ កង្ខតិ** តែងសង្ស័យក្នុងធម៌ដែលជាបដិច្ចសមុប្បាទក្នុងជាតិនេះ ថា អវិជ្ជាជាបច្ច័យឲ្យកើតបុណ្យ កើតបាបជាដើម ឲ្យកើតផលបុណ្យ និងផលបាបបន្តទៅក្នុងភពថ្មីជាដើម

មានពិតឬទេ ? ៕

# សេចក្ដីសង្ស័យ
# ក្នុងព្រះសូត្រ ១៦ យ៉ាង

## សង្ស័យក្នុងអតីត ៥ គឺ :

**១.** យើងធ្លាប់កើតហើយក្នុងអតីតឬមិនធ្លាប់ទេហ្ន៎ ។
**២.** យើងមិនធ្លាប់កើតមកហើយក្នុងអតីតឬក៏ធ្លាប់ដែរហ្ន៎ ។
**៣.** យើងធ្លាប់កើតក្នុងអតីត ជាអ្វីហ្ន៎ ។
**៤.** ក្នុងអតីតយើងមានរូបរាងសណ្ឋានយ៉ាងណាដែរហ្ន៎ ។
**៥.** យើងធ្លាប់កើតជាអ្វី ហើយកើតជាអ្វីដែរហ្ន៎ ។

## សង្ស័យក្នុងអនាគត ៥ គឺ :

**១.** យើងនឹងកើតក្នុងអនាគត ឬទេហ្ន៎ ។
**២.** យើងនឹងមិនកើតក្នុងអនាគត ឬទេហ្ន៎ ។
**៣.** យើងនឹងកើតក្នុងអនាគត ជាអ្វីដែរហ្ន៎ ។
**៤.** ក្នុងអនាគតយើងមានរូបរាងយ៉ាងណាដែរហ្ន៎ ។

**៥.** យើងនឹងកើតជាអ្វី ហើយនឹងកើតជាអ្វីដែរហ្ន៎ ។

## សង្ស័យក្នុងបច្ចុប្បន្ន ៦ គឺ :

**១.** យើងកំពុងមាន ឬទេហ្ន៎ ។

**២.** យើងមិនមាន ឬទេហ្ន៎ ។

**៣.** យើងជាអ្វីហ្ន៎ ។

**៤.** យើងមានរូបរាងសណ្ឋានយ៉ាងណាដែរហ្ន៎ ។

**៥.** យើងជាសត្វ មកពីណាហ្ន៎ ។

**៦.** សត្វគឺយើងនឹងទៅកើតទីណាហ្ន៎ ។

## ធម៌ដែលជាហេតុលះវិចិកិច្ឆា ៦

**១.ពហុស្សុតតា** ភាពជាអ្នកស្តាប់ច្រើន ។

**២.បរិបុច្ឆកតា** ភាពជាអ្នកសាកសួរ ។

**៣.វិនយេបកតញ្ញុតា** ភាពជាអ្នកដឹងទូទៅក្នុងព្រះវិន័យ ។

**៤.អធិមោក្ខពហុលតា** ភាពជាអ្នកច្រើនដោយអធិមោក្ខ ។

**៥.កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អ ។

**៦.សប្បាយកថា** មានកថាដែលជា សប្បាយៈ ។

# លក្ខណាទិចតុករបស់ឧទ្ធច្ចៈ

**-អវូបសម លក្ខណំ** មានការមិនស្ងប់ ជាលក្ខណៈ ។

**-អនវត្ថាន រសំ** មានការមិនតាំងនៅ ( ក្នុងអារម្មណ៍តែ ១ ) ជាកិច្ច ។

**-ភន្តត្ត បច្ចុប្បដ្ឋានំ** មានការភ័ន្តភាំងញាប់ញ័រ ជាអាការប្រាកដ ។

**-អយោនិសោមនសិការ បទដ្ឋានំ** មានការធ្វើទុកក្នុងចិត្តមិនដោយឧបាយល្អិតល្អន់ ជាបទដ្ឋាន ។

## ធម៌ដែលជាហេតុលះឧទ្ធច្ចៈ ៦

**១. ពហុស្សុតតា** ភាពជាអ្នកស្តាប់ច្រើន ។

**២. បរិបុច្ឆកតា** ភាពជាអ្នកសាកសួរ ។

**៣. វិនយេបកតញ្ញុតា** ភាពជាអ្នកដឹងទូទៅក្នុងព្រះវិន័យ ។

**៤. ពុទ្ធសេវិតា** ភាពជាអ្នកពេញចិត្តក្នុងធម៌ របស់ព្រះពុទ្ធ

ជាម្ចាស់ ។

**៥. កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អ ។

**៦. សប្បាយកថា** មានកថាដែលជាសប្បាយៈ ។

# ការចែកមោហមូលចិត្ត ២ ដោយន័យផ្សេងៗ

**១.ដោយជាតិ** មោហមូលចិត្ត២ ជាអកុសលជាតិ

**២.ដោយភូមិ** ” ” ជាកាមាវចរភូមិ

**៣.ដោយវេទនា** ” ” ជាឧបេក្ខាវេទនា

**៤.ដោយហេតុ** ” ” ជានហេតុ និង ជាឯកហេតុក-ចិត្ត

**៥.ដោយសង្ខារ** ” ” ជាអសង្ខារិក

**៦.ដោយសម្បយុត្ត** ” ” ជាសម្បយុត្តចិត្ត

**៧.ដោយសោភណៈ** ” ” ជាអសោភណចិត្ត

**៨.ដោយឈាន** ” ” ជាអកុសលឈាន ឬជាអឈាន

**៩.ដោយលោកិយ** ” ” ជាលោកិយចិត្ត

១០.ដោយកិច្ច　　”　　”　　ជាចិត្តធ្វើជវនកិច្ច

១១.ដោយអារម្មណ៍”　　”　　ជាចិត្តមានអារម្មណ៍ ៦

១២.ដោយទ្វារ　　”　　”　　ជាចិត្តកើតបាន ៦ ទ្វារ

១៣.ដោយវត្ថុ　　”　　”　　ជាចិត្តកើតត្រង់ហទយវត្ថុ( ក្នុងភូមិដែលមានខន្ធ៥ )

១៤.ដោយវិញ្ញាណ-”　　”　　ជាមនោវិញ្ញាណធាតុ
ធាតុ

# ផល(វិបាក)
# ដែលកើតពីមោហមូលចិត្ត

មោហមូលចិត្ត ជាចិត្តល្ងង់ខ្លៅ ល្ងីល្ងើ ។ អ្នកណាមួយត្រូវមោហចេតសិកគ្របសង្កត់ អ្នកនោះតែងតែវង្វេង ភ្លើតភ្លើន មិនដឹងអារម្មណ៍តាមសេចក្ដីពិត ។ ក្នុងសម័យណា មនុស្សមានសន្ដានច្រើនទៅដោយមោហៈ សម័យនោះ រមែងកើតសេចក្ដីអន្តរាយដោយសាររោគភ័យបៀតបៀន ជាហេតុឲ្យរោគរាតត្បាតដួលដេកស្លាប់ដ៏ច្រើន ។

ចំណែកក្នុងអនាគត អាស្រ័យដោយមោហៈជាហេតុ សត្វ

ទាំងឡាយតែងចូលទៅកាន់កំណើតជាសត្វតិរច្ឆាន ដែលមានសេចក្ដីវង្វេងជានិច្ច ៕

( មោហមូលចិត្ត ២ ដួងចប់ )

# តារាង
# អកុសលចិត្ត ១២ ដួង



# ហេតុឲ្យកើត
# អកុសលចិត្ត ១២ មាន ៥

**១. បុព្វេ អកតញ្ញុតា** មិនបានធ្វើបុណ្យទុកពីកាលមុន។

**២. អប្បដិរូបទេសវាស** នៅក្នុងប្រទេសមិនសមគួរ ។

**៣. អសប្បុរិសូបនិស្សយ** មិនសេពគប់សប្បុរស ។

**៤. អសទ្ធម្មស្សវន** មិនស្តាប់ធម៌(របស់សប្បុរស) ។

**៥. អត្តមិច្ឆាបណិធិ** តម្កល់ខ្លួនទុកគឺសេចក្តីប្រាថ្នាខុស ។

អកុសល ១២ នេះ មានទោសតិចឬច្រើន ក៏ស្រេចទៅលើចេតនាកម្មដែលជាកម្មបថ ។ បើអកុសលចិត្តនោះ ជាកម្មបថ ក៏មានទោសធ្ងន់ តែងនាំឲ្យទៅកើតក្នុងអបាយភូមិ បើមិនទាន់ដល់ជាកម្មបថទេក៏មានទោសតិច ឲ្យផលតែក្នុងបវត្តិកាល ៕

# សង្គ្រោះ
# អកុសលចិត្ត ១២ ដួង ចូលក្នុងកម្មបថ

----------------

## អកុសលកម្មបថ ១០

### ១. កើតតាមកាយទ្វារមាន ៣ គឺ :

(១) បាណាតិបាត សម្លាប់សត្វ

(២) អទិន្នាទាន លួចទ្រព្យ

(៣) កាមេសុមិច្ឆាចារ ប្រព្រឹត្តខុសក្នុងកាម

### ២. កើតតាមវចីទ្វារមាន ៤ គឺ :

(១) មុសាវាទ និយាយកុហក

(២) បិសុណាវាទ និយាយស៊កសៀត

(៣) ផរុសវាទ និយាយជេរប្រទេច

(៤) សម្ផប្បលាប និយាយរោយរាយ

## ៣. កើតតាមមនោទ្វារមាន ៣ គឺ :

(១) **អភិជ្ឈា** ការសម្លឹងចង់បាន

(២) **ព្យាបាទ** ព្យាបាទបំណងអាក្រក់

(៣) **មិច្ឆាទិដ្ឋិ** ការយល់ខុស(និយតមិច្ឆាទិដ្ឋិ)

# អធិប្បាយអកុសលកម្មបថ ដោយអាការ ៥

**១.ដោយមូល** មាន លោភៈ ទោសៈនិងមោហៈជាមូល ។

**២.ដោយកម្ម** ជាកាយកម្ម វចីកម្ម និងមនោកម្ម ។

**៣.ដោយទ្វារ** ជាកាយទ្វារ វចីទ្វារ និងមនោទ្វារ ។

**៤.ដោយទោស** ជាអប្បសាវជ្ជៈមានទោសតិច និងមហាសាវជ្ជៈមានទោសធ្ងន់ ។

**៥.ដោយអង្គ** គឺ អង្គនៃការកន្លងល្មើសកម្មបថ ។

# ១.បាណាតិបាត

ការញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះ ឈ្មោះថា **បាណាតិបាត** គឺសម្លាប់សត្វ។ ដោយវោហារ បានដល់ សត្វ ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រីយ៍ ២ យ៉ាង ។ មាន **វធកចេតនា** (ចេតនាសម្លាប់) តែបើសត្វមិនស្លាប់ អកុសលចិត្តមិនជាកាយកម្ម ព្រោះមិនដល់ជាកម្មបថ គ្រាន់តែឲ្យជ្រាបថា អកុសលចិត្តនេះជាកាយទុច្ចរិតតែម្យ៉ាង ។

ប៉ុន្តែ បើសត្វនោះ ត្រូវសម្លាប់ស្លាប់ដោយការធ្វើនោះមែន គប្បីជ្រាបការសម្លាប់នោះដោយអាការ ៥ យ៉ាង គឺ :

**១. ដោយមូល** ការសម្លាប់សត្វ កើតព្រោះទោសៈនិងមោហៈជាមូល ។

**២. ដោយកម្ម** ជាកាយកម្ម ព្រោះសម្រេចដោយការធ្វើតាមផ្លូវកាយ ។

**៣. ដោយទ្វារ** មាន ២ គឺ កាយទ្វារនិងវចីទ្វារ ។

**៤. ដោយសាវជ្ជៈ** គឺ :

សម្លាប់សត្វមានគុណច្រើន ដូចមនុស្សជាដើម          មានទោសធ្ងន់ ។

សម្លាប់សត្វមានគុណតិច មានទោសស្រាល ។
សម្លាប់សត្វមានសីលធម៌ មានទោសធ្ងន់ ។
សម្លាប់សត្វគ្មានសីលធម៌ មានទោសស្រាល ។
សម្លាប់សត្វធំ មានទោសធ្ងន់ ។
សម្លាប់សត្វតូច មានទោសស្រាល ។
បើគុណធម៌ និងសរីរៈស្មើគ្នា កិលេស និង សេចក្តីព្យាយាមខ្លាំងក្លា មានទោសធ្ងន់ ។
បើកិលេស និងសេចក្តីព្យាយាមខ្សោយ មានទោសស្រាល ។

៥. **ដោយអង្គ** ( ចំណែកប្រកប ) មានអង្គ ៥ គឺ :

- **បាណោ** សត្វមានជីវិត ។
- **បាណសញ្ញិតា** ដឹងថា សត្វមានជីវិត ។
- **វធកចិត្តំ** មានចិត្តគិតនឹងសម្លាប់ ។
- **ឧបក្កមោ** មានសេចក្តីព្យាយាម ។
- **តេន មរណំ** សត្វស្លាប់ដោយការព្យាយាមនោះ ។

កាលបើគ្រប់អង្គ ៥ ហើយ សីលរមែងដាច់ ដល់ភាពជាកម្មបថ អាចឲ្យផលនាំឲ្យកើតក្នុងអបាយភូមិ ។ បើមិនគ្រប់អង្គ ៥ ទេ ជាទុច្ចរិតកម្ម មិនឲ្យផលនាំឲ្យបដិសន្ធិក្នុងអបាយភូមិ ប៉ុន្តែឲ្យផល

ក្នុងបវត្តិកាល គឺ បន្ទាប់ពីបដិសន្ធិចិត្ត ទៅរហូតដល់ចុតិចិត្ត ។

## បាណាតិបាតនេះមានប្រយោគ ៦ គឺ :

**១. សាហត្ថិកបយោគ** ប្រយោគធ្វើឲ្យគេស្លាប់ដោយដៃខ្លួនឯង។

**២. អាណត្តិកបយោគ** ប្រយោគធ្វើឲ្យគេស្លាប់ដោយការបង្គាប់បញ្ជាអ្នកដទៃ ។

**៣. និស្សគ្គិយបយោគ** ប្រយោគធ្វើឲ្យគេស្លាប់ដោយការគ្រវែង បោះ ចោល បាញ់ ។

**៤. ថាវរបយោគ** ប្រយោគធ្វើឲ្យគេស្លាប់ ដោយគ្រឿងនៅនឹងមួយកន្លែង ដូចជា ជីកអណ្តូង អន្ទង់ ចំរូង ថ្នាំពិស អន្ទាក់ វត្ថុបន្ទាច សរសេរពណ៌នា ។ ល ។

**៥. វិជ្ជាមយបយោគ** សម្រេចដោយ វិជ្ជារាយមន្តអាគម ឬដោយអំណាចភូតបីសាច ។

**៦. ឥទ្ធិមយបយោគ** សម្រេចដោយឫទ្ធិ ដែលកើតពីផលនៃកម្ម ដូចឫទ្ធិនាគ គ្រុឌ យក្ខ ឬឫទ្ធិព្រះរាជា ។

# ២.អទិន្នាទាន

ការកាន់យកវត្ថុរបស់របរ ដែលម្ចាស់គេមិនបានឲ្យ ឈ្មោះថា **អទិន្នាទាន** គឺ លួចដោយថេយ្យចេតនា គឺ ចេតនាលួចរបស់អ្នកដទៃ ។

**១.ដោយមូល** ថេយ្យចេតនាកើតឡើងព្រោះ លោភៈ ទោសៈ មោហៈ ។ បើលោភៈជាមូល លួចដើម្បីបាននូវវត្ថុដែលខ្លួនត្រូវការ ។ បើទោសៈជាមូល លួចដោយធ្វើឲ្យម្ចាស់វិនាសទ្រព្យ និង មិនត្រូវការទ្រព្យនោះទេ ។

**២.ដោយកម្ម** ជាកាយកម្ម ព្រោះសម្រេចដោយការធ្វើ តាមផ្លូវកាយ ។

**៣.ដោយទ្វារ** មាន ២ គឺ កាយទ្វារនិងវចីទ្វារ ។

**៤.ដោយសាវជ្ជៈ** គឺ :

| | | |
|---|---|---|
| បើវត្ថុនោះប្រណីត មានតម្លៃខ្ពស់ | មានទោសធ្ងន់ | ។ |
| បើវត្ថុនោះអន់អាក្រក់ តម្លៃតិច | មានទោសស្រាល | ។ |
| បើវត្ថុនោះ ម្ចាស់ជាអ្នកមានគុណ មានសីល | មានទោសធ្ងន់ | ។ |
| បើមិនមានគុណ មិនមានសីល | មានទោសស្រាល | ។ |

បើវត្ថុធំ មានទោសធ្ងន់ បើវត្ថុតូច មានទោសស្រាល ។
បើវត្ថុនិងគុណស្មើគ្នាកិលេស និងការព្យាយាមខ្លាំង មានទោសធ្ងន់។
បើកិលេសនិងការព្យាយាមខ្សោយ មានទោសស្រាល ។

**៥.ដោយអង្គ មាន ៥** គឺ :

- **បរបរិគ្គហិតំ** វត្ថុនោះមានម្ចាស់ហួងហែង ។
- **បរបរិគ្គហិតសញ្ញិតា** ដឹងថារបស់ដែលម្ចាស់គេហួងហែង ។
- **ថេយ្យចិត្តំ** មានចិត្តគិតនឹងលួច ។
- **ឧបក្កមោ** មានការព្យាយាម ។
- **តេន ហរណំ** លួចបានដោយការព្យាយាមនោះ ។

កាលណាគ្រប់អង្គ ៥ សីលដាច់ ហើយជាកម្មបថ អាចឲ្យផលជាជនកកម្ម នាំឲ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គទេ សីលមិនដាច់ ជាទុច្ចរិតកម្ម មិនឲ្យផលក្នុងបដិសន្ធិកាល តែនឹងឲ្យផលក្នុងបវត្តិកាល ។

អទិន្នាទាននេះ មានប្រយោគដែលប្រព្រឹត្តទៅដោយអាការនៃ **អវហារ** (ការលួច) ច្រើន ដូចជា :

**-អាទិយន** ការលួចដោយការចោទប្រកាន់យក ។

**-អវហរណៈ** ការលួចដោយឆបោកយកទ្រព្យបញ្ញើរ

**-ធុរនិក្ខេបៈ** ការលួចដោយការដាក់ចុះធុរៈ

**-ហរណៈ** ការលួចដោយការនាំទៅ

**-សាហត្ថិកៈ** ការលួចដោយដៃខ្លួនឯង

**-អាណត្តិកៈ** ការលួចដោយការបង្គាប់បញ្ជា

**-និស្សគ្គិយៈ** ការលួចដោយការគ្រវែងបោះចោល

**-សំវិធាវហារ** ការលួចដោយការបបួលគ្នា

**-សង្កេតនិមិត្តកម្ម** ការលួច ដោយការកំណត់ពេលវេលា ឬ ធ្វើនិមិត្តប្រាប់

**-ថេយ្យាវហារ** ការលួចដូចជាចោរ

**-បសយ្ហាវហារ** ការលួចដោយ ការកំហែងយក រឹបជាន់ ប្លន់ដណ្តើម

**-បដិច្ឆន្នាវហារ** ការលួចដោយបិទបាំងលាក់ទុក

**-កុសាវហារ** ការលួចដោយការប្តូរស្លាក

# ៣.កាមេសុមិច្ឆាចារ

ពាក្យថា **កាមេសុ** បានដល់ ការសេពមេថុន ។

ពាក្យថា **មិច្ឆាចារ** បានដល់ ការប្រព្រឹត្តដ៏លាមក ដែលបណ្ឌិតតែងតិះដៀល ។

ប៉ុន្តែបើពោលដោយលក្ខណៈ បានដល់ ចេតនាជាហេតុកន្លងល្មើសឋានៈដែលមិនគួរទាក់ទង ដែលប្រព្រឹត្តតាមកាយទ្វារដោយបំណងអសទ្ធម្ម ឈ្មោះថា **កាមេសុមិច្ឆាចារ** ។

# អគមនីយដ្ឋាន ២០

ឋានៈដែលបុគ្គលមិនគប្បីទាក់ទង ដោយបំណងអសទ្ធម្មមានស្ត្រី ២០ ពួក គឺ :

## ស្ត្រីដែលមាតារក្សាជាដើម ១០ ពួក គឺ :

**១. មាតុរក្ខិតា** ស្ត្រីដែលមាតារក្សា

**២. បិតុរក្ខិតា** ស្ត្រីដែលបិតារក្សា

**៣. មាតាបិតុរក្ខិតា** ស្ត្រីដែលមាតាបិតារក្សា

៤. ភគិនីរក្ខិតា　ស្ត្រីដែលបងប្អូនប្រុសរក្សា
៥. ភាតុរក្ខិតា　ស្ត្រីដែលបងប្អូនស្រីរក្សា
៦. ញាតិរក្ខិតា　ស្ត្រីដែលញាតិរក្សា
៧. គោត្តរក្ខិតា　ស្ត្រីដែលត្រកូលរក្សា
៨. ធម្មរក្ខិតា　ស្ត្រីដែលមានធម៌រក្សា
៩. សបរិទណ្ឌា　ស្ត្រីដែលទទួលការស្តីដណ្តឹងហើយ
១០. សារក្ខា　ស្ត្រីដែលច្បាប់គ្រប់គ្រង

## ស្ត្រីដែលជាភរិយា ១០ គឺ :

១. ធនក្កីតា　ភរិយាដែលទិញលោះមកដោយទ្រព្យ
២. ឆន្ទវាសិនី　ភរិយាដែលនៅដោយសេចក្តីពេញចិត្ត
៣. គោតវាសិនី　ភរិយាដែលនៅដោយភោគៈ
៤. បដិវាសិនី　ភរិយាដែលនៅដោយសំពត់
៥. ឱទបត្តកិនី　ភរិយាដែលធ្វើពិធីច្រូចទឹក
៦. ឱភសម្មត្តា　ភរិយាដែលបុរសដាក់គ្រឿងប្រដាប់ចុះពីក្បាល

**៧. ទាសីភរិយា** ភរិយាដែលជាទាសីក្នុងផ្ទះ

**៨. កម្មការីភរិយា** ភរិយាដែលជួលមកធ្វើការងារ

**៩. ធជាហដា** ភរិយាដែលជាឈ្លើយ

**១០. មុហុត្តិកា** ភរិយាដែលនៅជាមួយគ្នាមួយភ្លែត

ក្នុងបណ្តាស្ត្រីទាំងឡាយ ស្ត្រី ១២ ពួក ដែលបុរសមិនគួរកន្លងល្មើស គឺ ស្ត្រីដែលទទួលការស្តីដណ្តឹង ១ ស្ត្រី ដែលច្បាប់គ្រប់គ្រង ១ និង ស្ត្រីដែលជាភរិយា ១០ ៕

# ដោយអាការ ៥ គឺ :

**១. ដោយមូល** កាមេសុមិច្ឆាចារ កើតឡើង ព្រោះលោភៈ និង មោហៈជាមូល ។

**២. ដោយកម្ម** ជាកាយកម្ម ។

**៣. ដោយទ្វារ** ជាកាយទ្វារតែម្យ៉ាង ។

**៤. ដោយសាវជ្ជៈ**

បុគ្គលដែលកន្លងល្មើសនោះ មានគុណ មានសីលធម៌ច្រើន មានទោសធ្ងន់ ។

បើមានគុណ មានសីលតិច មានទោសស្រាល ។

បើមិនមានឆន្ទៈរួមគ្នាទេ មានទោសធ្ងន់ ។
បើមានឆន្ទៈរួមគ្នា មានទោសស្រាល ។
បើកិលេស និងការព្យាយាមខ្លាំងក្លា មានទោសធ្ងន់ ។
បើកិលេស និងការព្យាយាមខ្សោយ មានទោសស្រាល ។

## ៥. ដោយអង្គមាន ៤ គឺ :

**-អគមនិយវត្ថុ** វត្ថុដែលមិនគួរទាក់ទង ។

**-តស្មឹ សេវនចិត្តំ** មានចិត្តគិតសេពក្នុងវត្ថុ ដែលមិនគួរនោះ ។

**-សេវនប្បយោគោ** ព្យាយាមក្នុងការសេព ។

**-មគ្គេនមគ្គប្បដិបត្តិ អធិវាសនំ** ញ៉ាំងមគ្គ និង មគ្គឲ្យដល់គ្នា ។

កាលគ្រប់អង្គ ៤ សីលដាច់ ដល់នូវសភាពជាកម្មបថអាចនាំឲ្យកើតក្នុង អបាយភូមិ បើមិនគ្រប់អង្គ ៤ ទេ សីលមិនដាច់ ជាទុច្ចរិតកម្ម មិនឲ្យផលក្នុងបដិសន្ធិកាលទេ ប៉ុន្តែឲ្យផលក្នុងបវត្តិកាល ។

ប្រយោគនៃមិច្ឆាចារនោះ មាន ១ គឺ សាហត្ថិកបយោគ ប៉ុណ្ណោះ ៕

# ៤.មុសាវាទ

ការព្យាយាមតាមផ្លូវវាចា ( វចីបយោគ ) ឬសេចក្ដីព្យាយាមតាមផ្លូវកាយ ដែលបំផ្លាញប្រយោជន៍របស់អ្នកដទៃ នៃអ្នកដែលបំណងពោលឲ្យទំនាស់គ្នា ឈ្មោះថា **មុសា** ។ ឯចេតនាដែលតាំងឡើង ដោយសេចក្ដីព្យាយាមតាមកាយ ឬតាមវាចា មានបំណងពោលឲ្យឃ្លៀងឃ្លាតពីសេចក្ដីពិត ឈ្មោះថា **មុសាវាទ** ។

ម្យ៉ាងទៀតរឿងដែលមិនពិត ឈ្មោះថា **មុសា** ការឲ្យបុគ្គលដទៃបានដឹងរឿងមិនពិតនោះ ដោយភាវៈថាពិត ថាមែន ហៅថា **វាទ** ឯភាវៈថាដោយលក្ខណៈ ចេតនាដែលឲ្យតាំងឡើងដោយចេតនានោះ នៃបុគ្គលដែលបំណងឲ្យបុគ្គលដទៃ ដឹងនូវរឿងមិនពិតមិនប្រាកដ ឈ្មោះថា **មុសាវាទ** ។

**១.ដោយមូល** មុសាវាទកើតព្រោះលោភៈ ទោសៈនិងមោហៈជាមូល ។

**២.ដោយកម្ម** ជាវចីកម្ម ព្រោះការធ្វើសម្រេច ដោយពាក្យពោល ។

**៣.ដោយទ្វារ** សម្រេចបានទ្វារ ២ គឺ វចីទ្វារនិងកាយទ្វារ ។

**- វចីទ្វារ** បានដល់ ការនិយាយកុហក ។

**- កាយទ្វារ** បានដល់ ការធ្វើនិមិត្តសញ្ញាឲ្យដឹងតាមកាយ ដូចជាញាក់មុខ ងក់ក្បាល សរសេរសំបុត្រ ។ ល ។

**៤.ដោយសាវជ្ជៈ** ពោលកុហកបំផ្លាញប្រយោជន៍នោះ អស់ច្រើន មានទោសច្រើន បើអស់តិចមានទោសតិច ។ កុហកដែលនិយាយធម្មតាថា មិនមាន ដោយបំណងមិនឲ្យឈ្មោះថាមានទោសតិច តែបើពោលដើម្បីបំផ្លាញប្រយោជន៍ មានទោសធ្ងន់។ បើបុគ្គលដែលត្រូវខូចខាតប្រយោជន៍ មានគុណ មានសីលធម៌ច្រើន មានទោសធ្ងន់ បើមានគុណ មានសីលតិច មានទោសស្រាល។ បើកិលេសនិងការព្យាយាមខ្លាំងក្លា មានទោសធ្ងន់ បើកិលេសនិងការព្យាយាមខ្សោយ មានទោសស្រាល ។

**៥. ដោយអង្គមាន ៤** គឺ :

**- អតថំវត្ថុ** រឿងមិនពិត ។

- **វិសំវាទនចិត្តំ** គិតនឹងពោលឲ្យខុសឃ្លៀងឃ្លាត ។
- **តជ្ជោ វាយាមោ** ព្យាយាមកើតដោយគំនិតនោះ ។
- **បរស្ស តទត្ថវិជាននំ** ជនដទៃដឹងសេចក្ដីនោះ ។

កាលណាគ្រប់អង្គ ៤ សីលដាច់ ដល់ភាពជាកម្មបថអាចឲ្យផលនាំកើតក្នុងអបាយភូមិ ។ បើមិនគ្រប់អង្គ ៤ ជាទុច្ចរិតកម្ម ឲ្យផលក្នុងបវត្តិកាល ។

ប្រយោគនៃមុសាវាទមានត្រឹមតែមួយ គឺ សាហត្ថិកបយោគប៉ុណ្ណោះ ៕

# ៥.បិសុណាវាចា

បានដល់ **សំកិលិដ្ឋចេតនា** ជាចេតនានៃអ្នកដែលមានចិត្តសៅហ្មង ព្រោះលោភៈ ទោសៈបៀតបៀន ឲ្យបំណងនិយាយស៊កសៀត ចាក់ដោតបំផ្លាញអ្នកដទៃ ដើម្បីឲ្យខ្លួនបានជាទីស្រឡាញ់ឯអ្នកដទៃបានជាទីសម្អប់ និងដើម្បីឲ្យអ្នកដទៃកើតនូវការឈឺចាប់ ឬដោយការ បញ្ចុកបញ្ចៀអែបអប ។

**១.ដោយមូល** កើតព្រោះលោភៈ ទោសៈ មោហៈ ជាមូល ។

**២.ដោយកម្ម** ជាវចីកម្ម ។

**៣.ដោយទ្វារ** សម្រេចបានទ្វារ២ គឺវចីទ្វារ និងកាយទ្វារ ។

**៤.ដោយសាវជ្ជៈ** បុគ្គលដែលត្រូវគេញុះញង់មានគុណច្រើន មានទោសធ្ងន់ បើមានគុណតិចមានទោសស្រាល ។ និយាយញុះញង់ធ្វើឲ្យអ្នកទាំង ២ បែកបាក់គ្នា មានទោសធ្ងន់ បើអ្នកទាំង ២ មិនបែកបាក់គ្នាទេ មានទោសស្រាល ។ បើមានកិលេស និងការព្យាយាមខ្លាំងក្លា មានទោសធ្ងន់ បើមានកិលេស និងការព្យាយាមខ្សោយ មានទោសស្រាល ។

**៥.ដោយអង្គមាន ៤** គឺ :

**-ភិន្និតព្វោ បរោ** មានអ្នកដទៃដែលខ្លួនគប្បីញុះញង់បំបែក ។

**-ភេទបុរេក្ខារតា** មានគំនិតនឹងញុះញង់បំបែកបំបាក់អ្នកដទៃនោះ ។

**-តជ្ជោ វាយាមោ** មានការព្យាយាមកើតឡើងដោយចិត្តនោះ ។

**-តស្ស តទត្ថវិជាននំ** អ្នកដទៃនោះដឹងច្បាស់នូវ ដំណើរការញុះញង់នោះ ។

កាលណាគ្រប់អង្គ ៤ សីលដាច់ ដល់ភាពជាកម្មបថ អាចឲ្យផលនាំកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ៤ ជាទុច្ចរិតកម្ម ឲ្យផលក្នុងបវត្តិកាល ៕

# ៦.ផរុសវាចា

បានដល់ **ទុដ្ឋល្លចេតនា** (ចេតនាកំណាច) នៃអ្នកដែលនិយាយពាក្យមិនជាទីស្រឡាញ់ មិនធ្វើឲ្យសប្បាយចិត្ត ព្រោះត្រូវទោសៈប្រទូស្ត និងដើម្បីបំណងបំផ្លាញបុគ្គលដទៃឲ្យវិនាស ។

ចំណែកពាក្យពោលកំណាច ដោយបំណងប្រាថ្នាឲ្យអ្នកដទៃមានការប្រព្រឹត្តល្អ មិនចាត់ជាផរុសវាទ (អដ្ឋកថា ធម្មសង្គណី) ។

**១.ដោយមូល** ផរុសវាទកើតព្រោះទោសៈនិងមោហៈជាមូល ។

**២.ដោយកម្ម** ជាវចីកម្ម ។

**៣.ដោយទ្វារ** សម្រេចបានទ្វារ២ គឺ វចីទ្វារនិងកាយទ្វារ ។

**៤.ដោយសាវជ្ជៈ**

ពោលជេរបុគ្គលមានគុណច្រើន មានទោសធ្ងន់ ។

បើបុគ្គលនោះមានគុណតិច មានទោសស្រាល ។
ជេរដោយកិលេសខ្លាំងក្លា មានទោសធ្ងន់ ។
បើកិលេសខ្សោយ មានទោសស្រាល ។

**៥.ដោយអង្គមាន ៣** គឺ :

- **អក្កោសិតព្វោ បរោ** មានបុគ្គលដទៃដែលខ្លួនគប្បីជេរ ។
- **កុបិត ចិត្តំ** មានចិត្តខឹងក្រោធ ។
- **អក្កោសនា** បានជេរប្រទេច ។

បើគ្រប់អង្គ ៣ សីលដាច់ដល់ភាពជាកម្មបថ អាចឲ្យផល នាំបដិសន្ធិក្នុង អបាយភូមិ បើមិនគ្រប់អង្គ ៣ ជាទុច្ចរិតកម្ម ឲ្យផលក្នុងបវត្តិកាល ។

# ៧.សម្ផប្បលាប

ពាក្យថា **សម្ផប្បលាប** គឺ **សម្ផំ + បលាប** ។

**សម្ផំ** = រោយរាយឥតប្រយោជន៍ ។

**បលាប** = ពោល និយាយ ។

បានដល់ **អនត្ថវិញ្ញាបិកា** គឺ ចេតនាដែលបំណងឲ្យអ្នក

ដទៃដឹងរឿងមិនជាប្រយោជន៍ ។

ពាក្យថា **អនត្ថ** = មិនមែនជាប្រយោជន៍ ។

ពាក្យថា **វិញ្ញាបិកា** = ឲ្យគេដឹង ។

បើដោយលោភមូលចិត្ត គឺ ត្រេកអរនឹងឲ្យគេដឹងរឿងដែលគ្មានប្រយោជន៍ តែបើដោយទោសមូលចិត្ត គឺដោយការមិនពេញចិត្ត ក៏ឲ្យគេដឹងរឿងដែលគ្មានប្រយោជន៍នោះទៅ ដើម្បីឲ្យគេក្តៅក្រហាយជាទុក្ខ ។

សម្ផប្បលាបនេះ ជាចេតនាតែងបៀតបៀនដោយ លោភៈ និង ទោសៈ ។

ខណៈណាអ្នកនិយាយដោយចិត្តមានលោភៈ ទោសៈ មោហៈ តែមិនមានចេតនាបំណងឲ្យអ្នកដទៃដឹងរឿង ដែលមិនជាប្រយោជន៍ទេ ក៏ជាវចីទ្វារនៃអកុសលចិត្ត មិនមែនជាវចីទ្វារនៃអកុសលកម្មទេ ។

**១.ដោយមូល** កើតឡើងព្រោះ លោភៈ ទោសៈ មោហៈ ជាមូល ។

**២.ដោយកម្ម** ជាវចីកម្ម ។

**៣.ដោយទ្វារ** សម្រេចបានទ្វារ២ គឺ កាយទ្វារនិងវចីទ្វារ ។

**៤.ដោយសាវជ្ជៈ**

| | | |
|---|---|---|
| បើសេពច្រើន | មានទោសធ្ងន់ | ។ |
| បើសេពតិច | មានទោសស្រាល | ។ |
| បើអ្នកដទៃកាន់យកនូវរឿង ឥតប្រយោជន៍នោះ | មានទោសធ្ងន់ | ។ |
| តែបើមិនកាន់យកទេ | មានទោសស្រាល | ។ |

**៥.ដោយអង្គមាន ២** គឺ :

- **និរត្ថកកថា បុរេក្ខារតា** បំណងនិយាយរឿងដែលមិនមែនជាប្រយោជន៍ ។
- **តថារូបីកថា កថនំ** បានពោលនូវរឿងឥតប្រយោជន៍មានសភាពដូច្នោះ ។

កាលបើគ្រប់អង្គ ២ ដល់ភាពជាកម្មបថ អាចឲ្យផលនាំបដិសន្ធិក្នុងអបាយភូមិ បើមិនគ្រប់អង្គ២ជាទុច្ចរិត មិនមែនជាកម្មបថឲ្យផលក្នុងបវត្តិកាល ៕

# ៨.អភិជ្ឈា

ធម្មជាតិដែលសម្លឹងរំពៃនូវភណ្ឌៈរបស់អ្នកដទៃ ជាលក្ខណៈយ៉ាងនេះ ឈ្មោះថា **អភិជ្ឈា** ។

បានដល់ **ចេតនា** ដែលប្រព្រឹត្តជាមួយនឹងលោភៈដ៏មានកម្លាំង រហូតដល់គិតប៉ងយករបស់គេ មកជារបស់ខ្លួន ដោយការបៀតបៀនគេនោះតាមផ្លូវទុច្ចរិត ។ តែបើពេញចិត្តក្នុងរបស់គេត្រឹមតែថាល្អ ស្អាតទេ មិនជាកម្មបថ ។

**១.ដោយមូល** កើតឡើងព្រោះលោភៈនិងមោហៈជាមូល។

**២.ដោយកម្ម** ជាមនោកម្ម ។

**៣.ដោយទ្វារ** សម្រេចបានទាំង ៣ ទ្វារ គឺ **មនោទ្វារ វចីទ្វារ** និង **កាយទ្វារ** ។

**-តាមមនោទ្វារ** ដូចខណៈដែលគិតបំណង ប៉ងយកវត្ថុរបស់គេ ដោយឧបាយ ឬដោយទុច្ចរិត ផ្សេងៗ ។

**-តាមវចីទ្វារ** ពេលដែលចិត្តបំណង ប៉ងយកវត្ថុរបស់គេមកជារបស់ខ្លួន ក៏និយាយចេញមកតាមដូចគំនិតគិតនោះ ដើម្បីឲ្យបានរបស់នោះមក ។

**-តាមកាយទ្វារ** ពេលដែលចិត្តបំណងប៉ងយក វត្ថុរបស់គេមកជារបស់ខ្លួន ក៏ធ្វើកាយទុច្ចរិត ដើម្បីឲ្យបានរបស់នោះមក ។

**អភិជ្ឈា** ជាមនោកម្ម ព្រោះកើតពីគំនិតប៉ងចង់ឲ្យរបស់នោះ

មកជារបស់ខ្លួន ដោយសេចក្ដីលោភ ។ ដូច្នេះ **លោភៈ** ឬ **អភិជ្ឈា** ជាប្រធាន **ចេតនា** ដែលកើតរួមជាមួយនោះ ជា **មនោកម្ម** ។ បើចេតនាដែលធ្វើតាមផ្លូវកាយជាប្រធាន ចេតនានោះ គឺ ជាកាយកម្ម ដូចឃើញប្រាក់គេជ្រុះ ក៏រើសយកដោយមិនឲ្យម្ចាស់គេវិញ ជាកាយកម្ម មិនមែនជាមនោកម្មទេ ៕

**៤.ដោយសាវជ្ជៈ** គឺ ទោសដូចនឹងអទិន្នាទាន ។

**៥.ដោយអង្គ** មាន ២ គឺ :

- **បរភណ្ឌំ** វត្ថុរបស់គេ ។
- **អត្តនោ បរិណាមនំ** បង្អោនមកជារបស់ខ្លួនដោយទុច្ចរិតកម្មផ្សេងៗ ។

កាលបើគ្រប់អង្គ ២ ទើបជាកម្មបថ អាចឲ្យផលនាំបដិសន្ធិក្នុងអបាយភូមិ បើមិនគ្រប់អង្គ ២ មិនមែនជាកម្មបថ ជាទុច្ចរិតឲ្យផលក្នុងបវត្តិកាល ៕

## ៩.ព្យាបាទ

សភាវធម៌ដែលញុាំងប្រយោជន៍ សេចក្ដីចំរើន និង សេចក្ដី

សុខឲ្យវិនាស ឈ្មោះថា **ព្យាបាទ** ។ ព្យាបាទនោះ មានបំណង អាក្រក់ឲ្យគេវិនាសជាលក្ខណៈ ។ បានដល់ ចេតនា ដែលប្រព្រឹត្ត ទៅជាមួយនឹងសេចក្ដីក្រោធដ៏មានកម្លាំង រហូតដល់គិតបំណងឲ្យគេ វិនាស ជាមនោកម្មបថ ។ បើចិត្តក្រោធ( មិនចូលចិត្ត )កើតឡើង ជាទោសមូលចិត្ត ជាអកុសលចិត្ត មិនមែនជាកម្មបថ ។ បើចិត្ត ក្រោធ(មិនចូលចិត្ត) នោះមានកម្លាំងខ្លាំងក្លា រហូតដល់គិតបំណង ឲ្យគេវិនាស ក្នុងខណៈណា ចេតនាក្នុងទោសមូលចិត្តនោះ ក៏ជា មនោកម្មបថ ៕

**១.ដោយមូល** ព្យាបាទកើតឡើងព្រោះ ទោសៈ និង មោហៈ ជាមូល ។

**២.ដោយកម្ម** ជាមនោកម្ម ព្រោះចេតនានោះ ប្រព្រឹត្តទៅជា មួយនឹងសេចក្ដីក្រោធ ដែលមានកម្លាំងរហូត ដល់គិតបំណង អាក្រក់ឲ្យគេវិនាស ។

**៣.ដោយទ្វារ** សម្រេចបានទាំង៣ទ្វារ គឺ មនោទ្វារ វចីទ្វារ និង កាយទ្វារ ។

**-តាមមនោទ្វារ** ដូចខណៈដែលសេចក្ដីក្រោធមានកម្លាំង រហូត ដល់គិតឲ្យគេវិនាសដោយទុច្ចរិតកម្មផ្សេងៗ ។

**-តាមវចីទ្វារ** កាលចិត្តគិតឲ្យគេវិនាស ដោយសេចក្ដីព្យាបាទ ហើយ ក៏ប្រើ ឬបញ្ជាឲ្យអ្នកដទៃធ្វើសេចក្ដីវិនាសដល់ជនដែលខ្លួនក្រោធនោះ ។

**-តាមកាយទ្វារ** កាលចិត្តគិតឲ្យគេវិនាស ដោយសេចក្ដីព្យាបាទ ហើយ ក៏ធ្វើទុច្ចរិតផ្សេងៗ ដោយកាយរបស់ខ្លួន ដើម្បីឲ្យអ្នកនោះវិនាស ។

ចេតនានិយាយ ឬចេតនាធ្វើឲ្យគេវិនាស ដែលកើតដោយចិត្តព្យាបាទ ជាមនោកម្មបថ មិនមែនជាកាយកម្ម និង វចីកម្មទេ កាលណាកើតនឹងចិត្តដែលមានទោសៈ ឬព្យាបាទជាប្រធាន ។

ប៉ុន្តែបើជាកាយកម្ម គឺ ធ្វើដោយកាយ ឬជាវចីកម្ម គឺ ធ្វើដោយវាចា ចេតនាដែលធ្វើដោយកាយកម្ម និងវចីកម្មនោះ ក៏ជាប្រធាន មិនមែនព្យាបាទជាប្រធានទេ ដូចការសម្លាប់មូស សម្លាប់ស្រមោចជាកាយកម្ម ព្រោះចេតនាដែលធ្វើដោយកាយជាប្រធាន ។

ការប្រយុទ្ធការពារខ្លួន ធ្វើឲ្យគេដទៃត្រូវរបួស ឬ ស្លាប់ នោះជាកាយកម្ម មិនមែនជាមនោកម្មទេ ព្រោះចេតនាធ្វើដោយកាយជាប្រធាន មិនមែនព្យាបាទ ជាប្រធានទេ ៕

**៤. ដោយសាវជ្ជៈ** គឺ មានទោសដូចនឹងផរុសវាទ ។

**៥. ដោយអង្គ** មាន ២ គឺ :

- **បរសត្តោ** អ្នកដទៃក្រៅពីខ្លួន ។
- **តស្ស ច វិនាសចិន្តា** គិតឲ្យអ្នកនោះវិនាស ។

កាលណាក្រោធមានសត្វដទៃជាទីតាំង ស្ទើរតែកើតហើយក៏ដោយ មិនទាន់ជាកម្មបថទេ ដរាបណាមិនទាន់គិតញុំាងសត្វឲ្យវិនាសថា ឱហ្ន៎ សត្វនេះគួរតែរលាយ គួរតែវិនាស ។

កាលបើគ្រប់អង្គ ២ ទើបជាកម្មបថ អាចឲ្យផលនាំបដិសន្ធិក្នុងអបាយភូមិ បើមិនគ្រប់អង្គ ២ មិនមែនជាកម្មបថ ឲ្យផលក្នុងបវត្តិកាល ៕

# ១០.មិច្ឆាទិដ្ឋិ

បានដល់ ចេតនា ដែលកើតរួមនឹងសេចក្តីឃើញខុសដ៏មានកម្លាំង ដោយសេចក្តីមិនកាន់យកតាមសេចក្តីពិត ។ មិច្ឆាទិដ្ឋិមានការឃើញវិបរិត គឺឃើញខុស ឃើញផ្ទុយជាលក្ខណៈ ដោយន័យជាអាទិថា ទានមិនមានផល ។ ជាចេតនាដែលជឿជាក់ក្នុងការឃើញខុសនោះយ៉ាងស៊ប់ ។

**១.ដោយមូល** កើតព្រោះមោហៈ លោភៈ ជាមូល ។

**២.ដោយកម្ម** ជាមនោកម្ម ព្រោះជាចេតនាកើតឡើងប្រព្រឹត្ត

ទៅជាមួយនឹងគំនិតយល់ឃើញតាមផ្លូវចិត្ត ។

**៣.ដោយទ្វារ** សម្រេចបាន ៣ ទ្វារ គឺ មនោទ្វារវចីទ្វារ និង កាយទ្វារ ។

**-តាមមនោទ្វារ** បានដល់ ចេតនាដែលកើតជាមួយនឹងការយល់ខុស ឃើញខុស ដែលបានយល់ឃើញស៊ប់នោះ។

**-តាមវចីទ្វារ** បានដល់ កាលណាមានការឃើញខុស យ៉ាងនោះហើយ ក៏មានចេតនាពោលនូវរឿងដែលយល់ឃើញខុសនោះៗ ។

**-តាមកាយទ្វារ** បានដល់ កាលណា មានការឃើញខុសយ៉ាងស៊ប់ហើយ ក៏មានចេតនាធ្វើនូវទុច្ចរិតកម្មផ្សេងៗ ដោយចិត្តដែលយល់ឃើញខុសនោះ ។

## ៤.ដោយសាវជ្ជៈ

| | |
|---|---|
| មានអាសេវនៈ(គឺសេព)ច្រើន | មានទោសធ្ងន់ ។ |
| មានអាសេវនៈតិច | មានទោសស្រាល ។ |
| អនិយតមិច្ឆាទិដ្ឋិ | មានទោសស្រាល ។ |
| តែបើនិយតមិច្ឆាទិដ្ឋិ | មានទោសធ្ងន់ ។ |

| | |
|---|---|
| **៥.ដោយអង្គ** | មាន ២ គឺ : |
| **-វត្ថុនោ ច គហិតាការ វិបរិតតា** | សភាពនៃរឿងទាំងឡាយវិបរិត ចាកអាការដែលកាន់យក គឺ ព្រះរតនត្រ័យជាដើម ។ |
| **-យថា ច តំ គណ្ហាតិ តថាភាវេន តស្ស បដ្ឋានំ** | ការប្រកាន់នូវរឿង ដោយ សេចក្តីមិនពិតនោះ ក៏ប្រាកដ។ |

ក្នុងបណ្តាមិច្ឆាទិដ្ឋិទាំងនោះ ចាត់ជាកម្មបថ អាស្រ័យដោយ **នត្ថិកទិដ្ឋិ អហេតុកទិដ្ឋិ** និង **អកិរិយទិដ្ឋិ** ប៉ុណ្ណោះ មិនជាកម្មបថ ដោយទិដ្ឋិដទៃឡើយ ។ កាលបើគ្រប់អង្គ ២ ដល់ភាពជាកម្មបថ អាចឲ្យផល នាំបដិសន្ធិក្នុងអបាយភូមិ បើមិនគ្រប់អង្គ ២ មិនមែនជាកម្មបថ ឲ្យផលក្នុងបវត្តិកាលប៉ុណ្ណោះ ។

# អកុសលកម្មបថ ៥ ប្រភេទ

**វិនិច្ឆ័យអកុសលកម្មបថ ១០ ដោយអាការ ៥** គឺ :

**១. ធម្មតោ** ដោយធម្ម គឺ អង្គធម៌ ។

**២. កោដ្ឋាសតោ** ដោយកោដ្ឋាស គឺ ចំណែក ។

**៣. អារម្មណតោ** ដោយអារម្មណ៍ ។

**៤. វេទនាតោ** ដោយវេទនា ។

**៥. មូលតោ** ដោយមូល ។

## ១.ដោយធម៌

បណ្ដាអកុសលកម្មបថ ១០ អកុសលកម្មបថ ៧ តាមលំដាប់ ( គឺ កាយកម្ម ៣ វចីកម្ម ៤ ) ដោយអង្គធម៌ គឺ ចេតនាប៉ុណ្ណោះ ។ អកុសលកម្មបថ ៣ ទៀត ( គឺ មនោកម្ម ៣ ) ដោយអង្គធម៌ គឺ ចេតសិកដែលប្រកបនឹងចេតនា ។

- **អភិជ្ឈា** អង្គធម៌ គឺ លោភៈ ដែលប្រកបនឹងចេតនា ។
- **ព្យាបាទ** អង្គធម៌ គឺ ទោសៈ ដែលប្រកបនឹងចេតនា ។
- **មិច្ឆាទិដ្ឋិ** អង្គធម៌ គឺ មោហៈ ដែលប្រកបនឹងចេតនា ។

## ២.កោដ្ឋាស

- **អកុសលកម្មបថ ៨** គឺ កាយកម្ម ៣ វចីកម្ម ៤ និង មិច្ឆាទិដ្ឋិ ១ ជាកម្មបថសុទ្ធ ។

- **អកុសលកម្មបថ ២** គឺ អភិជ្ឈា ១ និង ព្យាបាទ ១ ជាកម្មបថផង ជាមូលផង ។

## ៣.ដោយអារម្មណ៍

- **បាណាតិបាត** មានសង្ខារជាអារម្មណ៍ ព្រោះមានជីវិតិន្ទ្រិយ៍ជាអារម្មណ៍ ។
- **អទិន្នាទាន** មានសត្វ ឬ សង្ខារជាអារម្មណ៍ ។
- **មិច្ឆាចារ** មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃផោដ្ឋព្វៈ(ខ្លះថា មានសត្វជាអារម្មណ៍ដែរ) ។
- **មុសាវាទ** មានសត្វ ឬ សង្ខារជាអារម្មណ៍ ។
- **បិសុណាវាចា** មានសត្វ ឬ សង្ខារជាអារម្មណ៍ ។
- **ផរុសវាចា** មានសត្វប៉ុណ្ណោះជាអារម្មណ៍ ។
- **សម្ផប្បលាប** មានសត្វ ឬសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ គឺ **ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ** ។
- **អភិជ្ឈា** មានសត្វ ឬ សង្ខារជាអារម្មណ៍ ។
- **ព្យាបាទ** មានសត្វជាអារម្មណ៍ប៉ុណ្ណោះ ។
- **មិច្ឆាទិដ្ឋិ** មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌

ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

# ៤.ដោយវេទនា

- **បាណាតិបាត** ប្រកបដោយទុក្ខវេទនា(ទោមនស្សវេទនា) ។ ស្ងួម្បីព្រះរាជាកំពុងសើចកក្អៀកក៏ដោយ ពេលព្រះអង្គត្រាស់ថា ពួកឯងសម្លាប់វាជាចោរទៅយ៉ាងនេះ ចេតនាដែលព្រះទ័យសម្រេច ជាចេតនាសម្បយុត្តជាមួយទុក្ខវេទនា ។

- **អទិន្នាទាន** ប្រកបដោយវេទនា ៣ ។ ពេលរីករាយត្រេកអរកាន់យក គឺជាសុខវេទនា (សោមនស្សវេទនា) ។ ពេលកាន់យកដោយទាំងភ័យ ឬ ទាំងពិចារណាផលនៃការលួច គឺជាទុក្ខវេទនា ។ ពេលលួចតាំងនៅក្នុងភាវៈជាកណ្តាល គឺ ជាអទុក្ខមសុខវេទនា ។

- **មិច្ឆាចារ** មានវេទនា ២ គឺ សុខវេទនា និង អទុក្ខមសុខវេទនា តែក្នុងពេលដែលសម្រេចចិត្ត មិនជាឧបេក្ខាវេទនាទេ ។

- **មុសាវាទ** មានវេទនា ៣ ។
- **បិសុណាវាចា** មានវេទនា ៣ ។
- **ផរុសវាចា** ជាទុក្ខវេទនា ។
- **សម្ផប្បលាប** មានវេទនា ៣ ។
- **អភិជ្ឈា** មានវេទនា២ គឺសុខវេទនានិងឧបេក្ខាវេទនា។
- **ព្យាបាទ** មានទុក្ខវេទនាតែម៉្យាង ។
- **មិច្ឆាទិដ្ឋិ** មានវេទនា ២ គឺសុខវេទនា ឧបេក្ខាវេទនា ។

# ៥.ដោយមូល

- **បាណាតិបាត** មានមូល ២ គឺទោសមូល និងមោហមូល ។
- **អទិន្នាទាន** មានមូល ២ គឺ ទោសមូល និងមោហមូល ឬ លោភមូល និង មោហមូល ។
- **មិច្ឆាចារ** មានមូល ២ គឺលោភមូល និងមោហមូល ។
- **មុសាវាទ បិសុណាវាចា និង សម្ផប្បលាប** មានមូល ២ គឺ ទោសមូល និងមោហមូល ឬ លោភមូល និង មោហមូល ។

- **ផរុសវាទ** មានមូល ២ គឺ ទោសមូល និង មោហមូល ។
- **អភិជ្ឈា និង ព្យាបាទ** មានមូល ១ គឺ មោហមូល ។
- **មិច្ឆាទិដ្ឋិ** មានមូល ២ គឺ លោភមូល និង មោហមូល ។

# អកុសលមូល ៣
# ជាហេតុឲ្យកើត អកុសលកម្មបថ ១០

**១.លោភមូល ៨** ជាហេតុឲ្យកើតទុច្ចរិត ៧ គឺ :

-ក្នុងកាយកម្ម ២ គឺ អទិន្នាទាន កាមេសុមិច្ឆាចារ
-ក្នុងវចីកម្ម ៣ គឺ មុសាវាទ បិសុណាវាចា សម្ផប្បលាប
-ក្នុងមនោកម្ម ២ គឺ អភិជ្ឈា មិច្ឆាទិដ្ឋិ

**២.ទោសមូល ២** ជាហេតុឲ្យកើតទុច្ចរិត ៧ គឺ :

-ក្នុងកាយកម្ម ២ គឺ បាណាតិបាត អទិន្នាទាន
-ក្នុងវចីកម្ម ៤ គឺ មុសាវាទ ជាដើម
-ក្នុងមនោកម្ម ១ គឺ ព្យាបាទ

## ៣.មោហមូល ២

ជាហេតុឲ្យកើតទុច្ចរិត ១០ គឺ :
កាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣ ។

-ចំពោះអកុសលកម្មបថនោះ ទាល់តែមានចេតនា បំណងឲ្យអ្នកដទៃខាតប្រយោជន៍ ចេតនានោះទើបជាកម្មបថ មិនមែនជាលោភៈ ទោសៈ មោហៈ ដែលគ្រាន់តែជាអកុសលចិត្តទេ ។

-បើមិនមានចេតនាបៀតបៀនអ្នកដទៃឲ្យជាទុក្ខទេ ឬ ក្ដៅក្រហាយទេ ប៉ុន្តែប្រព្រឹត្តដោយលោភៈ ទោសៈ មោហៈ ក៏ជាកាយទ្វារ និងវចីទ្វារនៃអកុសលចិត្តប៉ុណ្ណោះ មិនមែនជាអកុសលកម្មទេ ។

ឧទាហរណ៍ ដូចការនិយាយជជែក ឆ្លើយឆ្លងគ្នាដើរទៅដើរមកធ្វើកិច្ចការផ្សេងៗ បើខណៈនោះ ចិត្តមិនមែនជាកុសលទេ ការធ្វើចលនា និយាយគ្នានោះៗ ក៏ត្រឹមតែជាកាយទ្វារ និងវចីទ្វារនៃអកុសលចិត្ត មិនមែនជាអកុសលកម្មទេ ។

-ការដែលនឹងដឹងថា កម្មណាជាកាយកម្ម កម្មណាជាវចីកម្ម កម្មណាជាមនោកម្ម ក៏ត្រូវពិនិត្យមើល ថាតើ អកុសលកម្មដែលកើតឡើងនោះ អាស្រ័យដោយអភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ឬក៏ មិនមែនទេ ? បើមិនមែនក៏ជាកាយកម្ម ឬ វចីកម្ម ។

-ចំណែកចេតនាក្នុងមនោកម្មនោះ សូម្បីនឹងធ្វើតាមកាយទ្វារ និងតាមវចីទ្វារក៏ដោយ ក៏មិនឈ្មោះថា ជាកាយកម្ម និងវចីកម្មដែរ

ព្រោះចេតនាក្នុងមនោកម្មនោះ មានអភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ជាប្រធាន ។

-ចំណែកចេតនាក្នុងកាយកម្ម និងវចីកម្ម មិនមែនជាមនោកម្ម ព្រោះចេតនាដែលសម្រេចឲ្យជាកាយកម្ម និង វចីកម្មនោះ មានចេតនាប្រព្រឹត្តតាមកាយនិងវាចាជាប្រធាន មិនមែនជាមនោកម្មក្នុងអភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ជាប្រធានទេ ។

- **មនោកម្ម ៣** កើតបានទ្វារទាំង ៣ គឺ កាយទ្វារ វចីទ្វារ និង មនោទ្វារ ។
- **វចីកម្ម ៤** កើតបានទ្វារ ២ គឺ កាយទ្វារ និងវចីទ្វារ ។
- **កាយកម្ម ២** គឺ បាណាតិបាត និង អទិន្នាទាន កើតបានទ្វារ ២ គឺ កាយទ្វារ និង វចីទ្វារ ។
- **កាយកម្ម ១** គឺ កាមេសុមិច្ឆាចារ កើតបានតែទ្វារ ១ ប៉ុណ្ណោះ គឺ កាយទ្វារ ។

-ក្នុងអដ្ឋសាលិនី កាយកម្មនិងវចីកម្ម មិនមែនកើតឡើង ព្រោះអសំវរៈក្នុងបញ្ចទ្វារសម្ផស្សនោះទេ គឺ កើតឡើងព្រោះអសំវរៈក្នុងមនោទ្វារសម្ផស្សតែប៉ុណ្ណោះ ឯចំណែកមនោកម្ម កើតឡើងបាន ព្រោះអសំវរៈក្នុងឆទ្វារសម្ផស្សដោយពិត ។

-ការពពាក់ពពូននៃកម្មមានច្រើនប្រការ ព្រោះកម្មដែលធ្វើ

ម្តងៗ នោះ ផ្សេងគ្នាដោយកម្ម ដោយទ្វារ ដោយចេតនា ដោយវត្ថុ ដោយកិលេស ដោយសេចក្តីព្យាយាម ។

ដោយទោសដែលធ្ងន់ឬស្រាល គឺ ទៅតាមកម្លាំងនៃកម្ម ។ ព្រះអង្គទ្រង់ត្រាស់ទុកដូច្នេះថា :

**១.** វិបាកធ្ងន់របស់បាណាតិបាត ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត ធ្វើឲ្យអាយុខ្លី កាលកើតមកជាមនុស្ស ។

**២.** វិបាកធ្ងន់របស់អទិន្នាទាន ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតមកជាមនុស្សតែងធ្វើឲ្យភោគៈវិនាស ។

**៣.** វិបាកធ្ងន់របស់កាមេសុមិច្ឆាចារ ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតមកជាមនុស្ស ធ្វើឲ្យមានសត្រូវ និងឲ្យមានពៀរ ។

**៤.** វិបាកធ្ងន់របស់មុសាវាទ ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតមកជាមនុស្ស តែងតែត្រូវគេពោលបង្កាច់ដោយពាក្យមិនពិត ។

**៥.** វិបាកធ្ងន់របស់បិសុណាវាចា ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតមកជាមនុស្ស តែងធ្វើឲ្យបែកបាក់នូវមិត្ត ។

**៦.** វិបាកធ្ងន់របស់ផរុសវាចា ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាក

ស្រាលបំផុត កាលបានអត្តភាពជាមនុស្ស ធ្វើឲ្យឮសំឡេង ដែលមិនចូលចិត្ត ។

**៧.** វិបាកធ្ងន់របស់សម្ផប្បលាប ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតមកជាមនុស្ស ធ្វើឲ្យមិនមាននរណាមួយជឿនូវពាក្យសំដីឡើយ ។

**៨.** វិបាកធ្ងន់របស់អភិជ្ឈា ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតមកជាមនុស្សតែងធ្វើឲ្យភោគៈវិនាស ហើយអភិជ្ឈានេះ តែងតាមដុតរោល (រាគគ្គិ) ។

**៩.** វិបាកធ្ងន់របស់ព្យាបាទ ធ្វើឲ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលបានអត្តភាពជាមនុស្ស ធ្វើឲ្យឮសំឡេងដែលមិនចូលចិត្ត ហើយព្យាបាទនេះ តែងតាមដុតរោល (ទោសគ្គិ) ។

**១០.** វិបាកធ្ងន់ស្រាលរបស់មិច្ឆាទិដ្ឋិ បើសេពច្រើនរហូតដល់ជាប់ជាទម្លាប់ ក៏កើតក្នុងលោកន្តរិកនរក បើសេពតិច ក៏ធ្វើឲ្យកើតក្នុងអបាយភូមិ ។

ការពពាក់ពពូនរបស់កម្ម និង ការឲ្យផលរបស់កម្ម នោះនរណាក៏មិនអាចដឹងអាចជ្រាបបានច្បាស់ដែរ មានតែព្រះដ៏មានព្រះ-ភាគដែលជាសព្វញ្ញូប៉ុណ្ណោះ ។ ដោយហេតុដូច្នេះហើយ ទើបជនខ្លះយល់ខុសគិតថា ការធ្វើកម្មអាក្រក់ បានផលល្អ ឬ ការធ្វើកម្មល្អ

បានផលអាក្រក់ ។ ឯសេចក្ដីពិត ការធ្វើល្អឬអាក្រក់នោះ តែងឲ្យផលកាលណាបានឱកាសនិងបច្ច័យ មិនមាននរណាមួយ រួចផុតចាកពីផលរបស់កម្មល្អ និងកម្មអាក្រក់បានឡើយ ។

# ចំណែកអកុសលចិត្ត ១២ ដោយន័យផ្សេងៗ

| | | |
|---|---|---|
| **១.ដោយជាតិ** | អកុសលចិត្ត ១២ | ជាអកុសលជាតិ |
| **២.ដោយភូមិ** | ” ” | ជាកាមាវចរភូមិ |
| **៣.ដោយវេទនា** | ” ” | ជាសោមនស្សវេទនា ៤ ជាទោមនស្សវេទនា ២ ជាឧបេក្ខាវេទនា ៦ |
| **៤. ដោយហេតុ** | ” ” | ជានហេតុ ជាសហេតុកចិត្ត គឺឯកហេតុកចិត្ត២ ទុហេតុកចិត្ត ១០ |
| **៥.ដោយសម្បយុត្ត** | ” ” | ជាសម្បយុត្តចិត្ត ៨ ជាវិប្បយុត្តចិត្ត ៤ |

| | | |
|---|---|---|
| **៦.ដោយសង្ខារ** | អកុសលចិត្ត ១២ | ជាអសង្ខារិក ៧ |
| | | ជាសសង្ខារិក ៥ |
| **៧.ដោយសោភណៈ** ” | ” | ជាអសោភណចិត្ត |
| **៨.ដោយឈាន** ” | ” | ជាអឈានចិត្ត |
| | | ជាអកុសលឈាន |
| **៩.ដោយលោកិយ** ” | ” | ជាលោកិយចិត្ត |
| **១០.ដោយកិច្ច** ” | ” | ជាជវនកិច្ច |
| **១១.ដោយអារម្មណ៍** ” | ” | ជាចិត្តមានអារម្មណ៍ ៦ |
| **១២.ដោយទ្វារ** ” | ” | កើតបានទ្វារ ៦ |
| **១៣.ដោយវត្ថុ** ” | ” | អាស្រ័យហទយវត្ថុ |
| **១៤.ដោយវិញ្ញាណ** ” | ” | ជាមនោវិញ្ញាណធាតុ |

( ចប់ អកុសលចិត្ត ១២ )

# តារាងអកុសលចិត្ត ១២ ដួង

អកុសលចិត្ត ១២ ដួង

- លោភមូល
  - សោមនស្ស
    - ទិដ្ឋិគតសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ទិដ្ឋិគតវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - ឧបេក្ខា
    - ទិដ្ឋិគតសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ទិដ្ឋិគតវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - (សរុប) ៨
- ទោសមូល
  - ទោមនស្ស
    - បដិឃសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - (សរុប) ២
- មោហមូល
  - ឧបេក្ខា
    - វិចិកិច្ឆាសម្បយុត្ត អសង្ខារិក ១
    - ឧទ្ធច្ចសម្បយុត្ត អសង្ខារិក ១
  - (សរុប) ២

# សំណួរចំឡើយសាឡើងវិញ

**១.** ព្រះសទ្ធម្ម គឺ ធម៌អ្វី ? មានអ្វីខ្លះ ?

-ព្រះសទ្ធម្ម គឺ ជាធម៌របស់សប្បុរសមាន ៣ យ៉ាង គឺ

(១) បរិយត្តិសទ្ធម្ម បានដល់ ព្រះពុទ្ធវចនៈ ដែលសិក្សារៀនសូត្រ ។

(២) បដិបត្តិសទ្ធម្ម បានដល់ ការរក្សាសីល ការកាន់នូវធុតង្គ និងការចំរើនកម្មដ្ឋាន ។

(៣) បដិវេធសទ្ធម្ម បានដល់ ការសម្រេចមគ្គ ផល ព្រះនិព្វាន និង ឈាន អភិញ្ញា ។

**២.** បរមត្ថធម៌សំដៅដល់ធម៌អ្វី ?

-បរមត្ថធម៌ សំដៅដល់សភាវៈរបស់នាមនិងរូប ដែលមាននៅដោយមិនវិបរិត មាន ៤ គឺ ចិត្ត ចេតសិក រូប និង និព្វាន ។

**៣.** ចិត្ត និង បរមត្ថធម៌ ៤ ផ្សេងគ្នា ឬ ដូចគ្នា ?

-ចិត្ត ជាបរមត្ថធម៌មួយប្រភេទក្នុងបរមត្ថធម៌ ៤ ហៅថាចិត្តបរមត្ថ ចំណែកបរមត្ថធម៌ ៤ នោះ សំដៅយកបរមត្ថធម៌ទាំងអស់ គឺ ចិត្ត ចេតសិក រូប និព្វាន ។

៤. បរមត្ថធម៌ ៤ មានលក្ខណៈយ៉ាងណា ?

+បរមត្ថធម៌ ៤ មានលក្ខណៈដូចតទៅ :

-ចិត្ត មានការដឹងនូវអារម្មណ៍ ជាលក្ខណៈ ។ វៀរ-ចាកអារម្មណ៍ហើយ ចិត្តក៏មិនកើតឡើងបានដែរ ។

-ចេតសិក មានការអាស្រ័យចិត្តកើត ជាលក្ខណៈ បើមិនមានចិត្ត ចេតសិកក៏កើតមិនបាន ។

-រូប មានការបែកធ្លាយទៅ ជាលក្ខណៈ ព្រោះអា-ស្រ័យបច្ច័យដែលជាសត្រូវ មានក្ដៅ និងត្រជាក់ជាដើម ។

-និព្វាន មានការស្ងប់ជាលក្ខណៈ ជាធម៌ផុតចាកពីខន្ធ។

៥. វេវចនៈ គឺរូបស័ព្ទផ្សេងគ្នា តែន័យដូចគ្នានៃចិត្ត មានអ្វីខ្លះ ?

-វេវចនៈរបស់ចិត្ត មាន ១០ គឺ ចិត្ត មនោ ហទយៈ មានសៈ បណ្ឌរៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ។

៦. លោភៈ និងលោភមូលចិត្ត ខុសគ្នាយ៉ាងណា ?

-លោភៈ ជាចេតសិក ចំណែកលោភមូលចិត្ត ជាចិត្តដែលមានលោភៈជាមូល ។

៧. ពាក្យថា “ ទិដ្ឋិ ” ក្នុងលោភមូលចិត្ត ៤ ដួង និង ពាក្យ

ថា “ មិច្ឆាទិដ្ឋិ ” ក្នុងអកុសលកម្មបថ ដូចគ្នា ឬក៏ខុសគ្នា ?

-ខុសគ្នា គឺ ទិដ្ឋិក្នុងលោភមូលចិត្តនោះ សំដៅយកការឃើញខុសទាំងអស់ គឺ សក្កាយទិដ្ឋិ សីលព្វតទិដ្ឋិ និយតមិច្ឆាទិដ្ឋិ ចំណែកមិច្ឆាទិដ្ឋិក្នុងអកុសលកម្មបថនោះ សំដៅ យកមិច្ឆាទិដ្ឋិ ៣ គឺ អកិរិយាទិដ្ឋិ អហេតុកទិដ្ឋិ និង នត្ថិកទិដ្ឋិ ។

**៨.** ការសម្លាប់ខ្លួនឯងឲ្យស្លាប់ នឹងជាវិបាកនាំកើត ក្នុងអបាយភូមិ ឬទេ ?

-ការសម្លាប់ខ្លួនឯង មិនគ្រប់អង្គនៃកម្មបថទេ ដូច្នោះ មិនជាវិបាកនាំឲ្យកើតក្នុងអបាយភូមិឡើយ ។

**៩.** បើលោភមូលចិត្តកើតមុនស្លាប់ តើនឹងកើតក្នុងទីណា ?

-បើស្រឡាញ់ហើយស្លាប់ លោភមូលចិត្តនោះជាបច្ច័យឲ្យអកុសលវិបាក ក៏កើតក្នុងកំណើតប្រេត ដែលមានជាតិរហេម-រហាម មិនចេះឆ្អែតដូចជាលោភៈអ៊ីចឹង ។

**១០.** បើទោសមូលចិត្តកើតមុនស្លាប់ តើនឹងកើតក្នុងទីណា ?

-បើក្រោធហើយស្លាប់ ទោសមូលចិត្តនោះជាបច្ច័យឲ្យអកុសលវិបាក ក៏កើតក្នុងនរក ដែលមានជាតិកាចសាហាវ ដូចជាទោសៈអ៊ីចឹង ។

**១១.** បើមោហមូលចិត្តកើតមុនស្លាប់ តើនឹងកើតក្នុងទីណា ?

-មោហមូលចិត្តមាន ២ ដួង គឺ មោហមូលចិត្តដែលប្រកបជាមួយវិចិកិច្ឆា ១ និងប្រកបជាមួយឧទ្ធច្ចៈ ១ ។

-មោហមូលចិត្តដែលប្រកបជាមួយនឹងឧទ្ធច្ចៈ មិនជាបច្ច័យឲ្យបដិសន្ធិ កើតបានទេ ។ ចំណែកចិត្តដែលប្រកបជាមួយសេចក្តីសង្ស័យ ៨ យ៉ាង គឺសង្ស័យក្នុងព្រះពុទ្ធជាដើម ជានីវរណៈ ស្លាប់ហើយតែង កើតជាសត្វតិរច្ឆាន ដែលមានសេចក្តីវង្វេងជានិច្ច ។

**១២.** ហេតុអ្វីបានជាមោហមូលចិត្ត ២ ដួងនេះ មានទោសតិចច្រើនជាងគ្នា ?

-វិចិកិច្ឆាសម្បយុត្តចិត្ត មានទោសច្រើនជាង ព្រោះជាបច្ច័យឲ្យអកុសលវិបាកបដិសន្ធិបាន ហើយក្រៅពីចិត្តល្ងង់ហើយ ចិត្តដួងនេះ នៅមានការពិចារណាសម្រេចពោល បញ្ជាក់គំនិតយល់ឃើញលើសភាវៈវត្ថុដ៏ប្រសើរ ដែលគួរគោរពបូជា ដែលខ្លួនមិនអាចដឹងដល់ ដែលខ្លួនស្មានៗ និងដោយការអំនួតក្រអើតក្រទមទៀតផង ។

ចំណែកឧទ្ធច្ចៈសម្បយុត្តចិត្ត មិនជាបច្ច័យឲ្យអកុសលវិបាកបដិសន្ធិទេ គ្រាន់តែជាការរាយមាយ ភ័ន្តភាំង ចាប់អារម្មណ៍ មិនមាំទាំ មិននឹងនប៉ុណ្ណោះ ដូចជាអណ្តាតភ្លើងត្រូវខ្យល់ ទាំងក៏មិនបានកន្លងល្មើសចំពោះអ្វីៗណាដែរ ។

**១៣.** សេចក្តីសង្ស័យដទៃក្រៅអំពីសេចក្តីសង្ស័យ ៨ យ៉ាង ដែលជា

នីវរណៈ តើជាវិចិកិច្ឆាដែរឬ ?

-មិនមែនជាវិចិកិច្ឆានីវរណៈទេ តែលោកហៅថា ជាបដិរូបកវិចិកិច្ឆា ។

**១៤.** តើបដិរូបកវិចិកិច្ឆានេះ ជាចិត្តអ្វី ?

-បើសង្ស័យនោះទាក់ទងនឹងលោភៈ ក៏ជាលោភមូលចិត្ត បើទាក់ទងនឹងទោសៈ ក៏ជាទោសមូលចិត្ត ។

**១៥.** អកុសលចិត្តជាចិត្តអាក្រក់ មានទោស ឲ្យផលជាទុក្ខ ជាបច្ច័យឲ្យកើតក្នុងអបាយភូមិបាន កាលបើជាចិត្តយ៉ាងនេះ តើត្រូវរៀនដូចម្តេចទើបដឹង នឹងរៀនតែអ្វីដែលជាចិត្តល្អៗ មានសោមនស្ស ឲ្យផលជាសុខល្អទេអ៊ីចឹង ? ឬមានការយល់យ៉ាងណាដែរ ?

ពិតហើយ អកុសលចិត្តជាចិត្តអាក្រក់ មានទោស ឲ្យផលជាទុក្ខ ជាបច្ច័យឲ្យកើតក្នុងអបាយភូមិមែន កាលបើយ៉ាងនេះ ទើបសមគួរយ៉ាងក្រៃលែងបំផុត ដែលត្រូវតែសិក្សារៀនសូត្រដើម្បី រកផ្លូវកម្ចាត់ ដុសខាត់ ឬធ្វើឲ្យស្រាលស្តើងចុះ ។ បើមិនសិក្សាឲ្យយល់ទេ ក៏មិនមានផ្លូវនឹងបំបែកកិលេស ដែលធ្វើឲ្យចិត្តសៅហ្មងបានដែរ ។ អ្នកឃើញទុក្ខ មិនចង់ឲ្យមានទុក្ខ គឺ ត្រូវខិតខំប្រឹងប្រែងព្យាយាមសិក្សាឲ្យយល់ ។

ម្យ៉ាងទៀត អកុសលចិត្ត ៣ ប្រភេទនេះ លោភមូលចិត្ត ៨

ជាចិត្តត្រេកអរពេញចិត្ត ធ្វើចិត្តឲ្យជាប់ស្អិតណែនក្នុងអារម្មណ៍ អ្នកដែលឃើញទោសហើយខំលះចំពោះខ្លួន ដោយខ្លួនឯងនោះ រមែងលំបាកណាស់ ឯអ្នកដែលមិនបានស្តាប់ព្រះពុទ្ធវចនៈនោះ ក៏កាន់តែមិនងាយមានផ្លូវនឹងលះបានឡើយ ។ ចំណែកទោសមូលចិត្ត ២ ដួងនោះ ក៏គឺ ចិត្តដែលជាទុក្ខ គ្រប់ៗគ្នាតែងមិនចូលចិត្ត តែកាលណាមិនសិក្សារៀនសូត្រទេ ក៏លំបាកនឹងលះបានដូចគ្នាដែរ ។ ចំណែកមោហមូលចិត្ត ២ ដួង ជាចិត្តកើតពីមោហៈ គឺ អវិជ្ជា ឯអវិជ្ជានេះព្រះអង្គទ្រង់ត្រាស់ថា ជាសិរសារបស់កិលេសទាំងពួង ជាប្រធានរបស់កិលេស ជាបច្ច័យនៃសង្សារវដ្ត ដកបានដោយលំបាក លះបានដោយកម្រ ធ្វើយ៉ាងណាទើបលះបង់អវិជ្ជាបាន ព្រោះអាស្រ័យហេតុនេះ ទើបចាំបាច់យ៉ាងក្រៃលែង ដែលអ្នកមានបញ្ញាទាំងឡាយ គួរសិក្សា ព្យាយាមប្រឹងប្រែងរៀនសូត្រតទៅ ។

**១៦.** ខណៈណាចិត្តឈ្មោះថា បណ្ឌរៈ ? ព្រោះអ្វី ?

-សំដៅយកភវង្គចិត្តដែលបរិសុទ្ធ ត្រឹមតែមួយជួរខណៈដែលមិនដឹងអារម្មណ៍តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តប៉ុណ្ណោះ ។ ព្រោះថាខណៈនោះមិនមានសេចក្តីដឹងខ្លួនថា ស្រឡាញ់ ស្អប់ ប្រណែនអ្វីឡើយ ដោយមិនឃើញ មិនឮ មិនជ្រាប មិនដឹងច្បាស់អ្វីៗទាំងអស់ ហាក់ដូចជាបរិសុទ្ធ ។

**១៧.** ចំណុចបំណងដែលត្រឹមត្រូវ នៃការសិក្សាព្រះធម៌ គឺ អ្វី ?

-គឺដើម្បីជាបច្ច័យឧបត្ថម្ភ ឧបការឲ្យយល់នូវលក្ខណៈ នៃធម៌ ដែលកំពុងមានក្នុងខណៈនេះ ដែលកំពុងឃើញ កំពុងឮ កំពុងនឹកគិតជាដើម ដើម្បីឲ្យសតិប្បដ្ឋានកើតឡើង រលឹកដឹងលក្ខណៈនៃសភាវៈធម៌ ជានាមធម៌ ឬជារូបធម៌ មួយបែបៗ ណាមួយដែលកំពុងប្រាកដ និងដើម្បីបញ្ញាដែលអប់រំចំរើនហើយនោះ នឹងបានលះបង់នូវការប្រកាន់សភាវៈធម៌ទាំងឡាយថា ជាតួខ្លួន ។

**១៨.** បរមត្ថធម៌ណា ជានាមធម៌ ?

-បរមត្ថធម៌ដែលជានាមធម៌ មាន ៣ គឺ ចិត្តបរមត្ថ ១ ចេតសិកបរមត្ថ ១ និព្វានបរមត្ថ ១ ។

**១៩.** សង្ខារធម៌ណា ជានាមធម៌ ?

-សង្ខារធម៌ដែលជានាមធម៌មាន ២ គឺ ចិត្ត១ ចេតសិក១ ។

**២០.** ខន្ធណាខ្លះ ជានាមធម៌ ?

-ខន្ធដែលជានាមធម៌មាន ៤ គឺ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ និង វិញ្ញាណក្ខន្ធ ១ ។

**២១.** ពាក្យថា “ មនុស្ស ” ជាខន្ធឬទេ ?

-ពាក្យថា មនុស្សមិនមែនជាខន្ធទេ ។

**២២.** បរមត្ថធម៌ណាជាខន្ធ ?

-បរមត្ថធម៌ដែលជាខន្ធមាន ៣ គឺ ចិត្តបរមត្ថ ១ ចេតសិក-បរមត្ថ ១ និង រូបបរមត្ថ ១ ៕

( ចប់ អកុសលចិត្ត ១២ )

# អហេតុកចិត្ត ១៨ ដួង

ខណៈដែលពេញចិត្ត ឬ មិនពេញចិត្តនោះ ជាអកុសលចិត្តដែលមានលោភៈជាមូល ឬមានទោសៈជាមូល ។ ប៉ុន្តែមុននឹងពេញចិត្ត ឬមិនពេញចិត្ត ក៏ត្រូវតែជាចិត្តដែលដឹងអារម្មណ៍ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ដែលចិត្តទាំងនេះមិនមែនជាអកុសលចិត្ត គឺជា **ចិត្តដែលប្រាសចាកហេតុ** ។

ចេតសិកដែលជាហេតុ មាន ៦ ដួង ។ ចេតសិក ៣ ដួងជាអកុសលហេតុ គឺលោភៈ ទោសៈ មោហៈ ។ ចេតសិក ៣ ដួងទៀត ជាសោភណហេតុ គឺ អលោភៈ អទោសៈ និង អមោហៈ ។ ចិត្ត ឬចេតសិកដែលមានហេតុកើតរួម ជា **សហេតុកៈ** ។

ចិត្តដែលមិនប្រកបដោយហេតុ ជា **អហេតុកចិត្ត** មួយថ្ងៃៗមានអហេតុកចិត្តកើតច្រើនណាស់ ។ ខណៈដែលឃើញ ឮ ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈនោះ អហេតុកចិត្តកើតមុន សហេតុកចិត្ត (កុសល ឬ អកុសលចិត្ត) ។

អហេតុកចិត្តមាន ១៨ ដួង ជាវិបាកមាន ១៥ ដួង ជាកិរិយា មាន ៣ ដួង ចែកចេញជា ៣ ប្រភេទ គឺ :

-ជាអកុសលវិបាកចិត្ត (ផលរបស់អកុសលកម្ម)មាន ៧ ដួង ។
-ជាអហេតុកកុសលវិបាកចិត្ត (ផលរបស់កុសលកម្ម)មាន ៨ ដួង ។
-ជាអហេតុកកិរិយាចិត្ត (មិនមែនហេតុមិនមែនផល)មាន ៣ ដួង ។

# អកុសលវិបាកចិត្ត ៧ ដួង

**១.ឧបេក្ខាសហគត ចក្ខុវិញ្ញាណ** ឃើញនូវអនិដ្ឋារម្មណ៍ គឺ រូបមិនជាទីប្រាថ្នា ព្រមដោយឧបេក្ខាវេទនា ១ ។

**២.ឧបេក្ខាសហគត សោតវិញ្ញាណ** ឮនូវអនិដ្ឋារម្មណ៍ គឺសំឡេងមិនជាទីប្រាថ្នា ព្រមដោយឧបេក្ខាវេទនា ១ ។

**៣.ឧបេក្ខាសហគត ឃានវិញ្ញាណ** ធុំនូវអនិដ្ឋារម្មណ៍ គឺក្លិនមិនជាទីប្រាថ្នា ព្រមដោយឧបេក្ខាវេទនា ១ ។

**៤.ឧបេក្ខាសហគត ជីវ្ហាវិញ្ញាណ** ដឹងនូវអនិដ្ឋារម្មណ៍ គឺរសមិនជាទីប្រាថ្នា ព្រមដោយឧបេក្ខាវេទនា ១ ។

**៥.ទុក្ខសហគត កាយវិញ្ញាណ** ដឹងនូវអនិដ្ឋារម្មណ៍ គឺផោដ្ឋព្វៈមិនជាទីប្រាថ្នា ព្រមដោយទុក្ខវេទនា ១ ។

**៦.ឧបេក្ខាសហគត មនោធាតុអហេតុកអកុសលវិបាក ឬឧបេក្ខាសហគត សម្បដិច្ឆន្ន** ចិត្តទទួលនូវអនិដ្ឋារម្មណ៍ទាំង ៥

ទ្វារ ព្រមដោយឧបេក្ខាវេទនា ១ ។

**៧.ឧបេក្ខាសហគតមនោវិញ្ញាណធាតុអហេតុក អកុសល-វិបាក ឬ ឧបេក្ខាសហគត សន្តីរណ** ចិត្តពិចារណានូវអនិដ្ឋារម្មណ៍ទាំង ៦ ព្រមដោយឧបេក្ខាវេទនា ១ ។

អកុសលចិត្តទាំងអស់ ទោះបីមានកម្លាំងក្តី មិនមានកម្លាំងក្តី លុះរលត់ទៅហើយ តែងជាបច្ច័យឲ្យអកុសលវិបាកចិត្តកើតឡើង ។ មិនថា អកុសលចិត្តដែលធ្វើកម្មក្នុងជាតិនេះ ឬក្នុងអតីតភព ឬក្នុងអនាគតជាតិក៏ដោយ តែងតែជាបច្ច័យឲ្យកើតអកុសលវិបាកចិត្ត បានទាំងអស់ ។

**១.ចក្ខុវិញ្ញាណ** ជាអហេតុកចិត្តកើតឡើង ដើម្បីទទួលផលរបស់កម្មដែលបានធ្វើទុកហើយ ។ **ចក្ខុវិញ្ញាណ** នេះ កើតម្តងក្តី ឬប៉ុន្មានដងក្តី តែងឃើញត្រឹមតែពណ៌ (រូប) ជាអារម្មណ៍ ប៉ុណ្ណោះមិនឃើញជាសត្វជាបុគ្គលទេ ។

ពាក្យថា **ចក្ខុ** សំដៅដល់ភ្នែក ឬកែវភ្នែក ដោយបរមត្ថសំដៅដល់ **ចក្ខុបសាទ** ។ ពាក្យថា **បសាទ** សំដៅដល់ ការថ្លានៃមហាភូតរូប តែមិនមែនជាមហាភូតរូបទេ ។

បើអកុសលកម្មឲ្យផល ក៏ធ្វើឲ្យចក្ខុវិញ្ញាណឃើញរូបារម្មណ៍ជា

អនិដ្ឋារម្មណ៍ គឺ អារម្មណ៍មិនជាទីប្រាថ្នា បើកុសលកម្មឲ្យផល ក៏ឃើញរូបារម្មណ៍ជាឥដ្ឋារម្មណ៍ គឺ អារម្មណ៍ជាទីប្រាថ្នា ។

ការឃើញរូបជាអនិដ្ឋារម្មណ៍ក្តី ឥដ្ឋារម្មណ៍ក្តីនោះ មិននៅក្នុងអំណាច និងមិនប្រព្រឹត្តទៅតាមសេចក្តីត្រូវការរបស់បុគ្គលណាៗ ទេ គឺ ស្រេចតែកម្មណាមួយមានឱកាសឲ្យផលប៉ុណ្ណោះ ។

ការដែលនឹងដឹងថា អនិដ្ឋារម្មណ៍ ឬឥដ្ឋារម្មណ៍ នោះមិនមែនជាកិច្ច ( នាទី ) របស់ចក្ខុវិញ្ញាណទេ ព្រោះចក្ខុវិញ្ញាណធ្វើ **ទស្សនកិច្ច** គឺឃើញប៉ុណ្ណោះ មិនដឹងថា អារម្មណ៍នោះជាអារម្មណ៍ល្អឬអាក្រក់ អនិដ្ឋារម្មណ៍ ឬ ឥដ្ឋារម្មណ៍អ្វីឡើយ ។

**ចក្ខុវិញ្ញាណ** កើតរួមនឹងឧបេក្ខា ព្រោះអាស្រ័យដោយរូបជាឧបាទាយរូបប៉ះខ្ទប់នឹងចក្ខុបសាទ ដែលជាឧបាទាយរូបដែរ ( មិនមែនជាមហាភូតរូបប៉ះខ្ទប់នឹងមហាភូតរូប ) មានកម្លាំងតិចណាស់ ។

# លក្ខណាទិចតុកៈរបស់ចក្ខុវិញ្ញាណ

| | |
|---|---|
| **-ចក្ខុសន្និស្សិត រូបវិជានន លក្ខណំ** | មានចក្ខុបសាទជាទីអាស្រ័យ ហើយដឹងនូវរូបារម្មណ៍ ជាលក្ខណៈ ។ |

| | |
|---|---|
| **-រូបមត្តារម្មណ រសំ** | មានអារម្មណ៍ត្រឹមតែរូប ជាកិច្ច ។ |
| **-រូបាភិមុខភាវ បច្ចុប្បដ្ឋានំ** | មានមុខតម្រង់ឆ្ពោះទៅទល់នឹងរូប ជាអាការប្រាកដ ។ |
| **-រូបារម្មណាយ កិរិយាមនោធាតុយា អបគមនបទដ្ឋានំ** | មានការប្រាសទៅនៃមនោធាតុអហេតុកកិរិយាចិត្តដែលមានរូបជាអារម្មណ៏ ជាហេតុជិត។ |

**២.សោតវិញ្ញាណ** ជាអហេតុកចិត្ត កើតឡើងដើម្បីទទួលផលរបស់អកុសលកម្ម ដែលបានធ្វើទុកមក ធ្វើឲ្យឮសំឡេងជាអនិដ្ឋារម្មណ៍ ។ ពាក្យថា **សោតះ** ដោយព្យញ្ជនៈ សំដៅដល់ត្រចៀក ដោយបរមត្ថសំដៅដល់ **សោតបសាទ** សំរាប់ប៉ះខ្ទប់នឹងសំឡេង ។

# លក្ខណាទិចតុកៈរបស់សោតវិញ្ញាណ

| | |
|---|---|
| **-សោតសន្និស្សិត សទ្ទវិជាននលក្ខណំ** | មានសោតបសាទជាទីអាស្រ័យហើយដឹងនូវសំឡេងជាលក្ខណៈ |

| | |
|---|---|
| **-សទ្ទមត្តារម្មណា រសំ** | មានអារម្មណ៍ ត្រឹមតែសំឡេង ជាកិច្ច ។ |
| **-សទ្ទាភិមុខភាវ បច្ចុប្បដ្ឋានំ** | មានមុខតម្រង់ឆ្ពោះទៅទល់នឹង សំឡេង ជាអាការប្រាកដ ។ |
| **-សទ្ទារម្មណាយ កិរិយាមនោ-ធាតុយា អបគមន បទដ្ឋានំ** | មានការប្រាសទៅនៃមនោធាតុ អហេតុកកិរិយាចិត្ត ដែល មានសំឡេងជាអារម្មណ៍ ជា ហេតុជិត ។ |

**៣.ឃានវិញ្ញាណ** ជាអហេតុកចិត្ត កើតឡើងដើម្បីទទួលផលរបស់អកុសលកម្មដែលបានធ្វើទុកមក ធ្វើឲ្យបានធុំក្លិនជាអនិដ្ឋារម្មណ៍ ។ ពាក្យថា **ឃានៈ** ដោយព្យញ្ជនៈ សំដៅដល់ច្រមុះ ដោយបរមត្ថសំដៅដល់ **ឃានបសាទរូប** សំរាប់ប៉ះខ្ទប់និងក្លិន ។

# លក្ខណាទិចតុកៈរបស់ឃានវិញ្ញាណ

| | |
|---|---|
| **-ឃានសន្និស្សិត គន្ធវិជាននលក្ខណំ** | មានឃានបសាទ ជាទីអាស្រ័យ ហើយដឹងនូវក្លិនជាលក្ខណៈ ។ |

**-គន្ធមត្តារម្មណ រសំ** មានអារម្មណ៍ត្រឹមតែក្លិនជាកិច្ច។

**-គន្ធាភិមុខភាវ បច្ចុប្បដ្ឋានំ** មានមុខតម្រង់ឆ្ពោះទៅទល់នឹងក្លិន ជាអាការប្រាកដ ។

**-គន្ធារម្មណាយ កិរិយាមនោធាតុយា អបគមន បទដ្ឋានំ** មានការប្រាសទៅនៃមនោធាតុអហេតុកកិរិយាចិត្ត ដែលមានក្លិនជាអារម្មណ៍ ជាហេតុជិត ។

**៤.ជីវ្ហាវិញ្ញាណ** ជាអហេតុកចិត្ត កើតឡើងដើម្បីទទួលផលរបស់អកុសលកម្មដែលបានធ្វើទុកមក ធ្វើឲ្យបានក្រេបជញ្ជក់ (ដឹង) រសជាអនិដ្ឋារម្មណ៍ ។ ពាក្យថា **ជីវ្ហា** ដោយព្យញ្ជនៈ សំដៅដល់អណ្តាត ដោយបរមត្ថសំដៅដល់ **ជីវ្ហាបសាទ** សំរាប់ប៉ះខ្ទប់នឹងរសអាហារ ។

# លក្ខណាទិចតុកៈរបស់ជីវ្ហាវិញ្ញាណ

**-ជីវ្ហាសន្និស្សិត រសវិជានន លក្ខណំ** មានជីវ្ហាបសាទ ជាទីអាស្រ័យ ហើយដឹងនូវរសជាលក្ខណៈ ។

**-រសមត្តារម្មណ រសំ** មានអារម្មណ៍ត្រឹមតែរស ជាកិច្ច។

| | |
|---|---|
| **-រសាភិមុខភាវ បច្ចុប្បដ្ឋានំ** | មានមុខតម្រង់ឆ្ពោះទៅទល់នឹងរស ជាអាការប្រាកដ ។ |
| **-រសារម្មណាយ កិរិយាមនោធាតុយា អបគមន បទដ្ឋានំ** | មានការប្រាសទៅនៃមនោធាតុ អហេតុកកិរិយាចិត្ត ដែលមានរសជាអារម្មណ៍ជាហេតុជិត ។ |

**៥.កាយវិញ្ញាណ** ជាអហេតុកចិត្ត កើតឡើងដើម្បី ទទួលផលរបស់អកុសលកម្ម ដែលបានធ្វើទុកមក ធ្វើឲ្យបានពាល់ត្រូវផោដ្ឋព្វៈជាអនិដ្ឋារម្មណ៍ ។ ពាក្យថា **កាយៈ** ដោយព្យញ្ជនៈ សំដៅដល់រាងកាយ ដោយបរមត្ថសំដៅដល់ **កាយបសាទរូប** សំរាប់ប៉ះខ្ទប់នឹងធាតុ ៣ វៀរអាបោធាតុ គឺប៉ះខ្ទប់នឹង រឹងទន់ ក្តៅត្រជាក់ តឹងញ៉ររ ដែលហៅថា **ផោដ្ឋព្វៈ** ។

ការដែលកាយវិញ្ញាណ កើតព្រមដោយទុក្ខវេទនា ឬសុខវេទនានោះ រមែងទៅតាមសភាវៈ ព្រោះសភាវៈធម៌ដែលប៉ះខ្ទប់នឹងកាយនោះ បានដល់ មហាភូតរូប ៣ គឺធាតុដីមានលក្ខណៈរឹង ឬ ទន់, ធាតុភ្លើងមានលក្ខណៈក្តៅ ឬ ត្រជាក់ , ធាតុខ្យល់មានលក្ខណៈញ៉ររឬតឹង ។ កាលណាធាតុទាំង ៣ នេះណាមួយប៉ះខ្ទប់នឹងកាយ-បសាទរូប ដែលជាឧបាទាយរូប ហើយប៉ះខ្ទប់នឹងមហាភូតរូប (ដូច

ជាគញ្ជាត់សំឡីត្រង់ប្រហោងពេញ) ក៏ជាហេតុធ្វើឲ្យទុក្ខ ឬ សុខកើតឡើង មិនមែនជាឧបេក្ខាវេទនា ។

# លក្ខណាទិចតុកៈរបស់កាយវិញ្ញាណ

**-កាយសន្និស្សិត ផោដ្ឋព្វវិជាននលក្ខណំ** មានកាយបសាទ ជាទីអាស្រ័យ ហើយដឹងនូវផោដ្ឋព្វៈជាលក្ខណៈ

**- ផោដ្ឋព្វមត្តារម្មណ រសំ** មានអារម្មណ៍ ត្រឹមតែផោដ្ឋព្វៈជាកិច្ច ។

**- ផោដ្ឋព្វាភិមុខភាវ បច្ចុប្បដ្ឋានំ** មានមុខតម្រង់ឆ្ពោះទៅទល់នឹងផោដ្ឋព្វៈ ជាអាការប្រាកដ ។

**-ផោដ្ឋព្វារម្មណាយ កិរិយាមនោធាតុយា អបគមន បទដ្ឋានំ** មានការប្រាសទៅនៃមនោធាតុ អហេតុកកិរិយាចិត្ត ដែលមានផោដ្ឋព្វៈជាអារម្មណ៍ ជាហេតុជិត ។

**៦.ឧបេក្ខា មនោធាតុអហេតុកវិបាកចិត្ត ឬ ឧបេក្ខា-សហគត សម្បដិច្ឆន្នចិត្ត** មកពីពាក្យថា **សំ + បដិ + ឥច្ឆន្និ** ។

**សំ** = ព្រម, **បដិ** = ចំពោះ, **ឥច្ឆន្តិ** = ប្រាថ្នា ប្រែថា ចិត្តព្រមទទួល គឺព្រមទទួលចំពោះអារម្មណ៍តពីបញ្ចវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ទោះជាអកុសលវិបាកក្តី ឬ កុសលវិបាកអហេតុកក្តី ។

ចិត្តនេះ **ជាមនោធាតុ** គឺ ធាតុដឹងអាស្រ័យហទយវត្ថុ ទើបកើត ។ ដែលឈ្មោះថា " **ធាតុ** " ព្រោះអត្ថថាសូន្យ គឺ សូន្យចាកសត្វបុគ្គលជាដើម ។

# លក្ខណាទិចតុករបស់ ឧបេក្ខាសហគតមនោធាតុអហេតុកវិបាកចិត្ត

| | |
|---|---|
| **-ចក្ខុវិញ្ញាណាទិនំ អនន្តរំ រូបាទីវិជាននលក្ខណា** | មានការដឹងច្បាស់នូវអារម្មណ៍ ក្នុងលំដាប់នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ជាលក្ខណៈ។ |
| **-រូបាទិ សម្បដិច្ឆន្ន រសា** | មានការទទួលអារម្មណ៍មានរូបជាដើម ជាកិច្ច ។ |
| **-តថភាវ បច្ចុប្បដ្ឋានា** | មានសភាពយ៉ាងនោះឯង គឺ សម្បដិច្ឆន្នៈ ជាអាការប្រាកដ។ |

**-ចក្ខុវិញ្ញាណាទិ អបគមន បទដ្ឋានា** មានការប្រាសទៅនៃចក្ខុវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ជាហេតុជិត ។

**៧.ឧបេក្ខាសហគត មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ឬ ឧបេក្ខាសហគត សន្តីរណចិត្ត** ប្រែថា ចិត្តពិចារណាអារម្មណ៍ ឬ សាកសួរអារម្មណ៍ ។ ជាអហេតុកវិបាកចិត្តធ្វើកិច្ចពិចារណាអារម្មណ៍ដែលកើតឡើងតាមទ្វារទាំង ៦ ។

ម្យ៉ាងទៀត **ឧបេក្ខាសហគត មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ឬ ឧបេក្ខាសហគត សន្តីរណចិត្ត** នេះធ្វើកិច្ចបាន ៥ គឺ :

**១-បដិសន្ធិកិច្ច** ធ្វើកិច្ច កើតក្នុងភពថ្មី ។

**២-ភវង្គកិច្ច** ធ្វើកិច្ច រក្សាភព ។

**៣-ចុតិកិច្ច** ធ្វើកិច្ច ឃ្លាតចាកភព ។

**៤-សន្តីរណកិច្ច** ធ្វើកិច្ច ពិចារណាអារម្មណ៍ ។

**៥-តទាលម្ពណកិច្ច** ធ្វើកិច្ច ទទួលអារម្មណ៍តពីជវន៍ ។

# លក្ខណាទិចតុកៈ
# របស់ឧបេក្ខាសហគត
# មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត

| | |
|---|---|
| -អហេតុកវិបាកានន្តរំ ឆឡារម្មណវិជាននលក្ខណា | មានការដឹងច្បាស់នូវអារម្មណ៍ ៦ ក្នុងលំដាប់នៃសម្បដិច្ឆនចិត្ត ជាលក្ខណៈ។ |
| -សន្តីរណាទិ រសា | មានការពិចារណា អារម្មណ៍ ជាដើម ជារស ។ |
| -តថាភាវ បច្ចុប្បដ្ឋានា | មានសភាពយ៉ាងនោះឯង គឺសន្តីរណៈ ជាអាការប្រាកដ ។ |
| -ហទយវត្ថុ បទដ្ឋានា | មានហទយវត្ថុ ជាហេតុជិត ។ |

# តារាងអកុសលវិបាកចិត្ត ៧

**អកុសលវិបាកចិត្ត**

- ឧបេក្ខាសហគត
  - ចក្ខុវិញ្ញាណ ១
  - សោតវិញ្ញាណ ១
  - ឃានវិញ្ញាណ ១
  - ជិវ្ហាវិញ្ញាណ ១
- ទុក្ខសហគត
  - កាយវិញ្ញាណ ១
- ឧបេក្ខាសហគត
  - មនោធាតុអហេតុក-អកុសលវិបាកចិត្ត ឬ សម្បដិច្ឆន្នចិត្ត ១ ។
  - មនោវិញ្ញាណធាតុ-អហេតុកអកុសលវិបាកចិត្ត ឬ សន្តីរណចិត្ត១ ។

# អហេតុកកុសលវិបាក ៨ ដួង

**១-ឧបេក្ខាសហគត ចក្ខុវិញ្ញាណ** ឃើញនូវឥដ្ឋារម្មណ៍ គឺ រូបជាទីប្រាថ្នា ព្រមដោយឧបេក្ខាវេទនា ។

**២-ឧបេក្ខាសហគត សោតវិញ្ញាណ** ឮនូវឥដ្ឋារម្មណ៍ គឺ សំឡេងជាទីប្រាថ្នា ព្រមដោយឧបេក្ខាវេទនា ។

**៣-ឧបេក្ខាសហគត ឃានវិញ្ញាណ** ធុំនូវឥដ្ឋារម្មណ៍ គឺ ក្លិនជាទីប្រាថ្នា ព្រមដោយឧបេក្ខាវេទនា ។

**៤-ឧបេក្ខាសហគត ជិវ្ហាវិញ្ញាណ** ដឹងនូវឥដ្ឋារម្មណ៍ គឺ រសជាទីប្រាថ្នា ព្រមដោយឧបេក្ខាវេទនា ។

**៥.សុខសហគត កាយវិញ្ញាណ** ដឹងនូវឥដ្ឋារម្មណ៍ គឺ ផោដ្ឋព្វៈជាទីប្រាថ្នា ព្រមដោយសុខវេទនា ។

**៦.ឧបេក្ខាសហគត មនោធាតុអហេតុកកុសលវិបាក** ឬ **ឧបេក្ខាសហគត សម្បដិច្ឆន្នៈ** ចិត្តទទួលនូវឥដ្ឋារម្មណ៍ទាំង ៥ ទ្វារ ព្រមដោយឧបេក្ខាវេទនា ។

**៧.ឧបេក្ខាសហគត មនោវិញ្ញាណធាតុអហេតុកកុសលវិបាក** ឬ **ឧបេក្ខាសហគត សន្តីរណៈ** ចិត្តពិចារណានូវឥដ្ឋារម្មណ៍ទាំង ៦ ទ្វារ ព្រមដោយសោមនស្សវេទនា ។

**៨.សោមនស្សសហគត មនោវិញ្ញាណធាតុអហេតុកកុសលវិបាក ឬ សោមនស្សសហគត សន្តីរណៈ** ចិត្តពិចារណានូវអតិឥដ្ឋារម្មណ៍ទាំង ៦ ទ្វារ ព្រមដោយសោមនស្សវេទនា ។

កាមាវចរកុសលវិបាកមាន ១៦ គឺ អហេតុកកុសលវិបាក ៨ និងសហេតុកកុសលវិបាក ឬ មហាវិបាក ៨ ។

ចំពោះអហេតុកកុសលវិបាក ៨ ដួងនេះ កើតពីចេតនាក្នុងមហាកុសលចិត្ត ដែលបានធ្វើទុកហើយក្នុងអតីតជាតិ ឬក្នុងបច្ចុប្បន្នជាតិ ។ បើចេតនាធ្វើកុសលនោះមានកម្លាំងខ្សោយ ឲ្យផលក្នុងបវត្តិកាល ។ អហេតុកកុសលវិបាក ៨ ដួងនេះ កើតឡើងទទួលអារម្មណ៍តាមបញ្ចទ្វារ ទំនងដូចនឹងអកុសលវិបាកចិត្ត ៧ ដួងនោះដែរ ខុសគ្នាត្រង់បានទទួលឥដ្ឋារម្មណ៍ជាទីប្រាថ្នាប៉ុណ្ណោះ ព្រោះជាផលរបស់កុសល ទើបធ្វើឲ្យឃើញរូប(ពណ៌) ដែលល្អជាទីប្រាថ្នា ។

ម្យ៉ាងទៀត អហេតុកកុសលវិបាក ៨ ដួងនេះ លើសអកុសលវិបាក ១ ដួង គឺ សោមនស្សសន្តីរណៈ ។ សន្តីរណៈដែលប្រកបព្រមដោយសោមនស្សវេទនានេះ ធ្វើកិច្ចនាទី ពិចារណាអារម្មណ៍ដែលជាទីប្រាថ្នាដ៏ក្រៃលែង តពីសម្បដិច្ឆន្នចិត្ត ដែលជាផលរបស់កុសលកម្មដែលល្អយ៉ាងក្រៃលែង ។

អតិឥដ្ឋារម្មណ៍ គឺ អារម្មណ៍ជាទីប្រាថ្នាដ៏ក្រៃលែង បានដល់

អារម្មណ៍ដូចជា សរីរៈរបស់ព្រះពុទ្ធ សូរសៀងរបស់ព្រះពុទ្ធ ព្រះភិក្ខុសង្ឃ ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក អាចជាអតិឥដ្ឋារម្មណ៍សម្រាប់បុគ្គលអ្នកមានសទ្ធាមិនកំរើកបាន ។

អតិឥដ្ឋារម្មណ៍ក្នុងភូមិមនុស្ស មានតិចជាងភូមិទេវតា ព្រោះទេវតាជាភូមិដែលមានអារម្មណ៍ប្រណីត ៕

# តារាងអហេតុកកុសលវិបាក ៨

**អហេតុកកុសលវិបាក ៨**

- -ឧបេក្ខាសហគត
  - -ចក្ខុវិញ្ញាណ ១
  - -សោតវិញ្ញាណ ១
  - -ឃានវិញ្ញាណ ១
  - -ជីវ្ហាវិញ្ញាណ ១
- -សុខសហគត
  - -កាយវិញ្ញាណ ១
- -ឧបេក្ខាសហគត
  - -មនោធាតុអហេតុកកុសលវិបាកចិត្ត ឬ សម្បដិច្ឆន្នចិត្ត ១ ។
  - -មនោវិញ្ញាណធាតុអហេតុកកុសលវិបាក ឬ សន្តីរណចិត្ត ១ ។
- -សោមនស្សសហគត
  - -មនោវិញ្ញាណធាតុអហេតុកកុសលវិបាកចិត្ត ឬ សន្តីរណចិត្ត ១ ។

# អហេតុកកិរិយាចិត្ត ៣ ដួង

**១. ឧបេក្ខាសហគត មនោធាតុអហេតុកកិរិយា** ឬ **ឧបេក្ខាសហគត បញ្ចទ្វារាវជ្ជនៈ** ចិត្តរំពឹង ឬនឹកដល់អារម្មណ៍ទាំង ៥ ទ្វារ ព្រមដោយឧបេក្ខាវេទនា ។

**២. ឧបេក្ខាសហគត មនោវិញ្ញាណធាតុអហេតុក-កិរិយា** ឬ **ឧបេក្ខាសហគត មនោទ្វារាវជ្ជនៈ** ចិត្តរំពឹង ឬ នឹកដល់អារម្មណ៍ដែលមកកាន់គន្លងនៃមនោទ្វារ ព្រមដោយឧបេក្ខាវេទនា។

**៣. សោមនស្សសហគត មនោវិញ្ញាណធាតុអហេតុក-កិរិយា** ឬ **សោមនស្សសហគត ហសិតុប្បាទ** ចិត្តរីករាយព្រមដោយសោមនស្សវេទនារបស់ព្រះអរហន្ត ៕

**(១).ឧបេក្ខាសហគត មនោធាតុអហេតុកកិរិយា** ឬ **បញ្ចទ្វារាវជ្ជនៈ( បញ្ច + ទ្វារ + អាវជ្ជនំ )** ប្រែថា ពិចារណាអារម្មណ៍ក្នុងបញ្ចទ្វារ គឺ ទ្វារ ៥ ។ ជាកិរិយាមនោធាតុ កាលបើបញ្ចទ្វារាវជ្ជនចិត្តមិនកើតសិនទេ វិញ្ញាណ ៥ ក៏មិនអាចកើតបាន ។ កាលណាចិត្តជាអាវជ្ជនៈ ទទួលអារម្មណ៍កើតរលត់ ហើយចិត្តដទៃ ។

ក៏កើតរលត់ជាប់បន្តគ្នាទៅរហូតដល់អស់អាយុនៃអារម្មណ៍ ដែលកើតឡើងម្តង នេះហៅថា **ចិត្តនិយាម** គឺ សេចក្តីពិតប្រាកដនៃចិត្ត។ បញ្ចទ្វារាវជ្ជនចិត្តនេះ ជាមនោធាតុជាកិរិយាអហេតុកចិត្ត កើតឡើងព្រោះអារម្មណ៍ ដែលជារូបមកប៉ះខ្ទប់នឹងបសាទរូបជាបច្ច័យ ។

**បញ្ចទ្វារាវជ្ជនចិត្ត :**

-បើទទួលអារម្មណ៍តាមផ្លូវភ្នែក ក៏ហៅថា **ចក្ខុទ្វារាវជ្ជនៈ**
-បើទទួលអារម្មណ៍តាមផ្លូវត្រចៀក ក៏ហៅថា **សោតទ្វារាវជ្ជនៈ**
-បើទទួលអារម្មណ៍តាមផ្លូវច្រមុះ ក៏ហៅថា **ឃានទ្វារាវជ្ជនៈ**
-បើទទួលអារម្មណ៍តាមផ្លូវអណ្តាត ក៏ហៅថា **ជីវ្ហាទ្វារាវជ្ជនៈ**
-បើទទួលអារម្មណ៍តាមផ្លូវកាយ ក៏ហៅថា **កាយទ្វារាវជ្ជនៈ**
រួមទាំង ៥ ទ្វារ ហៅថា **បញ្ចទ្វារាវជ្ជនចិត្ត ៕**

# លក្ខណាទិចតុក:របស់ ឧបេក្ខាសហគតមនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត

- **ចក្ខុវិញ្ញាណាទិ បុរេចរ** មានការនាំមុខនៃវិញ្ញាណ មាន

**រូបាទិវិជាននលក្ខណា** ចក្ខុវិញ្ញាណជាដើម ហើយដឹងច្បាស់នូវអារម្មណ៍ មានរូបជាដើម ជាលក្ខណៈ ។

**- អាវជ្ជនរសា** មានការរំពឹង ជាកិច្ច ។

**- រូបាទិ អភិមុខីភាវ បច្ចុប្បដ្ឋានា** ជាធម្មជាតិមានមុខតម្រង់ឆ្ពោះទៅរកអារម្មណ៍ មានរូបជាដើម ជាអាការប្រាកដ ។

**- ភវង្គវិច្ឆេទ បទដ្ឋានា** មានការដាច់ខ្សែភវង្គជាហេតុជិត។

**(២).ឧបេក្ខាសហគត មនោវិញ្ញាណធាតុអហេតុកកិរិយា** ឬ **មនោទ្វារាវជ្ជនចិត្ត** ជាមនោវិញ្ញាណធាតុ ជាអហេតុកកិរិយាចិត្ត ។ ពាក្យថា **មនោទ្វារាវជ្ជនំ (មនោ+ទ្វារ+អាវជ្ជនំ) មនោ** = ចិត្ត , **ទ្វារ** = ផ្លូវ , **អាវជ្ជនំ** = ការពិចារណា ប្រែថា ការពិចារណាតាមផ្លូវមនោទ្វារ ។

កាលណាអារម្មណ៍តាមផ្លូវបញ្ចទ្វារ មានចក្ខុទ្វារជាដើមរលត់ហើយ មនោទ្វារាវជ្ជនចិត្តក៏ដឹងអារម្មណ៍នោះត ។

មនោទ្វារាវជ្ជនចិត្ត អាចដឹងបញ្ញត្តិផ្សេង ៗ បានច្រើនណាស់

ដឹងអារម្មណ៍បានទាំងអនិដ្ឋារម្មណ៍ ទាំងឥដ្ឋារម្មណ៍ ដឹងរូបដទៃទៀតក៏បាន ទាំងចិត្ត ចេតសិក និង និព្វានក៏បាន ។

កាលណាមនោទ្វារាវជ្ជនចិត្តនេះ ធ្វើកិច្ចស្រេចហើយ ចិត្តដែលកើតតពីនោះ ជាកុសលចិត្តក៏មាន ជាអកុសលចិត្តក៏មាន ជាមហាកិរិយាចិត្តក៏មាន ។ កិច្ចរបស់មនោទ្វារាវជ្ជនៈនេះ គឺពិចារណាអារម្មណ៍ទាំង ៦ និងធ្វើកិច្ចកំណត់អារម្មណ៍តាមផ្លូវបញ្ចទ្វារ ហៅថាវោដ្ឋវនចិត្ត ។

# លក្ខណាទិចតុកៈរបស់ ឧបេក្ខាសហគត មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្ត ឬ មនោទ្វារាវជ្ជនចិត្ត

**-ឆឡារម្មណាវិជានន លក្ខណា** មានការដឹងច្បាស់អារម្មណ៍ ៦ ជាលក្ខណៈ ។

**-កិច្ចវសេន បញ្ចទ្វារមនោទ្វារេសុ វោដ្ឋវនាវជ្ជនរសា** មានវោដ្ឋវនៈក្នុងបញ្ចទ្វារ និងអាវជ្ជនៈក្នុងមនោទ្វារ ដោយអំណាចនៃកិច្ច ជារស ។

**-តថាភាវ បច្ចុប្បដ្ឋានា** មានសភាពជាយ៉ាងនោះឯង គឺ វោដ្ឋវនៈ និង អាវជ្ជនៈ ជាអាការប្រាកដ ។

**-អហេតុកវិបាកមនោវិញ្ញាណធាតុ ភវង្គានំ អញ្ញតរាបគម បទដ្ឋានា** មានការប្រាសទៅនៃសន្តីរណៈ (ក្នុងវោដ្ឋវនកាល) និង ភវង្គ (ក្នុងអាវជ្ជនកាល)ណាមួយជាហេតុជិត ។

**(៣). សោមនស្សសហគត មនោវិញ្ញាណធាតុ-អហេតុកកិរិយា ឬ ហសិតុប្បាទចិត្តំ ( ហសិត + ឧប្បាទ + ចិត្តំ )**

**ហសិត** = រីករាយ ញញឹមញញែម ។

**ឧប្បាទ** = ការកើតឡើង ។

ហសិតុប្បាទចិត្តនេះ ជាចិត្តរបស់ព្រះអរហន្ត កើតព្រមនឹងសោមនស្សវេទនា ជាចិត្តដែលធ្វើរូបឲ្យញញឹមញញែម ដូចរឿងព្រះមោគ្គល្លានឃើញប្រេតដែលកំពុងទទួលនូវទុក្ខវេទនា ការឃើញនោះដោយកិរិយាអភិញ្ញាចិត្ត ដែលប្រព្រឹត្តទៅព្រមនឹងការពិចារណាថា សភាពយ៉ាងនេះលែងកើតមានដល់លោកតទៅទៀតឡើយ ហើយ

ហសិតុប្បាទចិត្តក៏កើតឡើង ។

ក្នុងសុពោធាលង្ការ បានពោលពីការសើច ញញឹមញញែម មាន ៦ យ៉ាង គឺ :

**(១)-សិតៈ** ញញឹមមិនឃើញធ្មេញ ជាការញញឹមនៃព្រះពុទ្ធជាម្ចាស់ ។

**(២)-ហសិតៈ** ញញឹមល្មមឃើញធ្មេញ ជាការញញឹមរបស់ព្រះអរហន្ត ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន និង បុថុជ្ជន ។ ការញញឹមនេះ ក្រៅពីព្រះអរហន្តហើយ រមែងប្រកបដោយហេតុបុណ្យ ឬ ដោយហេតុបាប ។

**(៣)-វិហសិតៈ** សើចឮសំឡេងស្រាល ៗ កើតនឹងចិត្តរបស់បុថុជ្ជន និង ព្រះអរិយៈ ៣ ពួក ( វៀរព្រះអរហន្ត ) ។

**(៤)-អតិហសិតៈ** សើចឮសំឡេងខ្លាំង កើតចំពោះបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី ។

**(៥)-ឧបហសិតៈ** សើចរហូតដល់កាយញ័រ ជាការសើចរបស់បុថុជ្ជន ។

**(៦)-អវហសិតៈ** សើចរហូតដល់ហូរទឹកភ្នែក ជាការសើចរបស់

បុថុជ្ជន ។

**សិតៈ** និង **ហសិតៈ** ជាការញញឹមរបស់ព្រះអរហន្ត ជាចិត្តញញឹមដោយមិនប្រកាន់មាំក្នុងអារម្មណ៍ មិនដូចជាការសើចរបស់បុគ្គលដទៃៗទៀតឡើយ ចិត្តនេះទើបមានកម្លាំងខ្សោយ ជាចិត្តពិសេសហៅថា **ហសិតុប្បាទចិត្ត** ។ ការដែលចិត្តមានកម្លាំងតិចនេះឯងទើបជាអហេតុកចិត្ត ចំណែកចិត្តសើចដទៃៗជាសហេតុកចិត្ត ៕

# លក្ខណាទិចតុកៈរបស់ សោមនស្សសហគត មនោវិញ្ញាណធាតុ-អហេតុកកិរិយាចិត្ត ឬ ហសិតុប្បាទចិត្ត

| | |
|---|---|
| **-ឆឡារម្មណវិជាននលក្ខណា** | មានការដឹងច្បាស់នូវអារម្មណ៍ ៦ ជាលក្ខណៈ ។ |
| **-កិច្ចវសេន អរហតំ អនុឡារេសុ វត្ថុសុ ហសិតុប្បាទនរសា** | មានការញញឹមក្នុងវត្ថុទាំងឡាយដែលមិនជាល្អអ្វីទេ កើតមានដល់ ព្រះអរហន្តទាំងឡាយដោយអំណាចនៃកិច្ច ជារស ។ |

-តថាភាវ បច្ចុប្បដ្ឋានា មានសភាពជាយ៉ាងនោះឯង គឺហសិតុប្បាទជាអាការប្រាកដ ។

-ឯកន្តតោ ហទយវត្ថុ បទដ្ឋានា មានហទយវត្ថុប៉ុណ្ណោះ ជាហេតុជិត ៕

# តារាងអហេតុកកិរិយាចិត្ត ៣ ដួង

អហេតុកកិរិយា ៣
- -ឧបេក្ខាសហគត
  - -មនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត ១ ។
  - -មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬ មនោទ្វារាវជ្ជនចិត្ត ១ ។
- -សោមនស្សសហគត
  - -មនោវិញ្ញាណធាតុអហេតុកកិរិយា-ចិត្ត ឬ ហសិតុប្បាទចិត្ត ១ ។

# តារាងអហេតុកចិត្ត ១៨ ដួង

## អកុសលវិបាកចិត្ត ៧ ដួង

| | | | | | | |
|---|---|---|---|---|---|---|
| ឧ. | ឧ. | ឧ. | ឧ. | ទុក្ខ | ឧ. | ឧ. |
| ចក្ខុ. | សោ. | ឃា. | ជីវ្ហា | កាយ | សម្ប. | សន្តី. |

## អហេតុកកុសលវិបាកចិត្ត ៨ ដួង

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឧ. | ឧ. | ឧ. | ឧ. | សុខ | ឧ. | ឧ. | សោ. |
| ចក្ខុ. | សោ. | ឃា. | ជីវ្ហា. | កាយ | សម្ប. | សន្តី. | សន្តី. |

## អហេតុកកិរិយាចិត្ត ៣ ដួង

| | | |
|---|---|---|
| ឧ. | ឧ. | សោ. |
| បញ្ចទ្វា. | វោដ្ឋ. | ហសិ. |

អហេតុកចិត្ត ១៨ ដួងនេះ សង្គ្រោះចូលក្នុងអសង្ខារិក ព្រោះកើតឡើងឯងៗ ដោយអាស្រ័យឧប្បត្តិហេតុ គឺ ហេតុដែលប្រជុំគ្នាកើតឡើង សូម្បីមានអ្នកដឹកនាំក៏ដោយ បើឧប្បត្តិហេតុមិនគ្រប់អង្គទេ ចិត្តមានចក្ខុវិញ្ញាណជាដើម ក៏រមែងមិនកើតដែរ ។

# ឧប្បត្តិហេតុនៃអហេតុកចិត្ត

**ឧប្បត្តិហេតុ** គឺហេតុកើតឡើងនៃអហេតុកចិត្ត ១៨ ដួង ។ ក្នុងអដ្ឋកថា អដ្ឋសាលិនី សម្តែងទុកថា :

## ១.ហេតុឲ្យកើតចក្ខុវិញ្ញាណ ២ ដួង គឺ :

**-អសម្ភិន្នត្តា ចក្ខុស្ស** ព្រោះចក្ខុបសាទមិនទាន់បែកធ្លាយ ។
**-អាបាថគតត្តា រូបានំ** ព្រោះរូបមកកាន់ដល់គន្លង ។
**-អាលោកសន្និស្សិតំ** អាស្រ័យដោយពន្លឺ ។
**-មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្តាបច្ច័យទាំង ៤ នោះ ចក្ខុនៃអ្នកស្លាប់ក្តី ចក្ខុនៃអ្នកមានជីវិតដែលរលត់ក្តី ឬចក្ខុដែលត្រូវទឹកប្រមាត់ ឬដែលត្រូវស្លេស្ម ឬលោហិតបាំងបិទក្តី ដែលមិនអាចជាបច្ច័យដល់ចក្ខុវិញ្ញាណ ឈ្មោះ

ថា បែកធ្លាយហើយ ប៉ុន្តែបើនៅអាចជាបច្ច័យបាន ឈ្មោះថា មិនទាន់បែកធ្លាយទេ ។

សូម្បីចក្ខុបសាទមិនទាន់បែកធ្លាយក៏ដោយ ប៉ុន្តែបើរូបារម្មណ៍ ( ពណ៌ ) នៅមិនទាន់មកកាន់គន្លងនៃចក្ខុបសាទទេ ចក្ខុវិញ្ញាណ ក៏កើតមិនបាន ។

បើសិនរូបារម្មណ៍នោះមកកាន់គន្លងហើយ ប៉ុន្តែបច្ច័យដែលអាស្រ័យ គឺពន្លឺមិនមាន ចក្ខុវិញ្ញាណក៏កើតមិនបានដែរ ។

ប្រសិនបើពន្លឺដែលជាបច្ច័យនោះមាន ប៉ុន្តែកិរិយាមនោធាតុមិនញ៉ាំងភវង្គឲ្យផ្លាស់ប្តូរទៅទេ ចក្ខុវិញ្ញាណក៏កើតមិនបាន ។

កាលណាកិរិយាមនោធាតុ ញ៉ាំងភវង្គឲ្យផ្លាស់ប្តូរទៅបាន , ចក្ខុវិញ្ញាណទើបកើតឡើងធ្វើទស្សនកិច្ច(ឃើញរូប) ចក្ខុវិញ្ញាណកាលកើតឡើង រមែងកើតឡើងព្រមដោយសម្បយុត្តធម៌ទាំងឡាយ ដោយពិត ដូច្នេះហើយទើបពោលថា ចក្ខុវិញ្ញាណកើតព្រោះអាស្រ័យបច្ច័យ ៤ ប៉ុណ្ណោះ ។

## ២.ហេតុឲ្យកើតសោតវិញ្ញាណ ២ ដួង គឺ :

**-អសម្ភិន្នត្តា សោតស្ស** ព្រោះសោតប្បសាទមិនទាន់បែកធ្លាយ ។
**-អាបាថគតត្តា សទ្ទានំ** ព្រោះសំឡេងមកកាន់គន្លង ។

**-អាកាសសន្និស្សិតំ** អាស្រ័យអាកាស (លំហ) ។
**-មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យអាកាស គឺ សោតវិញ្ញាណនោះ បានអាស្រ័យនូវអាកាសទើបកើតឡើង វៀរនូវអាកាសហើយកើតមិនបាន ព្រោះកាលណាបុគ្គលបិទរន្ធត្រចៀកជិត សោតវិញ្ញាណក៏មិនអាចប្រព្រឹត្តទៅបាន ។ ពាក្យដែលក្រៅពីនេះសូមជ្រាបដោយន័យដែលបានពោលហើយ ក្នុងរឿងចក្ខុវិញ្ញាណ ។

## ៣.ហេតុឲ្យកើតឃានវិញ្ញាណ ២ ដួង គឺ :

**-អសម្ភិន្នត្តា ឃានស្ស** ព្រោះឃានបសាទ មិនទាន់បែកធ្លាយ ។
**-អាបាថគតត្តា គន្ធានំ** ព្រោះក្លិនមកកាន់គន្លង ។
**-វាយោសន្និស្សិតំ** អាស្រ័យវាយោ ។
**- មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្តាបច្ច័យទាំង ៤ នោះពាក្យថាអាស្រ័យ វាយោ គឺ កាលណាវាយោផាត់នូវក្លិន ចូលមកកាន់រន្ធច្រមុះនោះហើយ ឃានវិញ្ញាណទើបកើតឡើង ប្រសិនបើវាយោ គឺ ខ្យល់មិនមាន ឃានវិញ្ញាណ ក៏មិនអាចប្រព្រឹត្តទៅបាន ។

# ៤.ហេតុឲ្យកើតជីវ្ហាវិញ្ញាណ ២ ដួង គឺ :

- **អសម្ភិន្នត្តា ជីវ្ហាយ** ព្រោះជីវ្ហាបសាទមិនទាន់បែកធ្លាយ ។
- **អាបាថគតត្តា រសានំ** ព្រោះរសមកកាន់គន្លង ។
- **អាបោសន្និស្សិតំ** អាស្រ័យអាបោ គឺ ទឹក ។
- **មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យអាបោ អាបោ គឺទឹកធ្វើឲ្យសើម ជីវ្ហាវិញ្ញាណទើបកើតឡើង វៀរនូវអាបោហើយកើតមិនបាន ព្រោះកាលណាបុគ្គលមានអណ្តាតស្ងួតស្ងួម្បីដាក់ខាទនីយៈត្រង់អណ្តាតនោះក៏ដោយ ជីវ្ហាវិញ្ញាណក៏មិនអាចប្រព្រឹត្តទៅបានដែរ ។

# ៥.ហេតុឲ្យកើតកាយវិញ្ញាណ ២ ដួង គឺ :

- **អសម្ភិន្នត្តា កាយស្ស** ព្រោះកាយបសាទ មិនទាន់បែកធ្លាយ ។
- **អាបាថគតត្តា ផោដ្ឋព្វានំ** ព្រោះផោដ្ឋព្វៈមកកាន់គន្លង ។
- **បថវីសន្និស្សិតំ** អាស្រ័យបថវី ។
- **មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្ដាបច្ច័យទាំង ៤ នោះ ពាក្យថាអាស្រ័យបឋវី គឺអាស្រ័យបឋវីដែលផ្គុំគ្នា គឺ កាយបសាទនោះឯងជាបច្ច័យទើបកាយវិញ្ញាណកើតឡើង វៀរនូវកាយបសាទហើយ កាយវិញ្ញាណក៏កើតមិនបានដែរ ព្រោះមហាភូតរូបជាអារម្មណ៍ខាងក្រៅ ប៉ះខ្ទប់នឹងកាយបសាទ ខាងក្នុងត្រង់កាយទ្វារ រមែងប៉ះខ្ទប់ត្រង់មហាភូតរូបដែលមានកាយប្បសាទជាបច្ច័យ ។

## ៦.ហេតុឲ្យកើតមនោធាតុ ៣ ដួង គឺ :

-មានបសាទ ៥ គឺ ចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយ

-មានអារម្មណ៍ ៥ គឺ រូប ជាដើមមកកាន់គន្ធង

-អាស្រ័យហទយវត្ថុ

-មានមនសិការជាហេតុ

**មនោធាតុ ៣ ដួង** គឺបញ្ចទ្វារាវជ្ជនចិត្ត ១ ដួង សម្បដិច្ឆន្នចិត្ត ២ ដួង ។ ចិត្ត ៣ ដួងនេះ ហៅថា **មនោធាតុ** ប្រែថាធាតុដឹង ។

មនោវិញ្ញាណធាតុ ជាចិត្តដែលមានអំណាច អាចដឹងអារម្មណ៍បានច្រើនជាងបញ្ចវិញ្ញាណ និង មនោធាតុ ។ ក្នុងអហេតុកចិត្តនេះ មានមនោវិញ្ញាណធាតុ ៥ ដួង គឺ មនោទ្វារាវជ្ជនចិត្ត ១ ដួង

សន្តីរណចិត្ត ៣ ដួង និង ហសិតុប្បាទចិត្ត ១ ដួង ។ តាមសេចក្តីពិត ចិត្តទាំងអស់ ៨៩ ដួង ឬ ១២១ ដួងនោះ វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង និង មនោធាតុ ៣ ដួងចេញ ហើយនៅសល់ចិត្ត ៧៦ ឬ ១០៨ ដួង ទាំងនេះជាមនោវិញ្ញាណធាតុ ។

## ៧.ហេតុឲ្យកើតមនោវិញ្ញាណធាតុ គឺ :

**-អសម្ភិន្នត្តា មនស្ស** ព្រោះមនោនៅមិនទាន់បែកធ្លាយ ។
**-អាបាថគតត្តា ធម្មានំ** ព្រោះធម៌ទាំងឡាយមកកាន់ដល់គន្លង។
**-វត្ថុសន្និស្សិតំ** អាស្រ័យវត្ថុ ។
**-មនសិការហេតុកំ** មានមនសិការជាហេតុ ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា **មនោ** បានដល់ភវង្គចិត្តនោះបែកធ្លាយហើយក្តី មានកម្លាំងខ្សោយមិនអាចជាបច្ច័យដល់អាវជ្ជនចិត្តបានក្តី ឈ្មោះថា បែកធ្លាយហើយ ប៉ុន្តែពេលដែលអាចជាបច្ច័យដល់អាវជ្ជនចិត្តបាន ឈ្មោះថា នៅមិនទាន់បែកធ្លាយទេ ។ ពាក្យថា **ព្រោះធម៌ទាំងឡាយមកកាន់គន្លង** បានដល់ធម្មារម្មណ៍មកកាន់គន្លង ពាក្យថា **អាស្រ័យហទយវត្ថុ** គឺអាស្រ័យបានតែហទយវត្ថុប៉ុណ្ណោះទើបកើតឡើង វៀរហទយវត្ថុហើយ ក៏មិន

កើត ។ បញ្ហានេះ ព្រះថេរៈលោកពោលសំដៅដល់បញ្ចវោការភព គឺភពដែលមានខន្ធ ៥ ។ ពាក្យថា **មានមនសិការជាហេតុ** អធិប្បាយថា កិរិយាមនោវិញ្ញាណធាតុ ញ៉ាំងភវង្គឲ្យផ្លាស់ប្តូរទៅសិន ទើបមនោវិញ្ញាណកើតឡើង ។

នេះជាការពណ៌នានូវការទទួលអារម្មណ៍ ដោយឧបនិស្សយ-ប្បច្ច័យ ជាប្រយោជន៍ មានត្រឹមប៉ុណ្ណេះ ៕

# កិច្ច ១៤ យ៉ាង
# របស់អហេតុកចិត្ត ១៨

| | | |
|---|---|---|
| **១.ចក្ខុវិញ្ញាណ** | **២ ដួង** | ធ្វើទស្សនកិច្ច(ការឃើញ) |
| **២.សោតវិញ្ញាណ** | **២ ដួង** | ធ្វើសវនកិច្ច(ការឮ) |
| **៣.ឃានវិញ្ញាណ** | **២ ដួង** | ធ្វើឃាយនកិច្ច(ការស្រូបយកក្លិន) |
| **៤.ជីវ្ហាវិញ្ញាណ** | **២ ដួង** | ធ្វើសាយនកិច្ច(ការជញ្ជក់រស) |
| **៥.កាយវិញ្ញាណ** | **២ ដួង** | ធ្វើផុសនកិច្ច(ការប៉ះពាល់) |
| **៦.សម្បដិច្ឆន្នចិត្ត** | **២ ដួង** | ធ្វើសម្បដិច្ឆន្នកិច្ច( ការទទួលនូវបញ្ចារម្មណ៍ ) ។ |

**៧.ឧបេក្ខាមនោវិញ្ញាណធាតុ អហេតុកវិបាកចិត្ត ឬ ឧបេក្ខា-សន្តីរណចិត្ត ២ ដួង** ធ្វើកិច្ច ៥ យ៉ាង :

**-បដិសន្ធិកិច្ច** (ការបន្តជាប់ក្នុងភពថ្មី) ។

**-ភវង្គកិច្ច** (ការរក្សាភព) ។

**-ចុតិកិច្ច** (ការឃ្លាតចាកភព) ។

**-សន្តីរណកិច្ច** (ការពិនិត្យពិចារណាអារម្មណ៍) ។

**-តទាលម្ពណកិច្ច** (ការទទួលអារម្មណ៍ពីជវនៈ) ។

**៨.សោមនស្សមនោវិញ្ញាណធាតុ អហេតុកវិបាកចិត្ត ឬ សោមនស្សសន្តីរណចិត្ត ១ ដួង** ធ្វើកិច្ច ២ គឺ:

**-សន្តីរណកិច្ច** (ពិនិត្យពិចារណាអារម្មណ៍) ។

**-តទាលម្ពណកិច្ច** (ការទទួលអារម្មណ៍ពីជវនៈ) ។

**៩.មនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង**

**-ធ្វើអាវជ្ជនកិច្ច** ( ទទួលបញ្ចារម្មណ៍ ) ។

**១០.មនោវិញ្ញាណធាតុអហេតុកកិរិយា ឬ មនោទ្វារាវជ្ជនចិត្ត ១ ដួង** ធ្វើកិច្ច ២ យ៉ាង:

**-អាវជ្ជនកិច្ច** (ទទួលអារម្មណ៍តាមមនោទ្វារ) ។

**-វោដ្ឋវនកិច្ច** (កំណត់អារម្មណ៍តាមបញ្ចទ្វារ) ។

**១១.សោមនស្សមនោវិញ្ញាណធាតុអហេតុកកិរិយា ឬហសិតុប្បាទចិត្ត ១ ដួង** ធ្វើជវនកិច្ច គឺ:

សេពនូវអារម្មណ៍ធ្វើឲ្យកើតនូវការញញឹមរបស់ព្រះអរហន្ត ។

# ទ្វាររបស់អហេតុកចិត្ត ១៨

**១.** ចក្ខុវិញ្ញាណ ២ ដួង អាស្រ័យកើតតាមចក្ខុទ្វារ ។

**២.** សោតវិញ្ញាណ ២ ដួង អាស្រ័យកើតតាមសោតទ្វារ ។

**៣.** ឃានវិញ្ញាណ ២ ដួង អាស្រ័យកើតតាមឃានទ្វារ ។

**៤.** ជីវ្ហាវិញ្ញាណ ២ ដួង អាស្រ័យកើតតាមជីវ្ហាទ្វារ ។

**៥.** កាយវិញ្ញាណ ២ ដួង អាស្រ័យកើតតាមកាយទ្វារ ។

**៦.** មនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង
**៧.** មនោធាតុអហេតុកវិបាកចិត្ត ឬ សម្បដិច្ឆន្នចិត្ត ២ ដួង
} អាស្រ័យកើតតាមបញ្ចទ្វារ ។

**៨.** មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត
ឬ មនោទ្វារាវជ្ជនចិត្ត ១ ដួង
**៩.** មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត
ឬ សន្តីរណចិត្ត ៣ ដួង
**១០.** សោមនស្សមនោវិញ្ញាណធាតុ-
អហេតុកកិរិយាចិត្ត ឬហសិតុប្បាទចិត្ត១ដួង

} អាស្រ័យកើតត្រង់ហទយវត្ថុ

# វត្ថុរបស់អហេតុកចិត្ត ១៨

**១.**ចក្ខុវិញ្ញាណ ២ ដួង អាស្រ័យកើតត្រង់ចក្ខុវត្ថុ ។
**២.**សោតវិញ្ញាណ ២ ដួង អាស្រ័យកើតត្រង់សោតវត្ថុ ។
**៣.**ឃានវិញ្ញាណ ២ ដួង អាស្រ័យកើតត្រង់ឃានវត្ថុ ។
**៤.**ជីវ្ហាវិញ្ញាណ ២ ដួង អាស្រ័យកើតត្រង់ជីវ្ហាវត្ថុ ។
**៥.**កាយវិញ្ញាណ ២ ដួង អាស្រ័យកើតត្រង់កាយវត្ថុ ។
**៦.**មនោធាតុអហេតុកវិបាកចិត្ត
ឬ សម្បដិច្ឆន្នចិត្ត ២
**៧.**មនោវិញ្ញាណធាតុអហេតុក-
វិបាកចិត្ត ឬសន្តីរណចិត្ត ៣ ដួង

} អាស្រ័យកើតត្រង់ហទយវត្ថុ

| | |
|---|---|
| **៨.** មនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង<br>**៩.** មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬ មនោទ្វារាវជ្ជនចិត្ត ១ ដួង<br>**១០.** សោមនស្សមនោវិញ្ញាណធាតុ-អហេតុកកិរិយាចិត្ត ឬហសិតុប្បាទចិត្ត ១ ដួង | អាស្រ័យកើតត្រង់ហទយវត្ថុ |

# អហេតុកចិត្ត ១៨ ជាវិញ្ញាណធាតុ ៧

ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង ជាវិញ្ញាណធាតុ ៥ ។

មនោធាតុអហេតុកវិបាកចិត្ត ឬ សម្បដិច្ឆន្នចិត្ត ២ ដួង មនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង ជាមនោធាតុ ១ ។

មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ឬ សន្តីរណចិត្ត ៣ ដួង មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬ មនោទ្វារាវជ្ជនចិត្ត ១ ដួង សោមនស្សមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬហសិតុប្បាទចិត្ត ១ ដួង ជាមនោវិញ្ញាណធាតុ ១ ។

# ចំណែកអហេតុកចិត្ត ១៨ ដោយន័យផ្សេងៗ

**១.ដោយជាតិ** ជាវិបាកជាតិ ១៥ កិរិយាជាតិ ៣

**២.ដោយភូមិ** ជាកាមាវចរភូមិ

-អហេតុកចិត្ត ១៨ កើតក្នុងភូមិដូចតទៅនេះ :

-ឃានវិញ្ញាណ ២ ជីវ្ហាវិញ្ញាណ ២ កាយ-វិញ្ញាណ ២ កើតក្នុងកាមភូមិ ១១

-ចក្ខុវិញ្ញាណ ២ សោតវិញ្ញាណ ២ មនោធាតុ-អហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត ១ មនោធាតុអហេតុកវិបាកចិត្ត ឬសម្បដិច្ឆន្នចិត្ត ២ មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ឬ សន្តីរណចិត្ត ៣ កើតបាន ២៦ ភូមិ គឺ កាមភូមិ ១១ រូបភូមិ ១៥

-មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្ត ឬ មនោទ្វារាវជ្ជនចិត្ត កើតបាន ៣០ ភូមិ

-សោមនស្សមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬ ហសិតុប្បាទចិត្ត ១ កើតបាន ២២

ភូមិ គឺកាមសុគតិភូមិ ៧ និងរូបភូមិ ១៥

**៣.ដោយវេទនា** ជាសុខវេទនា១ ទុក្ខវេទនា១ សោមនស្សវេទនា២ ឧបេក្ខាវេទនា ១៤

**៤.ដោយហេតុ** ជានហេតុ និងជាអហេតុកចិត្ត ១៨

**៥.ដោយសង្ខារ** សង្គ្រោះចូលក្នុងអសង្ខារិកចិត្តទាំង ១៨

**៦.ដោយសម្បយុត្ត** ជាវិប្បយុត្តទាំង ១៨

**៧.ដោយសោភណៈ** ជាអសោភណៈទាំង ១៨

**៨.ដោយឈាន** ជាអឈានចិត្តទាំង ១៨

**៩.ដោយលោកិយ** ជាលោកិយទាំង ១៨

**១០.ដោយកិច្ច** អហេតុកចិត្តធ្វើកិច្ចទាំង ១៤

**១១.ដោយអារម្មណ៍** អហេតុកចិត្ត១៨ ទទួលអារម្មណ៍បានទាំង៦

**១២.ដោយទ្វារ** អហេតុកចិត្ត ១៨ កើតបាន ៦ ទ្វារ

**១៣.ដោយវត្ថុ** អហេតុកចិត្ត ១៨ កើតត្រង់វត្ថុបាន ៦

**១៤.ដោយវិញ្ញាណធាតុ** អហេតុកចិត្ត ១៨ ជាវិញ្ញាណធាតុ ៧

( ចប់ អហេតុកចិត្ត ១៨ ដួង )

# បញ្ហាក្នុងអហេតុកចិត្ត ១៨

**១**.អហេតុកចិត្ត ១៨ ដួង ជាចិត្តដែលមិនមានហេតុ បើអ៊ីចឹងទេ មិនទាស់នឹងគោលនៃព្រះពុទ្ធសាសនា ដែលពោលថា " **យេធម្មា ហេតុប្បភវា** " ដែលប្រែថា ធម៌ទាំងឡាយមានហេតុជាដែនកើត ។ ល ។ ទៅហើយឬ ?

-មិនទាស់ទេ ព្រោះពាក្យថា អហេតុកចិត្តនោះ សំដៅដល់ចិត្តដែលមិនមានសម្បយុត្តហេតុ គឺ មិនមាន លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ កើតរួមជាមួយ មិនបានសំដៅដល់ហេតុឲ្យកើតឡើង ដែលហៅថា **ឧប្បត្តិហេតុ** គឺ ហេតុដែលឲ្យកើតឡើងនោះទេ ។

**២**.អហេតុកចិត្ត ( ចិត្តមិនមានហេតុប្រកប ) តើខុសពីសហេតុកចិត្ត ( ចិត្តដែលមានហេតុប្រកប ) យ៉ាងណា ?

-ខុសគ្នាត្រង់ អហេតុកចិត្តមានកម្លាំងខ្សោយ ចំណែកសហេតុកចិត្តជាចិត្តមានកម្លាំងខ្លាំង ដូចដើមឈើដែលមិនមានឫសកែវ និងដើមឈើមានឫសកែវ សេចក្ដីរឹងមាំ ក៏រមែងខុសគ្នាដូច្នោះឯង ។

**៣**.ក្នុងអហេតុកចិត្ត មានពាក្យថា ចិត្ត និង វិញ្ញាណ ។

ពាក្យថា ចិត្ត និង វិញ្ញាណ ផ្សេងគ្នាយ៉ាងណា ?

-បើនិយាយដោយលក្ខណៈ ដូចគ្នា គឺ ជាធម្មជាតិដឹងនូវអារម្មណ៍ ។ ដែលហៅថាវិញ្ញាណនោះ លោកហៅត្រង់ចិត្តដែលកើតតាមទ្វារ ដូចចិត្តដែលកើតត្រង់ចក្ខុទ្វារ ក៏ហៅថា ចក្ខុវិញ្ញាណជាដើម ។ ចំណែកពាក្យថា ចិត្តនោះ លោកប្រើជាទូទៅក្នុងការដឹងអារម្មណ៍ ដូចបាលីថា **វិជានន លក្ខណំ ចិត្តំ** ចិត្តមានការដឹងអារម្មណ៍ជាលក្ខណៈ ។

**៤**.ព្រោះហេតុអ្វី អហេតុកចិត្ត ១៨ ដួង ទើបមាន៣ពួក ?

-ព្រោះអហេតុកចិត្ត ១៨ មាន ៣ ពួក គឺ អកុសលវិបាកចិត្ត ៧ ដួង ដែលកើតឡើងជាផលរបស់អកុសលកម្ម ១ ពួក ។ អហេតុកកុសលវិបាកចិត្ត ៨ ដួង កើតពីកុសលកម្ម ១ ពួក និងអហេតុកកិរិយាចិត្ត ៣ ដួង មិនមែនជាចិត្តដែលជាអកុសល ។

-កុសលនិងវិបាក គឺ ជាចិត្តគ្រាន់តែជាការធ្វើប៉ុណ្ណោះ ១ ពួក ។

**៥**.អហេតុកចិត្ត ១៨ ដួង កាលបើចំណែកដោយវិញ្ញាណធាតុ ៧ តើចិត្តនោះមានទីអាស្រ័យកើត ដឹងអារម្មណ៍ ផ្សេងគ្នាយ៉ាងណា ?

វិញ្ញាណធាតុទាំងនោះ មានទីអាស្រ័យកើតផ្សេងគ្នា និងដឹង

អារម្មណ៍តិចច្រើនជាងគ្នាផ្សេងគ្នាដែរ គឺ វិញ្ញាណធាតុ ៥ អាស្រ័យបសាទទាំង ៥, មនោធាតុ ១ អាស្រ័យហទយវត្ថុ , មនោវិញ្ញាណធាតុ ១ អាស្រ័យហទយវត្ថុ ។ ចំណែកការដឹងអារម្មណ៍ផ្សេងគ្នា គឺ វិញ្ញាណធាតុដឹងអារម្មណ៍បានតិច , មនោធាតុដឹងអារម្មណ៍បានច្រើនជាងវិញ្ញាណធាតុ មនោវិញ្ញាណធាតុដឹងអារម្មណ៍បានច្រើនបំផុត ។

**៦**.ព្រោះហេតុអ្វី អកុសលវិបាកចិត្ត មិនហៅថា អហេតុកអកុសលវិបាកចិត្ត ដូចពាក្យថា អហេតុកកុសលវិបាកចិត្ត ?

-ព្រោះផលរបស់អកុសល ជាអហេតុកចិត្តតែម្យ៉ាង ចំណែកផលរបស់កុសល មានទាំងអហេតុកចិត្ត មានទាំងសហេតុកចិត្ត ។

ដើម្បីនឹងចែកផលរបស់កុសលនោះៗ ឲ្យដាច់ពីគ្នា ទើបលោកប្រើពាក្យថា អហេតុកកុសលវិបាក ។

**៧**.ក្នុងអហេតុកចិត្ត ១៨ ដួង មានវេទនាអ្វីខ្លះ ?

-មានឧបេក្ខាវេទនា ១៤ , មានទុក្ខវេទនា ១ , មានសុខវេទនា ១ , មានសោមនស្សវេទនា ២ ។

**៨**.អហេតុកចិត្ត ១៨ ដួង មានឧបេក្ខាវេទនា ១៤ ដួង កើតរួមនឹងចិត្តអ្វីខ្លះ ?

-ឧបេក្ខាវេទនា ១៤ កើតនឹងអហេតុកចិត្ត ១៤ ដួង គឺ ទ្វិបញ្ចវិញ្ញាណ ៨ ដួង , ( វៀរកាយវិញ្ញាណ ២ ) មនោធាតុ-

អហេតុកវិបាកចិត្ត ឬ សម្បដិច្ឆន្នចិត្ត ២ ដួង, ឧបេក្ខាមនោ-វិញ្ញាណធាតុអហេតុកវិបាកចិត្ត ឬ ឧបេក្ខាសន្តីរណចិត្ត ២ ដួង , មនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង , មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬមនោទ្វារាវជ្ជនចិត្ត ១ ដួង ។

**៩.**ព្រោះហេតុអ្វី សន្តីរណចិត្តផ្នែកកុសលវិបាកប្រកប នឹង វេទនា ២ គឺ ឧបេក្ខា និង សោមនស្ស ចំណែកសន្តីរណចិត្តផ្នែក អកុសលវិបាក ប្រកបតែនឹងឧបេក្ខាប៉ុណ្ណោះ ?

-ពីព្រោះវិបាកចិត្តដែលធ្វើសន្តីរណកិច្ចផ្សេងគ្នា គឺសន្តីរណ-ចិត្តផ្នែកកុសលវិបាក ធ្វើកិច្ចពិចារណាអារម្មណ៍ ដែលល្អយ៉ាងក្រៃលែង (អតិឥដ្ឋារម្មណ៍) និងអារម្មណ៍ល្អ មធ្យម (ឥដ្ឋារម្មណ៍) ។ ចំណែកសន្តីរណចិត្តផ្នែក អកុសលវិបាកនោះ មានការពិចារណា អារម្មណ៍មិនល្អ(អនិដ្ឋារម្មណ៍)តែម្យ៉ាង មិនមានអតិឥដ្ឋារម្មណ៍ទេ ។

**១០.**កាយវិញ្ញាណកុសលវិបាកនោះ មិនកើតព្រមនឹងសោម-នស្សវេទនា ព្រោះហេតុអ្វី ?

-ព្រោះសុខវេទនា ជាវេទនាតាមផ្លូវកាយ ឯសោមនស្ស-វេទនា ជាវេទនាតាមផ្លូវចិត្ត ។

**១១.**វិបាកដែលកើតពីលោភៈ ទោសៈ និង មោហៈ ជាហេតុ ធ្ងន់ខ្លះ ស្រាលខ្លះ ឲ្យកើតក្នុងអបាយភូមិ ។ ហេតុផ្សេងគ្នា ភូមិដែល

កើតក៏ផ្សេងគ្នា ខ្លះក៏រហូតដល់អនន្តរិយកម្ម តើដោយហេតុណា ទើបថា ចិត្តដែលធ្វើកិច្ចបដិសន្ធិ ថាជាឧបេក្ខាសន្តីរណអកុសលវិបាកចិត្តតែម្យ៉ាង ?

-ព្រោះឧបេក្ខាសន្តីរណអកុសលវិបាកនេះ មាននាទីធ្វើបដិសន្ធិកិច្ចក្នុងអបាយភូមិទាំងអស់ មិនថាកម្មនោះ ជាកម្មធ្ងន់ ឬស្រាលឡើយ ប្រៀបដូចវត្ថុមានទម្ងន់ ទោះធ្ងន់ក្តី ស្រាលក្តី កាលណាធ្លាក់ចុះ ក៏ត្រូវតែធ្លាក់ចុះមកដល់ផែនដីដូច្នោះ ។

**១២**.សត្វកើតក្នុងនរក តែងតែឃើញរូប ឮសំឡេង ធុំក្លិនលិទ្ធភ្លក្សរស ប៉ះពាល់ផោដ្ឋព្វៈដែលជាអនិដ្ឋារម្មណ៍ទាំងអស់ឬ ?

-សត្វនរកទាំងនោះ តែងទទួលតែផលរបស់អកុសលកម្មប៉ុណ្ណោះ ប៉ុន្តែមានពេលខ្លះ គ្រាខ្លះ ចក្ខុវិញ្ញាណកុសលវិបាកជាដើមរបស់ពួកសត្វនរកទាំងនោះតែងកើតបានដែរ ដូចគ្រាមួយពេលព្រះមោគ្គល្លានថេរៈចុះទៅប្រោសសត្វនរក គង់នៅលើត្របកផ្កា សម្តែងធម្មកថា ដល់ពួកសត្វនរក ពេលនោះចក្ខុវិញ្ញាណសុទ្ធសឹងជាកុសល-វិបាក ក៏កើតឡើងព្រោះឃើញព្រះថេរៈ ពេលឮសំឡេង សោតវិញ្ញាណកុសលវិបាកក៏កើតឡើង ពេលបានធុំក្លិនចីវររបស់លោក ( មានក្លិនចន្ទន៍ ព្រោះលោកអាស្រ័យក្នុងព្រៃឈើចន្ទន៍ )ឃានវិញ្ញាណកុសល-វិបាក ក៏កើតឡើង ពេលលោកបណ្តាលឲ្យធ្លាក់ភ្លៀងរំលត់ភ្លើងនរកសត្វ ទាំងនោះបានក្រេបផឹកទឹក ជីវ្ហាវិញ្ញាណកុសលវិបាក ក៏កើតឡើង

ពេលបណ្ដាលឲ្យខ្យល់បក់រហៀកៗ កាយវិញ្ញាណកុសលវិបាកក៏កើតឡើង ។

**១៣.**ពួកនាគ ពួកគ្រុឌក្ដី ពួកវិមានិកប្រេតក្ដី ពួកសេះ ដំរីមង្គលរបស់ស្ដេចចក្រពត្តិក្ដី សុទ្ធតែរស់នៅស្រួល ស៊ីស្រួល ថែមទាំងមានឫទ្ធិ មានអំណាចច្រើន តើវិបាកអ្វី ធ្វើបដិសន្ធិកិច្ចឲ្យកើតមក ?

-អកុសលវិបាកចិត្ត ធ្វើបដិសន្ធិកិច្ចឲ្យកើតមក ប៉ុន្ដែពួកខ្លះ មានការរស់នៅស្រួល ស៊ីស្រួល ក៏ព្រោះជាផលរបស់កុសលកម្មឲ្យផលក្នុងបវត្តិកាល ។

**១៤.**មនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត និង មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬ មនោទ្វារាវជ្ជនចិត្ត ទាំង ២ ដួង នេះ នីមួយៗក៏ជាអហេតុកកិរិយាដូចគ្នា ធ្វើអាវជ្ជនកិច្ចដូចគ្នា ព្រោះហេតុអ្វី មនោធាតុអហេតុកកិរិយាចិត្ត ឬ បញ្ចទ្វារាវជ្ជនចិត្ត ទើបជាមនោធាតុ ដឹងអារម្មណ៍តិច ចំណែកមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬ មនោទ្វារាវជ្ជនចិត្ត ជាមនោវិញ្ញាណធាតុ ដឹងអារម្មណ៍ ច្រើនជាងគ្នា ?

-ផ្សេងគ្នាព្រោះ បញ្ចទ្វារាវជ្ជនចិត្តធ្វើអាវជ្ជនកិច្ច ពិចារណាអារម្មណ៍ដែលមកប៉ះខ្ទប់តាមបញ្ចទ្វារប៉ុណ្ណោះ មិនមាននាទីដទៃទៀតទេ ចំណែកមនោទ្វារាវជ្ជនចិត្ត ធ្វើកិច្ច គឺ ពិចារណាអារម្មណ៍តាម

មនោទ្វារ និងធ្វើនាទីវោដ្ឋវនកិច្ច គឺ កំណត់នូវអារម្មណ៍តាមបញ្ចទ្វារផងដែរ ទើបដឹងអារម្មណ៍ច្រើនជាង ។

**១៥.**បញ្ចទ្វារាវជ្ជនចិត្ត និងមនោធាតុអហេតុកវិបាកចិត្ត ឬសម្បដិច្ឆន្នចិត្តនីមួយៗ ក៏ជាមនោធាតុដូចគ្នា និងធ្វើកិច្ចក្នុងបញ្ចទ្វារដូចគ្នា ចុះហេតុអ្វី បញ្ចទ្វារាវជ្ជនចិត្ត ទើបជាកិរិយាចិត្ត ចំណែកឯសម្បដិច្ឆន្នចិត្ត ២ ដួង ជាវិបាកចិត្តទៅវិញ ?

-ព្រោះបញ្ចទ្វារាវជ្ជនចិត្ត ធ្វើអាវជ្ជនកិច្ច នឹកដល់អារម្មណ៍ដែលមកប៉ះខ្ទប់កើតឡើង ព្រោះអារម្មណ៍និងវត្ថុខ្ទប់គ្នា មិនមែនជាផលរបស់កុសលកម្មឬអកុសលកម្មទេ ចំណែកសម្បដិច្ឆន្នចិត្ត ២ ដួងនោះ ជាផលវិបាករបស់កុសលកម្ម និង អកុសលកម្មកើតឡើងទទួលផលរបស់កម្ម ។

**១៦.**មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬមនោទ្វារាវជ្ជនចិត្ត មានឈ្មោះម្យ៉ាងទៀតថា វោដ្ឋវនចិត្ត កាលបើឈ្មោះ ក៏ផ្សេងគ្នា នាទីក៏ផ្សេងគ្នា ដូចគ្នាត្រឹមតែបច្ច័យឲ្យជវនចិត្តកើត ប៉ុណ្ណោះ ចុះហេតុណាទើបពោលថា ជាចិត្តតែមួយដួង ?

-ការដែលចិត្ត ២ ដួងនេះផ្សេងគ្នា ព្រោះមានកិច្ចនាទីផ្សេងគ្នា គឺមនោទ្វារាវជ្ជនចិត្ត ធ្វើអាវជ្ជនកិច្ចតាមមនោទ្វារ វោដ្ឋវនចិត្តធ្វើវោដ្ឋវនកិច្ចតាមបញ្ចទ្វារ ។ ចំណែកដែលថាចិត្ត ២ ដួងនេះ ជា

ចិត្តតែមួយដួងនោះ ក៏ព្រោះមានចេតសិកប្រកបស្មើគ្នា និងជាកិរិយាចិត្តដូចគ្នា ។

**១៧**.អហេតុកចិត្ត មិនមានហេតុប្រកប មានកម្លាំងខ្សោយ មិនដូចជាសហេតុកចិត្តដែលមានកម្លាំងខ្លាំងជាងទេ ប៉ុន្តែមនោទ្វា-រាវជ្ជនចិត្តដែលជាអហេតុកកិរិយាចិត្តនោះ មិនកើតក្នុងអសញ្ញសត្វ-ព្រហ្ម និង មគ្គបុគ្គលទេ ក្រៅពីនោះ មនោទ្វារាវជ្ជនចិត្តតែងកើតបានគ្រប់ភូមិ កើតបានគ្រប់បុគ្គល កើតបានគ្រប់ទ្វារ ទទួលបានគ្រប់អារម្មណ៍ និងគ្រប់កាល តើនឹងថា ចិត្តដួងនេះ មានកម្លាំងខ្សោយដូចម្តេចបាន ?

-ចិត្តដួងនេះ ជាចិត្តទូលំទូលាយ កើតបានច្រើនជាងចិត្តដទៃ ដូចបានពោលមកហើយ ។ លោកហៅមនោវិញ្ញាណធាតុ-អហេតុកកិរិយាចិត្ត ឬមនោទ្វារាវជ្ជនចិត្តនេះថា មហាគជៈ(ដំរីធំ)។ ក្នុងអដ្ឋសាលិនី បានពោលថា សភាវៈដែលមិនជាអារម្មណ៍របស់ចិត្តនេះ មិនមានទេ ហើយបានពោលទៀតថា ចិត្តដែលមិនមែនជាសព្វញ្ញុតញ្ញាណ តែមានគតិដូចសព្វញ្ញុតញ្ញាណ គឺ មនោវិញ្ញាណ-ធាតុដែលជាកិរិយាចិត្តសហគតដោយឧបេក្ខា គឺ មនោទ្វារាវជ្ជនចិត្តនោះឯង ។ ត្រង់ដែលលោកពោលថា ចិត្តដួងនេះ មានកម្លាំងខ្សោយ ព្រោះចិត្តដួងនេះ ធ្វើកិច្ចត្រឹមតែជាអាវជ្ជនៈឲ្យដល់ជវនៈប៉ុណ្ណោះ ហើយក៏រលត់ទៅ ។

**១៨.**សោមនស្សសហគតមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬហសិតុប្បាទចិត្ត ជាចិត្តញញឹមញញែមរបស់ព្រះពុទ្ធ ឬព្រះអរហន្ត ព្រោះហេតុអ្វីទើបពោលថា ហសិតុប្បាទចិត្តជាអសោភណចិត្តវិញ ?

-សោមនស្សសហគតមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ឬ ហសិតុប្បាទចិត្ត ជាអសោភណចិត្តនោះ សំដៅថា មិនមានសោភណចេតសិកប្រកបជាមួយ ។

**១៩.ហសនចិត្ត** គឺចិត្តដែលរីករាយឬសើចមានប៉ុន្មាន អ្វីខ្លះ?

**-ហសនចិត្ត** មាន ១៣ ដួង គឺ :

**-បុថុជ្ជន** សើចដោយចិត្ត ៨ ដួង គឺមហាកុសលសោមនស្សចិត្ត៤ ដួង លោភមូលសោមនស្សចិត្ត ៤ ។

**-ព្រះសេក្ខ** សើចដោយចិត្ត ៦ ដួង គឺកុសលសោមនស្សចិត្ត ៤ ដួង និងលោភមូលសោមនស្សទិដ្ឋិគតវិប្បយុត្តចិត្ត ២ ដួង ។

**-ព្រះខីណាស្រព** សើចដោយចិត្ត ៥ ដួង គឺហសិតុប្បាទចិត្ត ១ ដួង និងមហាកិរិយាសោមនស្សចិត្ត ៤ ដួង។

**២០.**ព្រះអរហន្តញញឹមដោយមហាកិរិយាសោមនស្សចិត្ត ៤ ដួងមែនទេ តើហេតុអ្វី ទើបត្រូវញញឹមដោយហសិតុប្បាទចិត្តទៀតនោះ ?

-មហាកិរិយាចិត្តដែលជាសោមនស្សនោះ តាមប្រក្រតី មានអារម្មណ៍ជាឱឡារិកអារម្មណ៍ បានដល់អារម្មណ៍ធំ ឬ អារម្មណ៍ដែលដឹងដោយចិត្តធម្មតា ដូចចក្ខុវិញ្ញាណឃើញពណ៌ សោតវិញ្ញាណឮសំឡេងជាដើម ( វៀរតែខណៈធ្វើនាទីត្រង់បច្ចវេក្ខណៈ ទើបជាអនោឡារិកអារម្មណ៍ គឺ អារម្មណ៍ល្អិត ) ចំណែកហសិតុប្បាទចិត្តមានអារម្មណ៍ជាអនោឡារិកអារម្មណ៍ ដឹងបានដោយអភិញ្ញាចិត្ត ឬ ដោយបច្ចវេក្ខណញ្ញាណ ។

**២១**.ព្រះអរហន្តឃើញប្រេតដែលកំពុងត្រូវភ្លើងឆេះ ដែលជាអនិដ្ឋារមណ៍ ការឃើញយ៉ាងនេះ ជាវិបាករបស់អកុសលកម្ម ឬ កុសលកម្ម ?

-ការឃើញជាអនិដ្ឋារម្មណ៍ ជាអកុសលវិបាក ទោះជាព្រះអរហន្តឃើញក៏ដោយ និងឃើញដោយអភិញ្ញាចិត្តក៏ដោយ ក៏មិនមានអ្នកណាមួយអាចកែវិបាកឲ្យជាយ៉ាងដទៃបានឡើយ ។

**២២**.ហសិតុប្បាទចិត្តរបស់ព្រះអរហន្ត មានគ្រប់ៗភូមិ ឬ យ៉ាងណាដែរ ?

-ហសិតុប្បាទចិត្តរបស់ព្រះអរហន្ត មាននៅក្នុងកាមភូមិ រូបភូមិ មិនមានក្នុងអរូបភូមិ ព្រោះក្នុងអរូបភូមិមិនមានរូប ៕

( ចប់អហេតុកចិត្ត ១៨ )

# សោភណចិត្ត
# ៥៩ ឬ ៩១ ដួង

ក្រៅអំពីបាបចិត្ត ( អកុសលចិត្ត ១២ ) និង អហេតុកចិត្ត ១៨, រួមជា ៣០ ដួង, មានចិត្ត ៥៩ ដួង ឬ ៩១ ដួង ដែលលោកពោលថាជា **សោភណចិត្ត** ។

# សោភណចិត្ត ៤ ប្រភេទ

សោភណចិត្តទាំងអស់ចែកជា ៤ ប្រភេទ គឺ :

**១.** កាមាវចរសោភណចិត្ត ២៤ ដួង

**២.** រូបាវចរសោភណចិត្ត ១៥ ដួង

**៣.** អរូបាវចរសោភណចិត្ត ១២ ដួង

**៤.** លោកុត្តរសោភណចិត្ត ៨ ឬ ៤០ ដួង

រួម ៥៩ ឬ ៩១ ដួង

# ១.កាមាវចរសោភណចិត្ត ២៤

ក្នុងកាមាវចរសោភណចិត្ត ២៤ នេះ ចែកចេញជា ៣ គឺ :

**១.** កាមាវចរកុសលចិត្ត ៨ ឬ មហាកុសលចិត្ត ៨

**២.** កាមាវចរវិបាកចិត្ត ៨ ( មហាវិបាក )

**៣.** កាមាវចរកិរិយាចិត្ត ៨ ( មហាកិរិយា )

# កាមាវចរកុសលចិត្ត
# ឬ មហាកុសលចិត្ត ៨

## ១. សោមនស្សសហគត ញាណសម្បយុត្ត អសង្ខារិក

ចិត្តកើតព្រមនឹងសោមនស្ស ប្រកបដោយញាណ ជាអសង្ខារិក ១

## ២. សោមនស្សសហគត ញាណសម្បយុត្ត សសង្ខារិក

ចិត្តកើតព្រមនឹងសោមនស្ស ប្រកបដោយញាណ ជាសសង្ខារិក ១

## ៣. សោមនស្សសហគត ញាណវិប្បយុត្ត អសង្ខារិក

ចិត្តកើតព្រមនឹងសោមនស្ស មិនប្រកបដោយញាណជាអសង្ខារិក ១

## ៤. សោមនស្សសហគត ញាណវិប្បយុត្ត សសង្ខារិក

ចិត្តកើតព្រមនឹងសោមនស្ស មិនប្រកបដោយញាណជាសសង្ខារិក ១

## ៥. ឧបេក្ខាសហគត ញាណសម្បយុត្ត អសង្ខារិក

ចិត្តកើតព្រមនឹងឧបេក្ខា ប្រកបដោយញាណ ជាអសង្ខារិក ១

## ៦. ឧបេក្ខាសហគត ញាណសម្បយុត្ត សសង្ខារិក

ចិត្តកើតព្រមនឹងឧបេក្ខា ប្រកបដោយញាណ ជាសសង្ខារិក ១

## ៧. ឧបេក្ខាសហគត ញាណវិប្បយុត្ត អសង្ខារិក

ចិត្តកើតព្រមនឹងឧបេក្ខា មិនប្រកបដោយញាណ ជាអសង្ខារិក ១

## ៨. ឧបេក្ខាសហគត ញាណវិប្បយុត្ត សសង្ខារិក

ចិត្តកើតព្រមនឹងឧបេក្ខា មិនប្រកបដោយញាណ ជាសសង្ខារិក ១

ចិត្ត ៨ ដួងនេះ ឈ្មោះថា **សហេតុកកាមាវចរកុសលចិត្ត** ឬ ហៅថា **មហាកុសលចិត្ត** ។

# តារាងកាមាវចរកុសលចិត្ត ៨

- កាមាវចរកុសល ៨
  - សោមនស្ស
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - ឧបេក្ខា
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១

កាមាវចរកុសលចិត្ត ៨ ដួងនេះ សម្តែងដោយសេចក្តីផ្សេងគ្នានៃវេទនា(ការសោយអារម្មណ៍) នៃញាណ(បញ្ញា) និង នៃសង្ខារ (ការតាក់តែង) ។

**សោភណចិត្ត** គឺ ជាចិត្តអ្វី ?

ពាក្យថា **សោភណចិត្តនេះ** សំដៅដល់ចិត្តដែលមានសោភណចេតសិកប្រកបជាមួយមានសទ្ធា សតិ ហិរិ និងឱត្តប្បៈជាដើម ។

# អធិប្បាយ កាមាវចរកុសលចិត្ត ឬ មហាកុសលចិត្ត ៨ ដួង

**មហាកុសលចិត្តដួងទី ១** ពេលណា បុគ្គលណាមួយ អាស្រ័យនូវហេតុនៃសោមនស្ស មានសេចក្ដីសប្បាយរីករាយ ( មានទេយ្យធម៌ច្រើន និង បដិគ្គាហកៈអ្នកទទួល ) នូវសម្មាទិដ្ឋិជាខាងដើម ( គឺ ធ្វើដោយសេចក្ដីគោរព ) ដោយន័យថា ទានដែលឲ្យហើយមានផល យ៉ាងនេះជាដើម មិនរួញរា មិនចាំបាច់ឲ្យអ្នកដទៃខ្នះខ្នែងធ្វើឲ្យទេ តែងធ្វើបុណ្យ មានការឲ្យទានជាដើម ក្នុងពេលនោះ ចិត្តរបស់បុគ្គលនោះ ជាចិត្តសហគតដោយសោមនស្ស សម្បយុត្តដោយញាណជាអសង្ខារិក ។

**មហាកុសលចិត្តដួងទី ២** ពេលណា បុគ្គលត្រេកអរសប្បាយ រីករាយ ធ្វើនូវសម្មាទិដ្ឋិជាខាងដើមទុក ប៉ុន្តែចិត្តនៅរួញរាដោយសេចក្ដីជាអ្នកកំណាញ់ (គឺមិនងាយឲ្យ) ឬ ត្រូវអ្នកដទៃជួយដឹកនាំ ទើបធ្វើបុណ្យក្នុងពេលនោះ ចិត្តរបស់បុគ្គលនោះឯង រមែងជាចិត្តសហគតដោយសោមនស្ស សម្បយុត្តដោយញាណ ជាសសង្ខារិក។

**មហាកុសលចិត្តដួងទី ៣** ម្យ៉ាងទៀត ពេលណា ក្មេង

ដែលមិនដឹងអ្វី មានសេចក្ដីគោរពរាប់អាន ដោយបានឃើញការបដិបត្តិរបស់ជនជាញាតិ ឃើញភិក្ខុទាំងឡាយហើយក៏កើតសោមនស្ស រមែងឲ្យវត្ថុដែលមានណាមួយ ឬក៏រមែងថ្វាយបង្គំ ក្នុងពេលនោះចិត្តរបស់ក្មេងនោះ ជាចិត្តសហគតដោយសោមនស្ស តែមិនប្រកបដោយញាណ ជាអសង្ខារិក ។

**មហាកុសលចិត្តដួងទី ៤** ម្យ៉ាងទៀត ពេលណា ក្មេងដែលមិនដឹងអ្វីនោះ ត្រូវពួកញាតិជួយដាស់តឿននាំថា នែកូន! ចូរឲ្យ ចូរសំពះយ៉ាងនេះ កូនក៏បដិបត្តិតាម ក្នុងពេលនោះ ចិត្តសហគតដោយសោមនស្ស មិនប្រកបដោយញាណ ជាសសង្ខារិក កើតឡើងដល់ក្មេងនោះ ។

មហាកុសលចិត្តកើតព្រមនឹងឧបេក្ខា ៤ ដួង កុសល ៤ ដួងក្រោយនេះ លោកពោលថា ក្នុងពេលណាបុគ្គលណាមួយ មិនមានហេតុឲ្យសោមនស្សកើតឡើង ដូចជាមិនសំបូរនូវទេយ្យធម៌ ឬបដិគ្គាហកៈជាដើម ពេលនោះកុសលចិត្ត ក៏សហគតដោយឧបេក្ខាតែងកើតឡើង ។ ចំពោះសម្បយុត្ត ដោយញាណ និង សសង្ខារិក មានន័យដូចខាងដើម ។

# វិធីរាប់មហាកុសលចិត្តដោយពិស្តារ

ក្នុងអភិធម្មត្ថសង្គហៈបាលីដីកា បានអធិប្បាយទុកថា ៖

**កមេន បុញ្ញវត្ថូហិ គោចរាធិបតីហិ**
**កម្ម ហីនាទិតោ ចេវ គណេយ្យ នយកោវិទោតិ**

អ្នកឈ្លាសក្នុងន័យ គប្បីរាប់ចិត្តទាំងឡាយដោយបុញ្ញវត្ថុ ១០ ដោយគោចរ គឺ អារម្មណ៍ ៦ ដោយអធិបតី ៤ ដោយកម្ម ៣ ដោយចិត្តជាថោកទាបជាដើម ៣ តាមលំដាប់ ។

គប្បីជ្រាបវិធីរាប់មហាកុសលចិត្តនោះ យ៉ាងនេះ គឺ :

**១.** មហាកុសល ៨ × បុញ្ញកិរិយាវត្ថុ ១០ = ៨០ ដួង

**២.** មហាកុសលចិត្ត ៨០ × អារម្មណ៍ ៦ = ៤៨០ ដួង

**៣.** មហាកុសលចិត្ត ៤៨០ ដួងនោះ ចែកជា ២ ពួក គឺ ជាញាណសម្បយុត្ត ២៤០ ដួង ជាញាណវិប្បយុត្ត ២៤០ ដួង

ចិត្តវិប្បយុត្តចាកញាណ ២៤០ × អធិបតី ៣ = ៧២០ ដួង ។

ចិត្តសម្បយុត្តនឹងញាណ ២៤០ × អធិបតី ៤ = ៩៦០ ដួង ។

រួមទាំង ២ ពួកបាន ១.៦៨០ ដួង ។

**៤.** ចិត្ត ១.៦៨០ × កម្ម ៣ (កាយកម្មជាដើម) = ៥.០៤០ ដួង ។

**៥.** ចិត្ត ៥.០៤០ × ចិត្ត ៣ យ៉ាង គឺ ថោកទាប កណ្ដាល ប្រណីត = ១៥.១២០ ដួង ។

កាមាវចរកុសលចិត្ត ឬ មហាកុសលចិត្ត ដែលគណនាបានរហូតដល់ ១៥.១២០ ដួងនោះ បើសម្ដែងឲ្យល្អិតទៅទៀត ដូចជា ដោយកាល និង ដោយទេសៈ ( គឺកន្លែងឬប្រទេស )ទាំងអស់ ក៏នឹងគណនាបានយ៉ាងច្រើនបំផុត ។

# អធិប្បាយពាក្យថា កុសល

**កុសល** ក្នុងអភិធម្មត្ថវិភាវិនី លោកធ្វើវិគ្រោះស័ព្ទទុក ៣ ន័យ យ៉ាងនេះ :-

## ១. កុច្ឆិតេ បាបធម្មេ សលយន្តិ កម្បេន្តិ ហឹសេន្តិ អបគមេន្តីតិ វា កុសលានិ ។

ប្រែថា ឈ្មោះថា **កុសល** ព្រោះ អត្ថថា កំចាត់បង់នូវបាបធម៌ដែលគួរខ្ពើម គឺរមែងញ៉ាំងបាបធម៌នោះឲ្យញាប់ញ័រ ឬថា រមែងបៀតបៀន ឬរមែងឲ្យប្រាសចាកទៅ ( កាមកុសល មហគ្គតកុសល លោកុត្តរកុសលដោយលំដាប់ ) ។

## ២. កុច្ឆិតាការេន សន្តានេ សយនតោ បវត្តនតោ កុសសង្ខាតេ បាបធម្មេ លុនន្តិ ឆិន្ទន្តីតិ កុសលានិ ។

ប្រែថា ឈ្មោះថា **កុសល** ព្រោះអត្ថថា កាត់ គឺច្រូតនូវបាបធម៌ទាំងឡាយ ដែលឈ្មោះថា **កុសះ** ព្រោះដេកត្រាំ គឺប្រព្រឹត្តក្នុងសន្តានដោយអាការគួរខ្ពើម ។

## ៣. កុច្ឆិតេ បាបធម្មេ សានតោ តនុករណតោ ឱសានករណតោវា កុសសង្ខាតេន ញាណេន សទ្ធាទិធម្មជាតេន វា លាតព្វានិ សហជាត-ឧបនិស្សយ ភាវេន យថារហំ បវត្តេតព្វានីតិ កុសលានិ ។

ប្រែថា ឈ្មោះថា **កុសល** ព្រោះអត្ថថា បុគ្គលគប្បីកាត់ គឺគប្បីឲ្យប្រព្រឹត្តទៅដោយសេចក្តីជាសហជាត និង ឧបនិស្ស័យតាមសមគួរដោយញាណ ឬថា ដោយសេចក្តីកើតឡើងនៃធម៌មានសទ្ធាជាដើម ព្រោះញុំាងបាបធម៌ដែលគួរស្អប់ខ្ពើមនោះឲ្យស្រាល ឬឲ្យស្តើង ឬ ឲ្យដាច់អស់តែម្តង ៕

# កុសលមានអត្ថ ៥ គឺ ៖

**១.អរោគ្យត្ថ** ដោយអត្ថថា មិនមានរោគ គឺ មិនមានកិលេស មានរាគៈ ទោសៈ និង មោហៈ ជាដើម ។ ដែលឈ្មោះថា រោគ ព្រោះចាក់ដោត គឺ ប្រទូសរ៉ាយចិត្តឲ្យទុព្វល ខ្សោយកម្លាំង ។

**២.សុន្ទរត្ថ** ដោយអត្ថថា ជាធម៌ល្អស្អាត គឺជាប្រយោជន៍ឧបត្ថម្ភគាំទ្រដល់ពពួកសត្វទាំងឡាយ ។

**៣.ឆេកត្ថ** ដោយអត្ថថា ឈ្លាសប្រសប់ វាងវៃ ស្រួច ។

**៤.អនវជ្ជត្ថ** ដោយអត្ថថា មិនមានទោសដែលគួរតិះដៀល។

**៥.សុខវិបាកត្ថ** ដោយអត្ថថា មានសេចក្ដីសុខជាវិបាក ។

# ពាក្យថា បុញ្ញំ ( បុណ្យ )

ពាក្យថា **បុញ្ញំ** ប្រែថា បុណ្យ ប្រើជំនួសពាក្យថា កុសល មានវិគ្រោះស័ព្ទថា :

**អត្តនោ សន្តានំ បុនាតិ សោធេតីតិ បុញ្ញំ**

ប្រែថា ធម្មជាតិណាតែងជំរះ គឺ ញុាំងសន្តាននៃខ្លួនឲ្យបរិសុទ្ធ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **បុញ្ញ** ។

# លក្ខណាទិចតុកៈរបស់កុសលចិត្ត

| | |
|---|---|
| **-អនវជ្ជសុខវិបាក លក្ខណំ** | មានសុខជាវិបាកដែលមិនមានទោសជាលក្ខណៈ ។ |
| **-អកុសលវិទ្ធំសន រសំ** | មានការកំចាត់អកុសលជាកិច្ច ។ |
| **-វោទាន បច្ចុប្បដ្ឋានំ** | មានការផូរផង់ជាអាការប្រាកដ។ |
| **-យោនិសោមនសិការ បទដ្ឋានំ** | មានយោនិសោមនសិការ ជាហេតុជិត ។ |

ពាក្យថា " **កុសលធម៏មានសុខជាវិបាក** " មិនមានទោស ជាលក្ខណៈ គឺជាកុសលធម៏ដែលឲ្យផលជាសុខតាមផ្លូវកាយ ហៅថា **កាយិកសុខ** ចំណែកឯឲ្យផលជាសុខតាមផ្លូវចិត្ត ហៅថា **ចេតសិកសុខ** ។

ពាក្យថា " **មានការកំចាត់កុសលជាកិច្ច** " គឺខណៈដែលកុសលកើតឡើងនោះ រមែងលះអកុសលធម៏ គឺ លោភៈ ទោសៈ

និងមោហៈជាដើម ដោយបហាន ៣ យ៉ាង គឺដោយតទង្គប្បហាន (លះមួយជួរខណៈដោយអង្គនោះ) ឬ ដោយវិក្ខម្ភនប្បហាន ( លះដោយសង្កត់សង្កិនដោយឈានសមាបត្តិ ) ឬ ដោយសមុច្ឆេទប្បហាន ( លះដោយកាត់ផ្តាច់ដោយអរិយមគ្គ ) ។

ពាក្យថា “ **មានការផ្លូវផង់ជាអាការប្រាកដ** ” គឺក្នុងខណៈដែលកុសលកើតនោះ ចិត្តរមែងផ្លូវផង់ប្រាសចាកនីវរណៈ មិនមាន លោភៈ ទោសៈ មោហៈជាដើមកើតរួមជាមួយទេ ។

ពាក្យថា “ **មានយោនិសោមនសិការជាហេតុជិត** ” គឺមានការពិចារណាដោយត្រូវទំនង ដោយប្រពៃមិនខុសក្នុងរូប(ពណ៌) ដែលកំពុងប្រាកដ ក្នុងសំឡេងដែលកំពុងប្រាកដ ក្នុងក្លិន ក្នុងរស ក្នុងផោដ្ឋព្វៈ ក្នុងធម៌ដែលកំពុងប្រាកដ ព្រោះយោនិសោមនសិការនេះជាកុសលធម៌ ។

# លក្ខណាទិចតុកៈរបស់កុសលចិត្ត

( ន័យម្យ៉ាងទៀត )

**-អនវជ្ជលក្ខណមេវ** មានការមិនមានទោស ជាលក្ខណៈ ។

**-វោទានភាវ រសំ** មានការផ្លូវផង់ ជាកិច្ច ។

**-ឥដ្ឋវិបាក បច្ចុប្បដ្ឋានំ** មានវិបាកដែលជាទីប្រាថ្នា ជាអាការប្រាកដ ។

**-យថាវុត្តបទដ្ឋានមេវ** មានហេតុជិត ដូចបានពោលមកហើយនោះ ជាបទដ្ឋាន ។

ពាក្យថា " **កុសលមានការមិនមានទោសជាលក្ខណៈ** " បានដល់ លក្ខណៈទូទៅរបស់កុសលនោះមិនមានទោស មិនដូចជាលក្ខណៈរបស់កិលេសទេ ។

ពាក្យថា " **មានការផ្សរផង់ជាកិច្ច** " បានដល់ សម្បត្តិរស គឺ កិច្ចនាទីសំបូរហើយ ទើបធ្វើឲ្យផូរផង់ក្នុងខណៈនោះ ។

# សេចក្តីផ្សេងគ្នានៃន័យទាំង ២

ក្នុងលក្ខណាទិចតុកៈទាំង ២ ន័យនោះ **ន័យទី ១** លោកបំណងសម្តែងពីផលដែលល្អនៃកុសលកម្ម ដែលនឹងកើតក្នុងអនាគតជាលក្ខណៈ គឺ កាលណាកុសលចិត្តកើតហើយ សេចក្តីសុខប្រាស-ចាកទោស រមែងកើតឡើង មិនមែនសម្តែងសេចក្តីសុខដែលមានទោស ដូចសេចក្តីសុខកើតពីលោភមូលចិត្ត ។ មិនសម្តែងការកំចាត់អកុសលថាជាកិច្ច គឺ កាលណាកុសលកើតឡើង ក៏ធ្វើនាទី

កំចាត់អកុសលទាន់ពេលភ្លាមៗ និងសម្ដែងការផ្សួរផង់នៃចិត្តជាផល ។

ចំណែក **ន័យទី ២** នោះ លោកបំណងសម្ដែងកុសលចិត្ត ដែលកើតឡើងក្នុងបច្ចុប្បន្ន ជាលក្ខណៈ លក្ខណៈទូទៅរបស់កុសល ដែលប្រកបដោយអត្ថ ៣ គឺ ឈ្មោះថា កុសល ព្រោះមិនមានរោគ សេចក្ដីរសាប់រសល់ដោយកិលេស ១ ព្រោះមិនមានទោស គឺកិលេស ដែលធ្វើឲ្យក្រវល់ក្រវាយ ១ ព្រោះកើតពីបញ្ញា ដែលឈ្មោះថា កោសល្លៈ ( ភាពជាអ្នកឈ្លាស ) បើជាកុសលញាណវិប្បយុត្ត ក៏ មិនប្រកបដោយកោសល្លៈ ។

ចំពោះភាវៈដែលធ្វើឲ្យផ្សួរផង់នោះ សម្ដែងដល់សម្បត្តិ រស គឺនាទីនោះសំបូរហើយទើបធ្វើឲ្យផ្សួរផង់ និង សម្ដែងដល់វិបាករបស់ កុសលនោះ គឺ ជាផលគួរជាទីប្រាថ្នា ជាទីពេញចិត្ត ។ ចំណែក ហេតុជិតឲ្យកើតនោះ ប្រព្រឹត្តទៅក្នុងយោនិសោមនសិការដូចគ្នា ។

កុសលចិត្តនឹងកើតឡើងបាន ព្រោះយោនិសោមនសិការ ហើយ យោនិសោមនសិការៈនឹងកើតឡើង ត្រូវអាស្រ័យហេតុដែល ជាអតីត និង បច្ចុប្បន្នជាបច្ច័យផងដែរ ។ ក្នុង **អង្គុត្តរនិកាយ ចតុក-និបាត** ហៅហេតុដែលធ្វើឲ្យកុសលកើតនេះថា ចក្កៈ ៤ ( ចក្កៈ គឺ សម្បត្តិ ) ។

# ចក្កៈ ៤

| | | |
|---|---|---|
| **១.បដិរូបទេសវាស** | នៅក្នុងប្រទេសដ៏សមគួរ | ។ |
| **២.សប្បុរិសូបសំសេវ** | សេពគប់សប្បុរស | ។ |
| **៣.អត្តសម្មាបណិធិ** | តាំងខ្លួនទុកដោយប្រពៃ | ។ |
| **៤.បុព្វេ កតបុញ្ញតា** | ភាពជាអ្នកបានធ្វើបុណ្យ ទុកមកក្នុងកាលមុន ។ | |

ពាក្យថា **ចក្កៈ** គឺ ការដល់ព្រមដោយបច្ច័យ ៤ នេះ ជាបច្ច័យឲ្យកើតយោនិសោមនសិការៈ ព្រោះការរស់នៅក្នុងអាវាស ឬប្រទេសដ៏សមគួរ មានវត្ថុល្អ ។ ដូចនៅទីកន្លែងដែលមានសប្បុរស រមែងតែមានការឃើញ ឮជាដើម ក្នុងផ្នែកដែលល្អ ៗ ។

ក្នុងអដ្ឋកថាពោលថា ការរស់នៅក្នុងអាវាសដែលប្រាកដទៅដោយពុទ្ធបរិស័ទ ហៅថា **បដិរូបទេសវាសៈ** ការសេពគប់សប្បុរសមានព្រះពុទ្ធជាម្ចាស់ជាដើមហៅថា **សប្បុរិសូបសំសេវៈ** ការតាំងខ្លួនទុកដោយប្រពៃក្នុងគុណធម៌ មានសទ្ធាជាដើម ឈ្មោះថា **អត្តសម្មា-បណិធិ** និង ភាពជាអ្នកមានកុសលដែលបានសន្សំទុកក្នុងកាលមុន

ឈ្មោះថា **បុញ្ញេ ច កតបុញ្ញតា** ។ ក្នុងចំណុចចុងក្រោយនេះ ជាហេតុបច្ច័យ និង ជាប្រយោជន៍ច្រើន ព្រោះកម្មប៉ុណ្ណោះ ដែលបុគ្គលធ្វើដោយចិត្តណា ដែលសម្បយុត្តដោយញាណណា កុសលចិត្តនោះឯង ក៏រមែងញាំងបុគ្គលនោះ ឲ្យរស់នៅក្នុងអាវាសដែលសមគួរឲ្យគប់រកសប្បុរស បុគ្គលនោះ ឈ្មោះថា តាំងខ្លួនទុកដោយប្រពៃដោយអាការយ៉ាងនេះ ។

សេចក្តីពិត បុគ្គលប្រកបដោយចក្កៈ ៤ នេះហើយ មិនមែនជាហេតុឲ្យយោនិសោមនសិការកើតតែប៉ុណ្ណោះទេ ចក្កៈ ៤ នេះតែងឲ្យបានវត្ថុគ្រប់យ៉ាងដែលជាទីប្រាថ្នាផង មានស្រូវ អង្ករ ទ្រព្យ យស កិត្តិយស និងសេចក្តីសុខជាដើម មានដល់បុគ្គលនោះ ។

មហាកុសល ឬ កាមាវចរកុសលចិត្តនេះ ចែកជា ៨ នោះក៏ព្រោះវេទនាជាសោមនស្សខ្លះ ជាឧបេក្ខាខ្លះ ជាញាណខ្លះ ជាសង្ខារខ្លះ ។ ដើម្បីឲ្យធម៌ទាំងនេះជាក់ច្បាស់ ទើបគួរជ្រាបនូវធម៌ដែលជាបច្ច័យ ៖

# ហេតុឲ្យកើតកុសលសោមនស្ស ៦

**១.សោមនស្សបដិសន្ធិកតា** បដិសន្ធិដោយចិត្តសោមនស្ស។

**២.សទ្ធាពហុលតា** ជាអ្នកមានសទ្ធាច្រើន ។

**៣.វិសុទ្ធទិដ្ឋិតា** មានការឃើញប្រពៃ ជាសម្មា-ទិដ្ឋិ ។

**៤.អនិសំសទស្សាវិតា** ឃើញអានិសង្សនៃកុសល ។

**៥.ឥដ្ឋារម្មណសមាយោគោ** ប្រសប់នឹងឥដ្ឋារម្មណ៍ ។

**៦.កស្សចិ បិឡាភាវោ** មិនមានឧបសគ្គរារាំង ។

បុគ្គលអ្នកបដិសន្ធិក្នុងលោកនេះ ដោយកុសលវិបាកប្រកបដោយសោមនស្ស តែងមានចិត្តរីករាយ មិនចូលចិត្តមានទុក្ខច្រើន ពេលធ្វើកុសល ឬអកុសលក្តី តែងជាអ្នកច្រើនដោយសោមនស្ស ។

បុគ្គលច្រើនទៅដោយសទ្ធា មានការឃើញប្រាសចាកមន្ទិល ឃើញអានិសង្សនៃកុសល រមែងធ្វើកុសលដោយចិត្តសោមនស្ស ។

បុគ្គលដែលប្រសប់នឹងឥដ្ឋារម្មណ៍តាមផ្លូវ ភ្នែក ត្រចៀក ជាដើម តែងត្រេកអរពេញចិត្ត កាលធ្វើកុសលក៏ជាសោមនស្ស តែបើមនសិការមិនល្អទេ ក៏ជាសោមនស្សនៃលោភមូលចិត្តក៏មាន ។ ការធ្វើកុសលគ្រប់យ៉ាង មិនមានឧបសគ្គឯណានីមួយមករារាំងទេ ក៏ជាហេតុឲ្យកុសលកើតព្រមនឹងសោមនស្ស ។

# ហេតុឲ្យកើតកុសលឧបេក្ខា ៦

**១.ឧបេក្ខាបដិសន្ធិកតា** បដិសន្ធិដោយឧបេក្ខា ។
**២.អប្បសទ្ធតា** ជាអ្នកមានសទ្ធាតិច ។
**៣.អវិសុទ្ធទិដ្ឋិតា** មានការឃើញមិនបរិសុទ្ធ ។
**៤.អានិសំសអទស្សាវិតា** មិនឃើញអានិសង្សនៃកុសល។
**៥.មជ្ឈត្តារម្មណសមាយោគោ** ប្រសប់នឹងអារម្មណ៍ជាមធ្យម។
**៦.កស្សចិ បិឡិកតា** មានឧបសគ្គមករារាំង ។

# ហេតុឲ្យកើតកុសលញាណសម្បយុត្ត ៤

១. **បញ្ញាសំវត្តនិក កម្មុប្បនិស្សយតា** ភាពជាអ្នកមានឧបនិស្ស័យក្នុងការធ្វើកុសល ដែលប្រព្រឹត្តទៅដោយបញ្ញា ដូចការសម្តែងធម៌ ការអារាធនាឲ្យសម្តែងធម៌ ការបង្ហាត់សិល្បវិទ្យាដែលមិនមានទោស ការបូជា និង ការថ្វាយទានតាំងសេចក្តីប្រាថ្នា ជាដើម ។

២. **អព្យាបជ្ឈលោកូបបត្តិតា** ភាពជាអ្នកកើតឡើង ក្នុងលោក

ដែលមិនមានការបៀតបៀន ។

៣. **ឥន្ទ្រីយបរិបាកតា** ភាពជាអ្នកមានឥន្ទ្រីយ៍ចាស់ក្លា គឺ មានឥន្ទ្រីយ៍ ៥ មានបញ្ញិន្ទ្រីយ៍ជាប្រធាន ។

៤. **កិលេសទូរតា** ភាពជាអ្នកឆ្ងាយចាកកិលេសដោយតាំងខ្លួនទុកប្រពៃ ដូចចំរើនវិបស្សនា ឬ ចំរើនធម្មវិចយសម្ពោជ្ឈង្គៈ ដែលជាភាវៈឆ្ងាយចាកកិលេស ។

# ហេតុឲ្យកើតកុសលញាណសម្បយុត្ត ៧

( ន័យទី ២ )

| | |
|---|---|
| **១.បរិបុច្ឆកតា** | ភាពជាអ្នកសាកសួរបញ្ហាផ្សេងៗ |
| **២.វត្ថុវិសុទ្ធករិយតា** | ការស្អាតទាំងកាយ ទាំងចិត្ត និង ទាំងវត្ថុ ។ |
| **៣.ឥន្ទ្រិយសមត្តបដិបាទនតា** | មានឥន្ទ្រីយ៍ ៥ ស្មើៗគ្នា ។ |
| **៤.ទុប្បញ្ញាបុគ្គលបរិវជ្ជនា** | គេចចេញពីមនុស្សអាក្រក់ ។ |
| **៥.បញ្ញាវន្តបុគ្គលសេវនា** | សមាគមនឹងមនុស្សមានបញ្ញា។ |
| **៦.គម្ភីរញាណចរិយ-បច្ចវេក្ខណា** | ពិចារណាញាណចរិយា ដែលជ្រាលជ្រៅ គឺពិចារណានូវការ |

ប្រព្រឹត្តនៃអ្នកដែលព្រមដោយបញ្ញាជាគ្រឿងត្រាស់ដឹង ។

៧.តទធិមុត្តតា — ភាពជាអ្នកបង្អោនចិត្តទៅក្នុងញាណនោះ ។

# ហេតុឲ្យកើតញាណវិប្បយុត្ត ៤

១.បញ្ញាអសំវត្តនិកកម្មុប្បនិស្សយតា — មានឧបនិស្ស័យក្នុងកម្មមិនប្រកបដោយបញ្ញា ។

២.សព្យាបជ្ឈលោកូបបត្តិតា — កើតក្នុងលោកដែលមានការបៀតបៀន ។

៣.ឥន្ទ្រិយអបរិបាកតា — មានឥន្ទ្រីយ៍ខ្សោយ ។

៤.កិលេសាទូរតា — មិនឆ្ងាយពីកិលេស ។

# ហេតុឲ្យកើតញាណវិប្បយុត្ត ៧

( ន័យទី ២ )

១.អបរិបុច្ឆកតា — មិនចូលចិត្តសួរបញ្ហាផ្សេងៗ ។

| | |
|---|---|
| ២.វត្ថុអវិសុទ្ធករិយតា | ការមិនស្អាតទាំងកាយ ទាំងចិត្ត និង ទាំងវត្ថុ ។ |
| ៣.ឥន្ទ្រិយអសមត្តបដិបាទនតា | មិនសំបូរដោយឥន្ទ្រីយ៍ ៥ ។ |
| ៤.ទុប្បញ្ញបុគ្គលសេវនា | សមាគមនឹងមនុស្សមិនមានបញ្ញា ។ |
| ៥.បញ្ញាវន្តបុគ្គលបរិវជ្ជនា | គេចពីមនុស្សមានបញ្ញា ។ |
| ៦.គម្ភីរញាណចរិយា-អបច្ចវេក្ខណា | មិនពិចារណាញាណចរិយាដែលជ្រាលជ្រៅ ។ |
| ៧.អតទធិមុត្តតា | មិនបង្អោនចិត្តទៅក្នុងញាណនោះ ។ |

# ហេតុឲ្យកើតអសង្ខារិក ៦

| | |
|---|---|
| ១.អសង្ខារិកកម្មជនិត-បដិសន្ធិកតា | បដិសន្ធិដោយកម្ម ដែលជាអសង្ខារិក ។ |
| ២.កល្លកាយចិត្តតា | មានការសប្បាយកាយនិងចិត្ត។ |

**៣.សីតុណ្ហាទីនំ ខមនពហុលតា** អត់ធន់ចំពោះក្តៅ និង ត្រជាក់ជាដើម ។

**៤.កត្តព្វកម្មេសុ ទិដ្ឋានិសំសតា** ឃើញប្រយោជន៍ ក្នុងការងារដែលគប្បីធ្វើ ។

**៥.កម្មេសុ ចិណ្ណវសិតា** មានការជំនាញក្នុងការងារទាំងឡាយ ។

**៦.ឧតុភោជនាទិសប្បាយលាភោ** មានអាកាស និង អាហារល្អជាដើម ។

ក្នុងវិសុទ្ធិមគ្គ សម្តែងសប្បាយ ៧ គឺ :-

**១.** អាវាស **២.** គោចរ **៣.** ភស្ស (ការនិយាយកថាវត្ថុ ១០) **៤.** បុគ្គល **៥.** ភោជនៈ **៦.** ឧតុ **៧.** ឥរិយាបថ ។

ក្នុងវិភាវិនីដីកា ពោលហេតុឲ្យកើតអសង្ខារិកដោយសង្ខេបថា:

**១. អាវាសប្បាយាទិ វសេន កាយចិត្តានំ កល្លភាវតោ** ព្រោះការដែលកាយនិងចិត្ត ជាធម្មជាតិអាចទៅបាន ក៏ដោយអំណាចនៃសប្បាយទាំងឡាយ មានអាវាសសប្បាយជាដើម ។

**២. បុព្វេ ទានាទីសុ កតបរិចយតាទីហិ** ព្រោះបុព្វចរិយាជាដើម ធ្លាប់ក្នុងការធ្វើបុណ្យ មានទានជាដើម ក្នុងកាលមុន ។

ចំណែក **ហេតុឲ្យកើតសសង្ខារិកនោះ** មានន័យផ្ទុយពីន័យអសង្ខារិក ហើយមានទំនង ដូចបានពោលទុកក្នុងសង្ខារភេទក្នុងលោភមូលចិត្តដែរ ។

# មហាកុសល ២ ប្រភេទ

## ១. មហាកុសលញាណវិប្បយុត្ត ៤ ដួង ។
## ២. មហាកុសលញាណសម្បយុត្ត ៤ ដួង ។

មហាកុសលញាណវិប្បយុត្ត ៤ ដួងនោះ ជាចិត្តប្រកបដោយកុសលហេតុ ២ គឺ អលោភហេតុ និង អទោសហេតុ ហៅថា **ទ្វិហេតុកចិត្ត** ។ ចំណែកមហាកុសល ញាណសម្បយុត្ត ប្រកបដោយហេតុ ៣ គឺ អលោភហេតុ អទោសហេតុ និង អមោហ-ហេតុ ហៅថា **តិហេតុកចិត្ត** ។

ការដែលមហាកុសលចិត្តជាញាណវិប្បយុត្ត មានអលោភ-ហេតុ និង អទោសហេតុកើតរួមជាមួយ អាស្រ័យដោយការធ្វើកុសលណាមួយ មានការឲ្យទាន រក្សាសីលជាដើម ការដែលកុសលនោះៗនឹងកើតឡើងបាន ក៏ព្រោះ ខណៈនោះមិនមានលោភៈមិនមានទោសៈ ប្រសិនបើនៅមានលោភៈ ក៏លំបាកនឹងលះបង់របស់

របរឲ្យជាទានបានដែរ ឬ កំពុងតែក្រោធក៏អញ្ជឹងដែរ ។

ដូច្នេះ កុសលចិត្តជាញាណវិប្បយុត្តនេះ ទើបមានត្រឹមតែអលោភៈ និងអទោសៈប៉ុណ្ណោះ កើតរួមជាមួយ ។

ចំណែកឯមហាកុសលញាណសម្បយុត្តនោះ ត្រូវមានកុសល-ចេតសិក ៣ ប្រភេទ កើតរួមជាមួយចិត្ត គឺ អលោភហេតុ អទោសហេតុ និង អមោហហេតុ ។

ក្នុងការធ្វើកុសលយ៉ាងណាក៏ដោយ បើប្រកបដោយបញ្ញា ក៏រមែងជាកុសលប្រសើរខ្ពស់បំផុត ។

# ហេតុឲ្យកើតបញ្ញា ៣ យ៉ាង

**១.សុតមយបញ្ញា** បញ្ញាកើតពីការស្តាប់ ។

**២.ចិន្តាមយបញ្ញា** បញ្ញាកើតពីការគិត ។

**៣.ភាវនាមយបញ្ញា** បញ្ញាកើតពីការភាវនា ។

បញ្ញាទាំងឡាយនឹងកើតឡើងបាន ក៏ត្រូវអាស្រ័យបច្ច័យ ឲ្យកើតដែរ មានការស្តាប់ជាដើម ។

ការស្តាប់ ក៏គឺ ការរៀន ការសិក្សា ហើយប្រយោជន៍ពីការស្តាប់ធម៌ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា “ ម្នាលភិក្ខុ

ឡាយ អានិសង្សនៃការស្តាប់ធម៌ ៥ ប្រការ នោះគឺ អ្នកស្តាប់តែង បានស្តាប់នូវរឿងដែលមិនទាន់ធ្លាប់ស្តាប់ ១ រឿងណាដែលធ្លាប់ស្តាប់ ហើយតែមិនទាន់យល់ច្បាស់ តែងយល់ច្បាស់ក្នុងរឿងនោះ ១ កំចាត់ បង់នូវការសង្ស័យបាន ១ ធ្វើឲ្យឃើញតាមសេចក្តីពិត ១ ចិត្តអ្នក ស្តាប់តែងថ្លាផូរផង់ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការ ស្តាប់ធម៌ ៥ ប្រការនេះឯង ” ( អង្គុត្តរ-បញ្ចក ) ។

**សុតមយប្បញ្ញា** នេះត្រូវអាស្រ័យអ្នកដទៃប្រាប់ ឬ រៀន សូត្រក្នុងសំណាក់អាចារ្យទើបបាន ហើយបញ្ញានេះជាបញ្ញាថ្នាក់ទាប។

ចំណែក **ចិន្តាមយបញ្ញា** នៃបុគ្គលជាអ្នកធម្មតា តែងកើត ព្រោះអាស្រ័យនូវការស្តាប់ជាដំបូងសិន ទើបកើតបាន ប៉ុន្តែចំពោះ អ្នកមានបារមីអប់រំមកល្អហើយ មិនចាំបាច់ស្តាប់ពីអ្នកដទៃ ក៏អាច កើតឡើងបានដែរ ។ ក្នុងអដ្ឋកថា សម្មោហវិនោទនី បានលើក យកព្រះពោធិសត្វទាំង ២ ជាឧទាហរណ៍ គឺ សព្វញ្ញូពោធិសត្វ និង បច្ចេកពោធិសត្វ ។ ព្រះពោធិសត្វទាំង ២ នេះ ក្នុងជាតិចុងក្រោយ អាចត្រឹមតែចិន្តាមយប្បញ្ញា ក៏សម្រេចមគ្គផលបានដែរ ។

ចំណែក **ភាវនាមយបញ្ញា** ជាបញ្ញាកើតពីភាវនានោះ បាន ដល់ ការចម្រើនវិបស្សនា ។

បញ្ញាទាំង ៣ នេះ ជាហេតុឲ្យបាននូវ កម្មស្សកតាបញ្ញា

( បញ្ញាដឹងថាសត្វទាំងឡាយមានកម្មជារបស់ខ្លួន ) សូម្បីសម្មាទិដ្ឋិ ១០ ក៏ឈ្មោះថា កម្មស្សកតាបញ្ញាដែរ ក្នុងអដ្ឋកថា ហៅថា **កម្មស្សកតាសម្មាទិដ្ឋិ ១០** ។

# សម្មាទិដ្ឋិ ១០

**១.អត្ថិ ទិន្នំ** ឃើញត្រូវថា ទានឲ្យហើយមានផល។

**២.អត្ថិ យិដ្ឋំ** ឃើញត្រូវថាការបូជាតូចមានផល ។

**៣.អត្ថិ ហុតំ** ឃើញត្រូវថា ការបូជាធំមានផល (បួងសួង ធ្វើសក្ការៈ ) ។

**៤.អត្ថិ សុកតទុក្កតានំ កម្មានំ ផលំវិបាកោ** ឃើញត្រូវថា ផលវិបាករបស់កម្មល្អអាក្រក់ដែលធ្វើហើយ មាន ។

**៥.អត្ថិ អយំលោកោ** ឃើញត្រូវថា លោកនេះ មាន ។

**៦.អត្ថិ បរោ លោកោ** ឃើញត្រូវថា លោកខាងមុខ មាន ។

**៧.អត្ថិ មាតា** ឃើញត្រូវថា មាតាមានគុណ ។

**៨.អត្ថិ បិតា** ឃើញត្រូវថា បិតាមានគុណ ។

**៩.អត្ថិសត្តា ឱបបាតិកា** ឃើញត្រូវថា សត្វទាំងឡាយដែលជា

ឱបបាតិក មាន ។

**១០.អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា** ឃើញត្រូវថា សមណព្រាហ្មណ៍ទាំង-ឡាយដែលធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ចំពោះលោកនេះ និងលោកខាងមុខ ហើយអាចដឹងនិង ប្រកាសបាន ជាអ្នកប្រព្រឹត្តល្អប្រតិបត្តិល្អ មានក្នុងលោកនេះ ។

# ចេតនាក្នុងមហាកុសលចិត្ត ៨ ដួង

ចេតនាក្នុងមហាកុសលចិត្ត ៨ ដួង សម្តែងបាន ២ ន័យ គឺ :-

**១.** ដោយកម្មទ្វារ ៣ និង ២ ដោយបុញ្ញកិរិយាវត្ថុ ១០ ។

## ១.មហាកុសលដោយកម្មទ្វារ ៣

- **កាយកម្ម ៣** គឺ ចេតនាវៀរចាកបាណាតិបាត ចេតនាវៀរចាកអទិន្នាទាន ចេតនាវៀរចាកកាមេសុមិច្ឆាចារៈ ។

- **វចីកម្ម ៤** គឺ ចេតនាវៀរចាកមុសាវាទ ចេតនាវៀរចាក

ចាកបិសុណាវាទ ចេតនាវៀរចាកផរុសវាទ ចេតនាវៀរចាក សម្ផប្បលាបវាទ ។

- **មនោកម្ម ៣** គឺ អនភិជ្ឈា ( មិនគិតរំពៃក្នុងវត្ថុរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន ) អព្យាបាទ( មិនព្យាបាទ ) សម្មាទិដ្ឋិ ( សេចក្តីយល់ឃើញត្រូវ ) ។

# អង្គធម៌របស់កុសលកម្មបថ ១០

| | |
|---|---|
| **១.កាយកម្ម ៣** | បានដល់ សម្មាកម្មន្តចេតសិក និង សម្មាអាជីវចេតសិក ។ |
| **២.វចីកម្ម ៤** | បានដល់ សម្មាវាចាចេតសិក និង សម្មាអាជីវចេតសិក ។ |
| **៣.មនោកម្ម ៣** | បានដល់ អនភិជ្ឈា(អលោភចេតសិក) អព្យាបាទ(អទោសចេតសិក) សម្មាទិដ្ឋិ (បញ្ញាចេតសិក) ។ |

ភារៈនៃការវៀរចាកបាប ឈ្មោះថា វិរតិចេតសិក(សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវៈ) ឬ ហៅថា វិរតិ ។ វិរតិ នេះ មាន ៣ ប្រភេទ គឺ :-

សម្បត្តវិរតិ ១ សមាទានវិរតិ ១ សេតុឃាតវិរតិ ១ ( អដ្ឋកថា កូដទន្តសូត្រ សុមង្គលវិលាសិនី ) ។

**សម្បត្តវិរតិ** បានដល់ ការវៀរចាកបាបដោយអធ្យាស្រ័យរបស់ខ្លួន គឺ ខ្លួនមិនបានទទួលសិក្ខាបទទេ ពេលនឹកដល់ជាតិគោត្រ ត្រកូល ឬ ប្រទេសជាដើម ។

**សម្មាទានវិរតិ** បានដល់ ការវៀរចាកបាបដោយសមាទានសិក្ខាបទ មានសីល ៥ សីល ៨ ជាដើមថា ពីពេលនេះទៅខ្ញុំនឹងវៀរចាកការសម្លាប់សត្វជាដើម សូម្បីព្រោះហេតុនៃជីវិត ក៏ដោយ ក៏សូមសមាទាននូវការវៀរចាក ។

**សេតុឃាតវិរតិ** គឺសមុច្ឆេទវិរតិ បានដល់ ការវៀរចាកបាបដែលសម្បយុត្តដោយមគ្គ របស់ព្រះអរិយបុគ្គលទាំងឡាយ ។

# ២.មហាកុសលដោយបុញ្ញកិរិយាវត្ថុ ១០

**១.ទានមយ** បុណ្យសម្រេចដោយការឲ្យទាន)គឺ លះបង់វត្ថុឲ្យជាប្រយោជន៍ដល់អ្នកដទៃ) ។

**២.សីលមយ** បុណ្យសម្រេចដោយសីល គឺ វិរតិទុច្ចរិតកម្ម ។

**៣.ភាវនាមយ** បុណ្យសម្រេច ដោយការចំរើនសមថៈ និង វិបស្សនា ។

**៤.អបចាយនមយ** បុណ្យសម្រេច ដោយការគោរពថ្វាយបង្គំចំពោះបុគ្គលដែលគួរគោរព ។

**៥.វេយ្យាវច្ចមយ** បុណ្យសម្រេច ដោយការជួយសង្គ្រោះនូវការងារផ្សេងៗ ។

**៦.បត្តិទានមយ** បុណ្យសម្រេចដោយការឧទ្ទិសចំណែកកុសលឲ្យអ្នកដទៃអនុមោទនា ។

**៧.បត្តានុមោទនាមយ** បុណ្យសម្រេច ដោយការអនុមោទនាក្នុងកុសលនៃអ្នកដទៃ ។

**៨.ធម្មទេសនាមយ** បុណ្យសម្រេចដោយការសម្តែងធម៌ ។

**៩.ធម្មស្សវនមយ** បុណ្យសម្រេចដោយការស្តាប់ធម៌ ។

**១០.ទិដ្ឋុជុកម្ម** បុណ្យសម្រេចដោយការឃើញត្រូវត្រង់តាមធម៌ ។

បុញ្ញកិរិយាវត្ថុ ១០ នេះ កាលបើពោលដោយសង្ខេប ក៏មានត្រឹម ៣ ប៉ុណ្ណោះ គឺ ទានមយ ១ បត្តិទានមយ ១ បត្តានុមោទនាមយ ១ រួមទាំង ៣ នេះ សង្គ្រោះចូលក្នុង **ទាន** ។

សីលមយ ១ អបចាយនមយ ១ វេយ្យាវច្ចមយ ១ រួមទាំង ៣ នេះ សង្គ្រោះចូលក្នុង **សីល** ។

ភាវនាមយ ១ ធម្មទេសនាមយ ១ ធម្មស្សវនមយ ១ រួមទាំង ៣ នេះ សង្គ្រោះចូលក្នុង **ភាវនា** ។

ចំណែក**ទិដ្ឋុជុកម្ម** សង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ គឺ ប្រព្រឹត្តទៅក្នុងទានក៏បាន ប្រព្រឹត្តទៅក្នុងសីលក៏បាន ប្រព្រឹត្តទៅក្នុងភាវនាក៏បាន ។ ព្រោះបើគ្មានទិដ្ឋុជុកម្មទេ កុសលនោះៗ ក៏រមែងមិនបរិបូណ៌ ៕

# ចំណែក
# មហាកុសល ៨ ប្រកបដោយចេតនា ៤

**១. បុព្វចេតនា** ចេតនាមុនធ្វើ ។
**២. មុញ្ចនចេតនា** ចេតនាកំពុងធ្វើ ។
**៣. អបរចេតនា** ចេតនាពេលបានធ្វើហើយ ។
**៤. អបរាបរចេតនា** ចេតនាពេលនឹកដល់កុសលដែលខ្លួនបានធ្វើយូរយាណាស់មកហើយ ។

ចេតនាក្នុងមហាកុសល ៨ ដែលជា តិហេតុកកុសល និង ទុហេតុកកុសល មាន ២ ប្រភេទ គឺ :-

**១. ឧក្កដ្ឋកុសលំ** កុសលថ្នាក់ឧក្រិដ្ឋ ។
**២. ឱមកកុសល** កុសលថ្នាក់រង ។

ក្នុងបណ្តាកុសលទាំង ២ ប្រភេទនេះ កាលបុគ្គលឲ្យទាន ឬរក្សាសីលជាដើម មុនធ្វើ (បុព្វចេតនា) ក្តី កំពុងធ្វើ (មុញ្ចន-ចេតនា) ក្តី ធ្វើរួចហើយ (អបរចេតនា) ក្តី មានចិត្តមិនប្រកបដោយអកុសល គឺមានចេតនាបរិសុទ្ធទាំង ៣ កាល ផលនៃទានក្តី

ឬ ផលនៃសីលក្តី របស់អ្នកនោះ ទោះជាតិហេតុកកុសល ឬទុហេតុកកុសលក៏ដោយ ក៏ចាត់ជា **ឧក្កដ្ឋកុសល** ដែរ ។ ប៉ុន្តែបើបុព្វចេតនាក្តី មុញ្ចនចេតនាក្តី អបរចេតនាក្តី មានអកុសលលាយឡំ គឺ មានចេតនាមិនបរិសុទ្ធក្នុងកាលណាមួយ កុសលនោះទោះជាតិហេតុកកុសល ឬទុហេតុកកុសលក៏ដោយ ក៏ចាត់ជាឱមកកុសល ។

# ចំណែកកុសលដោយឧក្កដ្ឋនិងឱមកៈ ៤

**១. តិហេតុកកុសល** ប្រភេទ ឧក្កដ្ឋៈ (ឧក្រិដ្ឋ)
**២. តិហេតុកកុសល** ប្រភេទ ឱមកៈ (ថ្នាក់រង)
**៣. ទុហេតុកកុសល** ប្រភេទ ឧក្កដ្ឋៈ (ឧក្រិដ្ឋ)
**៤. ទុហេតុកកុសល** ប្រភេទ ឱមកៈ (ថ្នាក់រង)

# ចំណែកកុសលដោយឧក្កដ្ឋៈនិងឱមកៈ ៨

**១.**តិហេតុកកុសល ឧក្រិដ្ឋ ( ថ្នាក់ទី ១ ) ហៅថា **តិហេតុកឧក្កដ្ឋុក្កដ្ឋៈ** ។

**២.**តិហេតុកកុសល ឧក្រិដ្ឋ ( ថ្នាក់រង ) ហៅថា **តិហេតុកឧក្កដ្ឋោមកៈ** ។

៣.តិហេតុកកុសល ឱមកៈ ( ថ្នាក់ទី ១ ) ហៅថា **តិហេតុកឱមកុក្កដ្ឋៈ ។**

៤.តិហេតុកកុសល ឱមកៈ ( ថ្នាក់រង ) ហៅថា **តិហេតុកឱមកោមកៈ ។**

៥.ទុហេតុកកុសល ឧក្រិដ្ឋ ( ថ្នាក់ទី ១ ) ហៅថា **ទុហេតុកឧក្កដ្ឋុក្កដ្ឋៈ ។**

៦.ទុហេតុកកុសល ឧក្រិដ្ឋ ( ថ្នាក់រង ) ហៅថា **ទុហេតុកឧក្កដ្ឋោមកៈ ។**

៧.ទុហេតុកកុសល ឱមកៈ ( ថ្នាក់ទី ១ ) ហៅថា **ទុហេតុកឱមកុក្កដ្ឋៈ ។**

៨.ទុហេតុកកុសល ឱមកៈ ( ថ្នាក់រង ) ហៅថា **ទុហេតុកឱមកោមកៈ ។**

កុសលទាំង ៨ ប្រការ ដែលបានពោលមកនេះ អាស្រ័យដោយមុញ្ចនចេតនាជាប្រធាន គឺ ខណៈដែលមុញ្ចនចេតនាកើតឡើង បើប្រកបដោយតិហេតុ ហៅថា **តិហេតុកកុសល** ប៉ុន្តែបើមុញ្ចន-ចេតនាប្រកបដោយទុហេតុ កុសលនោះក៏ហៅថា **ទុហេតុកកុសល ៕**

# ញាណសម្បយុត្ត ៤ ន័យ

| | | |
|---|---|---|
| ន័យទី១ តិហេតុកឧក្កដ្ឋុក្កដ្ឋះ | បុព្វចេតនា | ល្អ |
| | មុញ្ចនចេតនា | ល្អ |
| | អបរចេតនា | ល្អ |
| | អបរាបរចេតនា | ល្អ |
| ន័យទី២ តិហេតុកឧក្កដ្ឋោមកះ | បុព្វចេតនា | ល្អ |
| | មុញ្ចនចេតនា | ល្អ |
| | អបរចេតនា | ល្អ |
| | អបរាបរចេតនា | មិនល្អ |
| ន័យទី៣ តិហេតុកឱមកុក្កដ្ឋះ | បុព្វចេតនា | ល្អ |
| | មុញ្ចនចេតនា | ល្អ |
| | អបរចេតនា | មិនល្អ |
| | អបរាបរចេតនា | ល្អ |
| ន័យទី៤ តិហេតុកឱមកោមកះ | បុព្វចេតនា | ល្អ |
| | មុញ្ចនចេតនា | ល្អ |
| | អបរចេតនា | មិនល្អ |
| | អបរាបរចេតនា | មិនល្អ |

# ញាណវិប្បយុត្ត ៤ ន័យ

| | | |
|---|---|---|
| ន័យទី១ ទុហេតុកឧក្កដ្ឋុក្កដ្ឋះ | បុព្វចេតនា | ល្អ |
| | មុញ្ចនចេតនា | ល្អ |
| | អបរចេតនា | ល្អ |
| | អបរាបរចេតនា | ល្អ |
| ន័យទី២ ទុហេតុកឧក្កដ្ឋោមកះ | បុព្វចេតនា | ល្អ |
| | មុញ្ចនចេតនា | ល្អ |
| | អបរចេតនា | ល្អ |
| | អបរាបរចេតនា | មិនល្អ |
| ន័យទី៣ ទុហេតុកឱមក្កុដ្ឋុក្កដ្ឋះ | បុព្វចេតនា | ល្អ |
| | មុញ្ចនចេតនា | ល្អ |
| | អបរចេតនា | មិនល្អ |
| | អបរាបរចេតនា | ល្អ |
| ន័យទី៤ ទុហេតុកឱមកោមកះ | បុព្វចេតនា | ល្អ |
| | មុញ្ចនចេតនា | ល្អ |
| | អបរចេតនា | មិនល្អ |
| | អបរាបរចេតនា | មិនល្អ |

# ចំណែកអានិសង្សតាមន័យនៃតិហេតុក

**ន័យទី ១ ( តិហេតុកឧក្កដ្ឋុក្កដ្ឋៈ )** ជាញាណសម្បយុត្ត ប្រភេទទី ១ បានទទួលវិបាក ១៦ ដួង គឺ មហាវិបាក ៨ ដួង និងអហេតុកកុសលវិបាក ៨ ដួង ហើយមានអានិសង្សខ្ពស់បំផុត អាចឲ្យកើតបានក្នុងភូមិមនុស្សនិងទេវតា ហើយបរិបូរណ៍ព្រមដោយ មនុស្សសម្បត្តិ សួគ៌សម្បត្តិ ទាំងប្រកបដោយបញ្ញា អាចចំរើន មគ្គផល និព្វាន និង ឈានសមាបត្តិ ឲ្យកើតឡើងបានក្នុងបច្ចុប្បន្ន ជាតិនេះ ដែលចាត់ជាបុគ្គលប្រណីតក្រៃលែង មានសេចក្ដីសុខតាំង ពីកើតមករហូតដល់ចាស់ស្លាប់ ។

**ន័យទី ២ ( តិហេតុកឧក្កដ្ឋោមកៈ )** ជាញាណសម្បយុត្ត ប្រភេទទី ២ បានទទួលវិបាក ១៦ ដួង ដូចគ្នានឹងន័យទី ១ អាចកើត បានក្នុងភូមិមនុស្សនិងទេវតា ប៉ុន្តែល្អមិនរហូត នៅពេលជាខាង ក្រោយ មិនល្អ និងមានសតិ-បញ្ញា ។

**ន័យទី ៣ ( តិហេតុកឱមកុក្កដ្ឋៈ )** ជាញាណសម្បយុត្ត ប្រភេទទី ៣ បានទទួលវិបាក ១២ ដួង គឺ មហាវិបាកញាណ-វិប្បយុត្ត ៤ ដួង និងអហេតុកកុសលវិបាក ៨ ដួង អាចកើតបាន ក្នុងភូមិមនុស្ស និង ទេវតា សេចក្ដីសុខក្នុងកាមគុណមិនសូវសម្បូរចុះ

ឡើងៗ ពេលក្មេងមិនល្អ ពេលពេញវ័យល្អ ពេលកណ្តាលមនុស្ស ល្អ ពេលចាស់មិនល្អ ។

**ន័យទី ៤ ( តិហេតុកឱមកោមកៈ )** ជាញាណសម្បយុត្ត ប្រភេទទី ៤ បានទទួលវិបាក ១២ ដួង ដូចគ្នានឹងន័យទី ៣ គឺអាច កើតបានក្នុងភូមិមនុស្សនិងទេវតា សេចក្តីសុខមិនស្មើ សម្បត្តិតិច ជាង គឺ ពេលក្មេងមិនល្អ ពេលពេញវ័យល្អ ពេលកណ្តាលមនុស្ស មិនល្អ ពេលចាស់មិនល្អ ។

# ចំណែកអានិសង្សតាមន័យនៃទុហេតុកៈ

**ន័យទី ១ ( ទុហេតុកឧក្កដ្ឋុក្កដ្ឋៈ )** ជាញាណវិប្បយុត្ត ប្រភេទទី ១ បានទទួលវិបាក ១២ ដួង គឺ មហាវិបាកញាណ-វិប្បយុត្ត ៤ ដួង និងអហេតុកកុសលវិបាក ៨ ដួង អាចកើត បានក្នុងភូមិមនុស្សនិងទេវតា ជាបុគ្គលសម្បូរដោយសម្បត្តិ មាន សេចក្តីសុខតាំងពីក្មេងរហូតដល់ស្លាប់ ប៉ុន្តែមិនអាចចំរើនមគ្គផល និព្វាន ឈានសមាបត្តិឲ្យកើតឡើងបានទេ ព្រោះជាវិបាកដែលមិន ប្រកបដោយបញ្ញា ។

**ន័យទី ២ ( ទុហេតុកឧក្កដ្ឋោមកៈ )** ជាញាណវិប្បយុត្ត

ប្រភេទទី ២ បានទទួលវិបាក ១២ ដួង ដូចគ្នានឹងន័យទី ១ អាចកើតបានក្នុងភូមិមនុស្សនិងទេវតា មានសេចក្ដីសុខរហូត ប៉ុន្តែពេលចាស់មិនល្អនិងមិនអាចញ៉ាំងមគ្គផលនិព្វាន ឈានសមាបត្តិឲ្យកើតបានទេ។

**ន័យទី ៣ ( ទុហេតុកឱមកុក្កដ្ឋះ )** ជាញាណវិប្បយុត្ត ប្រភេទទី ៣ មានអហេតុកកុសលវិបាក ៨ ដួង តែប៉ុណ្ណោះ តែអាចកើតបានក្នុងភូមិមនុស្ស និង ទេវតា មានសេចក្ដីសុខតិចជាងប្រភេទទី ២ ទៀត ។

**ន័យទី ៤ ( ទុហេតុកឱមកោមកះ )** ជាមហាកុសលញាណវិប្បយុត្តប្រភេទថ្នាក់ទាបបំផុត ញ៉ាំងឲ្យអហេតុកកុសលវិបាក ៨ ដួង កើតបានក្នុងសុគតិភូមិ គឺ ភូមិមនុស្ស និង ទេវតាជាន់ទាបជាបុគ្គលជាន់ទាបណាស់ ឬមិនដូច្នោះទេ គឺ មានសតិមិនបរិបូរណ៍ ជាមនុស្សឆ្កួតល្ងីល្ងើ ជាមនុស្សគថ្លង់ ខ្វាក់ខ្វិន ពិការមកពីកំណើត ថែមទាំងមិនអាចចំរើនសមថៈ វិបស្សនាបានទៀតផង ៕

# ផលក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល នៃមហាកុសលចេតនា

ចេតនានៃមហាកុសលញាណសម្បយុត្តក្ដី ញាណវិប្បយុត្តក្ដី

ក្នុងសង្គហៈ មានអធិប្បាយទុកអំពីការឲ្យផលថា ចេតនាក្នុងការធ្វើកុសលនោះ បើចេតនាល្អ ក្នុងកាលទាំង ៤ ជា **កុសលថ្នាក់ឧក្កដ្ឋុក្កដ្ឋៈ ,** បើចេតនាល្អក្នុងកាលទាំង ៣ តែអបរាបរចេតនាមិនល្អនោះ ជា **កុសលថ្នាក់ឧក្កដ្ឋោមកៈ ,** ប្រសិនបើបុព្វចេតនាល្អមុញ្ចនចេតនាល្អ អបរាបរចេតនាល្អ តែអបរចេតនាមិនល្អនោះ ជា **កុសលថ្នាក់ឱមកុក្កដ្ឋៈ** តែបើបុព្វចេតនាល្អ មុញ្ចនចេតនាល្អហើយសល់ពីនោះមិនល្អ នោះជាកុសលថ្នាក់ឱមកោមកៈ ។

ការឲ្យផលក្នុងបដិសន្ធិកាល និង ក្នុងបវត្តិកាល បានពោលទុកថា :

**១.តិហេតុកឧក្កដ្ឋៈកុសល** ឲ្យបដិសន្ធិជា **តិហេតុកវិបាក** ហើយក្នុងបវត្តិកាល រមែងឲ្យវិបាក ១៦ ដួង គឺមហាវិបាក ៨ និងអហេតុកកុសលវិបាក ៨ ។

**២.តិហេតុកឱមកៈ និង ទុហេតុកឧក្កដ្ឋៈកុសល** ឲ្យបដិសន្ធិជា **ទុហេតុកវិបាក** ហើយក្នុងបវត្តិកាល រមែងឲ្យវិបាក ១២ ដួង វៀរតិហេតុកវិបាក គឺ មហាវិបាកញាណសម្បយុត្ត ៤ ។

**៣.ទុហេតុកឱមកៈ** ឲ្យបដិសន្ធិជា **អហេតុកវិបាក** តែប៉ុណ្ណោះ ហើយក្នុងបវត្តិកាល ឲ្យវិបាក ៨ ជាអហេតុកវិបាក ៨ ដួង

នោះឯង ។

# នាមនៃកុសលចិត្ត

ក្នុងកុសលចិត្ត ៨ ដួងនេះ ហៅបានច្រើនយ៉ាង មានឈ្មោះដូចតទៅនេះ គឺ :

**១- កាមាវចរកុសល**

**២- កាមសោភណកុសល**

**៣- សហេតុកកុសល**

**៤- មហាកុសល**

១. ពាក្យថា **កាមាវចរកុសលនេះ** សំគាល់កុសលនេះជាហេតុនឹងញ៉ាំងឲ្យផលកើតឡើងបាន ត្រឹមតែក្នុងកាមភូមិ ឬ ជាកាមបុគ្គល ក្នុងភូមិក្រៃលែងជាង ឬបុគ្គលខ្ពស់ជាងពីនេះ ដូចជាព្រហ្មបុគ្គលជាដើម មិនអាចបានឡើយ ។ ម្យ៉ាងទៀត ដោយហេតុថា កុសលចិត្ត ៨ ដួងនេះ ក៏ជាកុសលញ៉ាំងឲ្យកើតបានតែកាមវិបាកចិត្តប៉ុណ្ណោះ ហើយនឹងឲ្យសេចក្ដីសុខ ក៏បានត្រឹមតែអាស្រ័យកើតអំពីកាមារម្មណ៍ប៉ុណ្ណោះ ទើបហៅចិត្តដែលជាកុសលទាំង ៨ ដួងនេះថា **កាមាវចរកុសល** យ៉ាងនេះឯង ។

២. ពាក្យថា **កាមសោភណកុសលនោះ** ព្រោះហេតុថា ចិត្ត ៨ ដួង នេះ ប្រកបដោយសោភណចេតសិក ទើបហៅចិត្តនេះថា **កាមសោភណកុសល** យ៉ាងនេះឯង ។

៣. ពាក្យថា **សហេតុកកុសល** ព្រោះថាចិត្ត ៨ ដួង នេះ ប្រកបជាមួយហេតុ គឺ អលោភហេតុ អទោសហេតុ និងអមោហ-ហេតុ ទើបហៅចិត្តនេះថា **សហេតុកកុសល** យ៉ាងនេះឯង ។

៤. ពាក្យថា **មហាកុសលនោះ** ព្រោះជាកុសលទូលំ-ទូលាយណាស់ ដោយហេតុថា កុសលចិត្ត ៨ ដួង នេះ អាចកើតបានក្នុងបុញ្ញកិរិយាវត្ថុ ១០ អាចប្រព្រឹត្តទៅបាន ក្នុងអារម្មណ៍ទាំង ៦ តាមទ្វារទាំង ៦ អាចកើតបានក្នុងបុគ្គលទាំង ១១ ពួក ( វៀរព្រះអរហន្ត ) និងអាចប្រព្រឹត្តទៅបាន ជាកាយកម្ម វចីកម្ម មនោកម្ម ទាំងថោកទាប កណ្តាល ប្រណីតផង ដូចបានពោលក្នុងវិធីរាប់កុសលចិត្តដោយពិស្តារ រួចហើយ ដែលគណនាបានដល់ ១៥.១២០ ដួង ។

# ចំណែកមហាកុសល ៨ ដោយន័យផ្សេងៗ

**១. ដោយជាតិ** ជាកុសលជាតិ ។

| | |
|---|---|
| ២. ដោយភូមិ | ជាកាមភូមិ(កើតបាន ៣០ ភូមិ) ។ |
| ៣. ដោយវេទនា | ជាសោមនស្ស ៤ និងឧបេក្ខា ៤ ។ |
| ៤. ដោយហេតុ | ជានហេតុ ជាសហេតុកចិត្ត ៨ ។ |
| ៥. ដោយសម្បយុត្ត | ជាញាណសម្បយុត្ត ៤ និង ញាណ-វិប្បយុត្ត ៤ ។ |
| ៦. ដោយសង្ខារ | ជាអសង្ខារិក ៤ ជាសសង្ខារិក ៤ ។ |
| ៧. ដោយសោភណៈ | ជាកាមសោភណចិត្ត ។ |
| ៨. ដោយឈាន | ជាអឈានកុសលចិត្ត ។ |
| ៩. ដោយលោកិយ | ជាលោកិយចិត្ត ។ |
| ១០.ដោយកិច្ច | ជាចិត្តធ្វើជវនកិច្ច ។ |
| ១១.ដោយអារម្មណ៍ | ដឹងនូវអារម្មណ៍ទាំង ៦ ។ |
| ១២.ដោយទ្វារ | កើតបានទាំងទ្វារ ៦ ។ |
| ១៣.ដោយវត្ថុ | កើតដោយអាស្រ័យហទយវត្ថុ ។ |
| ១៤.ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ ។ |

( មហាកុសល ៨ ចប់ )

# កាមាវចរវិបាកចិត្ត
# ឬ មហាវិបាកចិត្ត ៨

កាមាវចរកុសលចិត្ត ៨ ដួង ឬមហាកុសលចិត្ត ៨ ដួង ជាបច្ច័យ ឲ្យផលជាសហេតុកកុសលវិបាកចិត្ត ៨ ដួង ឬ មហា-វិបាកចិត្ត ៨ ដួង ហើយឲ្យផលជា អហេតុកកុសលវិបាកចិត្ត ៨ ដួងទៀត រួមជាកុសលវិបាកចិត្ត ១៦ ដួង ប៉ុន្តែការឲ្យផលនៃវិបាកទាំង ២ ប្រភេទនេះ ខុសគ្នា គឺ :

បណ្តាអហេតុកកុសលវិបាកចិត្ត ៨ នោះ មានអហេតុក-កុសលវិបាកឧបេក្ខាសន្តីរណចិត្ត ១ ដួង ធ្វើបដិសន្ធិកិច្ចក្នុងមនុស្សភូមិ ១ ក្នុងចាតុម្មហារាជិកាភូមិ ១ ហើយក្នុងបវត្តិកាល អហេតុ-កកុសលវិបាកចិត្តទាំង ៨ ដួង កើតឡើងទទួលផលរបស់កុសលកម្មបាន ក្នុងកាមភូមិ ១១ និង ក្នុងរូបភូមិ ១៥ ( វៀរអសញ្ញសត្តភូមិ ) តាមសមគួរដល់ទ្វារ និង អារម្មណ៍ ។

ចំណែកសហេតុកវិបាកចិត្តទាំង ៨ ដួង ឲ្យផលបានក្នុងសុគតិភូមិ ៧ ប៉ុណ្ណោះ គឺ ញុំាំងផលបដិសន្ធិកិច្ចក្នុងបដិសន្ធិកាល ជាភវង្គកិច្ច និង តទាលម្ពណកិច្ច ក្នុងបវត្តិកាល ។

ពាក្យថា **វិបាក** មានវិគ្រោះថា ធម៌ដែលជាផលរបស់កុសល

និង អកុសល ឈ្មោះថា វិបាក ហើយផលរបស់កុសល និង អកុសលនេះ មិនប្រកបជាមួយគ្នានិងគ្នាទេ ធ្ងន់ និង ស្រាល ក៏មិនស្មើគ្នាដែរ ។ ផលនៃកុសលជាឥដ្ឋារម្មណ៍ ផលនៃអកុសលជាអនិដ្ឋារម្មណ៍ ។

ក្នុងអដ្ឋសាលិនី សម្តែងផល ២ យ៉ាង គឺ :

**១. មុខយផល** ផលដោយត្រង់ បានដល់ ធម៌ដែលជាវិបាក គឺ ចិត្តនិងចេតសិក កើតឡើងទទួលផលនៃកម្ម ដែលបានធ្វើទុកមកហើយ ។

**២. សាមញ្ញផល** បានដល់ ផលដែលស្មើគ្នា ដែលជាផលដោយអម បានដល់ កម្មជរូប មានហទយរូបជាដើម ដែលកើតព្រមនឹងចិត្ត ក្នុងបដិសន្ធិកាល ។

ក្នុងទីនេះ លោកបំណងយកមុខយផល គឺ ផលដោយត្រង់ បានដល់ មហាវិបាកចិត្ត ៨ ដួង នោះឯង ។ ដូចបាលីដែលលោកពោលទុកថា :

**១. សោមនស្សសហគត ញាណសម្បយុត្ត អសង្ខារិក** = ចិត្តដែលកើតព្រមនឹងសោមនស្ស ហើយប្រកបដោយញាណ ជាអសង្ខារិក ១ ។

**២. សោមនស្សសហគត ញាណសម្បយុត្ត សសង្ខារិក =** ចិត្តដែលកើតព្រមនឹងសោមនស្ស ហើយប្រកបដោយញាណ ជាសសង្ខារិក ១ ។

**៣. សោមនស្សសហគត ញាណវិប្បយុត្ត អសង្ខារិក =** ចិត្តដែលកើតព្រមនឹងសោមនស្ស មិនប្រកបដោយញាណ ជាអសង្ខារិក ១ ។

**៤. សោមនស្សសហគត ញាណវិប្បយុត្ត សសង្ខារិក =** ចិត្តដែលកើតព្រមនឹងសោមនស្ស មិនប្រកបដោយញាណ ជាសសង្ខារិក ១ ។

**៥. ឧបេក្ខាសហគត ញាណសម្បយុត្ត អសង្ខារិក =** ចិត្តកើតព្រមនឹងឧបេក្ខា ប្រកបដោយញាណ ជាអសង្ខារិក ១ ។

**៦. ឧបេក្ខាសហគត ញាណសម្បយុត្ត សសង្ខារិក =** ចិត្តកើតព្រមនឹងឧបេក្ខា ប្រកបដោយញាណ ជាសសង្ខារិក ១ ។

**៧. ឧបេក្ខាសហគត ញាណវិប្បយុត្ត អសង្ខារិក =** ចិត្តកើតព្រមនឹងឧបេក្ខា មិនប្រកបដោយញាណ ជាអសង្ខារិក ១ ។

**៨. ឧបេក្ខាសហគត ញាណវិប្បយុត្ត សសង្ខារិក =** ចិត្តកើតព្រមនឹងឧបេក្ខាមិនប្រកបនឹងញាណ ជាសសង្ខារិក ១ ។

# មហាវិបាកផ្សេងពីមហាកុសល

មហាកុសលទាំងឡាយ មានច្រើនដោយកម្ម ( កាយកម្ម វចីកម្ម មនោកម្ម ) ដោយទ្វារ ( ៦ ទ្វារ ) ដោយកម្មបថ ដោយបុញ្ញកិរិយាវត្ថុ , ចំណែក **មហាវិបាក ៨** នេះមិនមានទេ ព្រោះមហាវិបាក ៨ ឲ្យវិញ្ញត្តិកើតមិនបាន គឺមិនធ្វើឲ្យវិបាកកើតទៀតទេ ។

ម្យ៉ាងទៀត ករុណា មុទិតា វិរតិ ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ រួមទាំង ៥ នេះ ជាមហាកុសលប៉ុណ្ណោះ ចំណែកមហាវិបាក ៨ មិនមានទេ ព្រោះ ករុណា និង មុទិតា មានសត្វជាអារម្មណ៍ និង ព្រោះព្រះមានព្រះភាគត្រាស់ថា សិក្ខាបទ ៥ ជាកុសល តែប៉ុណ្ណោះ ។

វិបាកធម៌ដែលជាអសង្ខារិក និង សសង្ខារិកនោះ ដូចនឹងមហាកុសល គឺកុសលជាអសង្ខារិក វិបាកក៏ជាអសង្ខារិក , កុសលជាសសង្ខារិក វិបាកក៏ជាសសង្ខារិក ។ ហើយនិង វិបាកនៃកុសលដែលថោកទាប ក៏រមែងថោកទាប , វិបាកនៃកុសលដែលជាកណ្តាលក៏រមែងជាកណ្តាល , វិបាកនៃកុសលប្រណីតក៏រមែងប្រណីត ។

ហើយក្នុងវិបាកទាំងនេះ សូម្បីធម៌ដែលជាអធិបតីទាំងឡាយក៏មិនមានដែរ ព្រោះមិនធ្វើឆន្ទៈជាដើម ឲ្យបានជាធុរៈកើតឡើងឡើយ ។

# ស្ថានដែលឲ្យផលនៃមហាវិបាក ៨ មាន ៤ ស្ថាន

១. **បដិសន្ធិស្ថាន** ធ្វើកិច្ចបដិសន្ធិ ។
២. **ភវង្គស្ថាន** ធ្វើកិច្ចរក្សាភពជាតិ ។
៣. **ចុតិស្ថាន** ធ្វើកិច្ចឃ្លាតចាកភព ។
៤. **តទាលម្ពណស្ថាន** ធ្វើកិច្ចទទួលអារម្មណ៍តពីជវនៈ ។

តើវិបាកទាំងនោះឲ្យផលយ៉ាងដូចម្តេច ?

វិបាកទាំងនោះ ឲ្យផលក្នុង**បដិសន្ធិស្ថាន**មុន គឺ ក្នុងពេលកាន់យកបដិសន្ធិនៃអ្នកមានបុណ្យដែលជាទុហេតុកៈ និងតិហេតុកៈ ឲ្យកើតក្នុងពពួកមនុស្ស ឬក្នុងទេវតាជាន់កាមាវចរភូមិ ។ កាលណាបដិសន្ធិរលត់ទៅហើយ ក៏ឲ្យផលជា**ភវង្គស្ថាន**ក្នុងបវត្តិកាល រហូតអស់អាយុ ៦០ ឆ្នាំខ្លះ ឬ ៨០ ឆ្នាំខ្លះ ឬ ១ អសង្ខេយ្យខ្លះ តាមសមគួរដល់អាយុខេយ្យនៃសត្វក្នុងភូមិដែលខ្លួនរស់នៅ ។ ឲ្យផលជា**តទាលម្ពណស្ថាន** ក្នុងអារម្មណ៍ដែលមានកម្លាំងក្នុងទ្វារ ៦ គឺទទួលអារម្មណ៍បន្តពីជវនចិត្ត តទាលម្ពណនេះកើតបានចំពោះតែក្នុង

កាមសត្វដែលនៅក្នុងកាមភូមិប៉ុណ្ណោះ ។ ឲ្យផលជា**ចុតិស្ថាន**ក្នុង មរណ កាលនៃភពដែលរស់នៅនោះ គឺមហាវិបាកចិត្តតែមួយប្រភេទ ដែល កាន់យកបដិសន្ធិនោះឯង ធ្វើចុតិកិច្ចឃ្លាតចាកភពនោះៗ ។

# មហាវិបាកចែកសត្វឲ្យផ្សេងគ្នា

មហាវិបាក ៨ ដួង នេះ រមែងចែកសត្វឲ្យប្រព្រឹត្តទៅតាម កម្ម គឺ បដិសន្ធិក្នុងកាមសុគតិភូមិ ៧ តាមសមគួរដល់កម្លាំងនៃ មហាកុសលចិត្តនោះ និងធ្វើសត្វឲ្យផ្សេងគ្នា ទោះជាកើតនៅក្នុង ភូមិជាមួយគ្នាក៏ដោយ ។ ឯកម្មដែលចែកសត្វឲ្យផ្សេង ៗ គ្នានោះ ក៏ព្រោះកិលេស និងកម្លាំងនៃសទ្ធាជាដើមក្នុងអតីតកាលនោះឯង ។ សូម្បីតែការឲ្យទាន តែមួយប៉ុណ្ណោះ វិបាកនៃទាននោះក៏នៅតែចែក សត្វឲ្យកើតក្នុងទីកន្លែងផ្សេងៗគ្នា ដល់ទៅ ៧ កន្លែងដែរ គឺ :-

**១**.អ្នកណាមួយឲ្យទាន ដោយសង្ឃឹមផលណាមួយក្នុងភពខាង មុខ ស្លាប់ហើយនឹងទៅកើតជាទេវតាជាន់ចាតុម្មហារាជ ។

**២**.អ្នកណាមួយឲ្យទាន ដោយមិនសង្ឃឹមផលទេ ដោយគិតថា ការឲ្យទានជាការប្រព្រឹត្តនូវអំពើល្អ ស្លាប់ហើយនឹងទៅកើតជាទេវតា ជាន់តាវតឹង្ស ។

៣.បុគ្គលណាមួយឲ្យទាន ដោយគិតថា ជីដូនជីតា ម៉ែឪ ធ្លាប់ធ្វើមកហើយ ដូច្នេះ គួរតែធ្វើបន្តទៅទៀតកុំឲ្យអស់ប្រពៃណីស្លាប់ ហើយក៏នឹងទៅកើតជាទេវតាជាន់យាមា ។

៤.បុគ្គលណាមួយឲ្យទាន ដោយមេត្តា ប្រាថ្នានឹងឲ្យអ្នកទទួលទានមានសេចក្ដីសុខ មិនមានការលំបាក ស្លាប់ហើយនឹងទៅកើតជាទេវតាជាន់តុសិត ។

៥.បុគ្គលណាមួយឲ្យទាន ដើម្បីបដិបត្តិតាមអ្នកប្រាជ្ញ ដែលលោកឲ្យទានមកពីកាលមុន ស្លាប់ហើយនឹងទៅកើតជា ទេវតាជាន់និម្មានរតី ។

៦.បុគ្គលណាមួយឲ្យទាន ដោយឃើញថា ឲ្យហើយ នឹងធ្វើឲ្យចិត្តរីករាយសោមនស្ស កើតសេចក្ដីជ្រះថ្លា ស្លាប់ហើយក៏នឹងទៅកើតជាទេវតាជាន់បរនិម្មិតវសវត្តី ។

៧.បុគ្គលណាមួយឲ្យទាន ដើម្បីលាងជំរះចិត្តឲ្យផូរផង់ បានឈាន ស្លាប់ហើយនឹងទៅកើតក្នុងព្រហ្មលោក ។

ព្រះសព្វញ្ញូពោធិសត្វគ្រប់ព្រះអង្គ តែងបដិសន្ធិដោយមហាវិបាកចិត្ត ជាសោមនស្សសហគត ញាណសម្បយុត្ត អសង្ខារិក តិហេតុកៈដួងមួយ តែប៉ុណ្ណោះ ។

# កុសលកម្មឲ្យផលផ្សេងគ្នា ៧ យ៉ាងទៀត

ក្នុង មជ្ឈិមនិកាយ ឧបរិបណ្ណាសក ចូឡកម្មវិភង្គសូត្រមានសេចក្តីថា :

**១.មានអាយុវែង** ព្រោះមិនសម្លាប់សត្វ ។
**២.មិនសូវមានរោគ** ព្រោះមិនបៀតបៀនសត្វ ។
**៣.មានសម្បុរថ្លា** ព្រោះមិនមានសេចក្តីក្រោធ ។
**៤.មានសក្តិធំ** ព្រោះមិនច្រណែន មិនប្រទូស្ត ។
**៥.មានភោគសម្បត្តិច្រើន** ព្រោះឲ្យបាយទឹក ។ ល ។
**៦.កើតក្នុងត្រកូលខ្ពង់ខ្ពស់** ព្រោះមិនរឹងត្អឹង ។
**៧.មានបញ្ញាច្រើន** ព្រោះចូលទៅរកសមណៈសិក្សាធម៌ ។

# បុព្វហេតុឲ្យសត្វផ្សេងគ្នា ៨ យ៉ាង

ក្នុងអដ្ឋសាលិនី អដ្ឋកថាចិត្តុប្បាទកណ្ឌ មានសេចក្តីថា :

១.ក្នុងខណៈប្រកបកម្ម បុគ្គលណាមាន **លោភៈ អទោសៈ**

**និង អមោហៈមានកម្លាំងខ្លាំង** តែ អលោភៈ ទោសៈ និង មោហៈ មានកម្លាំងខ្សោយ បុគ្គលនោះ កាលណាកើតដោយអំណាចបដិសន្ធិនៃកម្មនោះឲ្យផលហើយ រមែងជាអ្នកលោភលន់ ជាប្រក្រតីមានសេចក្តីសុខ ច្រើនមិនក្រោធ មិនឆេវឆាវ និង រមែងជាអ្នកមានបញ្ញា ។

២.ក្នុងខណៈប្រកបកម្ម បុគ្គលណាមាន **លោភៈ ទោសៈ និង អមោហៈមានកម្លាំងខ្លាំង** តែ អលោភៈ អទោសៈ និង មោហៈ មានកម្លាំងខ្សោយ បុគ្គលនោះ តែងជាអ្នកលោភលន់ផង ជាអ្នកច្រើនឆេវឆាវប្រទូសរ៉ាយផង ប៉ុន្តែជាអ្នកមានបញ្ញា ។

៣.ក្នុងខណៈប្រកបកម្ម បុគ្គលណាមាន **លោភៈ អទោសៈ និង មោហៈមានកម្លាំងខ្លាំង** ក្រៅពីនេះ ( អលោភៈ ទោសៈ និងអមោហៈ ) មានកម្លាំងខ្សោយ បុគ្គលនោះតែងជាអ្នកលោភលន់ផង ជាអ្នកល្ងង់ខ្លៅផង ប៉ុន្តែជាអ្នកមានចិត្តច្រើនតែមិនងាយក្រោធ មិនឆេវឆាវ ។

៤.ក្នុងខណៈប្រកបកម្ម បុគ្គលណាមាន **លោភៈ ទោសៈ និង មោហៈមានកម្លាំងខ្លាំង** ហើយ អលោភៈ អទោសៈ និង អមោហៈ មានកម្លាំងខ្សោយ បុគ្គលនោះ តែងជាអ្នកលោភលន់ផង

ជាអ្នកច្រើនឆេវឆាវប្រទូសរ៉ាយផង និង ជាអ្នកល្ងង់វង្វេងផង ។

**៥.**ក្នុងខណៈប្រកបកម្ម បុគ្គលណាមាន **អលោភៈ ទោសៈ និង មោហៈមានកម្លាំងខ្លាំង** ក្រៅពីនេះ គឺ លោភៈ អទោសៈ និងអមោហៈ មានកម្លាំងខ្សោយ បុគ្គលនោះតែងជាអ្នកមិនលោភលន់ សូម្បីដល់ឃើញអារម្មណ៍ជាទិព្វ ក៏មិនញាប់ញ័រដែរ ប៉ុន្តែជាអ្នកច្រើនឆេវឆាវប្រទូសរ៉ាយ និង មានបញ្ញាអន់ ។

**៦.**ក្នុងខណៈប្រកបកម្ម បុគ្គលណាមាន **អលោភៈ អទោសៈ និង មោហៈមានកម្លាំងខ្លាំង** ក្រៅពីនេះ គឺ លោភៈ ទោសៈ និង អមោហៈ មានកម្លាំងខ្សោយ បុគ្គលនោះ តែងជាអ្នកមិនលោភលន់ ជាប្រក្រតី ជាអ្នកមានសេចក្ដីសុខ តែជាអ្នកល្ងង់ខ្លៅ ។

**៧.**ក្នុងខណៈប្រកបកម្ម បុគ្គលណាមាន **អលោភៈ ទោសៈ និង អមោហៈមានកម្លាំងខ្លាំង** ក្រៅពីនេះ គឺ លោភៈ អទោសៈ និងមោហៈមានកម្លាំងខ្សោយ បុគ្គលនោះ តែងជាអ្នកមិនលោភលន់ ផង ជាអ្នកមានបញ្ញាផង ប៉ុន្តែជាអ្នកច្រើនឆេវឆាវប្រទូសរ៉ាយ ចងនូវសេចក្ដីក្រោធ ។

**៨.**ក្នុងខណៈប្រកបកម្ម បុគ្គលណាមាន **អលោភៈ អទោសៈ និង អមោហៈមានកម្លាំងខ្លាំង** ក្រៅពីនេះ គឺ លោភៈ ទោសៈ

និង មោហៈមានកម្លាំងខ្សោយ បុគ្គលនោះតែងជាអ្នកមិនលោភលន់ មិនច្រើនដោយការប្រទូសរ៉ាយ ចងកំហឹង និងមានបញ្ញា ។

បុព្វហេតុ ( ហេតុខាងដើម ) តាមដែលពោលមកនេះ រមែងកំណត់ផលឲ្យប្រាកដឡើង ដើម្បីឧបការៈដល់អ្នកប្រព្រឹត្ត ទើបសេចក្តីផ្សេងគ្នានៃវិបាកមានច្រើន ។ បុគ្គលធម្មតា លំបាកនឹងដឹងច្បាស់លាស់ណាស់ថា កម្មនេះឲ្យផលយ៉ាងនេះ ឬផលបែបនេះកើតព្រោះកម្មយ៉ាងនេះ ។ ហើយផលនៃកម្មនេះ ព្រះដ៏មានព្រះភាគបានត្រាស់ថា ជាអចិន្តេយ្យ គឺ ហេតុដែលបុគ្គលមិនគួរគិត ដូចព្រះអង្គទ្រង់ត្រាស់ទុកក្នុង អង្គុត្តរនិកាយ ចតុក្កនិបាត មាន ៤ គឺ :

**១.ពុទ្ធវិសយោ** ពុទ្ធវិស័យ គឺ ការប្រព្រឹត្តទៅនៃព្រះសព្វញ្ញុតញ្ញាណ ជាដើម ។

**២.ឈានវិសយោ** ឈានវិស័យ គឺ ឈានអភិញ្ញានៃអ្នកមានឫទ្ធិ ។

**៣.កម្មវិបាកោ** កម្មវិបាក គឺ ផលនៃកម្ម ។

**៤.លោកចិន្តា** ត្រិះរិះរឿងលោក ដូចគិតថា អ្នកណាហ្ន៎ បង្កើតព្រះចន្ទ ព្រះអាទិត្យ ផែនដី មហាសមុទ្រ អ្នកណាបង្កើតសត្វលោក សាងភ្នំ ព្រៃឈើ លតាវល្លិ

ទាំងឡាយជាដើម ។

ការដែលកម្មវិបាក គឺ ផលនៃកម្មដែលនឹងឲ្យផលនោះ ព្រោះសត្វបានធ្វើកម្មទុករួចហើយ គឺ មិនអាចនរណាមួយហាមឃាត់ការឲ្យផលនៃកម្មនោះបានឡើយ ហើយកម្មនោះឯង រមែងឲ្យផលតាមសមគួរដល់ចេតនាដែលធ្វើ សមដូចពាក្យដែលព្រះអង្គ ទ្រង់ត្រាស់ទុកថា “ **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ចេតយិត្វា កម្មំ ករោតិ កាយេន វាចាយ មនសា** ” ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចេតនាថាជា កម្ម ព្រោះមានការតាំងចិត្តហើយ ទើបធ្វើកម្មដោយកាយ ដោយវាចា ដោយចិត្ត ។

ក្នុងញាណវិភង្គអដ្ឋកថា ពោលសភាពនៃបុគ្គលដែលព្រមព្រៀងដោយកម្មជាដើម ក្នុងសមង្គិតាទុក ៥ ប្រការ គឺ :

**១.អាយូហនសមង្គិតា** សេចក្ដីព្រមព្រៀងដោយកម្មជាកុសល និង ជាអកុសលដែលជាគ្រឿងប្រមូលមក ។

**២.ចេតនាសមង្គិតា** ការព្រមព្រៀងដោយចេតនា ៣ ។

**៣.កម្មសមង្គិតា** ការព្រមព្រៀងនៃកម្ម ដែលគួរដល់វិបាក ។

៥.ឧបដ្ឋានសមង្គិតា ការព្រមព្រៀងនៃការប្រាកដ គឺ ដោយកម្មអារម្មណ៍ កម្មនិមិត្តអារម្មណ៍ និងគតិនិមិត្តអារម្មណ៍ណាមួយ ក្នុងវេលាជិតស្លាប់ ។

៤. វិបាកសមង្គិតា ការព្រមព្រៀងនៃវិបាក ក្នុងខណៈឲ្យផល ។

# ចំណែកមហាវិបាក ៨ ដួង ដោយន័យផ្សេងៗ

១.ដោយជាតិ មហាវិបាក ៨ ជាវិបាកជាតិ ។

២.ដោយភូមិ ជាកាមភូមិ(កើតក្នុងកាមសុគតិភូមិ ៧)

៣.ដោយវេទនា ជាសោមនស្ស ៤ និង ឧបេក្ខា ៤ ។

៤.ដោយហេតុ ជានហេតុ និង ជាសហេតុកចិត្ត ។

៥.ដោយសម្បយុត្ត ជាញាណសម្បយុត្ត ៤ និង ញាណវិប្បយុត្ត ៤ ។

៦.ដោយសង្ខារ ជាអសង្ខារិក ៤ និងជាសសង្ខារិក ៤ ។

៧.ដោយសោភណៈ ជាសោភណចិត្តទាំង ៨ ដួង ។

៨.ដោយឈាន ជាអឈានចិត្ត ។

៩.ដោយលោកិយ ជាលោកិយចិត្តទាំង ៨ ដួង ។

១០.ដោយកិច្ច ជាចិត្តធ្វើកិច្ច ៤ គឺ បដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ តទាលម្ពណ-កិច្ច ១ ។

១១.ដោយអារម្មណ៍ ដឹងអារម្មណ៍បានទាំង ៦ ។

១២.ដោយទ្វារ ចិត្តដឹងអារម្មណ៍បានទាំងទ្វារ ៦ និងដឹងអារម្មណ៍ក្រៅទ្វារ ។

១៣.ដោយវត្ថុ កើតដោយអាស្រ័យហទយវត្ថុ ។

១៤.ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ ។

# តារាងសហេតុកកាមាវចរវិបាកចិត្ត
# ឬ មហាវិបាកចិត្ត ៨

- មហាវិបាកចិត្ត ៨
  - សោមនស្ស
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - ឧបេក្ខា
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១

# កាមាវចរវិបាកចិត្តមាន ២៣ ដួង

១.អកុសលវិបាកចិត្ត ៧ ដួង ។
២.អហេតុកកុសលវិបាកចិត្ត ៨ ដួង ។
៣.សហេតុកកាមាវចរវិបាកចិត្ត ៨ ដួង ។
ឬ មហាវិបាកចិត្ត
រួម ២៣ ដួង ។

ក្នុងមហាវិបាក ៨ ដួង នេះ ហៅបានច្រើនន័យ ដូចនឹងមហាកុសលផងដែរ គឺ :

១.កាមាវចរវិបាក
២.កាមសោភណវិបាក
៣.សហេតុកវិបាក
៤.មហាវិបាក

១. ពាក្យថា **កាមាវចរវិបាក** នោះ សំដៅដល់ចិត្តដែលជាផលកើតឡើងនៃកាមាវចរកុសល ៨ ដួងនោះជាហេតុ ហើយនឹងកើតឡើងបានចំពោះតែក្នុងកាមភូមិប៉ុណ្ណោះ ដូច្នេះ ទើបហៅចិត្ត ៨

ដួងនេះ ថា **ជាកាមាវចរវិបាក** ។

**២.** ពាក្យថា **កាមសោភណវិបាក** គឺ វិបាកចិត្ត ៨ ដួង នេះ ប្រកបដោយសោភណចេតសិក ហើយជាកាមាវចរចិត្តផង ដូច្នេះទើបហៅចិត្ត ៨ ដួងនេះថា **ជាកាមសោភណវិបាក** ។

៣. ពាក្យថា **សហេតុកវិបាក** ព្រោះថា វិបាកចិត្ត ៨ ដួង នេះប្រកបជាមួយហេតុ គឺ អលោភហេតុ អទោសហេតុ និង អមោហហេតុ ដូច្នេះទើបហៅថា **សហេតុកវិបាក** ។

៤. ពាក្យថា **មហាវិបាក** ព្រោះជាវិបាកដែលកើតបានច្រើន ជាអនេកតាមចំនួននៃមហាកុសល ដែលគុណទុកនោះ ដោយន័យ នេះឯង ទើបហៅចិត្ត ៨ ដួង នេះថា **មហាវិបាក** ហើយមហា-វិបាក ៨ ដួង នេះ ក៏ចាត់ទៅតាមប្រភេទ តាមថ្នាក់នៃមហាកុសល ដែលជាហេតុនោះ ។

( កាមាវចរវិបាក ចប់ )

# មហាកិរិយាចិត្ត ៨ ដួង

មហាកិរិយាចិត្ត ឬ កាមាវចរកិរិយាចិត្តនេះ មិនមែនជាកុសលចិត្តផង មិនមែនជាអកុសលចិត្តផង ទាំងមិនមែនជាវិបាកចិត្តផង គឺ ជាចិត្តអព្យាកតៈ ត្រឹមតែជាការធ្វើប៉ុណ្ណោះ គឺ មាន ២ ប្រភេទ :

**១. អហេតុកកិរិយាចិត្ត** ៣ ដួង ។

**២. សហេតុកកិរិយាចិត្ត** ៨ ដួង ។

**ឬ មហាកិរិយាចិត្ត**

បណ្ដាអព្យាកតៈទាំងនោះ ពាក្យថា **កិរិយា** បានដល់ ត្រឹមតែធ្វើ ។ ពិតណាស់ ក្នុងកិរិយាចិត្ត ១១ ដួង , កិរិយាចិត្តណាមិនដល់ភាពជាជវនៈទេ កិរិយាចិត្តនោះ រមែងមិនមានផល ដូចផ្កាឈើជ្រុះ , និងកិរិយាចិត្តណា ដល់ភាពជាជវនៈក៏ដោយ កិរិយាចិត្តនោះក៏មិនមានផលដែរ ដូចជាផ្កាឈើដែលដើមមានឫសដាច់ហើយ ។ កិរិយាចិត្តទាំងនេះ ត្រឹមតែជាការធ្វើប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅដោយអំណាចការញុំាងកិច្ចនោះៗ ឲ្យសម្រេច ដូច្នេះទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **កិរិយាចិត្ត** ។

ក្នុងអហេតុកកិរិយាចិត្ត ៣ និង ក្នុងសហេតុកកិរិយាចិត្ត ឬ មហាកិរិយាចិត្ត ៨ នេះ អហេតុកកិរិយាចិត្តបានពោលរួចមកហើយ បន្ទាប់ពីនេះទៅ នឹងពោលអំពីសហេតុកកិរិយាចិត្ត ៨ ដួង ។ ចិត្ត ៨ ដួង នេះជាចិត្តឲ្យសម្រេចការធ្វើ ការនិយាយ ការគិតនៃព្រះអរហន្ត ជាកិរិយាចិត្តដែលដល់ភាពជាជវនៈ សោយអារម្មណ៍ជាសោមនស្ស ឬ ឧបេក្ខា មិនមែនជាហេតុនៃតណ្ហា និងឧបាទានទេ មិនអាចឲ្យកើតផលក្នុងអនាគតកាលបានឡើយ ។

មហាកិរិយាចិត្តនេះ មានសភាពប្រហែលនឹងមហាកុសល គឺចិត្ត ៨ ដួង នេះ បើមិនកើតនឹងព្រះអរហន្តទេនោះ ក៏គឺជាមហាកុសលនោះឯង ។

# មហាកិរិយាចិត្ត ៨ ដួង

**១. សោមនស្សសហគត ញាណសម្បយុត្ត អសង្ខារិក =** ចិត្តកើតព្រមនឹងសោមនស្ស ប្រកបដោយញាណ ជាអសង្ខារិក ១ ។

**២. សោមនស្សសហគត ញាណសម្បយុត្ត សសង្ខារិក =** ចិត្តកើតព្រមនឹងសោមនស្ស ប្រកបដោយញាណ ជាសសង្ខារិក ១ ។

**៣. សោមនស្សសហគត ញាណវិប្បយុត្ត អសង្ខារិក =** ចិត្តកើតព្រមនឹងសោមនស្សមិនប្រកបដោយញាណ ជាអសង្ខារិក១ ។

**៤. សោមនស្សសហគត ញាណវិប្បយុត្ត សសង្ខារិក =** ចិត្តកើតព្រមនឹងសោមនស្សមិនប្រកបដោយញាណ ជាសសង្ខារិក១ ។

**៥. ឧបេក្ខាសហគត ញាណសម្បយុត្ត អសង្ខារិក =** ចិត្តកើតព្រមនឹងឧបេក្ខា ប្រកបដោយញាណ ជាអសង្ខារិក ១ ។

**៦. ឧបេក្ខាសហគត ញាណសម្បយុត្ត សសង្ខារិក =** ចិត្តកើតព្រមនឹងឧបេក្ខា ប្រកបដោយញាណ ជាសសង្ខារិក ១ ។

**៧. ឧបេក្ខាសហគត ញាណវិប្បយុត្ត អសង្ខារិក =** ចិត្តកើតព្រមនឹងឧបេក្ខា មិនប្រកបដោយញាណ ជាអសង្ខារិក ១ ។

**៨. ឧបេក្ខាសហគត ញាណវិប្បយុត្ត សសង្ខារិក =** ចិត្តកើតព្រមនឹងឧបេក្ខា មិនប្រកបដោយញាណ ជាសសង្ខារិក ១ ។

ចិត្តទាំង ៨ ដួង នេះ ឈ្មោះថា សហេតុកកាមាវចរកិរិយា-ចិត្ត ឬហៅថា **មហាកិរិយាចិត្ត** ។

# កាមាវចរសោភណចិត្ត ២៤ ដួង



# តារាងកាមាវចរកិរិយាចិត្ត
# ឬ មហាកិរិយាចិត្ត ៨

- មហាកិរិយាចិត្ត ៨
  - សោមនស្ស
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - ឧបេក្ខា
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១

មហាកិរិយាចិត្តរបស់ព្រះអរហន្ត ដែលកើតព្រមនឹងសោមនស្សវេទនា តែងកើតក្នុងទ្វារទាំង ៦ ។

**ក្នុងចក្ខុទ្វារ** ព្រះខីណាស្រព កាលឃើញទីកន្លែងដ៏សមគួរដល់ការបំពេញសេចក្តីព្យាយាមហើយ តែងតែសោមនស្ស ដោយមហាកិរិយាចិត្តដួងនេះ ។

**ក្នុងសោតទ្វារ** នៅពេលដែលភិក្ខុត្រូវចែកភ័ណ្ឌៈ កាលបុគ្គលល្មោភឡូឡា អ៊ូអរ ព្រះអរហន្តលោកក៏កើតសោមនស្សដោយចិត្តនេះថា “ តណ្ហាជាហេតុឲ្យញាប់ញ័រយ៉ាងនេះ យើងបានលះហើយ ” ។

**ក្នុងឃានទ្វារ** ពេលលោកបូជាព្រះចេតិយដោយគ្រឿងក្រអូប ឬដោយផ្កាឈើ លោកក៏សោមនស្សដោយចិត្តនេះ ។

**ក្នុងជីវ្ហាទ្វារ** ព្រះខីណាស្រព រំលែកនូវបិណ្ឌបាតព្រមដោយរស ដែលបានមកយ៉ាងណា ក៏សោមនស្សដោយចិត្តនេះ ថា “ សារាណីយធម៌ ( គឺ ធម៌ជាទីតាំងនៃការឲ្យរលឹកដល់ ) យើងបានបំពេញហើយ ” ។

**ក្នុងកាយទ្វារ** ព្រះខីណាស្រពបំពេញនូវ អភិសមាចារិកវត្តជានិច្ច ក៏ដល់នូវសោមនស្សដោយចិត្តនេះថា “ វត្ត របស់យើងពេញបរិបូណ៌ហើយ ” ។

ព្រះខីណាស្រព តែងតែសោមនស្សក្នុងបញ្ចទ្វារ យ៉ាងនេះជាមុនសិន ។

**ប៉ុន្តែក្នុងមនោទ្វារ** ចិត្តសោមនស្សរបស់ព្រះខីណាស្រពតែងកើតឡើងព្រោះប្រារព្ធរឿងអតីត និងអនាគត ដូចព្រះអង្គទ្រង់រលឹកដល់ហេតុ ដែលព្រះអង្គទ្រង់បានធ្វើហើយ កាលសោយព្រះជាតិ ជា

ជោតិបាល ជាមយទេវរាជជាដើម ទើបព្រះអង្គធ្វើការញញឹមឲ្យប្រាកដ តែការរលឹកនោះ ជាកិច្ចនៃបុព្វេនិវាសញ្ញាណ និងសព្វញ្ញុតញ្ញាណ ក្នុងទីបំផុតនៃញាណទាំង ២ នេះ ចិត្តដួងនេះរមែងកើតរីករាយ ។ ក្នុងអនាគតព្រះអង្គក៏បានធ្វើការញញឹម ឲ្យប្រាកដថា នឹងមានព្រះបច្ចេកពុទ្ធ មានសំឡេងដូចសំឡេងពិណ ដូចសំឡេងសំភោរ យ៉ាងនេះ ឯការរលឹកនោះ ក៏ជាកិច្ចរបស់អនាគតង្សញ្ញាណ និងសព្វញ្ញុតញ្ញាណ តែក្នុងទីបំផុតនៃព្រះញាណ ទាំង ២ នេះ ចិត្តដួងនេះ រមែងរីករាយ ។

មហាកិរិយាចិត្ត ដែលកើតព្រមនឹងឧបេក្ខាវេទនានោះ តែងតែប្រាកដក្នុងខណៈដែល លោកពិចារណាអារម្មណ៍ ដែលមកប៉ះខ្ទប់ក្នុងទ្វារទាំង ៦ ដោយឆឡង្គុបេក្ខា មិនមានការញាប់ញ័រក្នុងប្រការណាៗឡើយ ។ ម្យ៉ាងទៀត មហាកិរិយាចិត្តរបស់ព្រះខីណាស្រពនោះ គ្រាខ្លះក៏ប្រកបដោយបញ្ញា គ្រាខ្លះក៏មិនប្រកបដោយបញ្ញា ត្រង់ដែលថាមិនប្រកបដោយបញ្ញា ដូចជាខណៈឈរ ដើរជាដើម មិនចាំបាច់មានបញ្ញាក៏ដើរ ឈរ អង្គុយ ដេកបាន ។

ក្នុងមហាកិរិយាចិត្ត ៨ ដួងនេះ មានឈ្មោះហៅបានច្រើនយ៉ាង គឺ :

## ១. កាមាវចរកិរិយាចិត្ត

**២. កាមសោភណកិរិយាចិត្ត**

**៣. សហេតុកកិរិយាចិត្ត**

**៤. មហាកិរិយាចិត្ត**

**១.** ពាក្យថា **កាមាវចរកិរិយាចិត្ត** គឺ ជាចិត្តដែលមិនរាប់បញ្ចូលក្នុងប្រភេទចិត្តជាហេតុ និង ជាផលទេ គឺជាចិត្តដែលប្រព្រឹត្តទៅដោយមិនមានផលវិញ ឬថាជាកម្មដែលចាត់នៅក្នុងប្រភេទអហោសិកម្ម ។ ដូច្នេះ កាមាវចរកិរិយាចិត្តនេះ ទើបមិនហៅថាកុសលនិងអកុសល ហើយកិរិយាចិត្តដួងនេះ ក៏ជាចិត្តនៃព្រះអរហន្តមិនមានក្នុងបុថុជ្ជនទេ តែជាជាតិកាមាវចរៈ ទើបហៅថា **កាមាវចរកិរិយាចិត្ត** ។

**២.** ពាក្យថា **កាមសោភណកិរិយាចិត្ត** ក៏ព្រោះដោយកាមកិរិយាចិត្តដួងនេះ ប្រកបដោយសោភណចេតសិក ដោយហេតុនេះទើបហៅថា **កាមសោភណកិរិយាចិត្ត** ។

**៣.** ពាក្យថា **សហេតុកកិរិយាចិត្ត** ព្រោះចិត្ត ៨ ដួងនេះ ប្រកបដោយអលោភហេតុ អទោសហេតុ និងអមោហហេតុ ដូច្នេះ ទើបហៅថា **សហេតុកកិរិយាចិត្ត** ។

**៤.** ពាក្យថា **មហាកិរិយាចិត្ត** ព្រោះហេតុថា ច្រើនទៅ

ដោយអារម្មណ៍ និង ទ្វារ ដូចនឹងមហាកុសលដែរ ដូច្នេះទើបហៅថា **មហាកិរិយាចិត្ត** ។

# ចំណែកមហាកិរិយា ៨ ដួង ដោយន័យផ្សេងៗ

**១. ដោយជាតិ** ជាកិរិយាជាតិ ។

**២. ដោយភូមិ** ជាកាមភូមិ (កើតបាន ២៦ ភូមិ)។

**៣. ដោយវេទនា** ជាសោមនស្ស ៤ និងឧបេក្ខា ៤ ។

**៤. ដោយហេតុ** ជានហេតុ ជាសហេតុកចិត្ត ។

**៥. ដោយសម្បយុត្ត** ជាញាណសម្បយុត្ត ៤ និង ញាណវិប្បយុត្ត ៤ ។

**៦. ដោយសង្ខារ** ជាអសង្ខារិក ៤ ជាសសង្ខារិក ៤ ។

**៧. ដោយសោភណៈ** ជាសោភណចិត្តទាំង ៨ ដួង ។

**៨. ដោយឈាន** ជាអឈានចិត្ត ។

**៩. ដោយលោកិយ** ជាលោកិយចិត្តទាំង ៨ ដួង ។

**១០. ដោយកិច្ច** ជាចិត្តធ្វើជវនៈកិច្ច ។

**១១.ដោយអារម្មណ៍** ដឹងអារម្មណ៍បានទាំង ៦ ។

**១២.ដោយទ្វារ** ចិត្តដឹងបានទ្វារទាំង ៦ ។

**១៣.ដោយវត្ថុ** កើតដោយអាស្រ័យហទយវត្ថុ ២២ ភូមិ ( វៀរអរូបភូមិ ៤ ) ។

**១៤.ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ ។

( កាមាវចរកិរិយាចិត្ត ចប់ )

កុសលចិត្ត វិបាកចិត្ត និង កិរិយាចិត្ត ដែលជាកាមាវចរ-សោភណចិត្ត ២៤ ដួង ចប់ដោយបរិបូណ៌ និង ដោយប្រការទាំងពួង ដោយសេចក្តីផ្សេងគ្នានៃវេទនា ញាណ និង សង្ខារ ។

# ចំណែកកាមាវចរសោភណចិត្ត ២៤ ដោយន័យផ្សេងៗ

**១. ដោយជាតិ** កុសលជាតិ ៨ វិបាកជាតិ ៨ កិរិយាជាតិ ៨ ។

**២. ដោយភូមិ** ជាកាមាវចរភូមិទាំង ២៤ ។

| | |
|---|---|
| ៣. ដោយវេទនា | ជាសោមនស្ស ១២ និងឧបេក្ខា ១២ ។ |
| ៤. ដោយហេតុ | ជានហេតុ និងជាសហេតុកចិត្ត ២៤ ។ |
| ៥. ដោយសម្បយុត្ត | ជាញាណសម្បយុត្ត ១២ និងញាណ-វិប្បយុត្ត ១២ ។ |
| ៦. ដោយសង្ខារ | ជាអសង្ខារិក ១២ ជាសសង្ខារិក ១២ ។ |
| ៧. ដោយសោភណៈ | ជាសោភណចិត្តទាំង ២៤ ។ |
| ៨. ដោយឈាន | ជាអឈានចិត្ត ។ |
| ៩. ដោយលោកិយ | ជាលោកិយចិត្តទាំង ២៤ ។ |
| ១០.ដោយកិច្ច | ជាចិត្តធ្វើកិច្ច ៥ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច សន្តីរណកិច្ច ជវន-កិច្ច តទាលម្ពណកិច្ច ។ |
| ១១.ដោយអារម្មណ៍ | ដឹងអារម្មណ៍បានទាំង ៦ ។ |
| ១២.ដោយទ្វារ | ចិត្តដឹងបានទ្វារ ៦ និងទ្វារវិមុត្តិ ។ |
| ១៣.ដោយវត្ថុ | កើតដោយអាស្រ័យហទយវត្ថុ ប៉ុន្តែ កុសល និង កិរិយាចិត្តមិនអាស្រ័យវត្ថុ ក៏ប្រព្រឹត្តទៅបាន ។ |
| ១៤.ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ ។ |

**កាមេ តេវីស បាកានិ បុញ្ញាបុញ្ញានិ វីសតិ**
**ឯកាទស ក្រយា ចេតិ ចតុបញ្ញាស សព្វទា**

ប្រែថា ចិត្តក្នុងកាម ដោយប្រការទាំងពួង ៥៤ ដួង គឺ :

| | | |
|---|---|---|
| -វិបាកចិត្ត | ២៣ | ដួង |
| -កុសលចិត្តនិងអកុសលចិត្ត | ២០ | ដួង |
| -កិរិយាចិត្ត | ១១ | ដួង |

បើដោយសេចក្តីផ្សេងដែលគិតក្នុង កុសល អកុសល វិបាក និង កិរិយា គឺ :

| | | |
|---|---|---|
| អកុសលចិត្ត | ១២ | ដួង |
| មហាកុសលចិត្ត | ៨ | ដួង |
| អកុសលវិបាកចិត្ត | ៧ | ដួង |
| អហេតុកកុសលវិបាកចិត្ត | ៨ | ដួង |
| មហាវិបាកចិត្ត | ៨ | ដួង |
| អហេតុកកិរិយាចិត្ត | ៣ | ដួង |
| មហាកិរិយាចិត្ត | ៨ | ដួង |
| រួមជាកាមាវចរចិត្ត | ៥៤ | ដួង |

( កាមាវចរចិត្ត ៥៤ ដួង ចប់ )

# សំនួរ-ចម្លើយឡើងវិញ

**១.** ពាក្យថា “ **សោមនស្សសហគតំ** ” ( កើតព្រមនឹងសោមនស្ស ) ក្តី និង “ **ឧបេក្ខាសហគតំ** ” ( កើតព្រមនឹងឧបេក្ខា ) ក្តី ក្នុងមហាកុសលចិត្ត និងក្នុងលោភមូលចិត្ត ដែលបានពោលរួចហើយ តើផ្សេងគ្នាយ៉ាងណាខ្លះ ?

-ផ្សេងគ្នាយ៉ាងនេះ គឺក្នុងលោភមូលចិត្តនោះ គឺជាចិត្តដែលមានលោភជាមូល ជាអកុសលឲ្យផលជាទុក្ខ ចំណែកក្នុងមហា-កុសលចិត្ត ៨ ដួងនេះ ជាចិត្តដែលប្រកបដោយកុសលហេតុ គឺអលោភៈ អទោសៈ អមោហៈ ជាកុសល ឲ្យផលជាសុខ ។

**២.** ចូរសម្តែងមហាកុសល ដែលជាញាណសម្បយុត្ត និងញាណវិប្បយុត្ត តើផ្សេងគ្នាយ៉ាងណា ?

-ការផ្សេងគ្នានៃញាណសម្បយុត្ត និងញាណវិប្បយុត្ត នោះផ្សេងគ្នាយ៉ាងនេះ គឺ :

កុសលចិត្តដែលប្រកបដោយញាណនោះ ដូចបុគ្គលឲ្យទានមានគំនិតថា ផលនៃទានមាន ( សម្មាទិដ្ឋិ ១០ យ៉ាង ) ហើយក៏ឲ្យទានទៅក្តី ឬថា ពេលណាបុគ្គលបានផ្កាពណ៌ខៀវក្តី លឿងក្តីក្រហមក្តី សក្តី ណាមួយជាដើម រលឹកដល់ពណ៌នោះហើយ ក៏បូជា

ដល់ព្រះពុទ្ធរតនៈជាដើម ដោយគិតថា យើងថ្វាយពណ៌ជាទាន ក្តី ទាននេះក៏ជាកុសលប្រកបដោយញាណ គឺ បញ្ញា ។ ក្នុងរឿង ការឲ្យនេះ មានរឿងរ៉ាវនៅក្នុងអដ្ឋកថា អដ្ឋសាលិនី ថា :

ឮថាអ្នករក្សាឃ្លាំងម្នាក់ ឈ្មោះ សង្ឃមិត្ត បានសំពត់សរសៃមាសមួយផ្ទាំងហើយគិតថា " សំពត់នេះមានពណ៌ដូចមាស ឯព្រះសម្មាសម្ពុទ្ធក៏មានឆវីវណ្ណដូចជាមាសដែរ ដូច្នេះ សំពត់នេះសមគួរដល់តែព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ហើយការឲ្យពណ៌ ( ថ្វាយពណ៌ ) នឹងមានដល់យើង " យ៉ាងនេះ រួចហើយ ទើបយកសំពត់នោះឡើងទៅហ៊ុំព្រះចេតិយ កុសលទានដែលប្រកបដោយញាណរបៀបនេះ គប្បីជ្រាបថា ជាមហាកុសលញាណសម្បយុត្ត ។

ចំណែកកុសល ដែលមិនប្រកបដោយ ញាណសម្បយុត្ត (ញាណវិប្បយុត្ត) នោះ មានន័យផ្ទុយគ្នា គឺ មិនមានបញ្ញាពិចារណា ឬក៏មិនមានការយល់ត្រូវតាមន័យដែល ពោលទុកក្នុងសម្មាទិដ្ឋិ ១០ ប្រការនោះទេ ដូចជាការធ្វើកុសលរបស់ពួកក្មេងៗ ដែលគេទាំងនោះធ្លាប់ឃើញជីដូន ជីតាម៉ែឪរបស់គេថ្វាយបិណ្ឌបាតជាទាន កាលពួកក្មេងទាំងនោះឃើញភិក្ខុនិមន្តមក ក៏ប្រគេនរបស់នៅនឹងដៃវា ឬក៏លើកដៃសំពះ ការធ្វើកុសលយ៉ាងនេះ មិនប្រកបដោយញាណទេ ហៅថា ញាណវិប្បយុត្ត ។

**៣.** ការចំរើនភាវនាយ៉ាងណា ទើបជាញាណសម្បយុត្ត ?

-ការចំរើនកុសល ដោយមានរូបនាមជាត្រៃលក្ខណ៍ ឬតាមន័យដែលពោលទុកក្នុងអដ្ឋសាលិនីថា “ កាលណា បុគ្គលធ្វើការបូជាព្រះរតនត្រៃដោយវត្ថុ (វណ្ណទានំ) ដូច្នេះ ហើយ ក៏តាំងឡើងដោយការអស់ទៅ សូន្យទៅនៃពណ៌ ដោយមនសិការ គឺឧបាយនៃប្រាជ្ញាថា ពណ៌នេះនឹងដល់ការអស់ទៅ សូន្យទៅ ” យ៉ាងនេះ ពេលនោះ កុសល រមែងជាភាវនាន័យ ជាញាណសម្បយុត្ត ។

**៤.** ចូរសម្តែងសេចក្តីផ្សេងគ្នានៃកុសលដែលជា អសង្ខារិកចិត្ត និង សសង្ខារិកចិត្ត ?

-កុសលដែលជាអសង្ខារិកចិត្តនោះ កើតឡើងដោយមិនមានការដឹកនាំ ដល់វេលាឲ្យផល តែងឲ្យផល មានកម្លាំងជាងផលនៃកុសលដែលមានចិត្តជាសសង្ខារិកចិត្ត ហើយក្នុងសន្តានចិត្តនៃបុគ្គលដែលមានចិត្ត ជាអសង្ខារិកនោះ ក៏តែងជាបច្ច័យឲ្យអសង្ខារិកចិត្តកើតឡើងបានងាយស្រួលក្នុងភពតទៅ ។ ចំណែកកុសលដែលជាសសង្ខារិកចិត្តនោះ កើតឡើងដោយមានការដឹកនាំ ដល់វេលាឲ្យផល ក៏ឲ្យផលខ្សោយជាងកុសលអសង្ខារិកចិត្ត ។

**៥.** ចូរសម្តែងមហាកុសលចិត្ត ក្នុងការធ្វើទានដែលប្រព្រឹត្តទៅក្នុងកម្មទាំង ៣ ?

-ក្នុងកាលណា បុគ្គលថ្វាយទានដល់ព្រះរតនត្រ័យដោយដៃខ្លួន

ឯង ក្នុងកាលនោះក៏ជាកុសលប្រកបដោយកាយកម្ម ។ ក្នុងកាលណា បង្គាប់ឲ្យបុត្រភរិយាជាដើមឲ្យថ្វាយទាន ក្នុងកាលនោះក៏ជាវចីកម្ម ។

-ក្នុងកាលណា បុគ្គលប្រារព្ធវត្ថុទានដែលមាន ហើយគិតថា យើងនឹងឲ្យទាន ក្នុងកាលនោះ ក៏ជាមនោកម្ម ។

**៦.** ការឲ្យពណ៌ជាទាន ( វណ្ណទានំ ) ដូចឲ្យផ្កាមាន ពណ៌ខៀវ លឿងជាដើម ក៏ល្មមយល់បាន ប៉ុន្តែការឲ្យសំឡេង ឲ្យក្លិន ឲ្យរស ឲ្យផោដ្ឋព្វៈជាទាននោះ ឲ្យបានយ៉ាងណាដែរ ?

-ជាធម្មតា សំឡេង នរណាក៏មិនអាចដើម្បីយកមកទុក នៅនឹងដៃ ហើយឲ្យដូចជាការឲ្យរបស់របរទាំងឡាយ មាន បាយ ទឹកជាដើមនោះទេ ប៉ុន្តែក៏អាចប្រើសំឡេងបាន ដោយគិតថា " យើងនឹងថ្វាយទានដោយសំឡេងរបស់យើង " ទើបថ្លែងវាចា ថ្វាយភេសជ្ជៈ មានទឹកអំពៅជាដើម ឬ តែងតែឃោសនាឲ្យគេមកស្តាប់ធម៌ រៀនធម៌ ឬ ពោលធម្មកថា ក្នុងកាលនោះ ក៏ជាការឲ្យសំឡេងជាទាន ( សទ្ទទានំ ) ។

-ក្នុងកាលណា ធុំក្លិនគួរជាទីពេញចិត្ត ហើយឲ្យក្លិននោះ ជាទាន ដោយការបូជាព្រះរតនត្រ័យជាដើម កាលនោះ ក៏ជាការឲ្យក្លិនជាទាន ( គន្ធទានំ ) ។

-ក្នុងកាលណា ធ្វើរសគួរជាទីពេញចិត្តហើយ ឲ្យរសនោះជា

ទាន ឬ បូជាព្រះរតនត្រ័យជាដើម កាលនោះ ក៏ជាការឲ្យរសជាទាន ( រសទានំ ) ។

ក្នុងរឿងការឲ្យរសជាទាននេះ ក្នុងមហាអដ្ឋកថា បានពោលដល់រឿងព្រះចៅទុដ្ឋគាមិនីអភ័យថា ព្រះរាជាអង្គនេះ ទ្រង់ត្រិះរិះថា “ ជាធម្មតា បើមិនទាន់បានថ្វាយសង្ឃទានទេ ហើយបរិភោគ យើងមិនធ្លាប់ប្រព្រឹត្តទេ ” យ៉ាងនេះ ទាល់តែថ្វាយទានដល់ភិក្ខុទាំងឡាយរួច ទើបព្រះអង្គសោយក្រយាហារមានរស ។

-កាលណាបុគ្គលបានវត្ថុដែលគួរឲ្យទានណាមួយ មានគ្រែតាំងជាដើម ហើយនឹកដល់ដោយអំណាចនៃការប៉ះពាល់ តែងឲ្យតែងបរិច្ចាគដោយគិតថា “ យើងឲ្យផោដ្ឋព្វៈជាទាន ” ( ផោដ្ឋព្វ-ទានំ ) ក្នុងកាលនោះ ក៏ជាការឲ្យផោដ្ឋព្វៈជាទាន ។

**៧.** ការឲ្យធម៌ដែលជាអារម្មណ៍ (ធម្មារម្មណ៍) ជាទាននោះ តើធ្វើយ៉ាងណាដែរ ?

-ធម្មារម្មណ៍ បានដល់ចិត្ត ចេតសិក រូប និព្វាន និងបញ្ញត្តិ។ តែក្នុងឋានៈនេះ បណ្ឌិតមិនធ្វើការប្រកបទុកដោយអំណាចនៃធម៌ទាំងនោះទេ គប្បីប្រកបទុកដោយការឲ្យ ឱជា( អាហារ ) ការឲ្យទឹកបានៈ ( ទឹកដែលគួរផឹក ) និង ការឲ្យជីវិតជាទានវិញ ក្នុងធម្មារម្មណ៍នេះ ពេលណាបុគ្គលថ្វាយនូវខ្លាញ់ខាប់ ខ្លាញ់រាវជាដើម ដោយគិតថា “ យើងថ្វាយឱជាជាទាន ” យ៉ាងនេះ ឬ ថ្វាយទឹក

បានះដោយគិតថា “ យើងថ្វាយទឹកបានះជាទាន ” យ៉ាងនេះ ឬ ថ្វាយស្លាកភត្តជាដើម ដោយគិតថា “ យើងថ្វាយជីវិតជាទាន ” ឬក៏ថ្វាយភេសជ្ជៈដល់ភិក្ខុដែលអាពាធទាំងឡាយ ឬ ឲ្យគ្រូពេទ្យមកព្យាបាល ឬ ឲ្យរុសរើទ្រុងសត្វចោល ឬ ដាក់ប្រកាសហាមមិនឲ្យសម្លាប់សត្វ ការធ្វើរបៀបនេះដទៃទៀត ដើម្បីការពារជីវិត ក្នុងកាលណោះ កុសលចិត្តក៏ជាទានមយៈ ជាធម្មារម្មណ៍ប្រព្រឹត្តទៅតាមមនោទ្វារ ។

**៨.** កាមាវចរកុសល ប្រកបដោយធម៌អ្វី ហើយដោយហេតុណា ទើបហៅថាកុសល ?

-កាមាវចរកុសល ៨ ប្រកបដោយសោភណចេតសិកធម៌ ៣ គឺ វេទនា ១ បញ្ញា ១ និងសង្ខារ ១ ហើយដែលហៅថា មហាកុសលនោះ ព្រោះជាចិត្តកើតបានក្នុងភូមិផ្សេងៗ ដល់ ៣០ ភូមិ (វៀរអសញ្ញសត្តាភូមិ) និងកើតបានក្នុងសន្តាននៃបុគ្គលទូទៅទាំងអស់ វៀរតែសន្តាននៃមគ្គបុគ្គល អរហត្តផលបុគ្គល និងអសញ្ញសត្តបុគ្គល ក្រៅពីនេះទៀត កាមាវចរកុសលនៅជាបាទនៃការឲ្យកើត ឈានចិត្ត អភិញ្ញាចិត្ត មគ្គចិត្ត ផលចិត្តផងដែរ ដោយហេតុនេះ ទើបហៅថា មហាកុសល ។

**៩.** មហាកុសលចិត្តកើតបានដល់ ៣០ ភូមិ បានសេចក្តីថា

ចិត្តនេះ កើតបានក្នុងសន្តាននៃកាមបុគ្គលក៏បាន រូបបុគ្គលក៏បាន អរូបបុគ្គលក៏បាន បើអ៊ីចឹងទេ ដូចម្តេច បានជាហៅ កាមាវចរ-ចិត្តវិញ ។

-មហាកុសលចិត្ត កើតក្នុងសន្តាននៃបុគ្គលក្នុងភូមិផ្សេងៗបាន អញ្ចឹងមែន ប៉ុន្តែលក្ខណៈការកើតប្រភេទនៃចិត្តនេះ កើតឡើងដោយមានកាមអារម្មណ៍មកប្រាកដ ឬ ចិត្តនេះភាគច្រើនដឹងនូវកាមារម្មណ៍ ( វៀរតែខណៈធ្វើគោត្រភូកិច្ច ឬ វោទាន ឬ បច្ចវេក្ខណញ្ញាណខ្លះប៉ុណ្ណោះ ) ដូច្នេះសូម្បីកើតក្នុងបុគ្គលដទៃៗ ដែលមិនមែនជាកាមបុគ្គលក៏ដោយ ក៏ឈ្មោះថា កាមាវចរចិត្តដែរ ។

**១០.** ព្រោះហេតុអ្វី ទើបមហាកុសល មិនកើតក្នុងសន្តាននៃមគ្គបុគ្គល និង អសញ្ញសត្តបុគ្គល ?

-ព្រោះឋានៈនៃមគ្គបុគ្គលនោះ ជាលោកុត្តរកុសល មិនមែនជាកាមាវចរកុសល ។ ចំណែកឯអសញ្ញសត្តបុគ្គល ក្នុងអសញ្ញ-សត្តភូមិនោះ ជាបុគ្គលដែលមានតែរូប មិនមានចិត្ត និង ចេតសិកទេ ។

**១១.**មហាកុសលចិត្ត ៨ នោះ តើដួងណាឲ្យផលខ្ពស់ជាង ?

-មហាកុសលដែលកើតព្រមដោយសោមនស្ស ឲ្យផលខ្ពស់ជាងឧបេក្ខា, ដែលសម្បយុត្តដោយបញ្ញា ឲ្យផលខ្ពស់ជាងញាណវិប្បយុត្ត,

ដែលជាអសង្ខារិក ឲ្យផលខ្ពស់ជាងសសង្ខារិក ។

**១២.** បុគ្គលម្នាក់ៗ សុទ្ធតែធ្វើកម្មមកច្រើនសន្ធឹកសន្ធាប់ ជាកុសលក៏មាន ជាអកុសលក៏មាន ចុះប្រសិនបើកុសលកម្មបានឱកាសធ្វើបដិសន្ធិហើយ ផលនៃអកុសលកម្ម តែងមិនបានឱកាសឲ្យផលទេឬ ?

-កាលណាផលនៃកុសលកម្ម បានឱកាសធ្វើបដិសន្ធិ ( នាំឲ្យកើត ) ហើយ ផលនៃអកុសលតែងមិនបានឱកាសធ្វើបដិសន្ធិទេ តែក៏បានឱកាសឲ្យផលក្នុងបវត្តិកាលដែរ ដូចឲ្យឃើញវត្ថុដែលមិនល្អ ឮសំឡេងមិនល្អជាដើម ធ្ងន់ជាងនោះទៅទៀត ធ្វើការកាត់ផ្ដាច់ទ្រូវជីវិតក៏បាន ។

**១៣.** ក្នុងអហេតុកចិត្តក៏មានវិបាក ក្នុងកាមាវចរសោភណចិត្តក៏មានវិបាក វិបាកទាំង ២ នេះ កើតផ្សេងគ្នា យ៉ាងណា ?

-វិបាកក្នុងអហេតុកចិត្ត ជាចិត្តមិនមានសម្បយុត្តហេតុ ឯវិបាកក្នុងកាមាវចរសោភណចិត្ត ជាវិបាកចិត្តដែលមានសម្បយុត្តហេតុ វិបាកទាំង ២ ពួកនេះមានការលើសខ្វះជាងគ្នា ដូចដើមឈើមួយមានឫសកែវ ឯមួយទៀតឥតមានឫសកែវ ជាឧទាហរណ៍ ។

**១៤.** វិបាកចិត្តឲ្យផលផ្សេងៗគ្នានោះ តើអាស្រ័យអ្វីជាបុព្វហេតុ ? ចូរបញ្ជាក់ ?

-អាស្រ័យចេតនាដែលប្រកបដោយហេតុ ៦ គឺ អលោភៈ អទោសៈ អមោហៈ ឬ លោភៈ ទោសៈ មោហៈ ជាបុព្វហេតុ គឺក្នុងខណៈធ្វើកុសលកម្មនោះ មាន អលោភៈ អទោសៈ អមោហៈ មានកម្លាំងខ្លាំង ឬកម្លាំងខ្សោយ ឬមានលោភៈ ទោសៈ មោហៈ មានកម្លាំងខ្លាំង ឬកម្លាំងខ្សោយ បុព្វហេតុទាំងនេះឯង ជាគ្រឿងចែកឲ្យកើតវិបាកផ្សេងៗគ្នា ។

**១៥.** ក្នុងអបាយភូមិ ៤ មានតទាលម្ពណកិច្ចឬទេ ? ចូរបញ្ជាក់ ?

-ក្នុងអបាយភូមិ ៤ មានតទាលម្ពណកិច្ច ប៉ុន្តែចិត្តដែលធ្វើកិច្ចនេះ ជាអហេតុកវិបាកចិត្តប៉ុណ្ណោះ ។

**១៦.** អហេតុកវិបាកចិត្ត កើតបានប៉ុន្មានភូមិ អ្វីខ្លះ ?

-កើតបានក្នុងអបាយភូមិ ៤ កាមសុគតិភូមិ ៧ និង ក្នុងរូបព្រហ្មភូមិតាមសមគួរ ។

**១៧.** ហេតុអ្វីបានជាមហាវិបាកចិត្ត ៨ មិនធ្វើតទាលម្ពណកិច្ចបន្តពីរូបាវចរកុសលចិត្ត និង អរូបាវចរកុសលចិត្ត?

-ព្រោះ មិនមែនជាចិត្តប្រភេទដូចគ្នា ។

អដ្ឋកថា លោកអធិប្បាយថា តទាលម្ពណកិច្ចនេះ ប្រៀបដូចជាទារកដែលធ្លាប់តែនៅជាមួយឪពុក ឬ អ្នកណាម្នាក់ ក៏រមែង

តាមជាប់តែឪពុក ឬ អ្នកនោះប៉ុណ្ណោះ មិនតាមអ្នកដទៃដែលមិនធ្លាប់នៅជាមួយឡើយ ព្រោះកាមចិត្ត រូបាវចរចិត្ត និងអរូបាវចរចិត្តនោះ មិនមែនជាចិត្តប្រភេទដូចនឹងខ្លួនទេ ។

**១៨.** អហេតុកកិរិយាចិត្ត ផ្សេងពីមហាកិរិយាយ៉ាងណាដែរ?

-អហេតុកកិរិយាចិត្ត ជាកិរិយាដែលមិនប្រកបដោយហេតុ ៦ ចំណែកមហាកិរិយាចិត្ត ជាចិត្តដែលប្រកបដោយ តិហេតុកចិត្ត និង ទ្វិហេតុកចិត្ត ។

**១៩.** កិរិយាចិត្ត (អហេតុក-សហេតុក) ទាំង ២ ប្រភេទនេះ កើតក្នុងភូមិណាខ្លះ ?

-អហេតុកកិរិយាចិត្ត កើតបាន ៣០ ភូមិ ( វៀរចាក អសញ្ញសត្តភូមិ ) ចំណែកមហាកិរិយាចិត្ត ជាចិត្តរបស់ព្រះអរហន្ត កើតបាន ២៦ ភូមិ គឺ កាមសុគតិភូមិ ៧ រូបាវចរភូមិ ១៥ កើតត្រង់ហទយវត្ថុ ក្នុងអរូបាវចរភូមិ ៤ កើតបានមិនចាំបាច់មានហទយវត្ថុ ( វៀរអបាយភូមិ ៤ និង អសញ្ញសត្តភូមិ ១ ) ៕

# ២. រូបាវចរសោភណចិត្ត ១៥

ពាក្យថា **រូបាវចរសោភណចិត្ត (រូបាវចរសោភណចិត្តំ)** គឺ **រូប+វចរ+សោភណ+ចិត្តំ** ប្រែថា សោភណចិត្តដែលប្រព្រឹត្តទៅក្នុងរូប បានដល់ រូបជ្ឈាន ។

ពាក្យថា **ឈាន** មានអត្ថន័យ ២ ន័យ គឺ :

**ន័យទី ១** សំដៅដល់ការសម្លឹងពិចារណា ដុតកំដៅនូវសភាវៈបដិបក្ខ ដូចនីវរណធម៌ជាដើមឲ្យអស់ទៅ ។

**ន័យទី ២** សំដៅដល់ចិត្តដែលតាំងណែនក្នុងអារម្មណ៍ នៃកម្មដ្ឋាន មានបឋវីកសិណជាដើម ដោយអំណាចនៃអប្បនាសមាធិនោះឯង ទើបហៅថា **ឈាន** ។

ពាក្យថា **រូបជ្ឈាន** មានន័យថា ឈានដែលបានមកពីការសម្លឹងរូប ដូចបឋវីកសិណជាដើម ដូច្នេះទើបហៅថា **រូបជ្ឈាន** ឬ **រូបាវចរឈាន** ។

- រូបជ្ឈានដែលជាកុសល ហៅថា **រូបាវចរកុសលចិត្ត** រូបជ្ឈានដែលជាវិបាក ហៅថា **រូបាវចរវិបាក** រូបជ្ឈានដែលជាកិរិយា

ហៅថា **រូបាវចរកិរិយា** ។ ឈានចិត្តទាំង ៣ ប្រភេទ នេះ ព្រះមានព្រះភាគទ្រង់លើកតម្កើងសរសើរ ប៉ុន្តែមានឈានប្រភេទមួយទៀតដែលព្រះដ៏មានព្រះភាគទ្រង់មិនសរសើរ គឺ **អកុសលឈាន** ។

- អកុសលឈាននោះ គឺ នីវរណៈ ៥ ដែលរារាំងចិត្តមិនឲ្យសម្រេចសេចក្ដីល្អនោះឯង ដូចព្រះតម្រាស់ដែលត្រាស់ទុកក្នុងសំយុត្តនិកាយមហាវារវគ្គ ដោយសេចក្ដីសង្ខេបថា :-

**១.កាមច្ឆន្ទៈ** ដូចភាជនៈដាក់ទឹក ដែលលាយដោយពណ៌ ។

**២.ព្យាបាទ** ដូចភាជនៈដាក់ទឹកកំពុងពុះ ។

**៣.ថីនមិទ្ធៈ** ដូចភាជនៈដាក់ទឹក ដែលជិតទៅដោយសារាយ និង ចក ។

**៤.ឧទ្ធច្ចកុក្កុច្ចៈ** ដូចជាភាជនៈដាក់ទឹកដែលត្រូវខ្យល់ធ្វើឲ្យញ័ររញ្ជួយ ។

**៥.វិចិកិច្ឆា** ដូចភាជនៈដាក់ទឹកល្អក់ខ្វល់ដូចភក់ ។

រូបាវចរចិត្តនេះ ក្នុងព្រះអភិធម្មកំណត់ទុកចំនួនមាន ១៥ ដួង ចែកជាកុសល ៥ ដួង ជាវិបាក ៥ ដួង ជាកិរិយា ៥ ដួង រួមទាំងអស់ ១៥ ដួង ។

# បាលីរូបាវចរកុសលចិត្ត ៥ ដួង

**១. វិតក្ក វិចារ បីតិ សុខេកគ្គតាសហិត បឋម-ជ្ឈានកុសល** ចិត្តជាបឋមជ្ឈានកុសលចិត្ត ១ ប្រកបព្រមដោយ វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា ។

**២. វិចារ បីតិ សុខេកគ្គតាសហិត ទុតិយជ្ឈាន-កុសល** ចិត្តជាទុតិយជ្ឈានកុសលចិត្ត ១ ប្រកបព្រមដោយ វិចារៈ បីតិ សុខ ឯកគ្គតា ។

**៣. បីតិ សុខេកគ្គតាសហិត តតិយជ្ឈានកុសល** ចិត្តជាតតិយជ្ឈានកុសលចិត្ត ១ ប្រកបព្រមដោយ បីតិ សុខ ឯកគ្គតា។

**៤. សុខេកគ្គតាសហិត ចតុត្ថជ្ឈានកុសល** ចិត្តជាចតុត្ថជ្ឈានកុសលចិត្ត ១ ប្រកបព្រមដោយ សុខ ឯកគ្គតា ។

**៥. ឧបេក្ខេកគ្គតាសហិត បញ្ចមជ្ឈានកុសល** ចិត្តជាបញ្ចមជ្ឈានកុសលចិត្ត ១ ប្រកបព្រមដោយឧបេក្ខា ឯកគ្គតា ។

# អធិប្បាយរូបាវចរកុសលចិត្ត

ចិត្តជារូបាវចរកុសលនេះ សំដៅយកចិត្តដែលជាកុសលកម្ម ប្រព្រឹត្តទៅដោយអំណាចនៃអប្បនាសមាធិ ដែលកើតឡើងពីការសម្លឹងកម្មដ្ឋានមានបឋវីជាដើម អាស្រ័យហេតុនេះ ទើបចាត់ចិត្ត ៥ ដួងនេះ ជាមហគ្គតកុសលកម្ម ជាគរុកម្ម ជាកម្មធ្ងន់ ហើយកុសលនេះនឹងញ៉ាំងនូវផល ឲ្យទៅកើតជារូបព្រហ្មបុគ្គល ក្នុងរូបព្រហ្ម ១៦ ជាន់ ។

ចិត្តជារូបាវចរកុសល ៥ ដួងនេះ ចែកចំណែកទៅតាមឈានទាំង ៥ គឺ :

១. ជាបឋមជ្ឈាន ១ ដួង ប្រកបដោយអង្គ ៥
២. ជាទុតិយជ្ឈាន ១ ដួង ប្រកបដោយអង្គ ៤
៣. ជាតតិយជ្ឈាន ១ ដួង ប្រកបដោយអង្គ ៣
៤. ជាចតុត្ថជ្ឈាន ១ ដួង ប្រកបដោយអង្គ ២
៥. ជាបញ្ចមជ្ឈាន ១ ដួង ប្រកបដោយអង្គ ២

ក្នុងការចំណែកនូវរូបជ្ឈានចេញជា ៥ ឈាននេះ ក៏ដោយអាស្រ័យអង្គនៃឈានជាប្រធាន ។ ពាក្យថា **អង្គឈាន ៗ** នោះ

ក៏សំដៅដល់សភាវធម៌ដែលជាបច្ច័យ ឬ ជាគ្រឿងទ្រទ្រង់ គ្រឿងអាស្រ័យ ឲ្យចិត្តនោះចូលទៅដល់អប្បនាសមាធិនោះឯង ។

# អង្គ ៥ នៃបឋមជ្ឈាន

## ១. វិតក្កោ វិតក្កៈ

បណ្ដាអង្គ ៥ នៃឈាននេះ វិតក្កស័ព្ទនេះមាន វចនត្ថៈថា **វិតក្កេតីតិ វិតក្កោ វតក្កនំ វិតក្កោ** ។ ធម៌ដែល ឈ្មោះថា **វិតក្កៈ** ព្រោះអត្ថថា ត្រិះរិះ ( គឺ នឹក ) ។ ម្យ៉ាងទៀត ការត្រិះរិះ ( គឺ ការទល់នឹងអារម្មណ៍ ) ឈ្មោះថា **វិតក្កៈ** ។

ចំណែកក្នុងព្រះអភិធម្មត្ថវិភាវិនី ពោលថា **អារម្មណំ វិតក្កេតិ សម្បយុត្តធម្មេ អភិនិរោបេតីតិ វិតក្កោ** ។ ធម៌ដែលឈ្មោះថា **វិតក្កៈ** ព្រោះអត្ថថា ត្រិះរិះ គឺលើកនូវសម្បយុត្តធម៌ឡើងកាន់អារម្មណ៍ ប្រៀបដូចជាអ្នកចូលដល់ ព្រះរាជមណ្ឌលបានអាស្រ័យមិត្ត បានទំនាក់ទំនងនឹងព្រះរាជា យ៉ាងណា ចិត្តអាស្រ័យវិតក្កៈ ក៏រមែងឡើងកាន់អារម្មណ៍ បានដូច្នោះដែរ ។

**មានពាក្យសួរថា** បើដូច្នោះ ឈានចិត្តដែលមិនមានវិតក្កៈ

តើនឹងអាចឡើងកាន់អារម្មណ៍បាន ដូចម្តេចទៅ ?

**ឆ្លើយថា** សូម្បីឈានចិត្តដែលមិនមានវិតក្កៈ ក៏តែងឡើងកាន់អារម្មណ៍បានដែរ ដោយកម្លាំងនៃវិតក្កៈនោះឯង ប្រៀបដូចបុគ្គលនោះ សូម្បីវៀរចាកមិត្តនោះ ក៏អាចចូលទៅកាន់ព្រះរាជ-មណ្ឌលបាន ព្រោះធ្លាប់ចូលហើយយ៉ាងណា ឈានចិត្តដែលមិនមានវិតក្កៈ ក៏រមែងឡើងកាន់អារម្មណ៍បាន យ៉ាងនោះដែរ ។

ដែលឈ្មោះថា ធ្លាប់ៗក្នុងទីនេះ បានដល់ ការអប់រំចិត្តដែលកើតឡើងដោយអំណាចនៃការប្រព្រឹត្តរឿយៗ ក្នុងសន្តាននៃចិត្តដែលមានវិតក្កៈ ។ ម្យ៉ាងទៀត ចិត្តដែលមិនមានវិតក្កៈទាំងនេះ គឺ **បញ្ចវិញ្ញាណ** សូម្បីមិនមានវិតក្កៈ ក៏រមែងឡើងកាន់អារម្មណ៍បានដោយកម្លាំងនៃវត្ថុ និង អារម្មណ៍ មកប៉ះខ្ទប់គ្នា និង ឈានមាន **ទុតិយជ្ឈាន** ជាដើម តែងឡើងកាន់អារម្មណ៍បានដោយកម្លាំង ការនៃចំរើនឈានថ្នាក់ទាប ។

**វិតក្កៈ** ក្នុងឈាននេះ ប្រហារនូវ **ថីនមិទ្ធនីវរណៈ** ដោយវិក្ខម្ភនប្បហាន ៕

## ២. វិចារោ វិចារៈ

**វិចារស័ព្ទ** នេះ មានវចនត្ថៈថា **អារម្មណេ តេន ចិត្តំ**

**វិចរតីតិ វិចារោ** ។ ធម៌ដែលឈ្មោះថា **វិចារៈ** ព្រោះអត្ថថា ជាហេតុពិចារណាអារម្មណ៍នៃចិត្ត ។

វិចារៈនេះ មានលក្ខណៈប្រនៀលនូវអារម្មណ៍ គឺ លោកអធិប្បាយថា ជាការជាប់បន្ត ( អនុសន្ធានតា ) ។

បណ្ដាធម៌ទាំង ២ នេះ **វិតក្កៈ** គឺ ជាការព្រមព្រៀងដំបូងនៃចិត្ត ប្រៀបដូចជាការគោះរគាំងដំបូង ដោយអត្ថថា គ្រោតគ្រាតជាងវិចារៈ និងជាធម៌ទៅមុនវិចារៈនោះឯង ចំណែក **វិចារៈ** ជាការស្រាវជ្រាវ ប្រៀបដូចសំឡេងខ្ទរនៃរគាំងនោះ ។

✳ ម្យ៉ាងទៀត **វិតក្កៈ** គឺជាការផ្សាយទៅ គឺជាការត្រដរនៃចិត្ត ប្រៀបដូចជាការ ទទះស្លាបនៃសត្វដែលត្រូវការនឹងហើរទៅ និងប្រៀបដូចជាការចុះសំដៅចំពោះផ្កាបទុមនៃភមរ ដែលមានចិត្តស្រង់ក្លិន ចំណែក **វិចារៈ** មានការប្រព្រឹត្តិទៅស្ងប់ មានការមិនត្រដរនៃចិត្តទៀតទេ ប្រៀបដូចជាការត្រដាងស្លាបនៃសត្វដែលហោះហើរក្នុងអាកាស និងប្រៀបដូចជាការហើរក្រឡឹងលើផ្កាបទុមនៃភមរដូច្នោះ ។

**វិចារៈ** ក្នុងអង្គឈាននេះ ប្រហារ **វិចិកិច្ឆានីវរណៈ** ៕

## ៣. បីតិ

**បីតិស័ព្ទ** នេះ មានវចនត្ថៈថា **បិនយតិ កាយចិត្តំ តប្បេតិ**

**វឡ្សតីតិ វា បីតិ** ។ ធម្មជាតិដែលឈ្មោះថា **បីតិ** ព្រោះអត្ថថា ញុំាងកាយនិងចិត្តឲ្យឆ្អែត ឲ្យរីករាយ ឬថាញុំាងកាយនិងចិត្តឲ្យចំរើន។

បីតិនេះ មានការឆ្អែត ជាលក្ខណៈ បានដល់ ការទទួលអារម្មណ៍ដោយគួរ ( ដល់កាយនិងចិត្ត ) ជាលក្ខណៈ គឺធ្វើកាយនិងចិត្តឲ្យត្រេកអរមាន ៥ យ៉ាង គឺ :

**១.ខុទ្ទកាបីតិ** សេចក្តីត្រេកអរតិចតួច គ្រាខ្លះក៏ព្រឺរោម ព្រឺស្បែក គ្រាខ្លះក៏ហូរទឹកភ្នែកក៏មាន ។

**២.ខណិកា បីតិ** សេចក្តីត្រេកអរមួយជួរខណៈ ប្រាកដដូចផ្លេកបន្ទោរ ។

**៣.ឱក្កន្តិកា បីតិ** បីតិកើតហើយ ធ្វើកាយឲ្យញ័រ ប្រាកដដូចជារលកទឹកបោកខ្ទប់មកត្រូវ ។

**៤.ឧព្វេង្គា បីតិ** បីតិខ្លាំងអាចញុំាងឲ្យកាយអណ្តែតឡើង ។

**៥.ផរណា បីតិ** បីតិធ្វើឲ្យត្រជាក់ជ្រួតជ្រាបទូទៅក្នុងកាយ ដូចសំឡីជប់ដោយប្រេងល្វ ។

បីតិដែលជាអង្គឈាន គឺ ផរណាបីតិ **បីតិ** នេះអាចប្រហារ **ព្យាបាទនីវរណៈ** បានដោយវិក្ខម្ភនប្បហាន ចំណែកបីតិដទៃ ៤ យ៉ាងទៀត មិនរាប់ថាជាអង្គនៃឈានទេ ព្រោះមានកម្លាំងតិច ។

# ៤. សុខ ( សោមនស្សវេទនា )

**សុខ** ស័ព្ទ ក្នុងអង្គឈាន មានវចនត្ថៈថា **សម្បយុត្តធម្មេ សុខយតីតិ សុខំ** ធម្មជាតិឈ្មោះថា **សុខ** ព្រោះអត្ថថា ញុំាង សម្បយុត្តធម៌ឲ្យសប្បាយ ។ ម្យ៉ាងទៀត ធម្មជាតិណា តែងទំពា ស៊ីសប្បាយ និងតែងកកាយ ( គឺ បំផ្លាញ ) អាពាធផ្លូវចិត្ត ព្រោះ ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **សុខ** ។

ពាក្យថា " **សុខ** " នេះជាឈ្មោះនៃសោមនស្សវេទនា ដែលមានការសោយនូវអារម្មណ៍ ដែលជាទីប្រាថ្នា ជាលក្ខណៈ ។

**សុខ** គឺ សោមនស្សវេទនាក្នុងអង្គឈាននេះ ប្រហារនូវ **ឧទ្ធច្ចកុក្កុច្ចនីវរណៈ** ។

ម្យ៉ាងទៀត **បីតិ** និង **សុខ** នេះ មានសភាវៈដែលជិតប្រហាក់ ប្រហែលគ្នាច្រើន គួរគប្បីកំណត់ដឹងនូវសេចក្ដីផ្សេងគ្នាយ៉ាងនេះ គឺ :

**បីតិ** បានដល់ សេចក្ដីត្រេកអរក្នុងការបាននូវឥដ្ឋារម្មណ៍ ។

**សុខ** បានដល់ ការសោយរសនៃឥដ្ឋារម្មណ៍ដែលបានហើយ ។

**បីតិ** មានក្នុងទីណា សុខក៏មានក្នុងទីនោះ ។

**សុខ** មានក្នុងទីណា ទីនោះមិនពិតថាមានបីតិទេ ។
**បីតិ** សង្គ្រោះចូលក្នុងសង្ខារខន្ធ ។
**សុខ** សង្គ្រោះចូលក្នុងវេទនាខន្ធ ។

# ឧបមា បីតិ និង សុខ

**បីតិ** ប្រៀបដូចជា ក្នុងករណីដែលបុគ្គលនឿយហត់កណ្ដាលផ្លូវកន្តារ បានឃើញ បានឮសំឡេងទឹកហូរក្នុងព្រៃជាដើម ( មិនទាន់បានផឹក ) ក៏កើតបីតិរីករាយចិត្តថា យើងនឹងបានផឹកបានមុជជម្រះរាងកាយឲ្យសប្បាយ ។ ឯចំណែក **សុខ** នោះ ប្រៀបដូចជាបុគ្គលដែលបានជ្រកម្លប់ បានផឹកបានងូតមុជតាមសប្បាយ ។

# ៥. ឯកគ្គតា

**ឯកគ្គតាចិត្ត** នោះ មានវចនត្ថៈថា៖

**នានាលម្ពនវិក្ខេបាភាវេន ឯកំ អារម្មណំ**
**អគ្គំ ឥមស្សាតិ ឯកគ្គំ ចិត្តំ ។**
**តស្ស ភាវោ ឯកគ្គតា សមាធិ**

ចិត្តដែលឈ្មោះថា **ឯកគ្គ** ដោយអត្ថថា មានអារម្មណ៍តែមួយ ព្រោះមិនមានការរាយមាយក្នុងអារម្មណ៍ផ្សេងៗ ភាវៈនៃចិត្តមានអារម្មណ៍តែមួយនោះ ឈ្មោះថា **ឯកគ្គតា** គឺ សមាធិ ។

**សមាធិ** ឈ្មោះថា មានការមិនរាយមាយ ជាលក្ខណៈ ព្រោះមិនឲ្យសហជាតធម៌ទាំងឡាយរាយមាយខ្វាត់ខ្វាយ ។

ដូចជាព្រះរាជា ឬ មេទ័ពទៅកាន់ទីកន្លែងកងទ័ពចម្បាំង ទាហានទាំងនោះតែងប្រជុំគ្នាកុះករ ត្រង់កន្លែងដែលព្រះរាជាយាង-ទៅ ទាហានតែងព្រមព្រៀងគ្នាកំចាត់សត្រូវ និងតែងព្រមស្របតាមព្រះរាជា ។

ម្យ៉ាងទៀតឈ្មោះថា **សមាធិ** គឺ **ឯកគ្គតានៃចិត្តនេះ** មានសេចក្ដីមិនរវើរវាយ ជាលក្ខណៈ , មានការប្រមូលមកនូវសហ-ជាតធម៌ទាំងឡាយចូលជាមួយគ្នា ជារស(កិច្ច) ដូចទឹកធ្វើកម្ទេចល្អិតឲ្យជាប់គ្នាជាដុំៗ , មានការចូលទៅស្ងប់ជាបច្ចុប្បដ្ឋាន ឬមានញាណគឺចិត្តតាំងមាំហើយជាក់ច្បាស់ តែងឃើញសេចក្ដីពិត , ជាពិសេសសមាធិមានសុខ ជាបទដ្ឋាន ។

បណ្ឌិត គប្បីជ្រាបការតាំងនៅនៃចិត្ត ដូចការតាំងនៅនៃអណ្ដាតប្រទីបដែលស្ងប់ខ្យល់ដូច្នោះ ។

**ឯកគ្គតានៃចិត្ត** នេះ ប្រហារនូវ **កាមច្ឆន្ទនីវរណៈ** ។

# សមាធិមាន ៣ យ៉ាង

**១.ខណិកសមាធិ** បានដល់ ចិត្តតាំងមាំនៅក្នុងអារម្មណ៍បានមួយជួរខណៈ ។

**២.ឧបចារសមាធិ** បានដល់ ចិត្តតាំងមាំនៅក្នុងអារម្មណ៍ជិតឈានចិត្ត ។

**៣.អប្បនាសមាធិ** បានដល់ ចិត្តតាំងមាំណែន ក្នុងអារម្មណ៍ដែលកំណត់ទុក កិលេសមិនអាចចូលមករំខានបាន ឈានចិត្តនោះ រមែងកើតឡើងដោយអប្បនាសមាធិនេះ ។

# ប្រភេទនៃឈានចិត្ត

ន័យក្នុងព្រះអភិធម្ម ចំណែកឈានទុកជា ៥ ហៅថា **បញ្ចកន័យ** ចំពោះមន្ទបុគ្គល ដែលមានបញ្ញាដឹងយឺតយូរ មិនអាចពិចារណាឃើញទោសនៃវិតក្កៈ និង វិចារៈទាំង ២ នេះបានក្នុងខណៈជាមួយគ្នាទេ ឈាន ៥ នោះ គឺ :-

**១.បឋមជ្ឈាន** មានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា ។

**២.ទុតិយជ្ឈាន** មានអង្គ ៤ គឺ វិចារៈ បីតិ សុខ ឯកគ្គតា។

**៣.តតិយជ្ឈាន** មានអង្គ ៣ គឺ បីតិ សុខ ឯកគ្គតា ។

**៤.ចតុត្ថជ្ឈាន** មានអង្គ ២ គឺ សុខ ឯកគ្គតា ។

**៥.បញ្ចមជ្ឈាន** មានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា ។

# បឋមជ្ឈាន

ឈ្មោះថា **ឈាន** ព្រោះចូលទៅសម្លឹងពិចារណាអារម្មណ៍ និងព្រោះដុតនូវធម៌ដែលជាសឹកសត្រូវ ។ ដែលឈ្មោះថា **បឋម** (ទី១) ព្រោះជាខាងដើមដោយលំដាប់នៃទេសនា និង ដោយលំដាប់នៃការកើតឡើង ព្រោះហេតុនោះ ទើបឈ្មោះថា បឋមជ្ឈាន (ឈានទី១) បានដល់ ការប្រជុំនៃអង្គឈាន ៥ មានវិតក្កៈ និង វិចារៈជាដើម ដូចក្នុងវិភង្គបករណ៍ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ឈ្មោះថា **ឈាន** បានដល់ វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា ។

# បឋមជ្ឈានកុសលចិត្ត

កុសលចិត្ត សម្បយុត្តដោយបឋមជ្ឈាន ឈ្មោះថា **បឋមជ្ឈានកុសលចិត្ត** ។

**មានពាក្យសួរថា** ពេលនោះសម្បយុត្តធម៌ដទៃ មានផស្សៈជាដើម មានដែរ ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់ត្រាស់តែធម៌ ៥ នេះប៉ុណ្ណោះថាជា អង្គឈាន ៥ ?

**លោកឆ្លើយថា** ព្រោះធម៌ ៥ ទាំងនេះមានកិច្ច (គឺ នាទី) សម្លឹងពិចារណាអារម្មណ៍ និងជាបដិបក្ខដោយត្រង់ ចំពោះកាមច្ឆន្ទនីវរណៈ ជាដើម គឺ :

| | | | | |
|---|---|---|---|---|
| **១-** | **ឯកគ្គតា** | បដិបក្ខនឹង | | **កាមច្ឆន្ទៈ** |
| **២-** | **បីតិ** | ” | ” | **ព្យាបាទ** |
| **៣-** | **វិតក្កៈ** | ” | ” | **ថីនមិទ្ធៈ** |
| **៤-** | **សុខ** | ” | ” | **ឧទ្ធច្ចកុក្កុច្ចៈ** |
| **៥-** | **វិចារៈ** | ” | ” | **វិចិកិច្ឆា** |

ក្នុងសារត្ថបកាសិនី អដ្ឋកថាសំយុត្តនិកាយ មហាវារវគ្គ ពោលការលះនូវនីវរណៈ ៥ ទុកយ៉ាងនេះ គឺ :-

**១.កាមច្ឆន្ទៈ** លះបង់ចេញដោយធម៌ ៣ គឺ ដោយតទង្គនិស្សរណៈ(វិបស្សនា) ១ ដោយវិក្ខម្ភននិស្សរណៈ(អសុភឈាន) ១ និងដោយសមុច្ឆេទនិស្សរណៈ( អនាគាមិមគ្គ ) ១ ។

**២.ព្យាបាទ** លះបង់ចេញដោយធម៌ ២ គឺ ដោយវិក្ខម្ភននិស្សរណៈ(មេត្តាឈាន) និងដោយសមុច្ឆេទនិស្សរណៈ( អនាគាមិមគ្គ ) ១ ។

**៣.ថីនមិទ្ធៈ** លះបង់ចេញដោយធម៌ ២ គឺ ដោយវិក្ខម្ភននិស្សរណៈ( អាលោកសញ្ញា ) និង ដោយសមុច្ឆេទនិស្សរណៈ( អរហត្តមគ្គ ) ។

**៤.ឧទ្ធច្ចកុក្កុច្ចៈ** លះបង់ចេញដោយ វិក្ខម្ភននិស្សរណៈ (សមថកម្មដ្ឋានណាមួយ) និង ដោយសមុច្ឆេទនិស្សរណៈ គឺ កុក្កុច្ចៈ ដោយអនាគាមិមគ្គ ឯឧទ្ធច្ចៈ ដោយអរហត្តមគ្គ ។

**៥.វិចិកិច្ឆា** លះបង់ចេញដោយធម៌ ២ គឺ ដោយវិក្ខម្ភននិស្សរណៈ( ឈានណាមួយ ) និង ដោយសមុច្ឆេទនិស្សរណៈ( សោតាបត្តិមគ្គ ) ។

# និយាយអំពីសង្ខារភេទនៃអប្បនាឈាន

ក្នុងកុសលឈាន គឺ រូបាវចរកុសលនេះ លោកមិនកាន់យកសេចក្តីផ្សេងគ្នានៃឈាន ដោយអសង្ខារិកនិងសសង្ខារិកទេ ដូចក្នុងអភិធម្មត្ថវិភាវិនី បាលីពោលទុកថា :-

-មិនអាចហៅថា **អសង្ខារិក** ព្រោះឈានទាំងអស់វៀរចាកការតាក់តែងខាងដើម គឺ បរិកម្ម រមែងកើតឡើងដោយអំណាចការតាំងចិត្តដំបូង ( អធិការ ) តែម្យ៉ាងមិនបានទេ ។

-មិនអាចហៅថា **សសង្ខារិក** ព្រោះវៀរចាកការតាំងចិត្តដំបូងហើយ កើតឡើងដោយការតាក់តែង គឺបរិកម្មតែម្យ៉ាងប៉ុណ្ណោះមិនបាន ។

ប៉ុន្តែអាចារ្យសម័យក្រោយៗ លោកសង្គ្រោះចូលជាសសង្ខារិក ។

# ឈាន ២ យ៉ាង

**១.អារម្មណូបនិជ្ឈាន** បានដល់ សមាបត្តិ ៨ ។

**២.លក្ខណូបនិជ្ឈាន** បានដល់ វិបស្សនា មគ្គ ផល។

សមាបត្តិ ៨ ឈ្មោះថា **អារម្មណូបនិជ្ឈាន** ព្រោះការ

សម្លឹងអារម្មណ៍ដែលជាកសិណ មានបឋវីកសិណជាដើម ចំណែក វិបស្សនា ឈ្មោះថា **លក្ខណូបនិជ្ឈាន** ព្រោះកិលេសដែលវិបស្សនា កំចាត់ហើយ តែងសម្រេចដោយមគ្គ ។ ចំណែកឯ ផលចិត្ត ឈ្មោះថា **លក្ខណូបនិជ្ឈាន** ក៏ព្រោះសម្លឹងពិចារណានូវលក្ខណៈ ដែលជាសច្ចៈ គឺ និរោធសច្ចៈ ។

ឈានក្នុងទីនេះ បំណងយកជា **អារម្មណូបនិជ្ឈាន** ។ ដូច្នេះឈាននេះដែលឈ្មោះថា **ឈាន** ព្រោះចូលទៅសម្លឹងអារម្មណ៍ ឬ ព្រោះជាគ្រឿងដុតរោលនូវបដិបក្ខធម៌ ( ធម៌ដែលជាសត្រូវដល់គ្នា និង គ្នា ) ។

អារម្មណ៍ដែលគួរចូលទៅសម្លឹង ដើម្បីធ្វើចិត្តឲ្យស្ងប់ចាក នីវរណៈ ៥ ហៅថា សមថកម្មដ្ឋាន មាន ៤០ យ៉ាង ។

# សមថកម្មដ្ឋាន ៤០ យ៉ាង

## ១. កសិណ ១០ គឺ :

បឋវីកសិណ(ដី) ១ អាបោកសិណ(ទឹក) ១ តេជោកសិណ (ភ្លើង) ១ វាយោកសិណ(ខ្យល់) ១ នីលកសិណ(ពណ៌ខៀវ) ១ បីតកសិណ(ពណ៌លឿង) ១ លោហិតកសិណ(ពណ៌ក្រហម) ១

ឱទាតកសិណ(ពណ៌ស) ១ អាកាសកសិណ(អាកាស) ១ និង អាលោកកសិណ(ពន្លឺ) ១ ។

## ២. អសុភ ១០ គឺ :

១. ឧទ្ធុមាតកំ អសុភហើមប៉ោង ។
២. វិនីលកំ អសុភហើមពណ៌ខៀវ ។
៣. វិបុព្វកំ អសុភហើមហូរខ្ទុះ ។
៤. វិច្ឆិទ្ទកំ អសុភដាច់ពាក់កណ្ដាលខ្លួន ។
៥. វិក្ខាយិតកំ អសុភសត្វកកេរស៊ីយរលួយ ។
៦. វិក្ខិត្តកំ អសុភដាច់ដៃ ដាច់ជើង ។
៧. ហតវិក្ខិត្តកំ អសុភគេកាប់ស្នាមរវាម ។
៨. លោហិតកំ អសុភឈាមស្រោចពេញខ្លួន ។
៩. បុឡុវកំ អសុភមានដង្កូវ ។
១០. អដ្ឋិកំ អសុភមានតែរាងឆ្អឹង ។

## ៣. អនុស្សតិ ១០ គឺ :

១. ពុទ្ធានុស្សតិ រលឹកដល់គុណព្រះពុទ្ធ ។

២. ធម្មានុស្សតិ     រលឹកដល់គុណព្រះធម៌ ។
៣. សង្ឃានុស្សតិ     រលឹកដល់គុណព្រះសង្ឃ ។
៤. សីលានុស្សតិ     រលឹកដល់សីល ។
៥. ចាគានុស្សតិ     រលឹកដល់ទាន ។
៦. ទេវតានុស្សតិ     រលឹកដល់ទេវតា ។
៧. ឧបសមានុស្សតិ     រលឹកដល់ព្រះនិព្វាន ។
៨. មរណានុស្សតិ     រលឹកដល់សេចក្តីស្លាប់ ។
៩. កាយគតាសតិ     កាយប្រជុំដោយអាការ ៣២ ។
១០. អានាបានស្សតិ     រលឹកដឹងខ្យល់ដង្ហើមចេញចូល ។

## ៤. ព្រហ្មវិហារធម៌ ៤

១. មេត្តា     សេចក្តីរាប់អាន ។
២. ករុណា     សេចក្តីអាណិតអាសូរ ។
៣. មុទិតា     សេចក្តីអំណរនឹងសេចក្តីសុខ ។
៤. ឧបេក្ខា     សេចក្តីស្មោះស្មើមិនលំអៀង ។

# ៥. អរូបជ្ឈាន ៤

១. **អាកាសានញ្ចាយតនៈ** អាកាសមិនមានទីបំផុត ។
២. **វិញ្ញាណញ្ចាយតនៈ** វិញ្ញាណមិនមានទីបំផុត ។
៣. **អាកិញ្ចញ្ញាយតនៈ** អ្វីតិចតួចមិនមាន ។
៤. **នេវសញ្ញានាសញ្ញាយតនៈ** វិញ្ញាណល្អិតប្រណីតក្រៃពេក ។

# ៦. អាហារេបដិក្ខូលសញ្ញា ១

សេចក្តីសំគាល់នូវអាហារថា ជារបស់គួរខ្ពើមរអើម ។

# ៧. ចតុធាតុវវដ្ឋាន ១

ការកំណត់ចែកធាតុ ៤ មានបឋវីធាតុជាដើម ដោយសសម្ភារៈមានកេសាជាដើម ។

ក្នុងអារម្មណ៍កម្មដ្ឋាន ៤០ នេះ អារម្មណ៍ដែលនឹងធ្វើឲ្យបានសម្រេចដល់អប្បនាសមាធិមានត្រឹមតែ ៣០ យ៉ាង ប៉ុណ្ណោះ ដែលលោកបានពោលទុកក្នុងវិសុទ្ធិមគ្គបឋមភាគ នូវសមថកម្មដ្ឋាន ៤០ វិនិច្ឆ័យដោយអាការៈ ១០ យ៉ាង គឺ :-

**១.ដោយសម្តែងចំនួន** បានដល់ សមថកម្មដ្ឋាន ៤០ គឺ កសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ អរូបជ្ឈាន ៤ អាហារេបដិកូលសញ្ញា ១ ចតុធាតុវវដ្ឋាន ១ ។

**២.ដោយនាំមកនូវឧបចារៈ និង អប្បនា** គឺ ក្នុងកម្មដ្ឋាន ៤០ នោះ អនុស្សតិ ៨ (វៀរកាយគតាសតិ និង អានាបានស្សតិ) អាហារេបដិកូលសញ្ញា ១ ចតុធាតុវវដ្ឋាន ១ រួម ១០ នេះ ជាកម្មដ្ឋាននាំឲ្យបានត្រឹមតែ **ឧបចារឈាន** (ឧបចារសមាធិ) ក្រៅពីនេះ នាំឲ្យបានដល់ **អប្បនាឈាន** (អប្បនាសមាធិ) ។

**៣.ដោយប្រភេទនៃឈាន** គឺ កសិណ ១០ អានាបានស្សតិ ១ ចំរើនបានដល់ **ចតុត្ថជ្ឈាន** ( ឈានទី ៤ ) ដោយចតុកន័យ) ។ អសុភ ១០ កាយគតាសតិ ១ ចំរើនបានដល់ត្រឹមតែ **បឋមជ្ឈាន**(ឈានទី ១) ដោយចតុកន័យ ។ ព្រហ្មវិហារ ៣ ខាងដើម ចំរើនបានដល់ **តតិយជ្ឈាន**(ឈានទី ៣) ដោយចតុកន័យ ។ ព្រហ្មវិហារទី ៤ និង អរូបជ្ឈាន ប្រព្រឹត្តទៅក្នុង **ចតុត្ថជ្ឈាន** ដោយចតុក្កន័យ ។

**៤.ដោយការកន្លង** បានដល់ ការកន្លង ២ យ៉ាង គឺ កន្លងអង្គឈាន ១ និង កន្លងអារម្មណ៍ ១ ។

ការកន្លងអង្គឈាន ដូចទុតិយជ្ឈាន ( ដោយចតុក្កន័យ ) កន្លងវិតក្កៈ វិចារៈជាដើម ។ ក្នុងព្រហ្មវិហារ ៤ ក៏ ដូចគ្នា ព្រហ្មវិហារទី ៤ ក៏កន្លងសោមនស្ស ។ ចំណែកការកន្លងអារម្មណ៍ តែងមានក្នុងអរូបជ្ឈាន ៤ គឺ អាកាសានញ្ចាយតនៈ កន្លងអារម្មណ៍ ក្នុងកសិណ ៩ ខាងដើមហើយ ទើបសម្រេចបានអរូបជ្ឈានថ្នាក់ ខ្ពស់ ក៏កន្លងអារម្មណ៍ថ្នាក់ទាប ប្រព្រឹត្តទៅដោយលំដាប់ ។

**៥.ដោយគួរពង្រីក ឬ មិនគួរពង្រីក** គឺ កសិណ ១០ គួរពង្រីក (និមិត្ត) ។ អានាបានស្សតិ ១ កាយគតាសតិ ១ អសុភ ១០ ព្រហ្មវិហារ ៤ អរូបជ្ឈាន ៤ មិនគួរពង្រីក ព្រោះ មិនកើតប្រយោជន៍ ។

**៦.ដោយអារម្មណ៍** ក្នុងចំណោមកម្មដ្ឋាន ៤០ នេះ កម្មដ្ឋាន ២២ គឺ កសិណ ១០ អសុភ ១០ អានាបានស្សតិ ១ កាយគតាសតិ ១ មានអារម្មណ៍ជាបដិភាគនិមិត្ត កម្មដ្ឋាន ១៨ ទៀត មិនមានអារម្មណ៍ជាបដិភាគនិមិត្តឡើយ ។

**៧.ដោយភូមិ** បានដល់ កម្មដ្ឋាន ១២ គឺ អសុភ ១០ កាយគតាសតិ ១ អាហារេបដិក្កូលសញ្ញា ១ មិនអាចប្រព្រឹត្ត ទៅក្នុងពួកទេវតាបានទេ ។

កម្មដ្ឋាន ១៣ គឺ កម្មដ្ឋាន ១២ ដែលបានពោលមកហើយ

និង អានាបានស្សតិ ១ មិនអាចប្រព្រឹត្តទៅក្នុងព្រហ្មលោកបានទេ ។ ក្នុងអរូបភព ប្រព្រឹត្តទៅបានចំពោះអរូបកម្មដ្ឋាន ៤ ប៉ុណ្ណោះ ។ ឯក្នុងពួកមនុស្សតែងចំរើនកម្មដ្ឋានបានទាំងអស់ ។

**៨.ដោយការកាន់យក** បានដល់ ការកាន់យកដោយភ្នែកមើល ដោយការប៉ះខ្ទប់ និងដោយការស្តាប់ ។ ក្នុង ៣ យ៉ាងនោះ កម្មដ្ឋាន ១៩ គឺ កសិណ ៩ ( វៀរវាយោកសិណ ) និង អសុភ ១០ គឺកាន់យកដោយការមើល ទើបធ្វើឲ្យកើតនិមិត្ត ៣ បាន។ កាយគតាសតិ កាន់យកដោយភ្នែកមើល និង ដោយការស្តាប់ គឺ តចបញ្ចកកម្មដ្ឋាន កាន់យកដោយភ្នែកមើល ក្រៅពីនោះកាន់យក ដោយការស្តាប់ ។ អានាបានស្សតិ កាន់យកដោយការប៉ះខ្ទប់ វាយោកសិណ កាន់យកដោយការមើល និង ដោយការប៉ះខ្ទប់ ។ នៅសល់ ១៨ ទៀត កាន់យកដោយការស្តាប់ ។

កម្មដ្ឋាន ៤០ នោះ ឧបេក្ខាព្រហ្មវិហារ និងអរូបកម្មដ្ឋាន ៤ ព្រះយោគាវចរជាអ្នកអាទិកម្មិកៈ( នៅមិនទាន់ជំនាញ ) មិនគួរកាន់យកទេ នៅសល់ ៣៥ ក្រៅពីនោះ ទើបគួរកាន់យក ។

**៩.ដោយបច្ច័យ** បានដល់ កសិណ ៩ (វៀរអាកាសកសិណ) ជាបច្ច័យដល់អរូបជ្ឈាន ។ កសិណ ១០ ជាបច្ច័យដល់អភិញ្ញា ។ ព្រហ្មវិហារ ៣ ជាបច្ច័យដល់ព្រហ្មវិហារទី ៤ ។

អរូបជ្ឈានថ្នាក់ក្រោមៗ ជាបច្ច័យដល់អរូបជ្ឈានថ្នាក់ខ្ពស់ៗ ។

នេវសញ្ញានាសញ្ញាយតនៈ ជាបច្ច័យដល់និរោធសមាបត្តិ ។ កម្មដ្ឋានទាំងអស់ ( ទាំងសមថៈទាំងវិបស្សនា ) ជាបច្ច័យដល់សុខ-វិហារ និង ភពសម្បត្តិ ( បាលីថា **សព្វានិបិ សុខវិហារស្ស វិបស្សនា ភាវសម្បត្តីនំ** ) ។

**១០.ដោយសមគួរដល់ចរិត** មានអធិប្បាយថា ក្នុងកម្មដ្ឋាន ៤០ នោះ កម្មដ្ឋាន ១១ គឺ អសុភ ១០ កាយគតាសតិ ១ **សមគួរដល់បុគ្គលដែលជារាគចរិត** ។ កម្មដ្ឋាន ៨ គឺ ព្រហ្មវិហារ ៤ វណ្ណកសិណ ៤ **សមគួរដល់បុគ្គលដែលជាទោសចរិត** ។

អានាបានស្សតិប៉ុណ្ណោះ សមគួរដល់បុគ្គលដែលជាមោហចរិត និង វិតក្កចរិត ។ អនុស្សតិ ៦ ខាងដើម **សមគួរដល់បុគ្គលដែលជាសទ្ធាចរិត** ។ កម្មដ្ឋាន ៤ គឺ មរណានុស្សតិ ១ ឧបសមានុស្សតិ ១ ចតុធាតុវវដ្ឋាន ១ អាហារេបដិក្កូលសញ្ញា ១ សមគួរដល់ **បុគ្គលដែលជាពុទ្ធិចរិត** ។ កសិណដែលនៅសល់ពីនោះ គឺ កសិណ ៦ ( វៀរវណ្ណកសិណ ៤ ) និងអរូបជ្ឈាន ៤ **សមគួរដល់បុគ្គលគ្រប់ចរិត** ។ ម្យ៉ាងទៀត ក្នុងកសិណទាំងឡាយ

កសិណណាមួយដែលជាបរិត្តារម្មណ៍ **សមគួរដល់បុគ្គលដែលជាវិតក្កចរិត** និងកសិណណាមួយដែលជាអប្បមាណារម្មណ៍ **សមគួរដល់បុគ្គលដែលជាមោហចរិត** ។

ការចំរើនសមថភាវនា គឺ ចំរើនរូបជ្ឈាន ប្រកបដោយអង្គឈាន ៥ មានវិតក្កៈជាដើមនោះ អាចបញ្ឈប់នូវនីវរណៈ ៥ មិនឲ្យកើតឡើងបាន ព្រោះចិត្តតាំងណែនក្នុងអារម្មណ៍តែមួយ រហូតដល់ឈានចិត្តកើត ។ ពេលឈានចិត្តកើតហើយ អង្គឈាននោះឯងតែងប្រហារនូវនីវរណៈ ៥ ដោយ វិក្ខម្ភនប្បហាន ។

ម្យ៉ាងទៀត ពេលឈានចិត្តនឹងកើតឡើង សមាធិរមែងកើតឡើងតាមលំដាប់ គឺ **ខណិកសមាធិ ឧបចារសមាធិ** និង **អប្បនាសមាធិ** ។ ឈានចិត្តកើតឡើងគ្រាដំបូងបានត្រឹមតែ **មួយខណៈនៃចិត្ត** ប៉ុណ្ណោះ ហើយក៏ជាភវង្គ ។ បើនឹងមិនឲ្យមកជាភវង្គទេ, ត្រូវហ្វឹកហាត់រហូតដល់ស្ទាត់ជំនាញ ( ដែលហៅថា វសី ៥ យ៉ាង ) ។ ឯ **ឈាន** គឺ រូបាវចរកុសលចិត្ត នឹងកើតឡើងនោះ វិថីចិត្តនឹងកើតឡើងតាមលំដាប់យ៉ាងនេះ គឺ :

**១.** ភវង្គចលនៈ

**២.** ភវង្គុបច្ឆេទៈ

៣. មនោទ្វារាវជ្ជនៈ

៤. បរិកម្ម
៥. ឧបចារៈ
៦. អនុលោម
៧. គោត្រភូ
} មហាកុសលញាណសម្បយុត្ត

៨. ឈាន	គឺ រូបាវចរកុសលចិត្ត

ភវង្គបាទ	ចិត្តជាភវង្គ

កាល **ភវង្គចលនៈ** គឺការញ័រនៃភវង្គរលត់ទៅ ភវង្គុបច្ឆេទៈ ក៏កើតឡើងហើយក៏រលត់ តពីនោះ មនោទ្វារាវជ្ជនៈ គឺ អហេតុក-កិរិយាចិត្តក៏កើតឡើង ធ្វើកិច្ចពិចារណាអារម្មណ៍ តាមមនោទ្វារ ។ កាលមនោទ្វារាវជ្ជនៈរលត់ទៅ មហាកុសលញាណសម្បយុត្ត ៤ ដួង ណាមួយ ក៏ធ្វើ បរិកម្ម ឧបចារៈ អនុលោម គោត្រភូ ។ ពេលដែលគោត្រភូចិត្តរលត់ទៅ ឈានចិត្ត ក៏កើតឡើងតែ **មួយខណៈ** ប៉ុណ្ណោះ រួចហើយចិត្ត ក៏ជាភវង្គ តទៅយ៉ាងនេះឯង ។

# ទុតិយជ្ឈាន

កាលព្រះយោគាវចរហ្វឹកហាត់ ព្យាយាមចូលបឋមជ្ឈានរហូត

ជំនាញដល់ព្រមដោយវសីទាំង ៥ គឺ :

១. **អាវជ្ជនវសី** ជំនាញឬស្ទាត់ក្នុងការនឹករក ។

២. **សមាបជ្ជនវសី** ស្ទាត់ក្នុងការចូលកាន់ឈាន ។

៣. **អធិដ្ឋានវសី** ស្ទាត់ក្នុងការឲ្យឈានតាំងមាំ ។

៤. **វុដ្ឋានវសី** ស្ទាត់ក្នុងការចេញចាកឈាន ។

៥. **បច្ចវេក្ខណវសី** ស្ទាត់ក្នុងការពិចារណាអង្គឈាន ។

ព្រះយោគាវចរ ចូលឈាន ចេញចាកឈាន រហូតដល់ជំនាញហើយ ហ្វឹកហាត់ដោយពិចារណាថា នឹករកអ្វី ទើបឈាននឹងកើតបានឆាប់រហ័ស ហ្វឹកហាត់ដោយវិធីនេះរឿយ ៗ រហូតស្ទាត់ល្អ ហៅថា **អាវជ្ជនវសី** ។ **សមាបជ្ជនវសី** គឺ ចូលឈានដែលស្ទាត់នោះជារឿយៗ ។ **អធិដ្ឋានវសី** គឺ ស្ទាត់ក្នុងការឲ្យឈាន កើតរលត់ជាបន្តគ្នាមិនមែនជាភវង្គ គឺ ឲ្យឈានតាំងនៅតាមសេចក្តីត្រូវការ ។ **វុដ្ឋានវសី** គឺ ដោយការតាំងចិត្តនឹងចេញចាកពីឈានក្នុងវេលាណា ក៏ចេញបានក្នុងវេលានោះមិនយឺតយូរ ។ **បច្ចវេក្ខណវសី** គឺ កាលបើចេញចាកពីឈានហើយ ពិចារណាដើម្បីលះនូវអង្គឈានដែលគ្រោតគ្រាតចេញ ដើម្បីធ្វើឲ្យអប្បនាសមាធិតាំងនៅមាំក្រៃលែងឡើង ។ រមែងពិចារណាឃើញថា **វិតក្កៈ** នេះជាអង្គឈានដែល

គ្រោតគ្រាតជាង **វិចារៈ** ព្រោះនៅកៀកនឹងកាមារម្មណ៍ ។

ដូច្នេះ កាលនឹងឆ្លងឡើងកាន់ទុតិយជ្ឈាន ទើបលោកសម្លឹងបដិភាគនិមិត្ត ដើម្បីឲ្យចិត្តជាអប្បនាសមាធិ ដោយមិនមាន វិតក្កៈតទៅ ព្យាយាមឧស្សាហ៍រហូតដល់ឈានចិត្ត មិនមានវិតក្កៈ កើតឡើង ប៉ុន្តែគង់នៅមាន វិចារៈ បីតិ សុខ ឯកគ្គតា ប៉ុណ្ណោះ ។ កាលទុតិយជ្ឈាននឹងកើតនោះ ក៏ត្រូវមានវិថីចិត្តដែលកើតមុន គឺមហាកុសលញាណសម្បយុត្តចិត្តដែលជា បរិកម្ម ឧបចារៈ អនុលោម និង គោត្រភូ ដូចគ្នានឹងបឋមជ្ឈាននោះដែរ ៕

# តតិយជ្ឈាន

កាលណាព្រះយោគាវចរ ស្ទាត់ជំនាញក្នុងទុតិយជ្ឈានប្រកបដោយវសី ៥ ល្អហើយ ក៏សម្លឹងនូវបដិភាគនិមិត្ត ឡើងកាន់ឈានទី ៣ ដោយពិចារណាឃើញវិចារៈ ជាអង្គឈានគ្រោតគ្រាត ជិតនឹងវិតក្កៈ ដែលធ្វើឲ្យវិនាសបានងាយ កាលឃើញទោសនៃវិចារៈហើយ ក៏ចូលឈានសម្លឹងបដិភាគនិមិត្ត ដើម្បីឲ្យអប្បនាសមាធិកើតឡើង ដោយមិនមាន វិចារៈ រហូតដល់តតិយជ្ឈានកើត មានទំនងដូចឈានមុនៗ ដែរ ។

# ចតុត្ថជ្ឈាន

កាលណាព្រះយោគាវចរ ស្ទាត់ជំនាញក្នុងតតិយជ្ឈានប្រកបដោយវសី ៥ ល្អហើយ ក៏ព្យាយាមកន្លងឡើងកាន់ឈានទី ៤ ដោយពិចារណា ឃើញបីតិដែលកើតក្នុងតតិយជ្ឈាននោះ ជាសេចក្ដីត្រេកអរជ្រួតជ្រាបទូទៅទាំងកាយទាំងចិត្ត ដែលគិតថា ជាសភាពដែលនៅគ្រោតគ្រាត ដើម្បីឲ្យចិត្តប្រណីតក្រៃលែងឡើង ទើបសម្លឹងបដិភាគនិមិត្ត ដើម្បីចំរើនអប្បនាសមាធិ រហូតមិនមានបីតិកើតរួមជាមួយ ។ វិថីចិត្តដែលកើតមុនចតុត្ថជ្ឈាន មានទំនងដូចជាឈានមុនៗដែរ ។

# បញ្ចមជ្ឈាន

កាលព្រះយោគាវចរ ស្ទាត់ជំនាញក្នុងចតុត្ថជ្ឈាន ប្រកបដោយវសី ៥ ល្អហើយ ក៏ពិចារណាឃើញទោសរបស់សុខថា ជាសភាពគ្រោតគ្រាតជាងឧបេក្ខា ព្រោះសុខនោះ នៅញាប់ញ័រ មិនតាំងមាំដូចឧបេក្ខាវេទនាទេ ទើបសម្លឹងនូវបដិភាគនិមិត្ត ចំរើនអប្បនាសមាធិដើម្បីលះសុខ រហូតបញ្ចមជ្ឈានកើត ប្រកបដោយអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

មហាកុសលញាណសម្បយុត្តដែលធ្វើ បរិកម្ម ឧបចារៈ អនុលោម និងគោត្រភូ ដែលកើតមុនបញ្ចមជ្ឈាននោះ កើតព្រមនឹង **ឧបេក្ខា-វេទនា** ព្រោះឈានទី ៥ នេះ មាន ឧបេក្ខា និង ឯកគ្គតា ជាអង្គឈាន ចំណែកឈាន ៤ ទៀត ក្រៅពីនេះ មហាកុសលនោះកើតព្រមនឹង **សោមនស្សវេទនា** ។

ម្យ៉ាងទៀត មហាកុសលញាណសម្បយុត្តចិត្ត ដែលកើតក្នុងរវាងការចំរើនសមថភាវនានោះ ពេលខ្លះក៏កើតព្រមនឹងសោមនស្ស-វេទនា ពេលខ្លះក៏កើតព្រមដោយឧបេក្ខាវេទនា ៕

# ការចែករូបាវចរកុសលចិត្ត ៥ ដោយន័យផ្សេងៗ

**១.ដោយជាតិ** ជាកុសលជាតិ ។

**២.ដោយភូមិ** ជារូបាវចរភូមិ( កើតបាន ២២ ភូមិ វៀរអបាយភូមិ ៤ អសញ្ញសត្តភូមិ ១ អរូបភូមិ ៤ ) ។

**៣.ដោយវេទនា** ជាសោមនស្សវេទនា ៤ ដួង គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន

| | |
|---|---|
| | និង ចតុត្ថជ្ឈាន ឧបេក្ខា ១ ។ |
| **៤.ដោយហេតុ** | ជានហេតុ និងជាតិហេតុកចិត្ត។ |
| **៥.ដោយសម្បយុត្ត** | ជាញាណសម្បយុត្ត ។ |
| **៦.ដោយសង្ខារ** | ជាសសង្ខារិក ។ |
| **៧.ដោយសោភណៈ** | ជារូបាវចរសោភណចិត្ត ។ |
| **៨.ដោយឈាន** | ជារូបាវចរឈាន ។ |
| **៩.ដោយលោកិយ** | ជាលោកិយចិត្ត ។ |
| **១០.ដោយកិច្ច** | ជាជវនកិច្ច ។ |
| **១១.ដោយអារម្មណ៍** | មានធម្មារម្មណ៍ជាអារម្មណ៍ ។ |
| **១២.ដោយទ្វារ** | ដឹងអារម្មណ៍តាមមនោទ្វារ ។ |
| **១៣.ដោយវត្ថុ** | កើតដោយអាស្រ័យហទយវត្ថុ ។ |
| **១៤.ដោយវិញ្ញាណធាតុ** | ជាមនោវិញ្ញាណធាតុ ។ |

( ចប់ រូបាវចរកុសលចិត្ត ៥ ដួង )

# រូបាវចរវិបាកចិត្ត ៥ ដួង

រូបាវចរកុសលចិត្ត ជាហេតុឲ្យកើតរូបាវចរវិបាកចិត្តដែលធ្វើបដិសន្ធិក្នុងរូបភូមិ ( រូបាវចរភូមិ ) ផ្សេងៗគ្នា យ៉ាងនេះ គឺ :

# អធិប្បាយរូបាវចរវិបាក

**កាមាវចរវិបាក** មានសភាពដូចគ្នាខ្លះ មិនដូចគ្នាខ្លះនឹងកុសលចិត្តនៃខ្លួន ដូច្នេះហើយវិបាកនៃកាមាវចរកុសលចិត្តនេះ ទើបលោកមិនបានចែកឲ្យវិបាកស្របតាមកុសលឡើយ ។

ចំណែក **រូបាវចរវិបាកនេះ** តែងស្របដូចគ្នានឹងកុសលរបស់ខ្លួន ប្រៀបដូចជាស្រមោលទាំងឡាយ មានស្រមោលដំរី សេះ និង ដើមឈើជាដើម តែងដូចនឹងដំរី សេះ និង ដើមឈើជាដើម នោះ ដោយហេតុនោះ ទើបលោកចែករូបាវចរវិបាកនេះ ធ្វើឲ្យស្របតាមកុសលរបស់ខ្លួន ។

ម្យ៉ាងទៀត **កាមាវចរកុសល** តែងឲ្យវិបាកក្នុងកាលខ្លះក៏បាន គ្រាសម័យខ្លះក៏បាន ។ ចំណែក **រូបាវចរកុសល** តែងឲ្យវិបាកក្នុងភពទី ២ តែមួយប៉ុណ្ណោះ ដោយហេតុនេះហើយ ទើបលោក

ចែកឲ្យស្របដូចកុសលរបស់ខ្លួន គឺ :

**១.បឋមជ្ឈានកុសល** ឲ្យផលជា បឋមជ្ឈានវិបាក បដិសន្ធិក្នុងបឋមជ្ឈានភូមិ ។

**២.ទុតិយជ្ឈានកុសល** ឲ្យផលជា ទុតិយជ្ឈានវិបាក បដិសន្ធិក្នុងទុតិយជ្ឈានភូមិ ។

**៣.តតិយជ្ឈានកុសល** ឲ្យផលជា តតិយជ្ឈានវិបាក បដិសន្ធិក្នុងទុតិយជ្ឈានភូមិ ។

**៤.ចតុត្ថជ្ឈានកុសល** ឲ្យផលជា ចតុត្ថជ្ឈានវិបាកបដិសន្ធិក្នុងតតិយជ្ឈានភូមិ ។

**៥.បញ្ចមជ្ឈានកុសល** ឲ្យផលជា បញ្ចមជ្ឈានវិបាក បដិសន្ធិក្នុងចតុត្ថជ្ឈានភូមិ ។

បុគ្គលអ្នកបដិសន្ធិ ក្នុងរូបាវចរភូមិ ដោយរូបាវចរវិបាកចិត្ត ជារូបព្រហ្ម ។ រូបព្រហ្មនោះតែងមាន ចក្ខុប្បសាទ និងសោតប្បសាទ តែមិនមានឃានប្បសាទ ជីវ្ហាបសាទ និង កាយប្បសាទ ។ ខណៈដែលចក្ខុវិញ្ញាណ ឬសោតវិញ្ញាណនៃព្រហ្មនោះកើតឡើង គប្បីជ្រាបថា ចក្ខុវិញ្ញាណក្តី សោតវិញ្ញាណក្តី មិនមែនជាវិបាក (ផល) នៃរូបាវចរកុសល ៥ ដួង នោះទេ គឺជាវិបាករបស់កាមាវចរកុសល និង

អកុសលប៉ុណ្ណោះ ។ ចំណែករូបាវចរវិបាកមាន តែ ៥ ដួង ប៉ុណ្ណោះ គឺ ធ្វើបដិសន្ធិក្នុងរូបភូមិ ១៥ ( វៀរអសញ្ញសត្តភូមិ ) គឺ :

| | | |
|---|---|---|
| ១. | បារិសជ្ជាភូមិ | បដិសន្ធិដោយបឋមជ្ឈានវិបាកចិត្ត |
| ២. | បុរោហិតាភូមិ | |
| ៣. | មហាព្រហ្មាភូមិ | |
| ៤. | បរិត្តាភាភូមិ | បដិសន្ធិ ដោយទុតិយជ្ឈានវិបាក (ចតុក្កន័យ) ឬ ទុតិយជ្ឈានវិបាក ឬ តិតយជ្ឈានវិបាក (បញ្ចកន័យ) |
| ៥. | អប្បមាណាភាភូមិ | |
| ៦. | អាភស្សរាភូមិ | |
| ៧. | បរិត្តសុភាភូមិ | បដិសន្ធិ ដោយតតិយជ្ឈានវិបាក (ចតុក្កន័យ) ឬ ចតុត្ថជ្ឈានវិបាក (បញ្ចកន័យ) |
| ៨. | អប្បមាណសុភាភូមិ | |
| ៩. | សុភកិណ្ហាភូមិ | |
| ១០. | វេហប្ផលាភូមិ | បដិសន្ធិ ដោយចតុត្ថជ្ឈានវិបាក (ចតុក្កន័យ) ឬ បញ្ចមជ្ឈានវិបាក (បញ្ចកន័យ) |

១១. អវិហាភូមិ
១២. អតប្បាភូមិ
១៣. សុទស្សាភូមិ
១៤. សុទស្សីភូមិ
១៥. អកនិដ្ឋាភូមិ

៥ ភូមិនេះ ជាព្រហ្មសុទ្ធាវាស នៃព្រះអនាគាមី បដិសន្ធិដោយ ចតុត្ថជ្ឈានវិបាក (ចតុក្កន័យ) ឬ បញ្ចមជ្ឈានវិបាក (បញ្ចកន័យ)

# អធិប្បាយព្រហ្មក្នុងព្រហ្មភូមិ

អ្នកដែលកើតជាព្រហ្ម តែងមានសេចក្ដីសុខប្រណីតជាងសុខរបស់ទេវតា មានរូបស្អាត មានសំឡេងពីរោះ ។

បណ្ដាព្រហ្មដែលកើតក្នុង **បឋមជ្ឈានភូមិ** នេះ មាន**មហាព្រហ្ម**ជាធំ អាចបញ្ចេញរស្មីទៅបានឆ្ងាយ ព្រហ្មខ្លះបញ្ចេញទៅបានដល់ ១.០០០ ចក្រវាល ព្រហ្មខ្លះបញ្ចេញបានដល់ ២.០០០ ចក្រវាល ខ្លះទៀតបានដល់ ៣.០០០ ចក្រវាល ព្រោះកើតឡើងដោយ **វិបាកនៃឈានដែលប្រណីត** មានអាយុ ១ កប្ប ។ ប្រសិនបើកើតដោយ **វិបាកឈានថ្នាក់កណ្ដាល** ក៏មានឈ្មោះថា **ព្រហ្មបុរោហិតា**( ព្រហ្មជាអ្នកទីប្រឹក្សា ) មានអាយុកន្លះកប្ប ។

ប៉ុន្តែបើកើតដោយ **វិបាកឈានថ្នាក់ខ្សោយ** ក៏មានឈ្មោះថា **ព្រហ្មបារិសជ្ជា**( ព្រហ្មអ្នកជាបរិវាររបស់ព្រហ្ម ) មានអាយុ ១ ភាគ ៣ នៃកប្ប ។ ព្រហ្មទាំង ៣ ពួកនេះមានកាយផ្សេងគ្នា ( នានត្តកាយា ឯកត្តសញ្ញិនោ ) ដូចនឹងសត្វក្នុងអបាយភូមិ ។

ព្រហ្មដែលកើតក្នុង **ទុតិយជ្ឈានភូមិ** មានអាភស្សរាព្រហ្មជាធំ កើតដោយ **វិបាកនៃទុតិយជ្ឈាន** ឬ **តតិយជ្ឈានដែលប្រណីត** មានរស្មីចេញពីសរីរៈដូចអណ្ដាតភ្លើង មានអាយុ ៨ កប្ប។ **វិបាកថ្នាក់កណ្ដាល** តែងកើតជាព្រហ្ម ឈ្មោះ **អប្បមាណាភាព្រហ្ម** មានអាយុ ៤ កប្ប(មានតំណែងប៉ុននឹងបុរោហិតាព្រហ្ម) ។ **វិបាកថ្នាក់ខ្សោយ** តែងកើតជាព្រហ្មឈ្មោះ **បរិត្តាភាព្រហ្ម** មានអាយុ ២ កប្ប (មានតំណែងប៉ុននឹងបារិសជ្ជាព្រហ្ម) ។ ព្រហ្មទាំង ៣ ពួក នេះ មានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ព្រោះសញ្ញាខ្លះមិនមាន វិតក្កៈ តែមានវិចារៈ សញ្ញាខ្លះមិនមានទាំងវិតក្កៈ ទាំងវិចារៈ ។

ព្រហ្មដែលកើតក្នុងតតិយជ្ឈានភូមិ មានព្រហ្មឈ្មោះ **សុភ-កិណ្ហាព្រហ្មជាធំ** កើតឡើងដោយ **វិបាកនៃចតុត្ថជ្ឈានដែល**

**ប្រណីត** មានរស្មីថ្លាស្អាត ដូចរស្មីដួងព្រះចន្ទ គឺ មានរស្មីចេញពីសរីរៈជាផ្ទាំងៗ ស្អាតព្រោងព្រាត មានអាយុ ៦៤ កប្ប ។ **វិបាកថ្នាក់កណ្តាល** តែងកើតជាព្រហ្មឈ្មោះ **អប្បមាណសុភាព្រហ្ម** មានអាយុ ៣២ កប្ប ( មានតំណែងប៉ុននឹងបុរោហិតាព្រហ្ម ) ។ **វិបាកថ្នាក់ខ្សោយ** តែងកើតជាព្រហ្មឈ្មោះ **បរិត្តសុភាព្រហ្ម** មានអាយុ ១៦ កប្ប ( មាន តំណែងប៉ុននឹងបារិសជ្ជាព្រហ្ម ) ។ ព្រហ្មទាំង ៣ ពួកនេះ មាន កាយខ្នាតតែមួយ មានសញ្ញាបដិសន្ធិតែមួយដូចគ្នា ។

ព្រហ្មដែលកើតក្នុងចតុត្ថជ្ឈានភូមិ មានឈ្មោះថា **វេហប្ផលាព្រហ្ម** កើតឡើងដោយ **វិបាកនៃបញ្ចមជ្ឈាន** ដែលមានឯកគ្គតានិងឧបេក្ខាជាអង្គ ជាឈានមាំមួន មានផលសំបូរ មិនញាប់ញ័រ តែងប្រព្រឹត្តទៅតាមឈាន មិនដូចបឋមជ្ឈានភូមិ ៣ ទុតិយជ្ឈានភូមិ ៣ និង តតិយជ្ឈានភូមិ ៣ ដែលប្រកបដោយសោមនស្សទេ ។ ព្រហ្មជាន់នេះ នឹងមិនត្រូវវិនាស ដោយភ្លើង ដោយទឹក និងដោយខ្យល់ឡើយ តែងមានអាយុពេញ ៥០០ កប្ប ។

ព្រហ្មដែលតាំងនៅក្នុងភូមិទាំង ៤ តាមដែលបានពោលមកហើយនេះ ជាវគ្គ: ។

ចំណែក **សុទ្ធាវាសភូមិ ៥** ដែលកើតក្នុងចតុត្ថជ្ឈានភូមិដែរ គឺ **អវិហា អតប្បា សុទស្សា សុទស្សី និង អកនិដ្ឋា ភូមិនេះ តាំងនៅក្នុងចំណែកវិវដ្តៈ** ជាភូមិរស់នៅរបស់ព្រះអនាគាមី តាំងនៅជាជាន់ៗ ឡើងទៅតាមលំដាប់នៃភូមិ មិន ដូចភូមិដទៃៗ មានបឋមជ្ឈានភូមិជាដើមនោះទេ ។

**អវិហា** ប្រែថា មិនវិនាសចាកសម្បត្តិ ។

**អតប្បា** ប្រែថា មិនក្តៅក្រហាយ ( មានសេចក្តីស្ងប់ត្រជាក់ ) ។

**សុទស្សា** ប្រែថា ឃើញវត្ថុផ្សេង ៗ បានល្អ ( ព្រោះសំបូរដោយចក្ខុប្បសាទ ទិព្វចក្ខុ ធម្មចក្ខុ បញ្ញាចក្ខុ ) ។

**សុទស្សី** ប្រែថា ឃើញវត្ថុផ្សេង ៗ បានល្អក្រៃលែងជាងសុទស្សាភូមិ ។

**អកនិដ្ឋា** ប្រែថា សុខមិនមែនតិចតួចទេ( សំបូរសេចក្តីសុខ) ជាព្រហ្មដែលមានគុណសម្បត្តិក្រៃលែងជាងព្រហ្មជាន់ទី ១-២-៣-៤ នៃសុទ្ធាវាសភូមិ ។

សុទ្ធាវាសភូមិ ៥ នេះមិនមានរហូតគ្រប់កាលរាល់ៗ ពេលទេ , គឺ មិនកើតឡើងក្នុងលោក ក្នុងពេលដែលលង្វែកចាកព្រះពុទ្ធជាម្ចាស់រហូតដល់ ១ សែនកប្បខ្លះ ដល់ ១ អសង្ខេយ្យកប្បខ្លះ ។

កាលណាព្រះពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិហើយ នោះឯង សុទ្ធាវាស ៥ នេះ ទើបកើតឡើងក្នុងដែន កំណត់វេលា ១៦.០០០ កប្ប ។

# ចំណែករូបាវចរវិបាកចិត្ត ៥ ដោយន័យផ្សេងៗ

| | |
|---|---|
| **១.ដោយជាតិ** | ជាវិបាកជាតិ ។ |
| **២.ដោយភូមិ** | ជារូបភូមិ ។ |
| **៣.ដោយវេទនា** | ដូចគ្នានឹងកុសលឈាន គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ជាសោមនស្ស , បញ្ចមជ្ឈាន ជាឧបេក្ខា ។ |
| **៤.ដោយហេតុ** | ជានហេតុ និងជាតិហេតុកចិត្ត ។ |
| **៥.ដោយសម្បយុត្ត** | ជាញាណសម្បយុត្ត ។ |

| | |
|---|---|
| ៦.ដោយសង្ខារ | ជាសសង្ខារិក ។ |
| ៧.ដោយសោភណៈ | ជារូបាវចរសោភណចិត្ត ។ |
| ៨.ដោយឈាន | ជាផលនៃឈាន ។ |
| ៩.ដោយលោកិយៈ | ជាលោកិយចិត្ត ។ |
| ១០.ដោយកិច្ច | មាន ៣ គឺ បដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ ។ |
| ១១.ដោយអារម្មណ៍ | កុសលចិត្ត មានអារម្មណ៍ណា ជាកម្មដ្ឋាន វិបាកចិត្ត ក៏មានអារម្មណ៍នោះដែរ ។ |
| ១២.ដោយទ្វារ | ដឹងអារម្មណ៍បាន ដោយមិនអាស្រ័យទ្វារ ។ |
| ១៣.ដោយវត្ថុ | កើតដោយអាស្រ័យហទយវត្ថុ ។ |
| ១៤.ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ ។ |

( ចប់ រូបាវចរវិបាកចិត្ត ៥ ដួង )

# រូបាវចរកិរិយាចិត្ត ៥ ដួង

បាលីរូបាវចរវិបាកក្តី រូបាវចរកិរិយាក្តី ដូចគ្នានឹងរូបាវចរ-កុសល ផ្សេងគ្នាត្រង់ដែលរូបាវចរកិរិយាចិត្ត ជាចិត្តរបស់ព្រះអរហន្ត ប៉ុណ្ណោះ ។

- **បឋមជ្ឈានកិរិយាចិត្ត** កើតព្រមនឹង វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា ។

-**ទុតិយជ្ឈានកិរិយាចិត្ត** កើតព្រមនឹង វិចារៈ បីតិ សុខ ឯកគ្គតា ។

-**តតិយជ្ឈានកិរិយាចិត្ត** កើតព្រមនឹង បីតិ សុខ ឯកគ្គតា ។

-**ចតុត្ថជ្ឈានកិរិយាចិត្ត** កើតព្រមនឹង សុខ ឯកគ្គតា ។

-**បញ្ចមជ្ឈានកិរិយាចិត្ត** កើតព្រមនឹង ឧបេក្ខា ឯកគ្គតា ។

( ចប់ រូបាវចរកិរិយា ៥ ដួង )

# តារាង
# រូបាវចរចិត្ត ១៥ ដួង

| | រូបាវចរកុសល ៥ | រូបាវចរវិបាក ៥ | រូបាវចរកិរិយា ៥ |
|---|---|---|---|
| បឋមជ្ឈាន | វិតក្កៈ_វិចារៈ_បីតិ សុខ_ឯកគ្គតា | វិតក្កៈ_វិចារៈ_បីតិ សុខ_ឯកគ្គតា | វិតក្កៈ_វិចារៈ_បីតិ សុខ_ឯកគ្គតា |
| ទុតិយជ្ឈាន | វិចារៈ_បីតិ_សុខ ឯកគ្គតា | វិចារៈ_បីតិ_សុខ ឯកគ្គតា | វិចារៈ_បីតិ_សុខ ឯកគ្គតា |
| តតិយជ្ឈាន | បីតិ_សុខ_ឯកគ្គតា | បីតិ_សុខ_ឯកគ្គតា | បីតិ_សុខ_ឯកគ្គតា |
| ចតុត្ថជ្ឈាន | សុខ_ឯកគ្គតា | សុខ_ឯកគ្គតា | សុខ_ឯកគ្គតា |
| បញ្ចមជ្ឈាន | ឧបេក្ខា_ឯកគ្គតា | ឧបេក្ខា_ឯកគ្គតា | ឧបេក្ខា_ឯកគ្គតា |

**រូបាវចរកិរិយាចិត្ត** ជារូបជ្ឈានចិត្តរបស់ព្រះខីណាស្រព គឺរូបាវចរឈានរបស់ព្រះខីណាស្រព ជាកិរិយា មិនមែនជាកុសល មិនមែនជាអកុសល មិនមែនជាវិបាកកម្ម ជា **ទិដ្ឋធម្មសុខវិហារធម៌** ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ននេះ ។

ក្នុងសមាបត្តិទាំងនោះ សមាបត្តិដែលព្រះខីណាស្រពឲ្យកើតឡើង ក្នុងពេលដែលលោកនៅជាបុថុជ្ជន កាលណាលោកបានសម្រេចព្រះអរហន្ត និងចូលសមាបត្តិនោះហើយ សមាបត្តិនោះ ក៏ជាកិរិយាចិត្ត ។

# ចំណែករូបាវចរកិរិយាចិត្ត ៥ ដួង ដោយន័យផ្សេងៗ

**១. ដោយជាតិ** ជាកិរិយាជាតិ ។

**២. ដោយភូមិ** ជារូបភូមិ កើតបាន ២២ ភូមិ ។

**៣. ដោយវេទនា** ជាសោមនស្ស ៤ ឧបេក្ខា ១ ។

**៤. ដោយហេតុ** ជានហេតុ និងជាតិហេតុកចិត្ត ។

**៥. ដោយសម្បយុត្ត** ជាញាណសម្បយុត្ត ។

| | | |
|---|---|---|
| **៦. ដោយសង្ខារ** | ជាសសង្ខារិក | ។ |
| **៧. ដោយសោភណៈ** | ជារូបាវចរសោភណចិត្ត | ។ |
| **៨. ដោយឈាន** | ជារូបាវចរកិរិយាចិត្ត | ។ |
| **៩. ដោយលោកិយៈ** | ជាលោកិយចិត្ត ព្រោះមិនមាននិព្វានជាអារម្មណ៍ ។ | |
| **១០. ដោយកិច្ច** | ធ្វើជវនៈកិច្ច ។ | |
| **១១. ដោយអារម្មណ៍** | មានធម្មារម្មណ៍ ជាអារម្មណ៍ | ។ |
| **១២. ដោយទ្វារ** | ដឹងអារម្មណ៍បានតាមមនោទ្វារ | ។ |
| **១៣. ដោយវត្ថុ** | កើតដោយអាស្រ័យហទយវត្ថុ | ។ |
| **១៤. ដោយវិញ្ញាណធាតុ** | ជាមនោវិញ្ញាណធាតុ | ។ |

( ចប់ រូបាវចរកិរិយាចិត្ត ៥ ដួង )

រូបាវចរចិត្ត ដោយប្រភេទនៃឈាន ចែកដោយ កុសលចិត្ត វិបាកចិត្ត និងកិរិយាចិត្ត ទើបរូបាវចរចិត្ត មាន ១៥ ដួង ៕

( រូបាវចរសោភណចិត្ត ១៥ ដួង ចប់ )

| ឈាន | កុសល | វិបាក | កិរិយា | រួម |
|---|---|---|---|---|
| បឋមជ្ឈាន | ១ | ១ | ១ | ៣ |
| ទុតិយជ្ឈាន | ១ | ១ | ១ | ៣ |
| តតិយជ្ឈាន | ១ | ១ | ១ | ៣ |
| ចតុត្ថជ្ឈាន | ១ | ១ | ១ | ៣ |
| បញ្ចមជ្ឈាន | ១ | ១ | ១ | ៣ |
| រួម | ៥ | ៥ | ៥ | ១៥ |

# ៣.អរូបាវចរសោភណចិត្ត ១២ ដួង

## អរូបាវចរកុសលចិត្ត ៤ ដួង

ពាក្យថា **អរូបាវចរចិត្ត** នោះ គឺជាចិត្តដែលប្រព្រឹត្តទៅក្នុងអារម្មណ៍នៃអរូបជ្ឈាន ។

ពាក្យថា **អរូបជ្ឈាន** សំដៅដល់ឈានដែលមិនសម្លឹងនូវរូប ឬ ឈានដែលមិនមានរូបជាអារម្មណ៍ បានដល់អារម្មណ៍ ៤ គឺ អាកាស ១ វិញ្ញាណ ១ សេចក្ដីមិនមានអ្វី ១ សញ្ញា ១ ។

ពាក្យថា **អរូបាវចរកុសល** មានន័យថា កុសលកម្មដែលជា

ហេតុបញ្ជូនផលឲ្យទៅកើតជាអរូបព្រហ្ម ។

ម្យ៉ាងទៀតព្រោះថា កុសលចិត្តនេះ កើតឡើងដោយអាស្រ័យអារម្មណ៍ដែលជាអរូប ។

# បាលីអរូបាវចរកុសលចិត្ត ៤ ដួង

## ១.អាកាសានញ្ចាយតនកុសលចិត្តំ ។

## ២.វិញ្ញាណញ្ចាយតនកុសលចិត្តំ ។

## ៣.អាកិញ្ចញ្ញាយតនកុសលចិត្តំ ។

## ៤.នេវសញ្ញានាសញ្ញាយតនកុសលចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរកុសលចិត្តានិ នាម ។

ប្រែថា - អាកាសានញ្ចាយតនកុសលចិត្ត ១ ។
- វិញ្ញាណញ្ចាយតនកុសលចិត្ត ១ ។
- អាកិញ្ចញ្ញាយតនកុសលចិត្ត ១ ។
- នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១ ។

ចិត្ត ៤ នេះ ឈ្មោះថា **អរូបាវចរកុសលចិត្ត** ។

# អធិប្បាយ អាកាសានញ្ចាយតនចិត្ត

**អាកាសានញ្ចាយតនៈ** គឺ **អាកាស+អានញ្ច+អាយតន** មានន័យថា អាយតនៈ(ជាទីកើត) មួយដែលអាកាសមិនមានទីបំផុត គឺថា អាកាសានញ្ចៈ នោះឯងជាអាយតនៈ (គឺ ជាទីកើត) នៃឈាននោះ ព្រមដោយសម្បយុត្តធម៌ ដោយអត្ថថា ជាទីតាំងនៅ ដូចទេវាយតនៈ ទីអាស្រ័យនៅនៃពួកទេវតា ។

**ឈាន** ឈ្មោះថា **អាកាសានញ្ចាយតនៈ** ព្រោះអត្ថថា មានអាកាសមិនមានទីបំផុត ជាទីកើតកុសលចិត្តដែលសម្បយុត្តជាមួយអាកាសានញ្ចាយតនៈនោះ ឈ្មោះថា **អាកាសានញ្ចាយតន-កុសលចិត្ត** ។

**អាកាសានញ្ចៈ** គឺ **អាកាសានន្តៈ អាកាសានន្តៈ** បានដល់ អាកាសបើក ដកចេញពីកសិណ ។

**អាកាស** មាន ៤ ប្រការ គឺ អជដាកាស ១ បរិច្ឆិន្នាកាស ១ កសិណុគ្ឃាដិមាកាស ១ និង បរិច្ឆេទាកាស ១ ។

**អជដាកាស** បានដល់ អាកាស មេឃ ។

**បរិច្ឆិន្នាកាស** បានដល់ អាកាសកសិណ ។

| | |
|---|---|
| **កសិណុគ្ឃាដិមាកាស** | បានដល់ អាកាសដែលបាន មកពីបើកកសិណ ៩ ( វៀរ អាកាសកសិណ ) ។ |
| **បរិច្ឆេទាកាស** | បានដល់ អាកាសរូប ។ |
| **អាកាសានញ្ចាយតនៈ** | បានដល់ កសិណុគ្ឃាដិមាកាស ប៉ុណ្ណោះ មិនបានសំដៅដល់ អាកាសនៃអាកាសកសិណទេ ។ |

# វិធីចំរើន
# អាកាសានញ្ចាយតនឈាន(ទី១)

ព្រះយោគាវចរដែលនឹងចំរើនអរូបជ្ឈានកម្មដ្ឋាន ឲ្យកន្លងនូវរូបជ្ឈាននោះ ដំបូងត្រូវបានរូបាវចរបញ្ចមជ្ឈាម ព្រមទាំងវសី ៥ មានការស្ទាត់ជំនាញល្អសិនហើយ ទើបឃើញទោសរបស់រូបជ្ឈានផ្សេងៗដោយប្រការទាំងពួង ។ លោកមិនមែនត្រឹមតែឃើញទោសនៃរូបជ្ឈានប៉ុណ្ណោះទេ រមែងឃើញដល់ទោសនៃរូបរាងកាយផងដែរ ថា មានរូបហើយក៏ ត្រូវតែមានទុក្ខទោស លំបាកកាយ មានការទទួលនូវអាជ្ញា និង រោគាព្យាធិផ្សេងៗជាដើម តែប្រសិនបើមិនមាន

រូបរាងកាយទេនោះ ទោសផ្សេងៗ រោគផ្សេងៗ តាមផ្លូវកាយ ក៏នឹងមិនមាន ឯការដែលនឹងផុតចាករូបរាងកាយទៅបាន ក៏ត្រូវអាស្រ័យការចំរើនឈានមិនមានរូប (អរូបជ្ឈាន) ជាអារម្មណ៍យ៉ាងនេះ ។

កាលព្រះយោគាវចរឃើញទោសនៃរូប និង វិធីដែលនឹងផុតចាកពីរូបយ៉ាងនេះហើយ ក៏ចូលរូបជ្ឈានទី ៥ ធ្វើឲ្យកើតឡើងសិន ។ កាលចេញពីឈាន ពិចារណាឃើញទោសនៃរូបកម្មដ្ឋាន ដែលជាអារម្មណ៍ហើយ ក៏ចូលឈាននោះ ផ្សាយពង្រីកនិមិត្ត(រូបកម្មដ្ឋាន) នោះ ឲ្យមិនមានទីបំផុត គឺ ផ្សាយចេញទៅបានដល់ ១ ចក្រវាល ។ ដោយការផ្សាយពង្រីកទៅៗ នូវនិមិត្តនៃរូបកម្មដ្ឋានដែលជាអារម្មណ៍ច្រើនដល់ត្រឹមណាៗ ក៏មិនមានទីបំផុត ក៏កាន់តែឃើញថា ត្រង់ការដែលផ្សាយពង្រីកនិមិត្តចេញទៅបាននោះ ក៏ព្រោះអាកាសមិនមានទីបំផុត អាកាសដែលល្ហល្ហេវនោះ មិនមានការកើត មិនមានការវិនាស រកទីបំផុតគ្មាន ។ កាលឃើញ អាកាសមិនមានទីបំផុត ទើបបើកសញ្ញា គឺ មិនដាក់ចិត្តទៅក្នុងរូបនិមិត្តដែលជាអារម្មណ៍នោះ ហើយយកចិត្ត ទុកដាក់ក្នុងសភាពនៃ **អាកាសមិនមានទីបំផុត** (អាកាសោ អនន្តោ) ។ ក្នុងខណៈ ចិត្តគិតដល់នូវអាកាសមិនមានទីបំផុតនេះ ពេលនោះ នៅមានរូបនិមិត្តដែលពង្រីកផ្សាយទៅ ដែរ ទាំងឧបចារសមាធិ ក៏កើតឡើងជាលំដាប់ ។ កាលដាក់ចិត្តដល់អាកាសមិនមានទីបំផុតនោះរឿយៗទៅ ទីបំផុតអប្បនាសមាធិ ក៏កើត

ឡើងដោយមានអាកាស ដែលមិនមានទីបំផុតនោះ ជាអារម្មណ៍ ។ អាកាសដែលមិនមានទីបំផុតនេះ ជាទីតាំងឲ្យកើត **បឋមអរូបជ្ឈាន ទី ១** ហៅថា **អាកាសានញ្ចាយតនកុសលចិត្ត** ជាកសិណុគ្ឃាដិមាកាសប្បញ្ញត្តិ ដែលបានបើកចេញពីរូបកសិណជាអារម្មណ៍ ។

កាលអប្បនាវិថី ដែលជា **អាទិកម្មិកអរូបជ្ឈានរបស់មន្ទបុគ្គល** ( អ្នកដឹងយឺត ) នឹងកើតនោះ វិថីរមែងកើតតាមលំដាប់យ៉ាងនេះ គឺ :

១. ភវង្គចលនៈ
២. ភវង្គុបច្ឆេទៈ } ចិត្តផុតវិថី

៣. មនោទ្វារាវជ្ជនៈ

៤. បរិកម្ម
៥. ឧបចារៈ
៦. អនុលោម
៧. គោត្រភូ } មហាកុសលឧបេក្ខា ញាណសម្បយុត្ត ២ ដួង

៨. បឋមអរូបជ្ឈាន អាកាសានញ្ចាយតនកុសល ១

ភវង្គបាតៈ ចិត្តជាភវង្គ

# អាទិកម្មិកអរូបជ្ឈានវិថីរបស់តិក្ខបុគ្គល

| | | |
|---|---|---|
| ១. | ភវង្គចលនៈ | ចិត្តផុតវិថី |
| ២. | ភវង្គុបច្ឆេទៈ | |
| ៣. | មនោទ្វារាវជ្ជនៈ | |
| ៤. | ឧបចារៈ | មហាកុសលឧបេក្ខា ញាណសម្បយុត្ត ២ ដួង |
| ៥. | អនុលោម | |
| ៦. | គោត្រភូ | |
| ៧. | បឋមអរូបជ្ឈាន អាកាសានញ្ចាយតនកុសល ១ | |
| | ភវង្គបាតៈ | ចិត្តជាភវង្គ |

# អធិប្បាយ អប្បនាវិថី

**ទី ១** ភវង្គចលនៈ **ទី ២** ភវង្គុបច្ឆេទៈ ចិត្ត ២ ដួងនេះ ជា ចិត្តផុតវិថី បានដល់ វិបាកចិត្តដែលសម្បយុត្តដោយបញ្ញា ជាតិហេតុកវិបាកចិត្ត មានអារម្មណ៍ដើម គឺ អារម្មណ៍នៃចុតិពីជាតិមុន ។

**ទី ៣** មនោទ្វារាវជ្ជនៈ ជាអហេតុកកិរិយាចិត្ត ។

**ទី ៤** បរិកម្ម **៥.** ឧបចារៈ **៦.** អនុលោម **៧.** គោត្រភូ បានដល់ មហាកុសលឧបេក្ខាញាណសម្បយុត្ត ២ ដួង ណាមួយ ។

**ទី ៨** បឋមអរូបជ្ឈាន បានដល់ អាកាសានញ្ចាយតន-កុសលចិត្ត ឈាននេះ មានអាកាសបញ្ញត្តិ ដែលបើកពីកសិណនៃរូបាវចរបញ្ចមជ្ឈាន ជាអារម្មណ៍ ហៅថា កសិណុគ្ឃាដិមាកាស-បញ្ញត្តិ ។

# វិញ្ញាណញ្ចាយតនចិត្ត

វិញ្ញាណញ្ចាយតនៈ គឺ **វិញ្ញាណ + អានញ្ច + អាយតនៈ** មានន័យថា ជាអាយតនៈមួយកន្លែង ដែលវិញ្ញាណមិនមានទីបំផុត វិញ្ញាណនោះឯង រកទីបំផុតមិនបាន ទើបឈ្មោះថា **វិញ្ញាណញ្ចៈ** បានដល់ អរូបវិញ្ញាណទី ១ ។ ម្យ៉ាងទៀតឈ្មោះថា **វិញ្ញាណញ្ចៈ** ព្រោះអត្ថថា ដែលត្រូវអរូបវិញ្ញាណទី ២ គប្បីដល់ គឺ គប្បីសម្រេច ។ ដូច្នេះ វិញ្ញាណញ្ចាយតនៈ ព្រោះអត្ថថា **វិញ្ញាណញ្ចៈ** នោះ ជាអាយតនៈ ព្រោះជាទីតាំងនៃ **អរូបជ្ឈានទី ២** គឺ **វិញ្ញាណ-ញ្ចាយតនឈាន** ។

# វិញ្ញាណញ្ចាយតនឈាន(ទី២)

យោគាវចរបុគ្គល កាលជំនាញក្នុងអាកាសានញ្ចាយតនៈហើយ បំណងនឹងចំរើននូវអរូបជ្ឈានទី ២ ត្រូវធ្វើវសី ៥ ឲ្យស្ទាត់ ហើយពិចារណាឃើញទោសរបស់អាកាសានញ្ចាយតនឈាន ឃើញសេចក្តីស្ងប់ប្រណីត របស់វិញ្ញាណញ្ចាយតនឈាន ហើយក៏ចូលឈានទាញយកបឋមអរូបជ្ឈានជាអារម្មណ៍ ដោយបង្អោនដល់សភាពរបស់វិញ្ញាណដែលមានអាកាសមិនមានទីបំផុត មកជាអារម្មណ៍ ថា **វិញ្ញាណមិនមានទីបំផុត(វិញ្ញាណំ អនន្តំ)** រហូតដល់ឈានចិត្តនឹងកើតអរូបជ្ឈានទី ២ ដែលកើតឡើង មានអាកាសានញ្ចាយតនចិត្តជាអារម្មណ៍ នេះឯងឈ្មោះថា **វិញ្ញាណញ្ចាយតនឈាន** ឬ ហៅថា **ទុតិយអរូបជ្ឈានចិត្ត** ។

# អប្បនាវិថីនៃទុតិយអរូបជ្ឈាន

**១.** ភវង្គចលនៈ
**២.** ភវង្គុបច្ឆេទៈ
} ចិត្តផុតវិថី

៣. មនោទ្វារាវជ្ជនៈ

| | |
|---|---|
| ៤. បរិកម្ម | មហាកុសលឧបេក្ខា ញាណសម្បយុត្ត ២ ដួង |
| ៥. ឧបចារៈ | |
| ៦. អនុលោម | |
| ៧. គោត្រភូ | |

៨. ទុតិយអរូបជ្ឈាន វិញ្ញាណញ្ចាយតនកុសល ១

ភវង្គបាតៈ ចិត្តជាភវង្គ

# អាកិញ្ចញ្ញាយតនឈាន(ទី៣)

**អាកិញ្ចញ្ញាយតនៈ** គឺ **ន** + **អាកិញ្ចន** + **អាយតន** មានន័យថា អាយតនៈមួយកន្លែងដែលវិញ្ញាណ សូម្បីបន្តិចបន្តួច ក៏រមែងមិនមាន។

ព្រះយោគាវចរ កាលបំណងនឹងធ្វើសមាធិចិត្ត ឲ្យតាំងមាំប្រណីតឡើងៗ ដោយការចូលអាកិញ្ចញ្ញាយតនឈាននោះ ត្រូវចូលវិញ្ញាណញ្ចាយតនឈាន រហូតដល់ជំនាញក្នុងវសីទាំង ៥ ។ កាលចេញពីឈាននេះហើយ ក៏ពិចារណាឃើញទោសនៃវិញ្ញាណញ្ចាយ-តនឈាន ថា បើដាច់ការចូលឈាននេះជានិច្ចហើយ ឈាននេះ

អាចវិនាស ត្រឡប់ទៅតាំងនៅក្នុងអាកាសានញ្ចាយតនឈានវិញ ឯសមាធិដែលកើតពីវិញ្ញាណញ្ចាយតនឈាន ក៏នៅគ្រោតគ្រាត មិនប្រណីតស្មើនឹងអាកិញ្ចញ្ញាយតនឈានដែរ ទើបដាក់ចិត្តដល់សភាពនៃសេចក្តីមិនមានអ្វីរបស់អរូបជ្ឈានទី ១ ជាអារម្មណ៍ ប្រៀបដូចសាលាធំ ជាទីប្រជុំព្រះសង្ឃធ្វើសង្ឃកម្ម ដែលជាអារម្មណ៍របស់អរូបជ្ឈានទី ២ នោះ ឥឡូវនេះសង្ឃធ្វើកិច្ចស្រេចហើយ ក៏ចេញពីសាលាទាំងអស់មិនមានសល់ ចិត្តក៏បង្អោនទៅក្នុង សភាពដែលមិនមានអ្វីទៀតឡើយ **នត្ថិ កិញ្ចិ**( អ្វីតិចតួចមិនមាន ) រហូតដល់អរូបជ្ឈានចិត្តកើត ដោយមាននត្ថិភាវបញ្ញត្តិជាអារម្មណ៍ ។ អរូប-ជ្ឈានចិត្តនេះ ឈ្មោះថា **អាកិញ្ចញ្ញាយតនឈាន** ឬ **តតិយ-អរូបជ្ឈាន** ( អាកិញ្ចញ្ញាយតនកុសលចិត្ត ) ។

វិថីចិត្តដែលកើតមុនអរូបជ្ឈានទី ៣ នេះ ដូចគ្នានឹងបឋម-អរូបជ្ឈាន ឬ ទុតិយអរូបជ្ឈានវិថីដែរ ផ្សេងគ្នាតែត្រង់ពាក្យអាកិញ្ច-ញ្ញាយតនកុសលចិត្តប៉ុណ្ណោះ ។

# នេវសញ្ញានាសញ្ញាយតនឈាន(ទី៤)

**នេវសញ្ញានាសញ្ញាយតនៈ** គឺ **នេវ + សញ្ញា + ន +**

**ន + សញ្ញា + អាយតន** មានន័យថា ជាអាយតនៈមួយកន្លែង ដែលតែង មានសញ្ញា ក៏មិនមែន មិនមានសញ្ញាក៏មិនមែន ព្រោះមិន មានសញ្ញាគ្រោតគ្រាត មានតែសញ្ញាល្អិត ។ **នេវសញ្ញានាសញ្ញា** នោះឯង ជាអាយតនៈ ព្រោះសង្គ្រោះចូលក្នុង មនាយតនៈ និង ធម្មាយតនៈ ព្រោះហេតុនេះ ទើបឈ្មោះថា **នេវសញ្ញានា-សញ្ញាយតនៈ** ។ នេវសញ្ញានាសញ្ញានោះឯង ជាអាយតនៈ ជាទី តាំងនៃឈាន ព្រមទាំងសម្បយុត្តធម៌ដោយនិស្ស័យប្បច្ច័យជាដើម ដូច្នេះហើយ ទើបឈ្មោះថា **នេវសញ្ញានាសញ្ញាយតនឈាន** ។

ព្រះយោគាវចរចំរើនអរូបជ្ឈានទី ៤ នោះ ត្រូវជំនាញក្នុង អរូបជ្ឈានទី ៣ ព្រមទាំងវសី ៥ រួចហើយចំរើនអរូបជ្ឈានទី ៤ ដែលជាឈានប្រណីតបំផុត ដោយពិចារណា ឃើញនូវអរូបជ្ឈានទី ៣ នេះ ថា ជាធម៌ស្ងប់ប្រណីត ប៉ុន្តែមិនទាន់ស្ងប់ប្រណីតបំផុតទេ ។ ដូច្នេះដើម្បីចំរើនអរូបជ្ឈានទី ៤ ទើបត្រូវចូលអរូបជ្ឈានទី ៣ ចេញហើយ យកចិត្តទុកដាក់ ពិចារណាសេចក្តីស្ងប់ សេចក្តីប្រណីត **ឯតំ យន្តំ ឯតំ បណីតំ** នៃសញ្ញាក្នុងអាកិញ្ចញ្ញាយតនឈាន មិនមែនសញ្ញា ដទៃទៀតទេ ( វេទនាជាដើមក្នុងទីនេះក៏ស្ងប់ប្រណីត ដូចគ្នា ការដែលប្រើ សញ្ញាស័ព្ទ ព្រោះសញ្ញាចេតសិកនេះ ជាតួ ចាំនិមិត្ត តាំងអំពីការចំរើនរូបជ្ឈានដំបូង ) ចំរើនទៅរហូតដល់

អរូបជ្ឈានទី ៤ កើតឡើង ។ កាលណាឈាននេះកើត ក៏មានឈ្មោះថា **នេវសញ្ញានាសញ្ញាយតនឈាន** ឬ **ចតុត្ថារូបជ្ឈាន** គឺ **នេវសញ្ញានាសញ្ញាយតនកុសលចិត្ត** ។ វិថីចិត្តដែលកើតមុន អរូបជ្ឈាន ទី ៤ ដូចន័យដែលបានពោលរួចមកហើយ ៕

# អរូបាវចរវិបាកចិត្ត ៤ ដួង

អរូបាវចរវិបាកចិត្ត ជាផលរបស់អរូបាវចរកុសលចិត្ត គឺ អាកាសានញ្ចាយតនកុសល មានអាកាសមិនមានទីបំផុត ជាអារម្មណ៍ អាកាសានញ្ចាយតនវិបាកចិត្ត ក៏មានអាកាសមិនមានទីបំផុត ជាអារម្មណ៍ដូចគ្នាដែរ ឯអរូបជ្ឈានទី ២ ទី ៣ ទី ៤ ក៏មានន័យយ៉ាងនេះដែរ ។

# បាលីអរូបាវចរវិបាកចិត្ត ៤ ដួង

- អាកាសានញ្ចាយតនវិបាកចិត្តំ
- វិញ្ញាណញ្ចាយតនវិបាកចិត្តំ
- អាកិញ្ចញ្ញាយតនវិបាកចិត្តំ

**- នេវសញ្ញានាសញ្ញាយតនវិបាកចិត្តញ្ចេតិ ឥមានិ ចិត្តានិ អរូបាវចរវិបាកចិត្តានិ នាម ។**

ប្រែថា :

**- អាកាសានញ្ចាយតនវិបាកចិត្ត ១**
**- វិញ្ញាណញ្ចាយតនវិបាកចិត្ត ១**
**- អាកិញ្ចញ្ញាយតនវិបាកចិត្ត ១**
**- នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ១**

ចិត្ត ៤ នេះឈ្មោះថា **អរូបាវចរវិបាកចិត្ត** ៕

ពេលដែល អរូបាវចរវិបាកចិត្តដួងណាមួយ នឹងកើតនោះ មិនបានកើតជាវិថីដូចអរូបាវចរកុសលចិត្តទេ គឺថា មុនចុតិចិត្តនឹងកើតឡើងនោះ អរូបាវចរកុសលដួងណាមួយ កើតឡើងមុន រួចទើបចុតិ ។ កាលចុតិចិត្តរលត់ហើយ អរូបាវចរវិបាកចិត្តដួងណាមួយ ក៏កើតឡើងធ្វើបដិសន្ធិ តអំពីចុតិចិត្តនោះ ទាន់ពេលភ្លាម ។ អរូបាវចរកុសលចិត្តមុនចុតិ ចិត្តមានអារម្មណ៍អ្វី អរូបាវចរវិបាកចិត្តដែលកើតបន្ទាប់ពីចុតិចិត្តមកនោះ ក៏មានអារម្មណ៍នោះ ដូចនឹងកុសលរបស់ខ្លួនដែរ មានន័យយ៉ាងនេះឯងទាំង ៤ ដួង ។

ដូច្នេះ អរូបាវចរកុសលមាននាទីធ្វើជវនកិច្ចតែម្យ៉ាង ចំណែក

អរូបាវចរវិបាកនោះ មានកិច្ច ៣ គឺ :

**១.បដិសន្ធិកិច្ច** ធ្វើកិច្ចទៅកើតជាអរូបព្រហ្ម ក្នុងអរូបភូមិ ៤ ប៉ុណ្ណោះ ។

**២.ភវង្គកិច្ច** ធ្វើកិច្ចបន្តរក្សាភពជាតិឲ្យតាំងនៅជរាបរហូត ស្មើអាយុនៃសង្ខារក្នុងភពនោះ ។

**៣.ចុតិកិច្ច** ធ្វើកិច្ចឃ្លាតចាកភពនោះៗ ក្នុងវារៈដែលអស់អាយុសង្ខារ ។

ហើយអរូបាវចរវិបាកចិត្ត ៤ ដួងនេះ ជាចិត្តកើតឡើងដោយមិនអាស្រ័យវត្ថុទាំង ៦ ណាមួយឡើយ និងមានចំពោះតែអរូប-ព្រហ្មបុគ្គលប៉ុណ្ណោះ ។

ក្នុងអរូបព្រហ្មភូមិទាំង ៤ នេះ ព្រហ្មបុគ្គលក្នុងអាកាសានញ្ចាយតនភូមិមានអាយុ **២** ម៉ឺនមហាកប្ប ព្រហ្មក្នុងវិញ្ញាណញ្ចាយតនភូមិមានអាយុ **៤** ម៉ឺនមហាកប្ប ព្រហ្មក្នុងអាកិញ្ចញ្ញាយតនភូមិមានអាយុ **៦** ម៉ឺនមហាកប្ប និង ក្នុងនេវសញ្ញានាសញ្ញាយតនភូមិមានអាយុ **៨** ម៉ឺន **៤** ពាន់មហាកប្ប ។

# អរូបាវចរកិរិយាចិត្ត ៤ ដួង

អរូបាវចរកិរិយាចិត្ត ៤ ដួងនេះ កើតមានដល់ព្រះអរហន្ត តែមួយពួកប៉ុណ្ណោះ បុថុជ្ជនក្តី ព្រះសេក្ខបុគ្គល ៧ ពួកក្តី ចំរើនអរូបជ្ឈាន ៤ អរូបជ្ឈានចិត្តនេះ តែងកើតជាកុសល មិនមែនជាអរូបាវចរកិរិយាចិត្តឡើយ ។

# បាលីអរូបាវចរកិរិយាចិត្ត

- អាកាសានញ្ចាយតនកិរិយាចិត្តំ
- វិញ្ញាណញ្ចាយតនកិរិយាចិត្តំ
- អាកិញ្ចញ្ញាយតនកិរិយាចិត្តំ
- នេវសញ្ញានាសញ្ញាយតនកិរិយាចិត្តញ្ចេតិ ឥមានិ ចិត្តានិបិ អរូបាវចរក្រិយាចិត្តានិ នាម ៕

ប្រែថា :

- អាកាសានញ្ចាយតនកិរិយាចិត្ត ១ ។
- វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១ ។

**- អាកិញ្ចញ្ញាយតនកិរិយាចិត្ត ១ ។**

**- នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១ ។**

ចិត្ត ៤ នេះឈ្មោះថា **អរូបាវចរកិរិយាចិត្ត** ។

អរូបាវចរកិរិយាចិត្ត ៤ ដួង នេះ មានអង្គឈានស្មើគ្នា និងដូចគ្នា គឺ ឧបេក្ខា និងឯកគ្គតា តែមានអារម្មណ៍ផ្សេងគ្នា ប្រព្រឹត្តតាមបែបដូចគ្នានឹងអរូបាវចរកុសលចិត្ត ។

កាលអរូបាវចរចិត្តរបស់ព្រះអរហន្តនឹងកើត វិថីចិត្តដែលកើតមុន ប្រព្រឹត្តទៅយ៉ាងនេះ គឺ :-

១. ភវង្គចលនៈ<br>
២. ភវង្គុបច្ឆេទៈ } ចិត្តផុតវិថី

៣. មនោទ្វារាវជ្ជនៈ

៤. បរិកម្ម<br>
៥. ឧបចារៈ<br>
៦. អនុលោម<br>
៧. គោត្រភូ } មហាកិរិយាឧបេក្ខាញាណសម្បយុត្ត ២ ដួង

៨. អរូបាវចរកិរិយាចិត្ត

ភវង្គបាតៈ ចិត្តជាភវង្គ ។

វិថីចិត្តនេះ សម្រាប់មន្ទបុគ្គល ចំណែកតិក្ខបុគ្គលមិនមានបរិកម្មទេ ។

# ចំណែកអរូបាវចរចិត្ត ១២ ដួង ដោយន័យផ្សេងៗ

១. ដោយជាតិ
ជាកុសលជាតិ ៤ ដួង ។
ជាវិបាកជាតិ ៤ ដួង ។
ជាកិរិយាជាតិ ៤ ដួង ។

២. ដោយភូមិ
ជាអរូបាវចរភូមិទាំង ១២ ដួង ។

៣. ដោយវេទនា
ជាឧបេក្ខាវេទនាទាំង ១២ ដួង ។

៤. ដោយហេតុ
ជានហេតុ និង ជាតិហេតុកចិត្ត ទាំង ១២ ដួង ។

៥. ដោយសម្បយុត្ត
ជាញាណសម្បយុត្តទាំង ១២ ដួង ។

៦. ដោយសង្ខារ
ជាសសង្ខារិកទាំង ១២ ដួង ។

៧. ដោយសោភណៈ
ជាអរូបាវចរសោភណចិត្តទាំង១២ដួង។

៨. ដោយឈាន
ជាបញ្ចមជ្ឈាន(បញ្ចកន័យ) ទាំង ១២ ដួង ។

៩. ដោយលោកិយ
ជាលោកិយចិត្តទាំង ១២ ដួង ។

**១០. ដោយកិច្ច** អរូបាវចរកុសល ៤ និងអរូបាវចរ-កិរិយា ៤ ធ្វើជវនកិច្ច , អរូបាវចរ-វិបាក ៤ ធ្វើកិច្ច ៣ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច ។

**១១. ដោយអារម្មណ៍** មានធម្មារម្មណ៍ ជាអារម្មណ៍ ទាំង ១២ ដួង ។

**១២. ដោយទ្វារ** អរូបាវចរកុសល ៤ និង អរូបាវចរ-កិរិយា ៤ ដឹងធម្មារម្មណ៍តាមមនោ-ទ្វារ ចំណែកអរូបាវចរវិបាក ៤ ដឹងអារម្មណ៍ដោយមិនអាស្រ័យទ្វារ (ទ្វារ-វិមុត្តិ ) ។

**១៣.ដោយវត្ថុ** អរូបាវចរកុសល ៤ និង អរូបាវចរ-កិរិយា ៤ កើតក្នុងបញ្ចវោការភូមិ អាស្រ័យហទយវត្ថុ បើកើតក្នុងចតុ-វោការភព មិនអាស្រ័យទេ ។

**១៤.ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុទាំង ១២ ដួង ។

- **ចំណាំ :** ក្នុងភូមិជាទីកើតរបស់សត្វ ៣១ ភូមិ នោះ

អរូបាវចរកុសលចិត្ត ៤ និងអរូបាវចរកិរិយាចិត្ត ៤ កើតបាន ២៦ ភូមិ ( វៀរអបាយភូមិ ៤ និង អសញ្ញសត្តាភូមិ ១ ) ចំណែក អរូបាវចរវិបាកចិត្ត ៤ កើតបានចំពោះតែក្នុងអរូបព្រហ្មភូមិ ៤ តែប៉ុណ្ណោះ ៕

## សង្គហគាថា

### អាលម្ពនប្បភេទេន តុធារុប្បមានសំ
### បុញ្ញាបាកក្រិយាភេទា បុន ទ្វាទសធាឋិតំ

ប្រែថា អរូបាវចរចិត្តនេះ ដោយប្រភេទនៃអារម្មណ៍ មាន ៤ ប្រការ បើដោយសេចក្ដីផ្សេងនៃកុសល វិបាក និងកិរិយា ទើបមាន ១២ ដួង ។

**ដីកាចារ្យអធិប្បាយថា** អរូបាវចរចិត្តមាន ៤ ដួង ដោយប្រភេទនៃអារម្មណ៍ ៤ មានអាកាសជាដើម ដែលគប្បីកន្លងនិងគប្បីទាញយក គឺ អាកាស វិញ្ញាណ និង សេចក្ដីមិនមាន នៃអារម្មណ៍ ទាំង ៣ នោះ ។

បានសេចក្ដីថា អរូបាវចរចិត្តនោះ តែងកន្លងនូវកសិណនិមិត្ត ដែលជាអារម្មណ៍នៃបញ្ចមជ្ឈាន រួចទាញយកអាកាសដែលបានដោយការបើកកសិណនិមិត្ត ( កសិណុគ្ឃាដិមាកាស ) នោះ :

តែងកន្លងនូវអាកាសនោះ ដោយទាញយកវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាសនោះ ។

តែងកន្លងនូវវិញ្ញាណនោះ រួចទាញយកសេចក្តីមិនមាន សូម្បីបន្តិចបន្តួច ដែលជាការមិនមាននៃវិញ្ញាណអរូបាវចរទី ១ នោះ ។

តែងកន្លងនូវសេចក្តីមិនមានសូម្បីបន្តិចបន្តួចនោះ រួចទាញយកអរូបាវចរវិញ្ញាណទី ៣ ដែលប្រព្រឹត្តទៅក្នុងការមិនមានសូម្បីបន្តិចបន្តួចនោះ ដែលប្រព្រឹត្តទៅតាមលំដាប់ ប៉ុន្តែមិនបានកាន់យកអារម្មណ៍នៃឈានខាងដើមៗ ដែលប្រព្រឹត្តទៅដោយអំណាចការកន្លងអង្គខាងដើមដូចរូបាវចរកុសលទេ. ដោយហេតុនេះ បុរាណាចារ្យ ទើបលោកពោលថា អរូបសមាបត្តិទាំង ៤ នេះ តែងមានដោយការកន្លងនូវអារម្មណ៍ បណ្ឌិតទាំងឡាយ តែងមិនបំណងការកន្លងនូវអង្គនៃអរូបសមាបត្តិទាំងនេះឯង ៕

# តារាងអរូបាវចរចិត្ត ១២ ដួង

| អារម្មណ៍ | បញ្ចមជ្ឈាន | កុសល | វិបាក | កិរិយា | រួម |
|---|---|---|---|---|---|
| អាកាស | អាកាសានញ្ចាយតនៈ | ១ | ១ | ១ | ៣ |
| វិញ្ញាណ | វិញ្ញាណញ្ចាយតនៈ | ១ | ១ | ១ | ៣ |
| អ្វីមិនមាន | អាកិញ្ចញ្ញាយតនៈ | ១ | ១ | ១ | ៣ |
| សញ្ញា | នេវសញ្ញានាសញ្ញាយតនៈ | ១ | ១ | ១ | ៣ |
| | រួម | ៤ | ៤ | ៤ | ១២ |

( អរូបាវចរសោភណចិត្ត ១២ ដួងចប់ )

# តារាងមហគ្គតចិត្ត ២៧ ដួង

មហគ្គតចិត្ត គឺ រូបាវចរចិត្ត និង អរូបាវចរចិត្តនោះឯង ។

| | | |
|---|---|---|
| មហគ្គតចិត្ត ២៧ | រូបាវចរចិត្ត ១៥ | រូបាវចរកុសលចិត្ត ៥ |
| | | រូបាវចរវិបាកចិត្ត ៥ |
| | | រូបាវចរកិរិយាចិត្ត ៥ |
| | អរូបាវចរចិត្ត ១២ | អរូបាវចរកុសលចិត្ត ៤ |
| | | អរូបាវចរវិបាកចិត្ត ៤ |
| | | អរូបាវចរកិរិយាចិត្ត ៤ |

( ចប់ មហគ្គតចិត្ត ២៧ ដួង )

# ៤.លោកុត្តរសោភណចិត្ត ៨ ដួង

ពាក្យថា **លោកុត្តរ** គឺ **លោក + ឧត្តរ** ប្រែថា លើពីលោក ឬ ផុតពីលោក ។

ពាក្យថា **លោកុត្តរចិត្ត** គឺ ចិត្តដែលលើពីលោក ឬផុតពីលោក ។ បានន័យថា ជាចិត្តដែលមានអារម្មណ៍ឡើងផុតពីសភាវៈធម៌មាននៅក្នុងលោក ឬថា ជាចិត្តដែលមានអំណាចទទួលអារម្មណ៍សភាវធម៌ក្រៅពីលោក ឬ ផុតពីលោកបាន **អារម្មណ៍នោះ បានដល់ ព្រះនិព្វាន** ។

ក្នុងចិត្ត ៨៩ ដួង ចិត្តដែលនឹងអាចទទួលព្រះនិព្វាន ជាអារម្មណ៍បានប្រាកដ មានតែ ៨ ដួង ប៉ុណ្ណោះ ក្រៅពីនេះ សូម្បីមាន ចិត្តខ្លះនឹងអាចទទួលអារម្មណ៍ព្រះនិព្វានបាន ក៏មិនប្រាកដដូច្នេះហើយ ទើបហៅ **ចិត្ត ៨ ដួង** នេះ ថាជា **លោកុត្តរចិត្ត** ។

ក្នុងលោកុត្តរចិត្ត ៨ នេះ ចែកចេញជា ២ ប្រភេទ គឺ មគ្គចិត្ត ៤ ផលចិត្ត ៤ ។ **មគ្គចិត្ត ៤ ដួង** ឈ្មោះថា **លោកុត្តរកុសលចិត្ត ១** ប្រភេទ និង ផលចិត្ត ៤ ដួង ឈ្មោះថា **លោកុត្តរវិបាកចិត្ត ១** ប្រភេទ មិនមានលោកុត្តរកិរិយាចិត្តឡើយ។

# លោកុត្តរកុសលចិត្ត ៤ ដួង

**សោតាបត្តិមគ្គចិត្តំ សកទាគាមិមគ្គចិត្តំ**
**អនាគាមិមគ្គចិត្តំ អរហត្តមគ្គចិត្តញ្ចេតិ**
**ឥមានិ ចត្តារិបិ លោកុត្តរកុសលចិត្តានិ នាម ។**

ប្រែថា :

- សោតាបត្តិមគ្គចិត្ត ១ ដួង
- សកទាគាមិមគ្គចិត្ត ១ ដួង
- អនាគាមិមគ្គចិត្ត ១ ដួង
- អរហត្តមគ្គចិត្ត ១ ដួង

ចិត្តទាំង ៤ ដួងនេះ ឈ្មោះថា លោកុត្តរកុសលចិត្ត ។

# សោតាបត្តិមគ្គចិត្ត

ពាក្យថា **សោតាបត្តិមគ្គចិត្ត** ( សោតាបត្តិមគ្គចិត្តំ ) គឺ **សោត + អាបត្តិ + មគ្គ + ចិត្តំ** ។

**សោតៈ** ប្រែថា ក្រសែ គឺថា អរិយមគ្គមានអង្គ ៨ បណ្ឌិត

ហៅថា **សោតះ** ( ក្រសែ ) ដោយហូរតម្រង់ទៅចូលកាន់ព្រះនិព្វាន ឬដូចជាក្រសែទឹក ដោយការហូរទៅកាន់មហាសមុទ្រ គឺព្រះនិព្វាន ។

**អាបត្តិ** ប្រែថា ការដល់ហើយ គឺ ការសម្រេចតាំងពីខាងដើម ជាការសេពគ្រាដំបូងនូវសោតះនោះ ។

**មគ្គ** ដោយអត្ថថា ការស្វែងរកព្រះនិព្វាន ឬអ្នកត្រូវការព្រះនិព្វានហើយស្វែងរក ឬ ដោយអត្ថថា ការទៅសម្លាប់កិលេសទាំងឡាយ ។

**ចិត្ត** សម្បយុត្តជាមួយមគ្គនោះ ឈ្មោះថា **មគ្គចិត្ត** ។

មគ្គចិត្តដែលបានសម្រេចក្រសែដំបូង ឈ្មោះថា **សោតាបត្តិ-មគ្គចិត្ត** បានដល់ មគ្គចិត្តរបស់ព្រះអរិយបុគ្គលដំបូង ដែលមានបដិសន្ធិទៀត យ៉ាងច្រើនមិនហួសពី ៧ ជាតិ ទៀត ក្នុងលោកនេះ ។

# សកទាគាមិមគ្គចិត្ត

ពាក្យថា **សកទាគាមិមគ្គចិត្ត** ( សកទាគាមិមគ្គចិត្តំ ) គឺ **សកឹ + អាគាមី + មគ្គ + ចិត្តំ** ។

**សកឹ** ប្រែថា មួយដង ឬ មួយវារៈ ។

**អាគាមី** ប្រែថា ត្រឡប់មក ។

**សកទាគាមិមគ្គចិត្ត** គឺ មគ្គចិត្តដែលញ៉ាំងឲ្យបុគ្គលត្រឡប់មកកាន់កាមលោកម្តងទៀត បានដល់ មគ្គចិត្តរបស់ព្រះអរិយបុគ្គលទី ២ ដែលត្រឡប់មកបដិសន្ធិក្នុងកាមភូមិ តែម្តងទៀតប៉ុណ្ណោះ ។

# អនាគាមិមគ្គចិត្ត

ពាក្យថា **អនាគាមិមគ្គចិត្ត** ( **អនាគាមិមគ្គចិត្តំ** ) គឺ **អន + អាគាមី + មគ្គ + ចិត្តំ** ។

**អនាគាមិមគ្គចិត្ត** គឺ មគ្គចិត្តដែលញ៉ាំងឲ្យបុគ្គលមិនចាំបាច់ត្រឡប់មកកាន់កាមលោកសូម្បីតែម្តងទៀតឡើយ បានដល់ មគ្គចិត្តរបស់ព្រះអរិយបុគ្គលទី ៣ ដែលមិនត្រូវត្រឡប់មកបដិសន្ធិ ក្នុងកាមលោក ។

# អរហត្តមគ្គចិត្ត

ពាក្យថា **អរហត្តមគ្គចិត្ត** ( **អរហត្តមគ្គចិត្តំ** ) **អរហត្ត + មគ្គ + ចិត្ត** ។

ឈ្មោះថា **ព្រះអរហន្ត** ដោយអត្ថថា គួរដល់ការបូជាវិសេស ព្រោះភាពជាព្រះទក្ខិណេយ្យបុគ្គលដ៏កំពូល ។ ម្យ៉ាងទៀត ឈ្មោះថា **ព្រះអរហន្ត** ដោយអត្ថថា **កាំ** ( កាំកង់ដែលវិលទៅ ) គឺ កិលេស ឬ កិលេសដែលជាកាំនៃសង្សារចក្រ ត្រូវលោកកាច់បំបាក់អស់ហើយ ។ ម្យ៉ាងទៀត ឈ្មោះថា **ព្រះអរហន្ត** ព្រោះមិនមានការត្រឡប់មកក្នុងការធ្វើបាបទេ បានដល់ ព្រះអរិយបុគ្គលទី ៤ ។ ភាវៈនៃបុគ្គលទី ៤ នេះ ឈ្មោះថា **អរហត្ត** ។

ពាក្យថា **អរហត្ត** នោះ ជាឈ្មោះនៃផលទី ៤ ។ មគ្គដែលជាហេតុនៃព្រះអរហត្តនោះ ឈ្មោះថា **អរហត្តមគ្គ** ។ ចិត្តដែលសម្បយុត្តដោយអរហត្តមគ្គនោះ ឈ្មោះថា **អរហត្តមគ្គចិត្ត** ។

ក្នុងមគ្គចិត្ត ៤ ដួងនោះ ចាត់ជាលោកុត្តរកុសល ។

ពាក្យថា **លោកុត្តរកុសលនេះ** ព្រោះជាកុសលដែលធ្វើឲ្យឆ្លងផុតចាកលោក ៣ មានកាមលោក ១ រូបលោក ១ អរូបលោក ១ ។

**កាមលោក** បានដល់ កាមភូមិ ១១ ភូមិ ។

**រូបលោក** បានដល់ រូបភូមិ ១៦ ភូមិ ។

**អរូបលោក** បានដល់ អរូបភូមិ ៤ ភូមិ ។
រួមទាំងអស់ត្រូវជា ៣១ ភូមិ ។

ន័យម្យ៉ាងទៀត ពាក្យថា **លោកុត្តរកុសល** ព្រោះជាកុសលដែលធ្វើឲ្យឆ្លងផុតពីបុថុជ្ជនទៅជាព្រះអរិយបុគ្គល ។

ន័យម្យ៉ាងទៀត ពាក្យថា **លោកុត្តរកុសល** ព្រោះជាកុសលដែលកើតឡើងមានព្រះនិព្វានជាលោកុត្តរធម៌ជាអារម្មណ៍ ។

ន័យម្យ៉ាងទៀត ពាក្យថា **លោកុត្តរកុសល** ព្រោះជាកុសលដែលមានអំណាចផុតលើសពីកុសលលោកិយទាំងឡាយ អាចរំលត់អកុសលឲ្យដាច់ជាសមុច្ឆេទបាន ។

**ន័យទី ១** ដែលថា ឆ្លងផុតលោកនោះ គឺ មគ្គចិត្តដួងទី ១ ហៅថា បឋមមគ្គ គឺ សោតាបត្តិមគ្គចិត្ត និង មគ្គចិត្តដួងទី ២ ហៅថា ទុតិយមគ្គ គឺសកទាគាមិមគ្គចិត្ត ២ ដួងនេះ ធ្វើឲ្យផុតចាកកាមលោក គឺ **អបាយភូមិទាំង ៤** ។ មគ្គចិត្តដួងទី ៣ ហៅថា តតិយមគ្គ គឺ អនាគាមិមគ្គ ១ ដួងនេះធ្វើឲ្យផុតចាក **កាមលោកទាំង ១១ ភូមិ** ។ មគ្គចិត្តដួងទី ៤ ហៅថា ចតុត្ថមគ្គ គឺ អរហត្ត-មគ្គចិត្ត ១ ដួង នេះធ្វើឲ្យផុតពី **លោកទាំងអស់ ៣១ ភូមិ** ។

**ន័យទី ២** ដែលថាឆ្លងផុតពីបុថុជ្ជន ទៅជាព្រះអរិយបុគ្គល គឺ មគ្គចិត្តដួងទី ១ ធ្វើឲ្យទៅជា **ព្រះសោតាបន្នបុគ្គល** , មគ្គចិត្តដួងទី ២ ធ្វើឲ្យទៅជា **ព្រះសកទាគាមិបុគ្គល** , មគ្គចិត្តដួងទី ៣ ធ្វើឲ្យទៅជា **ព្រះអនាគាមិបុគ្គល** និងមគ្គចិត្តដួងទី ៤ ធ្វើឲ្យទៅជា **ព្រះអរហន្ត** ។

**ន័យទី ៣** ដែលថា មានព្រះនិព្វានជាអារម្មណ៍ គឺព្រះនិព្វានជាលោកុត្តរធម៌ ហើយលោកុត្តរកុសល ៤ ដួង នេះ ដែលកើតឡើងបាន ក៏ដោយព្រះនិព្វានជាអារម្មណបច្ច័យ ទើបកើត ។

**ន័យទី ៤** ដែលថា រំលត់អកុសលឲ្យដាច់ជាសមុច្ឆេទប្បហាន គឺ ដោយមានព្រះនិព្វានជាអារម្មណ៍នោះឯង ។

លោកុត្តរកុសល ពោលគឺ មគ្គចិត្ត ៤ តាមសេចក្តីផ្សេងគ្នានៃការប្រកបរបស់អដ្ឋង្គិកមគ្គ មានសោតាបត្តិមគ្គជាដើម គឺ ដោយអំណាចការលះសំយោជនៈបាន ។ ការដែលលះសំយោជនៈបាន , ផ្សេងៗគ្នា ក៏ព្រោះឥន្ទ្រិយ ៥ មានសទ្ធាជាដើម មានកម្លាំងផ្សេងៗគ្នា គឺ ឥន្ទ្រីយ៍ ៥ របស់សោតាបត្តិមគ្គមិនចាស់ក្លា របស់សកទា-គាមិមគ្គចាស់ក្លា របស់អនាគាមិមគ្គចាស់ក្លាជាង របស់ព្រះអរហត្តមគ្គចាស់ក្លាជាទីបំផុតនោះឯង ។

**សួរថា** ការប្រហារកិលេសនោះ តើលោកុត្តរកុសលប្រហារបង់កិលេសអតីត ឬកិលេសអនាគត ឬកិលេសបច្ចុប្បន្ន ?

**ឆ្លើយថា** ការប្រហារបង់របស់អរិយមគ្គនោះ នឹងថា ដោយកាលណាមួយក្នុងកាលទាំង ៣ ក៏ថាមិនបាន ព្រោះកិលេសចំណែកអតីតបានរលត់ទៅហើយ ចំណែកកិលេសអនាគត ក៏មិនទាន់កើតដែរ ឯចំណែកកិលេសបច្ចុប្បន្នក៏មិនមានប្រាកដ មានប្រាកដចំពោះលោកុត្តរកុសលប៉ុណ្ណោះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការប្រហារកិលេសនេះ គឺថា តាំងពីមគ្គចិត្តប្រាកដឡើង កិលេសដែលនឹងប្រាកដទៀត ក៏រមែងមិនមានឱកាសឡើយ គឺ រមែងមិនប្រាកដដោយពិត បានសេចក្តីថា អរិយមគ្គកាត់ផ្តាច់ប្រហារនូវ **ឫសគល់ពូជរបស់កិលេសវដ្តៈ** មិនមានកើតតទៅទៀតបាន ឧបមាដូចដើមឈើមានផ្លែគេបេះអស់ហើយ បុរសម្នាក់មកកាត់ផ្តាច់ឫសកែវចេញ សូម្បីដើមឈើនោះនៅរស់ក្តី ក៏ពុំអាចឲ្យផលបានឡើយ ។ ក្នុងរឿងនេះការកាត់ដើមឈើនៃបុរសនោះ នឹងថាប្រហារផលក្នុងអតីតក៏មិនបាន ព្រោះផលក្នុងអតីតនោះ អ្នកស្រុកបេះអស់ហើយ, នឹងថាប្រហារផលក្នុងអនាគត ក៏មិនបាន ព្រោះផលនោះមិនទាន់មាន, ហើយនឹងថាប្រហារផលក្នុងបច្ចុប្បន្នក៏មិនបានទៀត ព្រោះផលក្នុងបច្ចុប្បន្នមិនមាន យ៉ាងណា ការប្រហារកិលេសរបស់អរិយមគ្គ ក៏យ៉ាងនោះ ថា

ដោយកាលទាំង ៣ មិនបាន គ្រាន់តែថា កិលេសនៃអនាគតនោះ រមែងមិនប្រាកដដោយពិត ។

ក្នុងកថាវត្ថុ អដ្ឋកថាពោលថា កាលអរិយមគ្គមានព្រះនិព្វាន ជាអារម្មណ៍ កើតឡើងនោះ កិលេសដែលមិនទាន់កើត ក៏រមែងមិន កើត ៕

# អកុសលធម៌ ៩ កង

អកុសលធម៌ គឺ ធម៌ដែលជាអកុសល ដែលព្រះអរិយបុគ្គល គប្បីលះ (ប្រហារ) ទាំងអស់មាន ៩ កង ឬ ៩ ប្រភេទ គឺ :-

**១. អាសវៈ** ធម៌ដែលត្រាំក្នុងសន្តាន មាន ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ និង អវិជ្ជាសវៈ ។

**២. ឱឃៈ** ធម៌ដែលប្រៀបដូចអន្លង់ទឹក ញ៉ាំងសត្វឲ្យលិច លង់ក្នុងសង្សារវដ្ត មាន ៤ គឺ កាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ និង អវិជ្ជោឃៈ ។

**៣. យោគៈ** ធម៌ដែលប្រកបសត្វទុកក្នុងភព មាន ៤ គឺ កាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈ និង អវិជ្ជាយោគៈ ។

**៤. គន្ថៈ** ធម៌ជាគ្រឿងចងផ្ចាក់ ចាក់ស្រែះសត្វទុកក្នុងភព មាន ៤ គឺ អភិជ្ឈាកាយគន្ថៈ ព្យាបាទកាយ-គន្ថៈ សីលព្វតបរាមាសកាយគន្ថៈ និង ឥទំ-សច្ចាភិនិវេសកាយគន្ថៈ ។

**៥. ឧបាទាន** ធម៌ដែលជាគ្រឿងប្រកាន់មាំ មាន ៤ គឺ កាមុ-បាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន និង អត្តវាទុបាទាន ។

**៦. នីវរណៈ** ធម៌ជាគ្រឿងរារាំងនូវសេចក្តីល្អ មាន ៦ គឺ កាមច្ឆន្ទៈ ព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា និង អវិជ្ជា ។

**៧. អនុស័យ** ធម៌ដែលដេកសម្ងំក្នុងខន្ធសន្តាន មាន ៧ គឺ កាមរាគានុស័យ ទិដ្ឋានុស័យ បដិឃានុស័យ ភវរាគានុស័យ មានានុស័យ វិចិកិច្ឆានុស័យ និង អវិជ្ជានុស័យ ។

**៨. សញ្ញោជនៈ** ធម៌ជាគ្រឿងរួបរឹតសត្វទុក មាន ១០ គឺ កាមរាគៈ ( កាមរាគសញ្ញោជនៈ ) ភវរាគៈ មានៈ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឥស្សា មច្ឆរិយៈ បដិឃៈ និង អវិជ្ជាសញ្ញោជនៈ ។

៩. កិលេស ធម៌ជាគ្រឿងសៅហ្មង មាន ១០ គឺ លោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និង អនោត្តប្បកិលេស ៕

# មគ្គចិត្តលះបង់អកុសលធម៌ ៩ កង

១.សោតាបត្តិមគ្គចិត្ត លះបង់ ទិដ្ឋាសវៈ ១ ទិដ្ឋោឃៈ ១ ទិដ្ឋិយោគៈ ១ សីលព្វត្តបរាមាសៈ ១ កាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ១ ទិដ្ឋុបាទាន១ អត្តវាទុបាទាន១ សីលព្វត្តុបាទាន១ វិចិកិច្ឆានីវរណៈ១ កុក្កុច្ចនីវរណៈ(គ្រោតគ្រាត) ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ សីលព្វត្តបរាមាសសញ្ញោជនៈ១ ឥស្សាសញ្ញោជនៈ ១ មច្ឆរិយសញ្ញោជន ១ មិច្ឆាទិដ្ឋិកិលេស ១ និង វិចិកិច្ឆាកិលេស ១ ៕

**២.សកទាគាមិមគ្គចិត្ត** លះបង់អកុសលធម៌គ្រោតគ្រាត ដែលសល់នៅពីបឋមមគ្គ បានលះបង់ហើយនោះឲ្យស្រាលស្តើង(តនុករប្បហាន)។

**៣.អនាគាមិមគ្គចិត្ត** លះបង់កាមាសវៈ ១ កាមោឃៈ ១ កាមយោគៈ ១ ព្យាបាទកាយគន្ថៈ ១ ព្យាបាទនីវរណៈ ១ កាមច្ឆន្ទនីវរណៈ ១ កាមរាគានុស័យ ១ បដិឃានុស័យ ១ កាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ ទោសកិលេស ១ ។

**៤.អរហត្តមគ្គចិត្ត** លះបង់អកុសលធម៌ដែលនៅសល់ទាំងអស់ពីមគ្គចិត្តខាងក្រោម ដែលនៅមិនទាន់បានលះ ឲ្យអស់ទៅ ។

# មគ្គចិត្តលះអកុសលចិត្ត ១២ ដួង

**១.សោតាបត្តិមគ្គចិត្ត** លះលោភមូលចិត្តបាន ៤ ដួង គឺលោភទិដ្ឋិសម្បយុត្តចិត្ត ៤ និង លះមោហមូលចិត្តបាន១ គឺមោហវិចិកិច្ឆា-

សម្បយុត្តចិត្ត ១ សរុបបាន ៥ ដួង ។

**២.សកទាគាមិមគ្គចិត្ត** លះអកុសលចិត្តគ្រោតគ្រាត ដែលនៅសល់ពីបឋមមគ្គបានលះហើយ ដោយតនុករប្បហាន ។

**៣.អនាគាមិមគ្គចិត្ត** លះទោសមូលចិត្ត បានទាំង ២ ។

**៤.អរហត្តមគ្គចិត្ត** លះលោភមូលចិត្ត ៤ ដួង គឺ លោភទិដ្ឋិវិប្បយុត្តចិត្ត ៤ និង លះមោហមូលចិត្ត ១ គឺ មោហឧទ្ធច្ចសម្បយុត្តចិត្ត ១ សរុបបាន ៥ ដួង ។

# មគ្គចិត្តលះអកុសលកម្មបថ ១០

**១.សោតាបត្តិមគ្គចិត្ត** លះបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារៈ មុសាវាទ និងមិច្ឆាទិដ្ឋិ ។

**២.សកទាគាមិមគ្គចិត្ត** លះអកុសលកម្មបថគ្រោតគ្រាត ដែលនៅសល់ពីបឋមមគ្គលះហើយ ដោយតនុករប្បហាន ។

**៣.អនាគាមិមគ្គ** លះបិសុណាវាចា ផរុសវាចា និងព្យាបាទ។

**៤.អរហត្តមគ្គ** លះសម្ផប្បលាបវាទ និង អភិជ្ឈា ។

# មគ្គលះសញ្ញោជនៈ ១០

**១.សោតាបត្តិមគ្គចិត្ត** លះសញ្ញោជនៈខាងក្រោមបាន ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និង សីលព្វត្ត-បរាមាស ដោយសមុច្ឆេទប្បហាន ។

**២.សកទាគាមិមគ្គ** លះសញ្ញោជនៈ ដោយតនុករប្បហាន គឺ ធ្វើកាមរាគៈ និងព្យាបាទឲ្យស្រាលស្ដើង ។

**៣.អនាគាមិមគ្គ** លះសញ្ញោជនៈបាន ២ គឺ កាមរាគៈ និងព្យាបាទ ដោយសមុច្ឆេទប្បហាន ។

**៤.អរហត្តមគ្គ** លះសញ្ញោជនៈខាងលើ ដែលសល់ពីមគ្គខាងក្រោមបានលះហើយបាន ៥ គឺ រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ និង អវិជ្ជា ដោយសមុច្ឆេទប្បហាន ។

ការដែលមគ្គចិត្ត មានអំណាចសម្លាប់កិលេសដាច់ ដោយ

សមុច្ឆេទប្បហាននោះ ក៏ដោយហេតុថា ក្នុងមគ្គចិត្ត ៤ ដួងនោះ ប្រកបបរិបូណ៌ព្រមដោយ ពោធិបក្ខិយធម៌ទាំង ៣៧ ប្រការ ហើយក្នុងពោធិបក្ខិយធម៌នោះ កាលបើបង្រួមមក ក៏បានដល់ **សីល សមាធិ បញ្ញា** ទាំង ៣ នោះឯង ។

# លោកុត្តរវិបាកចិត្ត ៤ ដួង

**សោតាបត្តិផលចិត្តំ សកទាគាមិផលចិត្តំ**
**អនាគាមិផលចិត្តំ អរហត្តផលចិត្តញ្ចេតិ**
**ឥមានិ ចត្តារិបិ លោកុត្តរវិបាកចិត្តានិ នាម ។**

ប្រែថា :

- **សោតាបត្តិផលចិត្ត ១**
- **សកទាគាមិផលចិត្ត ១**
- **អនាគាមិផលចិត្ត ១**
- **អរហត្តផលចិត្ត ១**

ចិត្តទាំង ៤ ដួងនេះឈ្មោះថា **លោកុត្តរវិបាកចិត្ត** ។

**សួរថា** ហេតុអ្វី លោកុត្តរវិបាកក៏មាន ៤ ប្រការ ?

**ឆ្លើយថា** ព្រោះជាផលរបស់លោកុត្តរកុសលនោះៗ គឺអាស្រ័យមគ្គចិត្តជាហេតុ ជាបច្ច័យ ឲ្យកើតឡើង ព្រោះហេតុនោះទើបហៅថា **ផលចិត្ត** ។ ផលចិត្តនេះមិនមាននាទីប្រហារនូវកិលេសណាមួយ ដូចជាមគ្គចិត្តទេ ប៉ុន្តែមានព្រះនិព្វានជាអារម្មណ៍ និងប្រកបព្រមដោយពោធិបក្ខិយធម៌ ទាំង ៣៧ ប្រការដូចគ្នា ។

លោកុត្តរចិត្តនោះ **មិនមានកិរិយាចិត្តទេ** ព្រោះមគ្គចិត្តកើតឡើងម្តង ក៏ប្រហារកិលេសដាច់ជាសមុច្ឆេទ ដូច្នេះ មគ្គចិត្តដែលកើតឡើងប្រហារកិលេសបានហើយនេះ នឹងមិនកើតឡើងជាលើកទី ២ ទៀតឡើយ ។ ចំណែកផលចិត្តកើតឡើងបានច្រើនដង គឺដែលជាផលសមាបត្តិមានព្រះនិព្វានជាអារម្មណ៍ ក៏ដើម្បីសេចក្តីនៅជាសុខក្នុងភពបច្ចុប្បន្ន ព្រោះហេតុនោះ ទើបលោកុត្តរចិត្តមិនមានកិរិយា ។

# លោកុត្តរចិត្តបែបពិស្តារ

លោកុត្តរចិត្តមាន ២ ន័យ គឺ បែបសង្ខេបមាន ៨ ដួង ១ ន័យ និងបែបពិស្តារមាន ៤០ ដួង ១ ន័យ ។

លោកុត្តរចិត្តបែបពិស្តារមាន ៤០ ដួង សម្តែងតាមអង្គឈាន គឺថា ធ្វើលោកុត្តរចិត្តមួយដួងៗ ជា ៥ យ៉ាង ដោយសេចក្តីខុសគ្នា

នៃការប្រកបជាមួយអង្គឈាន គឺ :-

| | | |
|---|---|---|
| បឋមជ្ឈានមានអង្គ | ៥ | មានសោតាបត្តិមគ្គចិត្ត ១ |
| ទុតិយជ្ឈានមានអង្គ | ៤ | មានសោតាបត្តិមគ្គចិត្ត ១ |
| តតិយជ្ឈានមានអង្គ | ៣ | មានសោតាបត្តិមគ្គចិត្ត ១ |
| ចតុត្ថជ្ឈានមានអង្គ | ២ | មានសោតាបត្តិមគ្គចិត្ត ១ |
| បញ្ចមជ្ឈានមានអង្គ | ២ | មានសោតាបត្តិមគ្គចិត្ត ១ |

សោតាបត្តិផលចិត្តមាន ៥ សកទាគាមិមគ្គចិត្តក៏មាន ៥ សកទាគាមិផលចិត្តក៏មាន ៥ អនាគាមិមគ្គចិត្តក៏មាន ៥ អនាគាមិ-ផលចិត្តក៏មាន ៥ អរហត្តមគ្គចិត្តក៏មាន ៥ អរហត្តផលចិត្ត ក៏មាន ៥ ដូចគ្នា រួមជាមគ្គចិត្ត ២០ ដួង និង ផលចិត្ត ២០ ដួង រួមទាំង ២ ចូលគ្នាមាន ៤០ ដួង ដោយពិស្តារ ។

# ចំណែកលោកុត្តរចិត្ត ៨ ដួង

**១. ដោយជាតិ** ជាកុសលជាតិ ៤ ដួង ។
ជាវិបាកជាតិ ៤ ដួង ។

**២. ដោយភូមិ** ជាលោកុត្តរភូមិទាំង ៨ ដួង ដូច្នេះហើយ ទើបអវត្ថានភូមិ ( មិនមានភូមិ

ប្រចាំរបស់ខ្លួន )កើតបាន ២៦ ភូមិ វៀរអបាយភូមិ ៤ និង អសញ្ញសត្ត-ភូមិ ១ ។

៣. ដោយវេទនា ជាសោមនស្សវេទនា និង ឧបេក្ខាវេទនា។

៤. ដោយហេតុ ជានហេតុ , មានហេតុប្រកប ជាសហេតុកចិត្តទាំង ៨ ដួង ។

៥. ដោយសម្បយុត្ត ជាញាណសម្បយុត្តទាំង ៨ ដួង ។

៦. ដោយសង្ខារ ជាសសង្ខារិកទាំង ៨ ដួង ។

៧. ដោយសោភណៈ ជាសោភណចិត្ត ។

៨. ដោយឈាន ជាឈានចិត្ត ។

៩. ដោយលោកិយ ជាលោកុត្តរចិត្ត ។

១០. ដោយកិច្ច ធ្វើជវនកិច្ច ។

១១. ដោយអារម្មណ៍ មានធម្មារម្មណ៍ គឺព្រះនិព្វានជាអារម្មណ៍។

១២. ដោយទ្វារ កើតឡើងអាស្រ័យមនោទ្វារ ។

១៣. ដោយវត្ថុ វៀរសោតាបត្តិមគ្គចិត្ត១ ដែលអាស្រ័យហទយវត្ថុ , លោកុត្តរចិត្តនៅសល់ ៧ ដួងទៀត អាស្រ័យហទយវត្ថុក្នុង

បញ្ចវោការភព គឺ មិនអាស្រ័យក្នុង ចតុវោការភព ។

**១៤. ដោយវិញ្ញាណធាតុ** ជាវិញ្ញាណធាតុ ៧ ។

# តារាងលោកុត្តរចិត្ត ៨ ដួង

| មគ្គចិត្ត | កុសល | ផលចិត្ត | វិបាក | រួម |
|---|---|---|---|---|
| សោតាបត្តិមគ្គ | ១ | សោតាបត្តិផល | ១ | ២ |
| សកទាគាមិមគ្គ | ១ | សកទាគាមិផល | ១ | ២ |
| អនាគាមិមគ្គ | ១ | អនាគាមិផល | ១ | ២ |
| អរហត្តមគ្គ | ១ | អរហត្តផល | ១ | ២ |
| រួម | ៤ | រួម | ៤ | ៨ |

# តារាងលោកុត្តរចិត្ត ៤០ ដួង

| **មគ្គចិត្ត** | បឋម | ទុតិយ | តតិយ | ចតុត្ថ | បញ្ចម | រួម |
|---|---|---|---|---|---|---|
| សោតាបត្តិមគ្គ | ១ | ១ | ១ | ១ | ១ | ៥ |
| សកទាគាមិមគ្គ | ១ | ១ | ១ | ១ | ១ | ៥ |
| អនាគាមិមគ្គ | ១ | ១ | ១ | ១ | ១ | ៥ |
| អរហត្តមគ្គ | ១ | ១ | ១ | ១ | ១ | ៥ |
| រួម | ៤ | ៤ | ៤ | ៤ | ៤ | ២០ |
| **ផលចិត្ត** | បឋម | ទុតិយ | តតិយ | ចតុត្ថ | បញ្ចម | រួម |
| សោតាបត្តិផល | ១ | ១ | ១ | ១ | ១ | ៥ |
| សកទាគាមិផល | ១ | ១ | ១ | ១ | ១ | ៥ |
| អនាគាមិផល | ១ | ១ | ១ | ១ | ១ | ៥ |
| អរហត្តផល | ១ | ១ | ១ | ១ | ១ | ៥ |
| រួម | ៤ | ៤ | ៤ | ៤ | ៤ | ២០ |

( ចប់លោកុត្តរចិត្ត ៨ ដួង )

# ព្រះសោតាបន្ន ៣ ប្រភេទ

ក្នុងគាថាធម្មបទ សរសើរព្រះសោតាបន្នថា សោតាបត្តិផល ប្រសើរជាងភាពជាស្តេចចក្រពត្តិ ឬថា ប្រសើរជាងការទៅកាន់ទេវលោក ឬថា ប្រសើរជាងភាពជាធំក្រៃលែង ក្នុងលោកទាំងពួង ។

## ១. ឯកពីជីសោតាបន្ន

ឈ្មោះថា **ឯកពីជី** ព្រោះអត្ថថា មានពូជ (ការកើត) ១ ជាតិទៀត គឺ ព្រះសោតាបន្នកើតឡើងតែម្តងទៀត ក៏បានសម្រេចនូវអរហត្តផល ហើយក៏បរិនិព្វាន ។

## ២. កោលំកោលសោតាបន្ន

ឈ្មោះថា **កោលំកោល** ព្រោះអត្ថថា ពីត្រកូលមួយទៅកាន់ត្រកូលមួយ គឺ ព្រះសោតាបន្នដែលត្រូវកើត ២ ជាតិទៅ ៦ ជាតិទៀត ទើបបរិនិព្វាន ។

## ៣. សត្តក្ខត្តុបរមសោតាបន្ន

ឈ្មោះថា **សត្តក្ខត្តុបរម** ព្រោះអត្ថថា មាន ៧ ជាតិទៀត យ៉ាងច្រើន គឺ ព្រះសោតាបន្នត្រូវកើតមិនហួសពី ៧ ជាតិទៀតឡើយ ហើយក៏បរិនិព្វាន ។

ក្នុងអដ្ឋកថានៃបុគ្គលបញ្ញត្តិពោលថា ព្រះសោតាបន្ន មាន អធ្យាស្រ័យត្រេកអរពេញចិត្តក្នុងភព នឹងទៅកើត ក្នុងទេវលោកទាំង ៦ រួចហើយនឹងតាំងនៅក្នុងអកនិដ្ឋភព ហើយបរិនិព្វានក្នុងភព នោះ មាន ៧ អង្គ គឺ :

១. អនាថបិណ្ឌិកសេដ្ឋី ។

២. ព្រះនាងវិសាខា ។

៣. ចូឡរថទេវបុត្ត ។

៤. មហារថទេវបុត្ត ។

៥. អនេកវណ្ណទេវបុត្ត ។

៦. ព្រះសក្កទេវរាជ ។

៧. នាគទត្តទេវបុត្ត ។

# ព្រះសកទាគាមី ៥ ប្រភេទ

**១. ឥធ បត្វា ឥធ បរិនិព្វាយី** ព្រះសកទាគាមីអ្នក សម្រេចក្នុងមនុស្សលោក ហើយបរិនិព្វានក្នុងមនុស្សលោកនេះ ។

**២. តត្ថ បត្វា តត្ថ បរិនិព្វាយី** ព្រះសកទាគាមី អ្នក

សម្រេចក្នុងទេវលោក ហើយបរិនិព្វានក្នុងទេវលោកនោះ ។

**៣. ឥធ បត្វា តត្ថ បរិនិព្វាយី** ព្រះសកទាគាមីអ្នកសម្រេចក្នុងមនុស្សលោក ហើយបរិនិព្វានក្នុងទេវលោក ។

**៤. តត្ថ បត្វា ឥធ បរិនិព្វាយី** ព្រះសកទាគាមីអ្នកសម្រេចក្នុងទេវលោក ហើយបរិនិព្វានក្នុងមនុស្សលោក ។

**៥. ឥធ បត្វា តត្ថ និព្វត្តិត្វា ឥធ បរិនិព្វាយី** ព្រះសកទាគាមីអ្នកសម្រេចក្នុងមនុស្សលោកនេះ បានកើតក្នុងទេវលោកនោះហើយ ចុតិពីទេវលោកនោះ រួចមកកើតក្នុងមនុស្សលោក ទើបបរិនិព្វានក្នុងមនុស្សលោកនេះ ។

# ព្រះអនាគាមី ៥ ប្រភេទ

**១. អន្តរាបរិនិព្វាយី** បានដល់ ព្រះអនាគាមីអ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយហើយ បរិនិព្វានមុនពាក់កណ្ដាលអាយុខេយ្យនៃភូមិនោះ ។

**២. ឧបហច្ចបរិនិព្វាយី** បានដល់ ព្រះអនាគាមីអ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិ ណាមួយហើយ បរិនិព្វានកន្លងពាក់កណ្ដាលអាយុខេយ្យនៃភូមិនោះ ។

**៣. អសង្ខារបរិនិព្វាយី** បានដល់ ព្រះអនាគាមីអ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយ ហើយសម្រេចអរហត្ត បរិនិព្វានដោយស្រួល មិនចាំបាច់ព្យាយាមច្រើន ។

**៤. សសង្ខារបរិនិព្វាយី** បានដល់ ព្រះអនាគាមីអ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយ ហើយសម្រេចព្រះអរហត្ត បានដោយលំបាក ចាំបាច់ត្រូវព្យាយាមច្រើន ទើបបរិនិព្វានក្នុងភូមិនោះ ។

**៥. ឧទ្ធំសោតោអកនិដ្ឋគាមី** បានដល់ ព្រះអនាគាមីអ្នកបដិសន្ធិ តាំងពីសុទ្ធាវាសភូមិខាងក្រោមណាមួយ គឺ អវិហាភូមិ (មានអាយុ ១.០០០ មហាកប្ប ) ចុតិហើយ កើតក្នុងអតប្បាភូមិ (មានអាយុ ២.០០០ មហាកប្ប ) ចុតិហើយ កើតក្នុងសុទស្សាភូមិ (មានអាយុ ៤.០០០ មហាកប្ប ) ចុតិហើយ កើតក្នុងសុទស្សីភូមិ (មានអាយុ ៨.០០០ មហាកប្ប ) ចុតិហើយ កើតក្នុងអកនិដ្ឋាភូមិ (មានអាយុ ១៦.០០០ មហាកប្ប ) ហើយក៏បរិនិព្វានក្នុងភូមិនោះ។

# ព្រះអរហន្ត ២ ប្រភេទ

១. ព្រះអរហន្តដែលសម្រេចដោយ **បញ្ញាវិមុត្តិ** ។

២. ព្រះអរហន្តដែលសម្រេចដោយ **ចេតោវិមុត្តិ** ។

ព្រះអរហន្តដែលសម្រេចដោយ **បញ្ញាវិមុត្តិ** មិនមានឈានលាភី ចំណែកព្រះអរហន្តដែលសម្រេចដោយ **ចេតោវិមុត្តិ** មានឈានលាភី ខ្លះបាន **វិជ្ជា ៣** គឺ បុព្វេនិវាសញ្ញាណ ចុតូបបាតញ្ញាណ និង អាសវក្ខយញ្ញាណ ។ ខ្លះបាន **អភិញ្ញា ៦** គឺ ឥទ្ធិវិធ ( សម្តែងឫទ្ធិបាន ) ទិព្វសោត( ត្រចៀកទិព្វ ) ចេតោបរិយញ្ញាណ ( កំណត់ដឹងចិត្តអ្នកដទៃបាន ) និង វិជ្ជា ៣ ជាគំរប់ ៦ ។

ម្យ៉ាងទៀត លោកដែលបាន បដិសម្ភិទា ( បញ្ញាបែកព្រម ) ៤ គឺ អត្ថប្បដិសម្ភិទា ( បញ្ញាបែកព្រមក្នុងអត្ថ ) ធម្មប្បដិសម្ភិទា ( បញ្ញាបែកព្រមក្នុងធម៌ ) និរុត្តិប្បដិសម្ភិទា( បញ្ញាបែកព្រមក្នុងស័ព្ទពាក្យបញ្ញត្តិភាសា ) និង បដិភាណប្បដិសម្ភិទា ( បញ្ញាបែកព្រមក្នុងញាណ ) ហៅថា **បដិសម្ភិទប្បត្តោ** ។ ចំណែកឯលោកអ្នកមិនបានបដិសម្ភិទា ហៅថា **អប្បដិសម្ភិទប្បត្តោ** ។

# សង្រ្គោះលោកុត្តរចិត្តក្នុងឈាន

រូបាវចរចិត្ត សង្រ្គោះក្នុងប្រភេទនៃឈាន មានបឋមជ្ឈានជាដើម យ៉ាងណា លោកុត្តរចិត្តក៏ដូច្នោះដែរ ។ ឯអរូបាវចរចិត្តក៏សង្រ្គោះចូលក្នុងបញ្ចមជ្ឈាន ។

ដោយលោកុត្តរចិត្តនីមួយៗ សង្គ្រោះក្នុងប្រភេទនៃឈានមាន ៥ ទើបក្នុងប្រភេទនៃឈាននីមួយៗ មានបឋមជ្ឈានជាដើម មាន លោកុត្តរចិត្ត ៨ ដួង ។

ព្រោះហេតុនេះ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាននីមួយៗទើបមាន ១១ ដួង ចំណែកបញ្ចមជ្ឈាន ឈាន ចុងក្រោយមាន ២៣ ដួង ។ ដូច្នេះ ឈានចិត្តមាន ៦៧ ដួង ។

# ឈានចិត្ត ៦៧ ដួង

**បឋមជ្ឈានចិត្ត មាន ១១ ដួង** គឺ រូបាវចរចិត្ត ៣ ដួង ( រូបាវចរកុសល ១ រូបាវចរវិបាក ១ រូបាវចរកិរិយា ១ ) និង លោកុត្តរចិត្ត ៨ ដួង ។

**ទុតិយជ្ឈានចិត្ត មាន ១១ ដួង** គឺ រូបាវចរចិត្ត ៣ ដួង និង លោកុត្តរចិត្ត ៨ ដួង ។

**តតិយជ្ឈានចិត្ត មាន ១១ ដួង** គឺ រូបាវចរចិត្ត ៣ ដួង និង លោកុត្តរចិត្ត ៨ ដួង ។

**ចតុត្ថជ្ឈានចិត្ត មាន ១១ ដួង** គឺ រូបាវចរចិត្ត ៣ ដួង និង លោកុត្តរចិត្ត ៨ ដួង ។

**បញ្ចមជ្ឈានចិត្ត មាន ២៣ ដួង** គឺ រូបាវចរចិត្ត ៣ ដួង អរូបាវចរចិត្ត ១២ ដួង និង លោកុត្តរចិត្ត ៨ ដួង ។

# ចំណែកចិត្តដោយពិស្តារ

## ចិត្តដោយសង្ខេបមាន ៨៩ ដួង

✷ **សម្តែងដោយភូមិ** គឺ :-

- កាមាវចរចិត្ត ៥៤ ដួង ជាកាមាវចរភូមិ ។
- រូបាវចរចិត្ត ១៥ ដួង ជារូបាវចរភូមិ ។
- អរូបាវចរចិត្ត ១២ ដួង ជាអរូបាវចរភូមិ ។
- អនុត្តរចិត្ត ៨ ដួង ជាលោកុត្តរភូមិ ។

✷ **សម្តែងដោយជាតិ** គឺ :-

- អកុសលចិត្ត ១២ ដួង ជាអកុសលជាតិ ។
- កុសលចិត្ត ២១ ដួង ( មហាកុសល ៨ មហគ្គតកុសល ៩ លោកុត្តរកុសល ៤ ) ជាកុសលជាតិ ។
- វិបាកចិត្ត ៣៦ ដួង ( អកុសលវិបាក ៧ អហេតុកកុសលវិបាក ៨ មហាវិបាក ៨

មហគ្គតវិបាក ៩ លោកុត្តរវិបាក ៤ )
ជាវិបាកជាតិ ។

- កិរិយាចិត្ត ២០ ដួង ( អហេតុកកិរិយា ៣
មហាកិរិយា ៨ មហគ្គតកិរិយា ៩ )
ជាកិរិយាជាតិ ។

ដោយលោកុត្តរកុសល និង លោកុត្តរវិបាក ដោយពិស្តារ នីមួយៗ មាន ២០ ដួង ទើបកុសលចិត្តដោយសង្ខេប ២១ ដួង ទៅជាមាន ៣៧ ដួងដោយពិស្តារ និង វិបាកចិត្ត ដោយសង្ខេប ៣៦ ដួង ទៅជាមាន ៥២ ដួង ដោយពិស្តារ ។

- កុសលចិត្ត ៣៧ ដួង វិបាក ៥២ ដួង រួមជាមួយ អកុសលចិត្ត ១២ ដួង និង កិរិយាចិត្ត ២០ ដួង បណ្ឌិត ទាំងឡាយពោលនូវចិត្តដោយពិស្តារថា មាន ១២១ ដួង ។

ដូច្នេះ លោកសម្តែងកុសលចិត្ត ២១ ដួង វិបាកចិត្ត ៣៦ ដួងនោះ ជាការសម្តែងចំនួនចិត្ត ៨៩ ដួង **ដោយសង្ខេប** ប៉ុន្តែ លោកសម្តែងកុសលចិត្ត ៣៧ ដួង វិបាកចិត្ត ៥២ ដួងនោះ គឺ ជាការសម្តែងចំនួនចិត្ត ១២១ ដួង **ដោយពិស្តារ** ៕

សោភណចិត្ត ៥៩ ដួង

## កុសលចិត្តដោយពិស្តារមាន ៣៧ ដួង គឺ :

| | | |
|---|---|---|
| - កាមាវចរកុសលចិត្ត ឬមហាកុសលចិត្ត | ៨ | ដួង |
| - មហគ្គកុសលចិត្ត | ៩ | ដួង |
| - លោកុត្តរកុសលចិត្ត | ២០ | ដួង |
| រួម | ៣៧ | ដួង |

## វិបាកចិត្តដោយពិស្តារ ៥២ ដួង គឺ :

| | | |
|---|---|---|
| - អកុសលវិបាកចិត្ត | ៧ | ដួង |
| - អហេតុកកុសលវិបាកចិត្ត | ៨ | ដួង |
| - មហាវិបាកចិត្ត | ៨ | ដួង |
| - មហគ្គតវិបាកចិត្ត | ៩ | ដួង |
| - លោកុត្តរវិបាកចិត្ត | ២០ | ដួង |
| រួម | ៥២ | ដួង |

# ចំណែកចិត្តពិស្តារ ១២១ ដួង ដោយន័យផ្សេងៗ

**១.ដោយជាតិ** អកុសលចិត្ត ១២ ដួង ជាអកុសលជាតិ ។

កុសល ៣៧ ដួង ជាកុសលជាតិ ។
វិបាកចិត្ត ៥២ ដួង ជាវិបាកជាតិ ។
កិរិយាចិត្ត ២០ ដួង ជាកិរិយាជាតិ។

**២.ដោយភូមិ**

កាមាវចរចិត្ត ៥៤ ដួង ជាកាមភូមិ ។
រូបាវចរចិត្ត ១៥ ដួង ជារូបភូមិ ។
អរូបាវចរចិត្ត ១២ ដួង ជាអរូបភូមិ។
លោកុត្តរចិត្ត ៤០ ដួង ជាលោកុត្តរភូមិ។

**៣.ដោយវេទនា**

សុខសហគតចិត្ត ១ ដួង ជាសុខវេទនា។
ទុក្ខសហគតចិត្ត ១ ដួង ជាទុក្ខវេទនា។
សោមនស្សសហគតចិត្ត ៦២ ដួង ជាសោមនស្សវេទនា ។
ទោមនស្សសហគតចិត្ត ២ ដួង ជាទោមនស្សវេទនា ។
ឧបេក្ខាសហគតចិត្ត ៥៥ ដួង ជាឧបេក្ខាវេទនា ។

**៤.ដោយហេតុ**

ចិត្ត ១២១ ដួង ជានហេតុ ។
ចិត្តមិនមានហេតុប្រកប ១៨ ដួង ជាអហេតុកចិត្ត ។

ចិត្តដែលមានហេតុប្រកប ១០៣ ដួង ជាសហេតុកចិត្ត ។

**៥.ដោយសម្បយុត្ត** សម្បយុត្តចិត្ត ៨៧ ដួង គឺ : ជាញាណសម្បយុត្ត ៧៩ ទិដ្ឋិគត-សម្បយុត្ត ៤ បដិឃសម្បយុត្ត ២ វិចិកិច្ឆាសម្បយុត្ត ១ ឧទ្ធច្ចសម្បយុត្ត ១ វិប្បយុត្តចិត្ត ៣៧ ដួង ។

**៦.ដោយសង្ខារ** អសង្ខារិកចិត្ត ៣៧ ដួង ជាអសង្ខារិក។ សសង្ខារិកចិត្ត ៨៤ ដួង ជាសសង្ខារិក។

**៧.ដោយសោភណៈ** អសោភណចិត្ត ៣០ ដួង ជាអសោ-ភណចិត្ត ។

សោភណចិត្ត ៩១ ដួង ជាសោភណ-ចិត្ត ។

**៨.ដោយឈាន** កាមាវចរចិត្ត ៥៤ ដួង ជាអឈាន-ចិត្ត ។

ចិត្តនៅសល់ គឺ រូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ លោកុត្តរចិត្ត ៤០ ជាឈានចិត្ត ។

| | |
|---|---|
| ៩.ដោយលោកិយ | ចិត្ត ៨១ ដួង ជាលោកិយចិត្ត ។<br>ចិត្ត ៤០ ដួង ជាលោកុត្តរចិត្ត ។ |
| ១០.ដោយកិច្ច | ចិត្ត ១២១ ដួង ធ្វើកិច្ច ១៤ កិច្ច ។ |
| ១១.ដោយអារម្មណ៍ | ចិត្ត ១២១ ដួង មានអារម្មណ៍ ៦ ។ |
| ១២.ដោយទ្វារ | ចិត្ត ១២១ ដួង អាស្រ័យទ្វារ ៦ និង ទ្វារវិមុត្តិ ទ្វារវិមុត្តិ កាលធ្វើបដិសន្ធិ ភវង្គ ចុតិ ។ |
| ១៣.ដោយវត្ថុ | ចិត្ត ១១៧ ដួង កើតត្រង់វត្ថុទាំង ៦ ។<br>ចិត្ត ៤ ដួង មិនអាស្រ័យវត្ថុ ។ |
| ១៤.ដោយវិញ្ញាណធាតុ | ចិត្ត ១២១ ដួង ជាមនោវិញ្ញាណធាតុ ។ |

# វិនិច្ឆ័យអសង្ខារិក និង សសង្ខារិក

ចិត្ត ៨៧ ដួង ព្រះអនុរុទ្ធាចារ្យមិនពោលថា ជាអសង្ខារិក ឬសសង្ខារិកទេ ចិត្តទាំងនោះ គឺមោហមូលចិត្ត ២ ដួង , អហេតុក-ចិត្ត ១៨ ដួង , មហគ្គតចិត្ត ២៧ ដួង និងលោកុត្តរចិត្ត ៤០ ដួង ។

ប៉ុន្តែកេចិអាចារ្យពោលថា មោហមូលចិត្ត ២ ដួង និង អហេតុកចិត្ត ១៨ ដួង សង្គ្រោះជាអសង្ខារិក និង ពោលថា មហគ្គតចិត្ត ២៧ ដួង និងលោកុត្តរចិត្ត ៤០ ដួង ជាសសង្ខារិក ។

សេចក្តីនេះ ព្រះដីកាចារ្យអ្នករចនាគម្ពីរអភិធម្មត្ថវិភាវិនីមិន ឃើញមានការសង្គ្រោះដូចកេចិអាចារ្យយ៉ាងនោះទេ ប៉ុន្តែលោកមាន គំនិតស្របតាមពាក្យរបស់ព្រះអនុរុទ្ធាចារ្យ តាមន័យផ្សេងៗ គឺ :

-មោហមូលចិត្ត មិនមានសង្ខារ ចិត្ត ២ ដួងនេះ ជា ឯកហេតុកៈ សហគតដោយឧបេក្ខា ព្រោះជាចិត្តវង្វេង និង ជាចិត្ត សង្ស័យ រាយមាយ ហើយគ្រប់ៗកាល ចិត្តនេះ ក៏មិនផ្សេងគ្នាដោយ សេចក្តីនៃសង្ខារដែរ ព្រោះមិនមានកម្លាំងដោយភាវៈនៃខ្លួន និង ព្រោះមិនមានអ្នកដឹកនាំ ។

-ឈាន មិនមានសង្ខារភេទ **មានសំនួរ** ថា ឈានដែល បានមកដោយកម្លាំងអំណាចការសម្រេចមគ្គ ក៏អាចហៅថា អសង្ខារិក បាន ទេតើ ?

ហើយដែលបានមកដោយការប្រកបសមថៈ ក៏អាចហៅថា សសង្ខារិកបានដែរទេតើ ?

**ឆ្លើយថា** មិនអាចហៅថា អសង្ខារិក ព្រោះឈានទាំងអស់ វៀរចាកការតាក់តែងដំបូង គឺ បរិកម្មហើយ នឹងកើតឡើងដោយ

អំណាចការតាំងចិត្តខាងដើមតែម្យ៉ាង ក៏មិនបាន ។ ទាំងមិនអាច ហៅថា សសង្ខារិកដែរ ព្រោះវៀរចាកការតាំងចិត្តខាងដើមហើយ កើតឡើងដោយការតាក់តែង គឺ បរិកម្មតែម្យ៉ាងប៉ុណ្ណោះក៏មិនបាន ។

ន័យម្យ៉ាងទៀតថា **ឈាន** ដែលកើតឡើងដោយអំណាច ការតាក់តែងដំបូងនោះ ជាអសង្ខារិក ក្នុងពេលខ្លះ គ្រាខ្លះក៏មិន បានដែរ ដោយហេតុនោះ អាចារ្យទើបមិនហៅថា អសង្ខារិក និង មិនហៅថាសសង្ខារិក គឺ មិនមានសេចក្តីផ្សេង ដោយសង្ខារភេទ យ៉ាងនេះឯង ។

# ការចែកចិត្ត ១២១ ដួង ដោយ ន័យនៃសង្ខារ គឺ :

- ចិត្ត ១៧ ដួង ជា អសង្ខារិកចិត្ត ។
- ចិត្ត ១៧ ដួង ជា សសង្ខារិក ។
- អសង្ខារិកចិត្ត ១៧ ដួង គឺលោភមូលចិត្តជាអសង្ខារិក ៤ ដួង ទោសមូលចិត្តជាអសង្ខារិក ១ ដួង និងកាមាវចរសោភណចិត្ត ជាអសង្ខារិក ១២ ដួង រួមទាំងអស់ ១៧ ដួង ។
- សសង្ខារិកចិត្ត ១៧ ដួង គឺ :-

លោភមូលចិត្តជាសសង្ខារិក ៤ ដួង ។

ទោសមូលចិត្តជាសសង្ខារិក ១ ដួង ។

កាមាវចរសោភណចិត្ត ជាសសង្ខារិក ១២ ដួង ។

រួមទាំងអស់ ១៧ ដួង ។

- មិនពោលថា អសង្ខារិកចិត្ត និង សសង្ខារិកចិត្ត មាន ៨៧ ដួង គឺ :-

| | | |
|---|---|---|
| មោហមូលចិត្ត | ២ | ដួង ។ |
| អហេតុកចិត្ត | ១៨ | ដួង ។ |
| រូបាវចរចិត្ត | ១៥ | ដួង ។ |
| អរូបាវចរចិត្ត | ១២ | ដួង ។ |
| លោកុត្តរចិត្ត | ៤០ | ដួង ។ |
| រួមទាំងអស់ | ៨៧ | ដួង ។ |

# ន័យរបស់ភូមិ ២ ន័យ

ពាក្យថា **ភូមិ** សំដៅដល់ ថ្នាក់របស់ចិត្ត ១ និង សំដៅដល់ ស្ថានទីកើត ១ ។

**១. ភូមិដែលសំដៅដល់ថ្នាក់របស់ចិត្ត** មាន ៤ គឺ :

(១) កាមភូមិ ឬហៅថា កាមាវចរចិត្ត ។

(២) រូបភូមិ ឬហៅថា រូបាវចរចិត្ត ។
(៣) អរូបភូមិ ឬហៅថា អរូបាវចរចិត្ត ។
(៤) លោកុត្តរភូមិ ឬហៅថា លោកុត្តរចិត្ត ។

## ២. ភូមិសំដៅដល់ ស្ថានទីកើត

ឧទាហរណ៍ សត្វទាំងឡាយកើតក្នុង ៣១ ភូមិ ក្នុងទីនេះ សំដៅយកចិត្តទាំងអស់ដែលកើតក្នុងភូមិផ្សេងៗ ដោយចំណែកជា ៣ ប្រភេទ ហៅថា វត្ថានភូមិ ១ អវត្ថានភូមិ ១ និង វត្ថានាវត្ថានភូមិ ១ ។

**វត្ថានភូមិ** បានដល់ ចិត្តដែលកើតប្រចាំក្នុងភូមិរបស់ខ្លួនប៉ុណ្ណោះ មិនកើតក្នុងភូមិដទៃឡើយ គឺ ចិត្តកើតបានតែមួយភូមិ ។

**អវត្ថានភូមិ** បានដល់ ចិត្តដែលកើតឡើង ដោយមិនមានភូមិរបស់ខ្លួន ។

**វត្ថានាវត្ថានភូមិ** បានដល់ ចិត្តដែលកើតក្នុងភូមិរបស់ខ្លួន ហើយ អាចកើតក្នុងភូមិដទៃ ។ បានទៀត គឺ ចិត្តកើតបាន ២ ភូមិ ឬ ៣ ភូមិ ។

# វត្ថានភូមិ ឬ ចិត្តកើតបានតែមួយភូមិ មាន ២៥ ដួង

១. មហាវិបាកចិត្ត ៨ កើតក្នុងកាមភូមិ ធ្វើកិច្ច ៤ យ៉ាង ។
២. ឃានវិញ្ញាណ ២ កើតក្នុងកាមភូមិ ធ្វើឃាយនកិច្ច ។
៣. ជីវ្ហាវិញ្ញាណ ២ កើតក្នុងកាមភូមិ ធ្វើសាយនកិច្ច ។
៤. កាយវិញ្ញាណ ២ កើតក្នុងកាមភូមិ ធ្វើផុស្សនកិច្ច ។
៥. ទោសមូលចិត្ត ២ កើតក្នុងកាមភូមិ ធ្វើជវនកិច្ច ។
៦. រូបាវចរវិបាកចិត្ត ៥ កើតក្នុងរូបភូមិ ធ្វើកិច្ច ៣ យ៉ាង ។
៧. អរូបាវចរវិបាកចិត្ត ៤ កើតក្នុងអរូបភូមិ ធ្វើកិច្ច ៣ យ៉ាង ។

# អវត្ថានភូមិ ឬ ចិត្តមិនមានភូមិកើតរបស់ខ្លួន មាន ៨ ដួង

គឺ លោកុត្តរចិត្ត ៨ ដួង ឬដោយពិស្តារ ៤០ ដួង មិនមានភូមិកើតរបស់ខ្លួនដោយចំពោះទេ ព្រោះមិនមែនជាចិត្តសង្គ្រោះចូលក្នុងកាមភព រូបភព និង ក្នុងអរូបភព ជាចិត្តដែលឆ្លងផុតចាក

លោក ដូច្នេះហើយ ទើបលោកហៅថា **អបរិយាបន្នធម៌** គឺ ធម៌មិនរាប់បញ្ចូលហើយ ៕

# វត្ថានាវត្ថានភូមិ ឬ ចិត្តកើតបាន ២ ភូមិ ឬ ៣ ភូមិ មាន ៥៦ ដួង

## ចិត្តកើតបាន ២ ភូមិមាន ២១ ដួង គឺ :

**១.** ចក្ខុវិញ្ញាណ ២ កើតក្នុង កាមភូមិ និង រូបភូមិ ។

**២.** សោតវិញ្ញាណ ២ កើតក្នុង កាមភូមិ និង រូបភូមិ ។

**៣.** សម្បដិច្ឆន្នចិត្ត ២ កើតក្នុង កាមភូមិ និង រូបភូមិ ។

**៤.** សន្តីរណចិត្ត ៣ កើតក្នុង កាមភូមិ និង រូបភូមិ ។

**៥.** បញ្ចទ្វារាវជ្ជចិត្ត ១ កើតក្នុង កាមភូមិ និង រូបភូមិ ។

**៦.** ហសិតុប្បាទចិត្ត ១ កើតក្នុង កាមភូមិ និង រូបភូមិ ។

**៧.** រូបាវចរកុសល ៥ កើតក្នុង កាមភូមិ និង រូបភូមិ ។

**៨.** រូបាវចរកិរិយា ៥ កើតក្នុង កាមភូមិ និង រូបភូមិ ។

# ចិត្តកើតបាន ៣ ភូមិ មាន ៣៥ ដួង

១.លោភមូលចិត្ត ៨ កើតក្នុង កាមភូមិ រូបភូមិនិងអរូបភូមិ ។

២.មោហមូលចិត្ត ២ កើតក្នុង កាមភូមិ រូបភូមិនិងអរូបភូមិ ។

៣.មនោទ្វារាវជ្ជនចិត្ត ១ កើតក្នុង កាមភូមិ រូបភូមិនិងអរូបភូមិ ។

៤.មហាកុសលចិត្ត ៨ កើតក្នុង កាមភូមិ រូបភូមិនិងអរូបភូមិ ។

៥.មហាកិរិយាចិត្ត ៨ កើតក្នុង កាមភូមិ រូបភូមិនិងអរូបភូមិ ។

៦.អរូបាវចរកុសលចិត្ត ៤ កើតក្នុង កាមភូមិ រូបភូមិនិងអរូបភូមិ ។

៧.អរូបាវចរចិត្ត ៤ កើតក្នុង កាមភូមិ រូបភូមិនិងអរូបភូមិ ។

ចិត្ត ៨៩ ឬដោយពិស្តារ ១២១ ដួងនេះ ដោយន័យផ្សេងៗ គឺដោយជាតិជាដើមនោះ ដើម្បីសម្តែងឲ្យដឹងនូវចិត្តប្រភេទនីមួយ ៗ តាមសភាពជា អកុសលចិត្តខ្លះ អហេតុកចិត្តខ្លះ មហាកុសលចិត្តខ្លះ មហាវិបាកចិត្តខ្លះ មហាកិរិយាចិត្តខ្លះ មហគ្គតចិត្តខ្លះ លោកុត្តរចិត្តខ្លះ ។

ដែលសម្តែងដល់ស្ថានទីកើតរបស់ចិត្ត ៣ ប្រភេទ ដែលហៅថា **វត្ថានភូមិ** និង **វត្ថានាវត្ថានភូមិ** នោះ ដើម្បីឲ្យដឹងថា ចិត្តបរមត្ថនេះ មានការវិចិត្រពិស្តារក្រៃលែង ។

ចិត្តទាំងឡាយដែលអន្ទោលទៅក្នុងកាមភព ក៏ដោយអំណាច

នៃ **កាមតណ្ហា** ដែលអន្ទោលទៅក្នុងរូបភព ក៏ដោយអំណាច **រូបតណ្ហា(ភវតណ្ហា)** ឬអន្ទោលទៅក្នុងអរូបភព ក៏ដោយអំណាច នៃ **អរូបតណ្ហា(វិភវតណ្ហា)** រមែងមិនផុតចាកវដ្តទុក្ខឡើយ ដល់កាលណាបានសម្រេចនូវព្រះនិព្វាន កាលនោះ ក៏រមែងដល់នូវសន្តិសុខដ៏ក្សេមក្សាន្តចាកយោគៈ ពោលគឺ អន្ទាក់នៃមារ យ៉ាងពិតប្រាកដ ៕

# អវសានគាថា

**ឥច្ចានុរុទ្ធរចិតេ អភិធម្មត្ថសង្គហេ**
**បឋមោបរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ**

បរិច្ឆេទទី ១ ឈ្មោះថា ចិត្តសង្គហវិភាគ ក្នុងបករណ៍ដែលរួបរួមនូវអត្ថនៃព្រះអភិធម្ម ( អភិធម្មត្ថសង្គហៈ ) ដែលព្រះអនុរុទ្ធាចារ្យរចនាទុកដោយសង្ខេប បានចប់ដោយប្រការយ៉ាងនេះ ៕

រៀបរៀងចប់ ថ្ងៃទី ២៨.មករា.១៩៩៧

**រស់ សុផាត**

# វគ្គដែលត្រូវស្វាធ្យាយ និង ចងចាំក្នុងចិត្តបរមត្ថ

## ចិត្តបរមត្ថ ៨៩ ដួង ឬ ១២១ ដួង គឺៈ

- កាមាវចរចិត្ត ៥៤ ដួង
- រូបាវចរចិត្ត ១៥ ដួង
- អរូបាវចរចិត្ត ១២ ដួង
- លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង

## កាមាវចរចិត្ត ៥៤ ដួង គឺ ៈ

- **អកុសលចិត្ត ១២ ដួង** គឺ
  - លោភមូលចិត្ត ៨ ដួង
  - ទោសមូលចិត្ត ២ ដួង
  - មោហមូលចិត្ត ២ ដួង
- **អហេតុកចិត្ត ១៨ ដួង** គឺ
  - អហេតុកអកុសលវិបាកចិត្ត ៧ ដួង

- អហេតុកកុសលវិបាកចិត្ត ៨ ដួង
- អហេតុកកិរិយាចិត្ត ៣ ដួង

- **កាមាវចរសោភណចិត្ត ២៤ ដួង** គឺ
  - មហាកុសលចិត្ត ៨ ដួង
  - មហាវិបាកចិត្ត ៨ ដួង
  - មហាកិរិយាចិត្ត ៨ ដួង

## រូបាវចរចិត្ត ១៥ ដួង គឺ ៖

- **រូបាវចរកុសលចិត្ត** ៥ ដួង
- **រូបាវចរវិបាកចិត្ត** ៥ ដួង
- **រូបាវចរកិរិយាចិត្ត** ៥ ដួង

## អរូបាវចរចិត្ត ១២ ដួង គឺ ៖

- **អរូបាវចរកុសលចិត្ត** ៤ ដួង
- **អរូបាវចរវិបាកចិត្ត** ៤ ដួង
- **អរូបាវចរកិរិយាចិត្ត** ៤ ដួង

# លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង គឺ ៖

- **លោកុត្តរកុសលចិត្ត** ហៅថា **មគ្គចិត្ត** ៤ ដួង ឬ ២០ ដួង
- **លោកុត្តរវិបាកចិត្ត** ហៅថា **ផលចិត្ត** ៤ ដួង ឬ ២០ ដួង

# អកុសលចិត្ត ១២ ដួង

## លោភមូលចិត្ត ៨ ដួង គឺ ៖

១-សោមនស្សៈ សហគតៈ ទិដ្ឋិគតៈ សម្បយុត្តៈ អសង្ខារិកៈ លោភចិត្ត១

២-សោមនស្សៈ សហគតៈ ទិដ្ឋិគតៈ សម្បយុត្តៈ សសង្ខារិកៈ លោភចិត្ត១

៣-សោមនស្សៈ សហគតៈ ទិដ្ឋិគតៈ វិប្បយុត្តៈ អសង្ខារិកៈ លោភចិត្ត១

៤-សោមនស្សៈ សហគតៈ ទិដ្ឋិគតៈ វិប្បយុត្តៈ សសង្ខារិកៈ លោភចិត្ត១

៥- ឧបេក្ខា សហគតៈ ទិដ្ឋិគតៈ សម្បយុត្តៈ អសង្ខារិកៈ លោភចិត្ត១

៦- ឧបេក្ខា សហគតៈ ទិដ្ឋិគតៈ សម្បយុត្តៈ សសង្ខារិកៈ លោភចិត្ត១

៧- ឧបេក្ខា សហគតៈ ទិដ្ឋិគតៈ វិប្បយុត្តៈ អសង្ខារិកៈ លោភចិត្ត១

៨- ឧបេក្ខា សហគតៈ ទិដ្ឋិគតៈ វិប្បយុត្តៈ សសង្ខារិកៈ លោភចិត្ត១

## ទោសមូលចិត្ត ២ ដួង គឺ ៖

១-ទោមនស្សៈ សហគតៈ បដិឃៈ សម្បយុត្តៈ អសង្ខារិកៈ ទោសចិត្ត ១
២-ទោមនស្សៈ សហគតៈ បដិឃៈ សម្បយុត្តៈ សសង្ខារិកៈ ទោសចិត្ត ១

## មោហមូលចិត្ត ២ ដួង គឺ ៖

១-ឧបេក្ខា សហគតៈ វិចិកិច្ឆា សម្បយុត្តៈ អសង្ខារិកៈ មោហចិត្ត ១
២-ឧបេក្ខា សហគតៈ ឧទ្ធច្ចៈ សម្បយុត្តៈ អសង្ខារិកៈ មោហចិត្ត ១

# អហេតុកចិត្ត ១៨ ដួង

# អហេតុកអកុសលវិបាក ៧ ដួង គឺ ៖

១-ឧបេក្ខា សហគតៈ ចក្ខុវិញ្ញាណ អហេតុកៈ អកុសលវិបាកចិត្ត ១
២-ឧបេក្ខា សហគតៈ សោតវិញ្ញាណ អហេតុកៈ អកុសលវិបាកចិត្ត ១
៣-ឧបេក្ខា សហគតៈ ឃានវិញ្ញាណ អហេតុកៈ អកុសលវិបាកចិត្ត ១
៤-ឧបេក្ខា សហគតៈ ជីវ្ហាវិញ្ញាណ អហេតុកៈ អកុសលវិបាកចិត្ត ១
៥-ទុក្ខ សហគតៈ កាយវិញ្ញាណ អហេតុកៈ អកុសលវិបាកចិត្ត ១
៦-ឧបេក្ខា សហគតៈ មនោធាតុ អហេតុកៈ អកុសលវិបាកចិត្ត ១

ឬ ឧបេក្ខា សហគតៈ សម្បដិច្ឆន្នៈ អហេតុកៈ អកុសលវិបាកចិត្ត(១)
៧-ឧបេក្ខា សហគតៈ មនោវិញ្ញាណធាតុ អហេតុកៈ អកុសលវិបាកចិត្ត ១
ឬ ឧបេក្ខា សហគតៈ សន្តីរណៈ អហេតុកៈ អកុសលវិបាកចិត្ត(១)

# អហេតុកកុសលវិបាកចិត្ត ៨ ដួង គឺ ៖

១-ឧបេក្ខា សហគតៈ ចក្ខុវិញ្ញាណ អហេតុកៈ កុសលវិបាកចិត្ត១

២-ឧបេក្ខា សហគតៈ សោតវិញ្ញាណ អហេតុកៈ កុសលវិបាកចិត្ត១

៣-ឧបេក្ខា សហគតៈ ឃានវិញ្ញាណ អហេតុកៈ កុសលវិបាកចិត្ត១

៤-ឧបេក្ខា សហគតៈ ជិវ្ហាវិញ្ញាណ អហេតុកៈ កុសលវិបាកចិត្ត១

៥-សុខ សហគតៈ កាយវិញ្ញាណ អហេតុកៈ កុសលវិបាកចិត្ត១

៦-ឧបេក្ខា សហគតៈ មនោធាតុ អហេតុកៈ កុសលវិបាកចិត្ត១
ឬ ឧបេក្ខា សហគតៈ សម្បដិច្ឆន្នៈ អហេតុកៈ កុសលវិបាកចិត្ត១

៧-ឧបេក្ខា សហគតៈ មនោវិញ្ញាណធាតុ អហេតុកៈ កុសលវិបាកចិត្ត១
ឬ ឧបេក្ខា សហគតៈ សន្តីរណៈ អហេតុកៈ កុសលវិបាកចិត្ត១

៨-សោមនស្សៈ សហគតៈ មនោវិញ្ញាណធាតុ អហេតុកៈ កុសលវិបាកចិត្ត១
ឬ សោមនស្សៈ សហគតៈ សន្តីរណៈ អហេតុកៈ កុសលវិបាកចិត្ត១

# អហេតុកកិរិយាចិត្ត ៣ ដួង គឺ ៖

| | | | |
|---|---|---|---|
| ១-ឧបេក្ខា | សហគតៈ | មនោធាតុ | អហេតុកៈ កិរិយាចិត្ត ១ |
| ឬ ឧបេក្ខា | សហគតៈ | បញ្ចទ្វារាវជ្ជនៈ | អហេតុកៈ កិរិយាចិត្ត(១) |
| ២-ឧបេក្ខា | សហគតៈ | មនោវិញ្ញាណធាតុ | អហេតុកៈ កិរិយាចិត្ត ១ |
| ឬ ឧបេក្ខា | សហគតៈ | មនោទ្វារាវជ្ជនៈ | អហេតុកៈ កិរិយាចិត្ត(១) |
| ៣-សោមនស្សៈ | សហគតៈ | មនោវិញ្ញាណធាតុ | អហេតុកៈ កិរិយាចិត្ត ១ |
| ឬ សោមនស្សៈ | សហគតៈ | ហសិតុប្បាទៈ | អហេតុកៈ កិរិយាចិត្ត(១) |

# កាមាវចរសោភណចិត្ត ២៤ ដួង

## មហាកុសលចិត្ត ៨ ដួង - មហាវិបាកចិត្ត ៨ ដួង
## មហាកិរិយាចិត្ត ៨ ដួង

| | | | |
|---|---|---|---|
| ១-សោមនស្សៈ | សហគតៈ | ញាណសម្បយុត្តៈ | អសង្ខារិកៈ |
| | កុសលចិត្ត១ | វិបាកចិត្ត១ | កិរិយាចិត្ត១ |
| ២-សោមនស្សៈ | សហគតៈ | ញាណសម្បយុត្តៈ | សសង្ខារិកៈ |
| | កុសលចិត្ត១ | វិបាកចិត្ត១ | កិរិយាចិត្ត១ |

| | | | |
|---|---|---|---|
| ៣-សោមនស្សៈ | សហគតៈ | ញាណវិប្បយុត្តៈ | អសង្ខារិកៈ |
| | កុសលចិត្ត១ | វិបាកចិត្ត១ | កិរិយាចិត្ត១ |
| ៤-សោមនស្សៈ | សហគតៈ | ញាណវិប្បយុត្តៈ | សសង្ខារិកៈ |
| | កុសលចិត្ត១ | វិបាកចិត្ត១ | កិរិយាចិត្ត១ |
| ៥-ឧបេក្ខា | សហគតៈ | ញាណសម្បយុត្តៈ | អសង្ខារិកៈ |
| | កុសលចិត្ត១ | វិបាកចិត្ត១ | កិរិយាចិត្ត១ |
| ៦-ឧបេក្ខា | សហគតៈ | ញាណសម្បយុត្តៈ | សសង្ខារិកៈ |
| | កុសលចិត្ត១ | វិបាកចិត្ត១ | កិរិយាចិត្ត១ |
| ៧-ឧបេក្ខា | សហគតៈ | ញាណវិប្បយុត្តៈ | អសង្ខារិកៈ |
| | កុសលចិត្ត១ | វិបាកចិត្ត១ | កិរិយាចិត្ត១ |
| ៨-ឧបេក្ខា | សហគតៈ | ញាណវិប្បយុត្តៈ | សសង្ខារិកៈ |
| | កុសលចិត្ត១ | វិបាកចិត្ត១ | កិរិយាចិត្ត១ |

# រូបាវចរចិត្ត ១៥ ដួង

## រូបាវចរកុសលចិត្ត ៥ ដួង
## រូបាវចរវិបាកចិត្ត ៥ ដួង រូបាវចរកិរិយាចិត្ត ៥ ដួង

១-វិតក្កៈ វិចារៈ បីតិ សុខេកគ្គតា ហសិតៈ បឋមជ្ឈាន -
កុសលចិត្ត ១
វិបាកចិត្ត ១
កិរិយាចិត្ត ១
២-វិចារៈ បីតិ សុខេកគ្គតា ហសិតៈ ទុតិយជ្ឈាន កុសលចិត្ត ១
វិបាកចិត្ត ១
កិរិយាចិត្ត ១
៣-បីតិ សុខេកគ្គតា ហសិតៈ តតិយជ្ឈាន កុសលចិត្ត ១
វិបាកចិត្ត ១
កិរិយាចិត្ត ១
៤-សុខេកគ្គតា ហសិតៈ ចតុត្ថជ្ឈាន កុសលចិត្ត ១
វិបាកចិត្ត ១
កិរិយាចិត្ត ១

៥-ឧបេក្ខេកគ្គតា ហសិតៈ បញ្ចមជ្ឈាន កុសលចិត្ត ១
វិបាកចិត្ត ១
កិរិយាចិត្ត ១

# អរូបាវចរចិត្ត ១២ ដួង

១-ឧបេក្ខេកគ្គតា ហសិតៈ អាកាសានញ្ចាយតនៈ បញ្ចមជ្ឈាន -
កុសលចិត្ត ១
វិបាកចិត្ត ១
កិរិយាចិត្ត ១

២-ឧបេក្ខេកគ្គតា ហសិតៈ វិញ្ញាណញ្ចាយតនៈ បញ្ចមជ្ឈាន -
កុសលចិត្ត ១
វិបាកចិត្ត ១
កិរិយាចិត្ត ១

៣-ឧបេក្ខេកគ្គតា ហសិតៈ អាកិញ្ចញ្ញាយតនៈ បញ្ចមជ្ឈាន -
កុសលចិត្ត ១
វិបាកចិត្ត ១
កិរិយាចិត្ត ១

៤-ឧបេក្ខេកគ្គតា ហសិតៈ នេវសញ្ញានាសញ្ញាយតនៈ បញ្ចមជ្ឈាន -

កុសលចិត្ត ១

វិបាកចិត្ត ១

កិរិយាចិត្ត ១

# លោកុត្តរចិត្ត ៨ ដួង

## **លោកុត្តរកុសលចិត្ត** ហៅថា **មគ្គចិត្ត ៤ ដួង**

## **លោកុត្តរវិបាកចិត្ត** ហៅថា **ផលចិត្ត ៤ ដួង**

| | | | |
|---|---|---|---|
| ១- សោតាបត្តិមគ្គចិត្ត | ១ | - សោតាបត្តិផលចិត្ត | ១ |
| ២- សកទាគាមិមគ្គចិត្ត | ១ | - សកទាគាមិផលចិត្ត | ១ |
| ៣- អនាគាមិមគ្គចិត្ត | ១ | - អនាគាមិផលចិត្ត | ១ |
| ៤- អរហត្តមគ្គចិត្ត | ១ | - អរហត្តផលចិត្ត | ១ |

# លោកុត្តរចិត្ត ៤០ ដួង

## **លោកុត្តរកុសលចិត្ត** ហៅថា **មគ្គចិត្ត ២០ ដួង**

## **លោកុត្តរវិបាកចិត្ត** ហៅថា **ផលចិត្ត ២០ ដួង**

**១-វិតក្កៈ វិចារៈ បីតិ សុខេកគ្គតា ហសិតៈ បឋមជ្ឈាន** សោតាបត្តិមគ្គចិត្ត១ - សោតាបត្តិផលចិត្ត១ - សកទាគាមិមគ្គចិត្ត១ - សកទាគាមិផលចិត្ត១- អនាគាមិមគ្គចិត្ត១ អនាគាមិផលចិត្ត១-អរហត្តមគ្គចិត្ត១-អរហត្តផលចិត្ត១

**២-វិចារៈ បីតិ សុខេកគ្គតា ហសិតៈ ទុតិយជ្ឈាន** សោតាបត្តិមគ្គចិត្ត១- សោតាបត្តិផលចិត្ត១- សកទាគាមិមគ្គចិត្ត១ - សកទាគាមិផលចិត្ត១-អនាគាមិមគ្គចិត្ត១ - អនាគាមិផលចិត្ត១-អរហត្តមគ្គចិត្ត១-អរហត្តផលចិត្ត១ ។

**៣-បីតិ សុខេកគ្គតា ហសិតៈ តតិយជ្ឈាន** សោតាបត្តិមគ្គចិត្ត១ សោតាបត្តិផលចិត្ត១ -សកទាគាមិមគ្គចិត្ត១ –សកទាគាមិផលចិត្ត១ -អនាគាមិមគ្គចិត្ត១ -អនាគាមិផលចិត្ត១ -អរហត្តមគ្គចិត្ត១ -អរហត្តផលចិត្ត១ ។

**៤-សុខេកគ្គតា ហសិតៈ ចតុត្ថជ្ឈាន** សោតាបត្តិមគ្គចិត្ត១-សោតាបត្តិផលចិត្ត១-សកទាគាមិមគ្គចិត្ត១-សកទាគាមិផលចិត្ត១-អនាគាមិមគ្គចិត្ត១-អនាគាមិផលចិត្ត១-អរហត្តមគ្គចិត្ត១-អរហត្តផលចិត្ត១ ។

**៥-ឧបេក្ខេកគ្គតា ហសិតៈ បញ្ចមជ្ឈាន** សោតាបត្តិមគ្គចិត្ត១-សោតាបត្តិផលចិត្ត១-សកទាគាមិមគ្គចិត្ត១-សកទាគាមិផលចិត្ត ១ -អនាគាមិមគ្គចិត្ត ១ -អនាគាមិផលចិត្ត ១ -

អរហត្តមគ្គចិត្ត១-អរហត្តផលចិត្ត១ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឈាន | ៥ | × | មគ្គចិត្ត | ៤ | = | មគ្គចិត្ត | ២០ ដួង |
| ឈាន | ៥ | × | ផលចិត្ត | ៤ | = | ផលចិត្ត | ២០ ដួង |
| ឈាន | ៥ | × | លោកុត្តរចិត្ត | ៨ | = | លោកុត្តរចិត្ត | ៤០ ដួង |

............. ✴ .............

# មាតិកា

**រឿង** **ទំព័រ**


អភិធម្មត្ថសង្គហៈ.............................. ៤
ពាក្យថា បរមត្ថ.............................. ៦
ហេតុដែលត្រាស់សម្មតិសច្ច ៨ ប្រការ.................. ៧
លក្ខណៈរបស់បរមត្ថធម៌ .............................. ៧
ខន្ធ ៥.............................................. ៨
សំណួរ.............................................. ១១
ចិត្តបរមត្ថ.......................................... ១២
លក្ខណាទិចតុកៈរបស់ចិត្ត............................ ១៣
អំណាចរបស់ចិត្ត...................................... ១៤
ចំណែកចិត្ត ១២៩ ដួង ដោយន័យផ្សេងៗ............ ១៥
ចិត្តបរមត្ថ ៨៩ ដួង បរិច្ឆេទ ទី ១.................... ៣១
សំដែងចិត្ត ៤ យ៉ាង................................... ៣៣
កាមាវចរចិត្ត ៥៤ ដួង................................ ៣៣
អកុសលចិត្ត ១២ ដួង................................ ៣៦
លោភមូលចិត្ត ៨ ដួង................................ ៣៦

## មាតិកា លេខទំព័រ


លក្ខណាទិចតុកៈរបស់លោភៈ........................... ៤០
ហេតុឲ្យកើតលោភមូលចិត្ត ៤ ប្រការ................... ៤១
ហេតុឲ្យកើតលោភសោមនស្ស ៤ ប្រការ.............. ៤៣
ព្យសនៈ(សេចក្តីវិនាស) ៥ ប្រការ..................... ៤៤
ហេតុឲ្យកើតឧបេក្ខា ៤ ប្រការ........................ ៤៥
ហេតុឲ្យកើតទិដ្ឋិគតសម្បយុត្ត ៥ ប្រការ................ ៤៦
ហេតុឲ្យកើតទិដ្ឋិគតវិប្បយុត្ត ៥ ប្រការ................. ៥០
ហេតុឲ្យកើតអសង្ខារិកៈ ៦ ប្រការ...................... ៥១
ហេតុឲ្យកើតសសង្ខារិកៈ ៦ ប្រការ..................... ៥៤
ចំណែកលោភមូលចិត្ត ៨ ដោយន័យផ្សេងៗ........... ៥៥
ផលរបស់លោភមូលចិត្ត............................... ៥៧
ទោសមូលចិត្ត ២ ដួង................................. ៥៨
លក្ខណាទិចតុកៈរបស់ទោសៈ........................... ៥៩
អាឃាតវត្ថុ ១០ ប្រការ................................ ៥៩
ហេតុឲ្យកើទោសមូលចិត្ត ៤ ប្រការ..................... ៦១
ធម៌ជាហេតុលះទោសៈ ៦ ប្រការ....................... ៦៣
ចំណែកទោសមូលចិត្ត ២ ដោយន័យផ្សេៗ............. ៦៤

## មាតិកា                                    លេខទំព័រ

ផលរបស់ទោសមូលចិត្ត................................ ៦៥
មោហមូលចិត្ត ២ ដួង................................ ៦៦
ហេតុឲ្យកើតមោហមូលចិត្ត ២ ប្រការ.................. ៦៧
លក្ខណាទិចតុកៈរបស់មោហៈ........................... ៦៨